

ឯកសារគម្ពីព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពីច្បាប់គម្ពីរព្រះត្រៃបិដកដប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥000ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ៗ

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ៗ

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ៗ

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ៗ

ថតស្កានដោយ
ប្អូនប្រុស ម៉ាន់ សាវ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងថ្លៃថ្លាអំពី៖

- ឧបាសិកា កាំង ហ៊ុចឈៃ (ភ្នំពេញ)
- ឧបាសក ជុត លីស្រ៊ុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ូច សាវៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ីវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជឹម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ាទី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រ៊ុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រ៊ុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រ៊ុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រ៊ុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទួត សេរីស័ក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ដុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)
- ឧបាសិកា វ៉ាន់ លុយ និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- លោកស្រី ហួ ច័ន្ទសុវណ្ណ និងស្វាមី ព្រមទាំងបុត្រ (ស.រ.អ)

# ព្រះ
# ត្រៃបិដកបាលី
និង
# សេចក្ដីប្រែជាភាសាខ្មែរ
# អភិធម្មបិដក
# វិភង្គ ទុតិយភាគ
# ៨៣



បោះពុម្ពលើកទី ១

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព. ស. ២៥០៨

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្ចង់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

អ្នកតំណាងចាត់ការ The Rev. Seikyo Muchaku

ប្រធានការិយាល័យ The Rev. Eiitsu Shinohara

អ្នកចាត់ការ

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　　有馬　実成
伊藤　佳通　　渡井　奎一
杉谷　義純　　茂田　真澄
前田　利勝　　中島　教之
永　六輔

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

អភិធម្មបិដក

វិភង្គ តតិយភាគ

៨២

ព.ស. ២៥០៨

# អភិធម្មបិដកេ

## វិភង្គស្ស តតិយោ ភាគោ

---

## សិក្ខាបទវិភង្គោ

(១) បញ្ច សិក្ខាបទានិ បាណាតិបាតា វេរមណីសិក្ខាបទំ អទិន្នាទានា វេរមណីសិក្ខាបទំ កាមេសុមិច្ឆាចារា វេរមណីសិក្ខាបទំ មុសាវាទា វេរមណីសិក្ខាបទំ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ ។

(២) តត្ថ កតមំ បាណាតិបាតា វេរមណីសិក្ខាបទំ ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ បាណាតិបាតា វិរមន្តស្ស យា តស្មឹ សមយេ បាណាតិបាតា អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ ឥទំ វុច្ចតិ បាណាតិបាតា វេរមណីសិក្ខាបទំ

# អភិធម្មបិដក

## វិភង្គ តតិយភាគ

---

## សិក្ខាបទវិភង្គ

(១) សិក្ខាបទ ៥ គឺ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញ៉ាំងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង ១ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ១ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាពោលនូវពាក្យកុហក ១ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ១ ។

(២) បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញ៉ាំងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ កើតឡើង ក្នុងសម័យនោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្តេញនូវពៀរ ចាកបាណាតិបាត គឺការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលា ការសម្លាប់ហេតុណា របស់បុគ្គលដែលវៀរ ចាកបាណាតិបាត នេះហៅថា សិក្ខាបទ

## អភិធម្មបិដកេ វិភង្គោ

អវសេសា ធម្មា វេរមណិយា សម្បយុត្តា ។
តត្ថ កតមំ បាណាតិបាតា វេរមណីសិក្ខាបទំ ។
យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ
ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ បា-
ណាតិបាតា វិរមន្តស្ស យា តស្មឹ សមយេ ចេត-
នា សញ្ចេតនា សញ្ចេតយិតត្តំ ឥទំ វុច្ចតិ បាណា-
តិបាតា វេរមណីសិក្ខាបទំ អវសេសា ធម្មា ចេត-
នាយ សម្បយុត្តា ។ តត្ថ កតមំ បាណាតិបា-
តា វេរមណីសិក្ខាបទំ ។ យស្មឹ សមយេ កា-
មាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្ស-
សហគតំ ញាណសម្បយុត្តំ បាណាតិបាតា វិរ-
មន្តស្ស ផស្សោ ។ បេ ។ បគ្គាហោ អវិក្ខេបោ
ឥទំ វុច្ចតិ បាណាតិបាតា វេរមណីសិក្ខាបទំ ។
តត្ថ កតមំ បាណាតិបាតា វេរមណីសិក្ខាបទំ ។

គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ធម៌ទាំងឡាយដ៏សេស គឺឈ្មោះថា សម្បយុត្តដោយចេតនាជាហេតុវៀរ ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ កើតឡើង ក្នុងសម័យនោះ ការគិត អាការគិត សេចក្តីគិត ណា របស់បុគ្គលដែលវៀរ ចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង ធម៌ទាំងឡាយដ៏សេស គឺឈ្មោះថា សម្បយុត្តដោយចេតនា ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ កើតឡើង ក្នុងសម័យនោះ ការពាល់ត្រូវ ។ បេ ។ ការផ្គងឡើង ការមិនរាយមាយ របស់បុគ្គលដែលវៀរ ចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង តើដូចម្តេច ។

## សិក្ខាបទវិភង្គ អភិធម្មភាជនីយំ

យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារេន ។បេ។ សោមនស្សសហគតំ ញាណសម្បយុត្តំ ។បេ។ សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារេន ។បេ។ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ ។បេ។ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារេន ។បេ។ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ ។បេ។ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារេន បាណាតិបាតា វិរមន្តស្ស យា តស្មឹ សមយេ បាណាតិបាតា អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ ឥទំ វុច្ចតិ បាណាតិបាតា វេរមណីសិក្ខាបទំ អវសេសា ធម្មា វេរមណិយា សម្បយុត្តា ។ តត្ថ កតមំ បាណាតិបាតា វេរមណីសិក្ខាបទំ ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារេន បាណាតិបាតា វិរមន្តស្ស យា តស្មឹ សមយេ ចេតនា សញ្ចេតនា សញ្ចេតយិតត្តំ ឥទំ វុច្ចតិ

ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។ បេ ។ ប្រឡំដោយសោមនស្ស ប្រាសចាកញាណ ។ បេ ។ ប្រឡំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ប្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ។បេ។ ប្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រឡំដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើង ក្នុងសម័យនោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្ដេញនូវពៀរ ចាកបាណាតិបាត គឺការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តិកន្លងវេលា ការសម្លាប់ហេតុ ណា របស់បុគ្គលដែលវៀរចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនាជាហេតុវៀរ ។ បណ្ដាសិក្ខាបទទាំង៥នោះ សិក្ខាបទគឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង តើដូចម្តេច ។ ក្នុងសម័យណាចិត្តជាកាមាវចរកុសល ប្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើងក្នុងសម័យនោះ ការគិត អាការគិត សេចក្តីគិត ណា របស់បុគ្គលដែលវៀរ ចាកបាណាតិបាត នេះហៅថា សិក្ខាបទ

## អភិធម្មបិដកេ វិភង្គោ

បាណាតិបាតា វេរមណី សិក្ខាបទំ អវសេសា ធម្មា ចេតនាយ សម្បយុត្តា ។ តត្ថ កតមំ បាណាតិបាតា វេរមណី សិក្ខាបទំ ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ[១] សសង្ខារេន បាណាតិបាតា វិរមន្តស្ស ផស្សោ ។ បេ ។ បគ្គាហោ អវិក្ខេបោ ឥទំ វុច្ចតិ បាណាតិបាតា វេរមណី សិក្ខាបទំ ។

(៣) តត្ថ កតមំ អទិន្នាទានា វេរមណី សិក្ខាបទំ ។ បេ ។ កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ ។ បេ ។ មុសាវាទា វេរមណី សិក្ខាបទំ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ សុរាមេរយមជ្ជប្បមាទដ្ឋានា វិរមន្តស្ស យា តស្មឹ សមយេ សុរាមេរយមជ្ជប្បមាទដ្ឋានា អារតិ វិរតិ

---

១ ម. ញាណសម្បយុត្តំ ទិស្សតិ ។

គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ។ បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង តើដូចម្ដេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើង ក្នុងសម័យនោះ ការប៉ះពាល់ ។បេ។ ការផ្គងឡើង ការមិនពយមាយ របស់បុគ្គលដែលវៀរ ចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង ។

(៣) បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ តើដូចម្ដេច ។បេ។ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ។បេ។ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាពោលនូវពាក្យកុហក ។បេ។ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្ប-យុត្តដោយញាណ កើតឡើង ក្នុងសម័យនោះ ការវៀរ ការវៀសវាង

## សិក្ខាបទវិភង្គេ អភិធម្មភាជនីយំ

បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ
វេលាអនតិក្កមោ សេតុឃាតោ ឥទំ វុច្ចតិ សុរាមេ-
រយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ អវសេសា
ធម្មា វេរមណិយា សម្បយុត្តា ។ តត្ថ កតមំ
សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ ។
យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ
ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ
សុរាមេរយមជ្ជប្បមាទដ្ឋានា វិរមន្តស្ស យា តស្មឹ
សមយេ ចេតនា សញ្ចេតនា សញ្ចេតយិតត្តំ ឥទំ
វុច្ចតិ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ
អវសេសា ធម្មា ចេតនាយ សម្បយុត្តា ។ តត្ថ កត-
មំ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ ។

## សិក្ខាបទវិភង្គ អភិធម្មភាជនីយ

ការវៀរស្រឡះ ការបណ្ដេញនូវពៀរ ចាកហេតុជាទីតាំង នៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ បានដល់ការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលា ការសម្លាប់ហេតុណា របស់បុគ្គលដែលវៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនាជាហេតុវៀរ ។ បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ តើដូចម្ដេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ កើតឡើង ក្នុងសម័យនោះ ការគិត អាការគិត សេចក្ដីគិត ណា របស់បុគ្គលដែលវៀរ ចាកហេតុជាទីតាំង នៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ។ បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ តើដូចម្ដេច ។

## អភិធម្មបិដកេ វិភង្គោ

យស្មឹំ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ
ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ សុរា-
មេរយមជ្ជប្បមាទដ្ឋានា វិរមន្តស្ស ផស្សោ ។ បេ ។
បគ្គាហោ អវិក្ខេបោ ឥទំ វុច្ចតិ សុរាមេរយ-
មជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ ។ តត្ថ កតមំ
សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ ។
យស្មឹំ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ
ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ
សសង្ខារេន ។ បេ ។ សោមនស្សសហគតំ ញាណ-
វិប្បយុត្តំ ។ បេ ។ សោមនស្សសហគតំ ញាណ-
វិប្បយុត្តំ សសង្ខារេន ។ បេ ។ ឧបេក្ខាសហគតំ
ញាណសម្បយុត្តំ ។ បេ ។ ឧបេក្ខាសហគតំ ញាណ-
សម្បយុត្តំ សសង្ខារេន ។ បេ ។ ឧបេក្ខាសហគតំ
ញាណវិប្បយុត្តំ ។ បេ ។ ឧបេក្ខាសហគតំ ញាណ-
វិប្បយុត្តំ សសង្ខារេន សុរាមេរយមជ្ជប្បមាទដ្ឋានា

ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ច្រឡំដោយសោមនស្ស សម្ប-យុត្តដោយញាណ កើតឡើង ក្នុងសម័យនោះ ការប៉ះពាល់ ។ បេ ។ ការផ្គងឡើង ការមិនរាយមាយ របស់បុគ្គលដែលវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមា-វចរកុសល ច្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ កើតឡើង ។ បេ ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ។ បេ ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ។ បេ ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ។ បេ ។ ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើង ក្នុងសម័យនោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្តេញនូវពៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ

## សិក្ខាបទវិភង្គ អភិធម្មភាជនីយំ

វិរមន្តស្ស យា តស្មិំ សមយេ សុរាមេរយមជ្ជប្បមា-
ទដ្ឋានា អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា
អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃា-
តោ ឥទំ វុច្ចតិ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី-
សិក្ខាបទំ អវសេសា ធម្មា វេរមណិយា សម្ប-
យុត្តា ។ តត្ថ កតមំ សុរាមេរយមជ្ជប្បមាទដ្ឋានា
វេរមណីសិក្ខាបទំ ។ យស្មិំ សមយេ កាមាវចរំ
កុសលំ ចិត្តំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ
ញាណវិប្បយុត្តំ សសង្ខារេន សុរាមេរយមជ្ជប្ប-
មាទដ្ឋានា វិរមន្តស្ស យា តស្មិំ សមយេ ចេត-
នា សញ្ចេតនា សញ្ចេតយិតត្តំ ឥទំ វុច្ចតិ សុរា-
មេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ អវសេសា
ធម្មា ចេតនាយ សម្បយុត្តា ។ តត្ថ កតមំ
សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ ។

## សិក្ខាបទវិភង្គ អភិធម្មភាជនីយ

បានដល់ការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលា ការសម្រាប់ហេតុ ណា របស់បុគ្គលដែលវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនាជាហេតុវៀរ ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើង ក្នុងសម័យនោះ ការគិត អាការគិត សេចក្តីគិត ណា របស់បុគ្គលដែលវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ តើដូចម្តេច ។

យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារេន សុរាមេរយមជ្ជប្បមាទដ្ឋានា វិរមន្តស្ស ផស្សោ ។បេ។ បគ្គាហោ អវិក្ខេបោ អយំ វុច្ចតិ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ ។

(៤) បញ្ច សិក្ខាបទានិ បាណាតិបាតា វេរមណីសិក្ខាបទំ អទិន្នាទានា វេរមណីសិក្ខាបទំ កាមេសុ មិច្ឆាចារា វេរមណីសិក្ខាបទំ មុសាវាទា វេរមណីសិក្ខាបទំ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ ។

(៥) តត្ថ កតមំ បាណាតិបាតា វេរមណីសិក្ខាបទំ ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ ហីនំ មជ្ឈិមំ បណីតំ ឆន្ទាធិបតេយ្យំ

ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើង ក្នុងសម័យនោះ ការប៉ះពាល់ ។បេ។ ការផ្គង់ឡើង ការមិនកាយមាយ របស់បុគ្គលដែលវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

(៤) សិក្ខាបទ ៥ គឺ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង ១ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ១ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាពោលនូវពាក្យកុហក ១ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ១ ។

(៥) បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ច្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ ជាចិត្តថោកទាប កណ្តាល ឧត្តម ជាចិត្តមានឆន្ទៈជាអធិបតី

វីរិយាធិបតេយ្យំ ចិត្តាធិបតេយ្យំ វីមំសាធិបតេយ្យំ ឆន្ទាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ វីរិយាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ ចិត្តាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ វីមំសាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ បាណាតិបាតា វិរមន្តស្ស យា តស្មឹ សមយេ បាណាតិបាតា អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ ឥទំ វុច្ចតិ បាណាតិបាតា វេរមណីសិក្ខាបទំ អវសេសា ធម្មា វេរមណិយា សម្បយុត្តា ។ តត្ថ កតមំ បាណាតិបាតា វេរមណីសិក្ខាបទំ ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ ហីនំ មជ្ឈិមំ បណីតំ ឆន្ទាធិបតេយ្យំ វីរិយាធិបតេយ្យំ ចិត្តាធិបតេយ្យំ វីមំសាធិបតេយ្យំ ឆន្ទាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ វីរិយាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ

## សិក្ខាបទវិភង្គ អភិធម្មភាជនីយ

មានវីរិយៈជាអធិបតី មានចិត្តជាអធិបតី មានវីមំសាជាអធិបតី ជាចិត្តមានឆន្ទៈជាអធិបតី តែថោកទាប កណ្តាល ឧត្តម ជាចិត្តមានវីរិយៈជាអធិបតី តែថោកទាប កណ្តាល ឧត្តម ជាចិត្តៈមានចិត្តជាអធិបតី តែថោកទាប កណ្តាល ឧត្តម ជាចិត្តមានវីមំសាជាអធិបតី តែថោកទាប កណ្តាល ឧត្តម កើតឡើង ក្នុងសម័យនោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្តាញនូវពៀរ ចាកបាណាតិបាត គឺការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលា ការសម្លាប់ហេតុ ណា របស់បុគ្គលដែលវៀរ ចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្ត ដោយចេតនាជាហេតុវៀរ ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្សសម្បយុត្តដោយញាណ ជាចិត្តថោកទាប កណ្តាល ឧត្តម ជាចិត្តមានឆន្ទៈជាអធិបតី មានវីរិយៈជាអធិបតី មានចិត្តជាអធិបតី មានវីមំសាជាអធិបតី ជាចិត្តមានឆន្ទៈជាអធិបតី តែថោកទាប កណ្តាល ឧត្តម ជាចិត្តមានវីរិយៈជាអធិបតី តែថោកទាប កណ្តាល ឧត្តម

ចិត្តាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ វីមំសាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ បាណាតិបាតា វិរមន្តស្ស យា តស្មឹ សមយេ ចេតនា សញ្ចេតនា សញ្ចេតយិតត្តំ ឥទំ វុច្ចតិ បាណាតិបាតា វេរមណី សិក្ខាបទំ អវសេសា ធម្មា ចេតនាយ សម្បយុត្តា ។ តត្ថ កតមំ បាណាតិបាតា វេរមណី សិក្ខាបទំ ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ ហីនំ មជ្ឈិមំ បណីតំ ឆន្ទាធិបតេយ្យំ វីរិយាធិបតេយ្យំ ចិត្តាធិបតេយ្យំ វីមំសាធិបតេយ្យំ ឆន្ទាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ វីរិយាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ ចិត្តាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ វីមំសាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ បាណាតិបាតា វិរមន្តស្ស ផស្សោ ។ បេ ។ បគ្គាហោ អវិក្ខេបោ ឥទំ វុច្ចតិ បាណាតិបាតា វេរមណី សិក្ខាបទំ ។

ជាចិត្តមានចិត្តៈជាអធិបតី តែថោកទាប កណ្តាល ឧត្តម ជាចិត្តមានវីមំសាជាអធិបតី តែថោកទាប កណ្តាល ឧត្តម កើតឡើង ក្នុងសម័យនោះ ការគិត អាការគិត សេចក្តីគិត ណា របស់បុគ្គលដែលវៀរចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមាតជីវិតឲ្យធ្លាក់ចុះកន្លង ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ ជាចិត្តថោកទាប កណ្តាល ឧត្តម ជាចិត្តមានឆន្ទៈជាអធិបតី មានវីរិយៈជាអធិបតី មានចិត្តៈជាអធិបតី មានវីមំសាជាអធិបតី ជាចិត្តមានឆន្ទៈជាអធិបតី តែថោកទាប កណ្តាល ឧត្តម ជាចិត្តមានវីរិយៈជាអធិបតី តែថោកទាប កណ្តាល ឧត្តម ជាចិត្តមានចិត្តៈជាអធិបតី តែថោកទាប កណ្តាល ឧត្តម ជាចិត្តមានវីមំសាជាអធិបតី តែថោកទាប កណ្តាល ឧត្តម កើតឡើង ក្នុងសម័យនោះ ការប៉ះពាល់ ។ បេ ។ ការផ្គងឡើង ការមិនរាយមាយ របស់បុគ្គលដែលវៀរ ចាកបាណាតិបាត នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ។

## សិក្ខាបទវិភង្គ អភិធម្មភាជនីយំ

តត្ថ កតមំ បាណាតិបាតា វេរមណី សិក្ខាបទំ ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារេន ។ បេ ។ សោមនស្សសហគតំ ញាណវិប្ប-យុត្តំ ។ បេ ។ សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារេន ។ បេ ។ ឧបេក្ខាសហគតំ ញាណសម្ប-យុត្តំ ។ បេ ។ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារេន ។ បេ ។ ឧបេក្ខាសហគតំ ញាណវិប្ប-យុត្តំ ។ បេ ។ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារេន ហីនំ មជ្ឈិមំ បណីតំ ឆន្ទាធិបតេយ្យំ វីរិយាធិបតេយ្យំ ចិត្តាធិបតេយ្យំ ឆន្ទាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ វីរិយាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ ចិត្តាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ បាណាតិបាតា វិរមន្តស្ស យា តស្មឹ សមយេ បាណាតិបាតា អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ ឥទំ វុច្ចតិ

## សិក្ខាបទវិភង្គ អភិធម្មភាជនីយ

បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង តើដូចម្ដេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ច្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ។ បេ ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ។ បេ ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ។ បេ ។ ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ ជាចិត្តថោកទាប កណ្ដាល ឧត្តម ជាចិត្តមានឆន្ទៈជាអធិបតី មានវីរិយៈជាអធិបតី មានចិត្តៈជាអធិបតី ជាចិត្តមានឆន្ទៈជាអធិបតី តែថោកទាប កណ្ដាល ឧត្តម ជាចិត្តមានវីរិយៈជាអធិបតី តែថោកទាប កណ្ដាល ឧត្តម ជាចិត្តមានចិត្តៈជាអធិបតី តែថោកទាប កណ្ដាល ឧត្តម កើតឡើង ក្នុងសម័យនោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបះណ្ដាញនូវពៀរ ចាកបាណាតិបាត គឺការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តិកន្លងវេលា ការសម្លាប់ហេតុណា របស់បុគ្គលដែលវៀរ ចាកបាណាតិបាត នេះហៅថា សិក្ខាបទ

បាណាតិបាតា វេរមណី សិក្ខាបទំ អវសេសា ធម្មា វេរមណិយា សម្បយុត្តា ។បេ។ អវសេសា ធម្មា ចេតនាយ សម្បយុត្តា ។បេ។ ផស្សោ ។បេ។ បគ្គាហោ អវិក្ខេបោ ឥទំ វុច្ចតិ បាណាតិបាតា វេរមណី សិក្ខាបទំ ។

(៦) តត្ថ កតមំ អទិន្នាទានា វេរមណី សិក្ខាបទំ ។បេ។ កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ ។បេ។ មុសាវាទា វេរមណី សិក្ខាបទំ ។បេ។ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ ហីនំ មជ្ឈិមំ បណីតំ ឆន្ទាធិបតេយ្យំ វីរិយាធិបតេយ្យំ ចិត្តាធិបតេយ្យំ វីមំសាធិបតេយ្យំ ឆន្ទាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ វីរិយាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ

គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាសម្បយុត្តដោយចេតនា ជាហេតុវៀរ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាសម្បយុត្តដោយចេតនា ។ បេ ។ ការប៉ះពាល់ ។ បេ ។ ការផ្គងឡើង ការមិនរាយមាយ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ។

(៦) បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ តើដូចម្ដេច ។ បេ ។ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។ បេ ។ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាពោលនូវពាក្យកុហក ។ បេ ។ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ ជាចិត្តថោកទាប កណ្ដាល ឧត្តម ជាចិត្តមានឆន្ទៈជាអធិបតី មានវីរិយៈជាអធិបតី មានចិត្តៈជាអធិបតី មានវីមំសាជាអធិបតី ជាចិត្តមានឆន្ទៈជាអធិបតី តែថោកទាប កណ្ដាល ឧត្តម ជាចិត្តមានវីរិយៈជាអធិបតី តែថោកទាប កណ្ដាល ឧត្តម

## សិក្ខាបទវិភង្គេ អភិធម្មភាជនីយំ

ចិត្តាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ វីមំសាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ សុរាមេរយមជ្ជប្បមាទដ្ឋានា វិរមន្តស្ស យា តស្មិំ សមយេ សុរាមេរយមជ្ជប្បមាទដ្ឋា-នា អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ ឥទំ វុច្ចតិ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ អវ-សេសា ធម្មា វេរមណិយា សម្បយុត្តា ។បេ។ អវ-សេសា ធម្មា ចេតនាយ សម្បយុត្តា ។បេ។ ផស្សោ ។បេ។ បគ្គាហោ អវិក្ខេបោ ឥទំ វុច្ចតិ សុរាមេរយមជ្ជប្ប-មាទដ្ឋានា វេរមណី សិក្ខាបទំ ។ តត្ថ កតមំ សុរា-មេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ ។ យស្មិំ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារេន ។បេ។ សោមនស្សសហគតំ ញាណវិប្បយុត្តំ ។បេ។

ជាចិត្តមានចិត្តៈជាអធិបតី តែថោកទាប កណ្តាល ឧត្តម ជាចិត្តមាន
វីមំសាជាអធិបតី តែថោកទាប កណ្តាល ឧត្តម កើតឡើង ក្នុងសម័យ
នោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្ដោញនូវពៀរ
ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិង
មេរ័យ បានដល់ការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រ-
ព្រឹត្តកន្លងវេលា ការសម្លាប់ហេតុណា របស់បុគ្គលដែលវៀរ ចាកហេតុ
ជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ នេះហៅ
ថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ
គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា
សម្បយុត្តដោយចេតនាជាហេតុវៀរ ។បេ។ ធម៌ទាំងឡាយដ៏សេស
ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ។បេ។ ការប៉ះពាល់ ។បេ។
ការផ្គងឡើង ការមិនរាយមាយ នេះហៅថា សិក្ខាបទ គឺចេតនាជា
ហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺ
សុរានិងមេរ័យ ។ បណ្តាសិក្ខាបទទាំង ៥ នោះ សិក្ខាបទ គឺចេតនា
ជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង
គឺសុរានិងមេរ័យ តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល
ច្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ
។បេ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ។បេ។

សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារេន ។ បេ ។ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ ។ បេ ។ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារេន ។ បេ ។ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ ។ បេ ។ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារេន ហីនំ មជ្ឈិមំ បណីតំ ឆន្ទាធិបតេយ្យំ វីរិយាធិបតេយ្យំ ចិត្តាធិបតេយ្យំ ឆន្ទាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ វីរិយាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ ចិត្តាធិបតេយ្យំ ហីនំ មជ្ឈិមំ បណីតំ សុរាមេរយមជ្ជប្បមាទដ្ឋានា វិរមន្តស្ស យា តស្មឹ សមយេ សុរាមេរយមជ្ជប្បមាទដ្ឋានា អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ ឥទំ វុច្ចតិ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ អវសេសា ធម្មា វេរមណិយា សម្បយុត្តា ។ បេ ។ អវសេសា ធម្មា ចេតនាយ សម្បយុត្តា ។ បេ ។

ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ។ បេ ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ។ បេ ។ ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ ជាចិត្តថោកទាប កណ្ដាល ឧត្ដម ជាចិត្តមានឆន្ទៈជាអធិបតី មានវីរិយៈជាអធិបតី មានចិត្តៈជាអធិបតី ជាចិត្តមានឆន្ទៈជាអធិបតី តែថោកទាប កណ្ដាល ឧត្ដម ជាចិត្តមានវីរិយៈជាអធិបតី តែថោកទាប កណ្ដាល ឧត្ដម ជាចិត្តមានចិត្តៈជាអធិបតី តែថោកទាប កណ្ដាល ឧត្ដម កើតឡើង ក្នុងសម័យនោះ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្ដេញនូវពៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ បានដល់ការមិនធ្វើ ការមិនសាង ការមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលា ការសម្លាប់ហេតុណា របស់បុគ្គលដែលវៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនាជាហេតុវៀរ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា សម្បយុត្តដោយចេតនា ។ បេ ។

ផស្សោ ។ បេ ។ បគ្គាហោ អវិក្ខេបោ ឥទំ វុច្ចតិ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ ។

(៧) កតមេ ធម្មា សិក្ខា ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ រូបារម្មណំ វា ។ បេ ។ ធម្មារម្មណំ វា យំ យំ វា បនារព្ភ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា សិក្ខា ។ កតមេ ធម្មា សិក្ខា ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារេន ។ បេ ។ សោមនស្សសហគតំ ញាណវិប្បយុត្តំ ។ បេ ។ សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារេន ។ បេ ។ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ ។ បេ ។ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារេន ។ បេ ។ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ ។ បេ ។ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារេន រូបារម្មណំ វា ។ បេ ។

ការប៉ះពាល់ ។ បេ ។ ការផ្គន់ឡើង ការមិនកយមាយ នេះហៅថា សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

(៧) ធម៌ទាំងឡាយ ដូចម្ដេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ មានរូបជាអារម្មណ៍ក្ដី ។ បេ ។ មានធម៌ជាអារម្មណ៍ក្ដី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ កើតឡើង ក្នុងសម័យនោះ ការប៉ះពាល់ ក៏កើតមាន ។ បេ ។ ការមិនកយមាយ ក៏កើតមាន ធម៌ទាំងឡាយនេះឈ្មោះថា សិក្ខា ។ ធម៌ទាំងឡាយ ដូចម្ដេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្ប-យុត្តដោយញាណ ប្រកបដោយសង្ខារ ។ បេ ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ។ បេ ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។ បេ ។ ប្រកបដោយឧបេក្ខា សម្បយុត្តដោយញាណ ។ បេ ។ ប្រកបដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។ បេ ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ។ បេ ។ ប្រកបដោយឧ-បេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្ដី ។ បេ ។

ធម្មារម្មណំ វា យំ យំ វា បនារព្ភ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា ។ កតមេ ធម្មា កុសលា ។ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ ។ បេ ។ អរូបូបបត្តិយា មគ្គំ ភាវេតិ ។ បេ ។ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា ។

អភិធម្មភាជនីយំ ។

---

# សិក្ខាបទវិភង្គេ បញ្ហាបុច្ឆកំ

(៨) បញ្ច សិក្ខាបទានិ បាណាតិបាតា វេរមណី សិក្ខាបទំ អទិន្នាទានា វេរមណី សិក្ខាបទំ កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ

មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ កើតឡើង ក្នុងសម័យនោះ ការប៉ះពាល់ ក៏កើតមាន ។ បេ ។ ការមិនរាយមាយ ក៏កើតមាន ធម៌ទាំងឡាយនេះ ឈ្មោះថា សិក្ខា ។ ធម៌ទាំងឡាយ ដូចម្តេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា បុគ្គលចំរើនមគ្គ ដើម្បីកើតក្នុងរូបភព ។ បេ ។ ចំរើនមគ្គ ដើម្បីកើតក្នុងរូបភព ។ បេ ។ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ មិនដល់នូវការសន្សំ (កិលេសវដ្ដៈ) ដើម្បីលះបង់នូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិដ៏លំបាក មានការត្រាស់ដឹងដ៏យឺតយូរ កើតឡើង ក្នុងសម័យនោះ ការប៉ះពាល់ ក៏កើតមាន ។ បេ ។ ការមិនរាយមាយ ក៏កើតមាន ធម៌ទាំងឡាយនេះ ឈ្មោះថា សិក្ខា ។

ចប់ អភិធម្មភាជនីយ ។

---

# សិក្ខាបទវិភង្គ បញ្ហាបុច្ឆកៈ

[៨] សិក្ខាបទ ៥ គឺ សិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ១ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ១ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ ១

## សិក្ខាបទវិភង្គេ បញ្ហាបុច្ឆកំ

មុសាវាទា វេរមណី សិក្ខាបទំ សុរាមេរយមជ្ជប្បមា·
ទដ្ឋានា វេរមណី សិក្ខាបទំ ។ បញ្ចន្នំ សិក្ខា·
បទានំ កតិ កុសលា កតិ អកុសលា កតិ អព្យា·
កតា ។ បេ ។ កតិ សរណា កតិ អរណា ។

(៩) កុសលាយេវ សិយា សុខាយ វេទនាយ
សម្បយុត្តា សិយា អទុក្ខមសុខាយ វេទនាយ
សម្បយុត្តា វិបាកធម្មធម្មា អនុបាទិន្នុបាទានិយា អ·
សង្កិលិដ្ឋសង្កិលេសិកា សវិតក្កសវិចារា សិយា បីតិ·
សហគតា សិយា សុខសហគតា សិយា ឧបេក្ខា·
សហគតា នេវ ទស្សនេន ន ភាវនាយ បហាតព្វា
នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា
អាចយគាមិនោ នេវ សេក្ខា នាសេក្ខា បរិត្តា បរិត្តា·
រម្មណា មជ្ឈិមា អនិយតា ន វត្តព្វា មគ្គារម្មណាតិបិ
មគ្គហេតុកាតិបិ មគ្គាធិបតិនោតិបិ សិយា ឧប្បន្នា

## សិក្ខាបទវិភង្គ បញ្ហាបុច្ឆកៈ

សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាពោលនូវពាក្យកុហក ១ សិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ១ ៗ បណ្ដាសិក្ខាបទទាំង ៥ សិក្ខាបទ ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

(៩) សិក្ខាបទទាំង ៥ ជាកុសលតែម្យ៉ាង ប្រកបដោយវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនា មានវិបាកធម៌ ជាប្រក្រតី មិនមានកម្ម ប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក តែជាប្រយោជន៍ដល់ឧបាទាន មិនប្រកបដោយសេចក្ដីសៅហ្មង តែគួរដល់នូវសេចក្ដីសៅហ្មង ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ក៏មាន កើតព្រមដោយបីតិ ក៏មាន កើតព្រមដោយសុខៈ ក៏មាន កើតព្រមដោយឧបេក្ខា តែមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដល់នូវការសន្សំ មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល មានសភាពតូចឆ្មារ មានអារម្មណ៍តូចឆ្មារ ជាកណ្ដាល មានសភាពមិនទៀង ពោលថា មានមគ្គជាអារម្មណ៍ផង ថាមានមគ្គ-ជាហេតុផង ថាមានមគ្គជាអធិបតីផង ក៏មាន កើតឡើងហើយក៏មាន

សិយា អនុប្បន្នា ន វត្តព្វា ឧប្បាទិនោតិ សិយា អតីតា សិយា អនាគតា សិយា បច្ចុប្បន្នា បច្ចុប្បន្នារម្មណា សិយា អជ្ឈត្តា សិយា ពហិទ្ធា សិយា អជ្ឈត្តពហិទ្ធា ពហិទ្ធារម្មណា អនិទស្សនាប្បដិឃា ។

(១០) ន ហេតូ សហេតុកា ហេតុសម្បយុត្តា ន វត្តព្វា ហេតូ ចេវ សហេតុកា ចាតិ សហេតុកា ចេវ ន ច ហេតូ ន វត្តព្វា ហេតូ ចេវ ហេតុសម្បយុត្តា ចាតិ ហេតុសម្បយុត្តា ចេវ ន ច ហេតូ ន ហេតូ សហេតុកា ។ សប្បច្ចយា សង្ខតា អនិទស្សនា អប្បដិឃា អរូបា លោកិយា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។ នោ អាសវា សាសវា អាសវវិប្បយុត្តា ន វត្តព្វា អាសវា ចេវ សាសវា ចាតិ សាសវា ចេវ នោ ច អាសវា ន វត្តព្វា អាសវា ចេវ អាសវសម្បយុត្តា ចាតិបិ អាសវសម្បយុត្តា ចេវ នោ ច អាសវាតិបិ អាសវវិប្បយុត្តសាសវា ។

មិនទាន់កើតឡើង តែមិនគួរពោលថា បំរុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្ន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុងនិងខាងក្រៅ មានអារម្មណ៍ជាខាងក្រៅ មិនប្រកបដោយការឃើញ តាំងមិនប្រកបដោយការប៉ះពាល់ក៏មាន ។

(១០) ពួកសិក្ខាបទមិនមែនហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ មិនគួរពោលថា ជាហេតុ តាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ មិនគួរពោលថា ជាហេតុ តាំងប្រកបដោយហេតុឡើយ ប្រកបដោយហេតុ តែមិនមែនហេតុ មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ។ ពួកសិក្ខាបទប្រព្រឹត្តទៅជាមួយនឹងបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ មិនមានរូប ជាលោកិយ គួរដឹងច្បាស់ដោយវិញ្ញាណណាមួយ មិនគួរដឹងច្បាស់ដោយវិញ្ញាណណាមួយ ។ ពួកសិក្ខាបទមិនមែនអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ប្រាសចាកអាសវៈ មិនគួរពោលថាជាអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈទេ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈ មិនគួរពោលថា ជាអាសវៈ តាំងប្រកបដោយអាសវៈ ផងជាប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងឡើយ គឺប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ។

## សិក្ខាបទវិភង្គេ បញ្ហាបុច្ឆកំ

នោ សញ្ញោជនា ។បេ។ នោ គន្ថា ។បេ។ នោ ឱឃា ។បេ។ នោ យោគា ។បេ។ នោ នីវរណា ។បេ។ នោ បរាមាសា ។បេ។ សារម្មណា នោ ចិត្តា ចេតសិកា ចិត្តសម្បយុត្តា ចិត្តសំសដ្ឋា ចិត្តសមុដ្ឋានា ចិត្តសហភុនោ ចិត្តានុបរិវត្តិនោ ចិត្តសំសដ្ឋសមុដ្ឋានា ចិត្តសំសដ្ឋសមុដ្ឋានសហភុនោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ពាហិរា នុបាទា អនុបាទិន្នា ។ នុបាទានា ។បេ។ នោ កិលេសា ។បេ។ ន ទស្សនេន បហាតព្វា ន ភាវនាយ បហាតព្វា ន ទស្សនេន បហាតព្វហេតុកា ន ភាវនាយ បហាតព្វហេតុកា សវិតក្កា សវិចារា សិយា សប្បីតិកា សិយា អប្បីតិកា សិយា បីតិសហគតា សិយា ន បីតិសហគតា សិយា សុខសហគតា សិយា ន សុខសហគតា សិយា ឧបេក្ខាសហគតា សិយា ន ឧបេក្ខាសហគតា កាមាវចរា ន រូបាវចរា ន អរូបាវចរា បរិយាបន្នា អនិយ្យានិកា អនិយតា សឧត្តរា អរណាតិ ។

បញ្ហាបុច្ឆកំ ។

សិក្ខាបទវិភង្គោ សមត្តោ ។

## សិក្ខាបទវិភង្គ បញ្ហាបុច្ឆកៈ

ពួកសិក្ខាបទមិនមែនសញ្ញោជនៈ ។ បេ ។ មិនមែនគន្ថៈ ។ បេ ។ មិនមែនឱឃៈ ។ បេ ។ មិនមែនយោគៈ ។ បេ ។ មិនមែននីវរណៈ ។ បេ ។ មិនមែនបរាមាសៈ ។ បេ ។ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ច្រឡំដោយចិត្ត តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្ត ច្រឡំទាំងតាំងឡើងដោយចិត្ត ច្រឡំទាំងតាំងឡើងទាំងកើតជាមួយនឹងចិត្ត ច្រឡំទាំងតាំងឡើងទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា មិនមានកម្ម ប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកទេ ។ ពួកសិក្ខាបទមិនមែនឧបាទាន ។ បេ ។ មិនមែនកិលេស ។ បេ ។ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ មានហេតុមិនគួរលះដោយភាវនា ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ប្រព្រឹត្តទៅជាមួយនឹងវិចារៈ ប្រព្រឹត្តទៅជាមួយនឹងបីតិ ក៏មាន មិនមានបីតិ ក៏មាន កើតព្រមដោយបីតិ ក៏មាន មិនកើតព្រមដោយបីតិ ក៏មាន ប្រកបដោយសុខៈ ក៏មាន មិនកើតព្រមដោយសុខៈ ក៏មាន កើតព្រមដោយឧបេក្ខា ក៏មាន មិនកើតព្រមដោយឧបេក្ខា ជាកាមាវចរៈ មិនមែនរូបាវចរៈ មិនមែនជាអរូបាវចរៈ ជាបរិយាបន្នៈ ជាអនិយ្យានិកៈ ជាអនិយតៈ ជាសឧត្តរៈ ជាអរណៈ ។

ចប់ បញ្ហាបុច្ឆកៈ ។

ចប់ សិក្ខាបទវិភង្គ ។

# បដិសម្ភិទាវិភង្គោ

(១១) ចតស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ អត្ថេ ញាណំ អត្ថប្បដិសម្ភិទា ធម្មេ ញាណំ ធម្មប្បដិសម្ភិទា តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។

(១២) ចតស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ទុក្ខេ ញាណំ អត្ថប្បដិសម្ភិទា ទុក្ខសមុទយេ ញាណំ ធម្មប្បដិសម្ភិទា ទុក្ខនិរោធេ ញាណំ អត្ថប្បដិសម្ភិទា ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ ធម្មប្បដិសម្ភិទា តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។

# បដិសម្ភិទាវិភង្គ

[ ១១ ] បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ សេចក្ដីដឹងក្នុងអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្ដីដឹងក្នុងធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្ដីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថនិងធម៌នោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្ដីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

[ ១២ ] បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ សេចក្ដីដឹងក្នុងទុក្ខ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្ដីដឹង ក្នុងការកើតឡើងនៃទុក្ខ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្ដីដឹងក្នុងការរលត់ទុក្ខ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្ដីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្ដីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថនិងធម៌នោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្ដីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

## បដិសម្ភិទាវិភង្គេ សុត្តន្តភាជនីយំ

(១៣) ចតស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ហេតុម្ហិ ញាណំ ធម្មប្បដិសម្ភិទា ហេតុផលេ ញាណំ អត្ថប្បដិសម្ភិទា តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។

(១៤) ចតស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ យេ ធម្មា ជាតា ភូតា សញ្ជាតា និព្វត្តា អភិនិព្វត្តា បាតុភូតា ឥមេសុ ធម្មេសុ ញាណំ អត្ថប្បដិសម្ភិទា យេហិ ធម្មេហិ[1] តេ ធម្មា ជាតា ភូតា សញ្ជាតា និព្វត្តា អភិនិព្វត្តា បាតុភូតា តេសុ ធម្មេសុ ញាណំ ធម្មប្បដិសម្ភិទា តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។

---

១ ម. យម្ហា ធម្មា ។

## បដិសម្ភិទាវិភង្គ សុត្តន្តភាជនីយ

(១៣) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ សេចក្តីដឹងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងផលនៃហេតុ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងធម៌និងអត្ថនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

(១៤) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ធម៌ទាំងឡាយណា កើត ចំរើន លូតលាស់ ដុះដាល ចំរុងចំរើន កើតប្រាកដហើយ សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា ធម៌ទាំងឡាយនោះ កើត ចំរើន លូតលាស់ ដុះដាល ចំរុងចំរើន កើតប្រាកដហើយ អំពីធម៌ទាំងឡាយណា សេចក្តីដឹងក្នុងធម៌ទាំងឡាយនោះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថនិងធម៌នោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

(១៨) ចតស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ជរាមរណេ ញាណំ អត្ថប្បដិសម្ភិទា ជរាមរណសមុទយេ ញាណំ ធម្មប្បដិសម្ភិទា ជរាមរណនិរោធេ ញាណំ អត្ថប្បដិសម្ភិទា ជរាមរណនិរោធគាមិនិយា បដិបទាយ ញាណំ ធម្មប្បដិសម្ភិទា តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។

(១៩) ចតស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ជាតិយា ញាណំ ។បេ។ ភវេ ញាណំ ។បេ។ ឧបាទានេ ញាណំ ។បេ។ តណ្ហាយ ញាណំ ។បេ។ វេទនាយ ញាណំ ។បេ។ ផស្សេ ញាណំ ។បេ។ សឡាយតនេ ញាណំ ។បេ។ នាមរូបេ ញាណំ ។បេ។ វិញ្ញាណេ ញាណំ ។បេ។ សង្ខារេសុ ញាណំ អត្ថប្បដិសម្ភិទា សង្ខារសមុទយេ ញាណំ ធម្មប្បដិសម្ភិទា សង្ខារនិរោធេ ញាណំ អត្ថប្បដិសម្ភិទា

(១៥) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ សេចក្ដីដឹងក្នុងជរានិងមរណៈ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្ដីដឹងក្នុងការកើតឡើងនៃជរានិងមរណៈ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្ដីដឹងក្នុងការរលត់នៃជរា និងមរណៈ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្ដីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃជរានិងមរណៈ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្ដីដឹងក្នុងការពោល នូវធម្មនិរុត្តិ ក្នុងអត្ថនិងធម៌នោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្ដីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

(១៦) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ សេចក្ដីដឹងក្នុងជាតិ ។ បេ ។ សេចក្ដីដឹងក្នុងភព ។ បេ ។ សេចក្ដីដឹងក្នុងឧបាទាន ។ បេ ។ សេចក្ដីដឹងក្នុងតណ្ហា ។ បេ ។ សេចក្ដីដឹងក្នុងវេទនា ។ បេ ។ សេចក្ដីដឹងក្នុងផស្សៈ ។ បេ ។ សេចក្ដីដឹងក្នុងសឡាយតនៈ ។ បេ ។ សេចក្ដីដឹងក្នុងនាមរូប ។ បេ ។ សេចក្ដីដឹងក្នុងវិញ្ញាណ ។ បេ ។ សេចក្ដីដឹងក្នុងសង្ខារទាំងឡាយ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្ដីដឹងក្នុងការកើតឡើងនៃសង្ខារ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្ដីដឹងក្នុងការរលត់នៃសង្ខារ ឈ្មោះថា អត្ថប្បដិសម្ភិទា

សង្ខារនិរោធគាមិនិយា បដិបទាយ ញាណំ ធម្មប្បដិសម្ភិទា តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។

(១៧) ចតស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ តត្ថ កតមា ធម្មប្បដិសម្ភិទា ។ ឥធ ភិក្ខុ ធម្មំ ជានាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ អយំ វុច្ចតិ ធម្មប្បដិសម្ភិទា សោ តស្ស តស្សេវ ភាសិតស្ស អត្ថំ ជានាតិ អយំ ឥមស្ស ភាសិតស្ស អត្ថោ អយំ ឥមស្ស ភាសិតស្ស អត្ថោតិ អយំ វុច្ចតិ អត្ថប្បដិសម្ភិទា តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។

សុត្តន្តភាជនីយំ ។

## បដិសម្ភិទាវិភង្គ សុត្តន្តភាជនីយ

សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថនិងធម៌នោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

( ១៧ ) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ បណ្តាបដិសម្ភិទាទាំង ៤ នោះ ធម្មប្បដិសម្ភិទា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ដឹងនូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ នេះឈ្មោះថា ធម្មប្បដិសម្ភិទា ភិក្ខុនោះ ដឹងនូវសេចក្តីនៃភាសិតនោះ ៗ ថា នេះសេចក្តីនៃភាសិតនេះ នេះសេចក្តីនៃភាសិតនេះ នេះឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថនិងធម៌នោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

ចប់ សុត្តន្តភាជនីយ ។

## អភិធម្មបិដកេ វិភង្គោ

(១៨) ចតស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ កតមេ ធម្មា កុសលា ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ រូបារម្មណំ វា ។ បេ ។ ធម្មារម្មណំ វា យំ យំ វា បនារព្ភ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា ឥមេសុ ធម្មេសុ ញាណំ ធម្មប្បដិសម្ភិទា តេសំ វិបាកេ ញាណំ អត្ថប្បដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។ ចតស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។

(១៨) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ច្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ មានរូបជាអារម្មណ៍ក្តី ។ បេ ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។ បេ ។ សេចក្តីមិនរាយមាយ ក៏កើតមាន នេះពួកធម៌ជាកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងនូវញាណទាំងឡាយថា បុគ្គលដឹងក្នុងញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។

## បដិសម្ភិទាវិភង្គេ អភិធម្មភាជនីយំ

កតមេ ធម្មា កុសលា ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារេន ។ បេ ។ សោមនស្សសហគតំ ញាណវិប្បយុត្តំ ។ បេ ។ សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារេន ។ បេ ។ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ ។ បេ ។ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារេន ។ បេ ។ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ ។ បេ ។ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារេន រូបារម្មណំ វា ។ បេ ។ ធម្មារម្មណំ វា យំ យំ វា បនារព្ភ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា ឥមេសុ ធម្មេសុ ញាណំ ធម្មបដិសម្ភិទា តេសំ វិបាកេ ញាណំ អត្ថបដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិបដិសម្ភិទា

## បដិសម្ភិទាវិភង្គ អភិធម្មភាជនីយ

ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ច្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ។បេ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។បេ។ ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។បេ។ សេចក្តីមិនរាយមាយ ក៏កើតមាន នេះពួកធម៌ជាកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា

យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណបដិសម្ភិទា ។ ចតស្សោ បដិសម្ភិទា អត្ថបដិសម្ភិទា ធម្មបដិសម្ភិទា និរុត្តិបដិសម្ភិទា បដិភាណបដិសម្ភិទា ។ កតមេ ធម្មា កុសលា ។ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ផស្សោ ហោតិ ។បេ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា ឥមេសុ ធម្មេសុ ញាណំ ធម្មបដិសម្ភិទា តេសំ វិបាកេ ញាណំ អត្ថបដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិបដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណបដិសម្ភិទា ។

## អភិធម្មបិដក វិភង្គ

សេចក្ដីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាកុសល តើដូចម្ដេច ។ ក្នុងសម័យណា បុគ្គលចំរើននូវមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។ បេ ។ សេចក្ដីមិនរាយមាយ ក៏កើតមាន នេះពួកធម៌ជាកុសល សេចក្ដីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្ដីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្ដីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្ដីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

## បដិសម្ភិទាវិភង្គ អភិធម្មភាជនីយំ

ចតស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិ-
ទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ កតម-
េ ធម្មា កុសលា ។ យស្មឹ សមយេ អរូបូបបត្តិយា
មគ្គំ ភាវេតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម
នេវសញ្ញានាសញ្ញាយតនសញ្ញាសហគតំ សុខស្ស ច
បហានា ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ
តស្មឹ សមយេ ផស្សោ ហោតិ ។បេ។ អវិក្ខេបោ
ហោតិ ឥមេ ធម្មា កុសលា ឥមេសុ ធម្មេសុ ញាណំ
ធម្មប្បដិសម្ភិទា តេសំ វិបាកេ ញាណំ អត្ថប្បដិ-
សម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ
ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិ-
សម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ
ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ
ញាណំ បដិភាណប្បដិសម្ភិទា ។ ចតស្សោ បដិសម្ភិទា
អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា
បដិភាណប្បដិសម្ភិទា ។ កតមេ ធម្មា កុសលា ។

## បដិសម្ភិទាវិភង្គ អភិធម្មភាជនីយ

បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចំរើននូវមគ្គ ដើម្បីកើតក្នុងអរូបភព ព្រោះកិរិយាកន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយលះបង់នូវសុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។ បេ ។ សេចក្តីមិនរាយមាយ ក៏កើតមាន នេះពួកធម៌ជាកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាកុសល តើដូចម្តេច ។

យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។បេ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា ឥមេសុ ធម្មេសុ ញាណំ ធម្មប្បដិសម្ភិទា តេសំ វិបាកេ ញាណំ អត្ថប្បដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។

(១៩) ចតស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ កតមេ ធម្មា អកុសលា ។

ក្នុងសម័យណា បុគ្គលចំរើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះបង់នូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។ បេ ។ សេចក្តីមិនរាយមាយ ក៏កើតមាន នេះពួកធម៌ជាកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងវិបាក នៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

(១៩) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអកុសល តើដូចម្តេច ។

## បដិសម្ភិទាវិភង្គេ អភិធម្មភាជនីយំ

យស្មឹ សមយេ អកុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោម-
នស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ រូបារម្មណំ វា ។
បេ ។ ធម្មារម្មណំ វា យំ យំ បនារព្ភ តស្មឹ សមយេ
ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា
អកុសលា ឥមេសុ ធម្មេសុ ញាណំ ធម្មប្បដិ-
សម្ភិទា តេសំ វិបាកេ ញាណំ អត្ថប្បដិសម្ភិទា
យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ
ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា យេន
ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ
ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណ-
ប្បដិសម្ភិទា ។ ចតស្សោ បដិសម្ភិទា អត្ថប្បដិស-
ម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្ប-
ដិសម្ភិទា ។ កតមេ ធម្មា អកុសលា ។ យស្មឹ
សមយេ អកុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមន-
ស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារេន ។ បេ ។

## បដិសម្ភិទាវិភង្គ អភិធម្មភាជនីយ

ក្នុងសម័យណា ចិត្តជាអកុសល ច្រឡំដោយសោមនស្ស សម្បយុត្តដោយទិដ្ឋិ មានរូបជាអារម្មណ៍ក្តី ។ បេ ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។ បេ ។ សេចក្តីមិនរាយមាន ក៏កើតមាន នេះពួកធម៌ជាអកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអកុសល តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាអកុសល ច្រឡំដោយសោមនស្ស សម្បយុត្តដោយទិដ្ឋិ ប្រកបដោយសង្ខារ ។ បេ ។

សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ ។ បេ ។ សោម-
នស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារេន ។ បេ ។
ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ ។ បេ ។ ឧបេក្ខា-
សហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារេន ។ បេ ។
ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ ។ បេ ។ ឧបេក្ខា-
សហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារេន ។ បេ ។ ទោម-
នស្សសហគតំ បដិឃសម្បយុត្តំ ។ បេ ។ ទោមនស្ស-
សហគតំ បដិឃសម្បយុត្តំ សសង្ខារេន ។ បេ ។ ឧបេ-
ក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ ។ បេ ។ ឧបេក្ខា-
សហគតំ ឧទ្ធច្ចសម្បយុត្តំ រូបារម្មណំ វា ។ បេ ។
ធម្មារម្មណំ វា យំ យំ វា បនារព្ភ តស្មឹ សមយេ
ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ
ធម្មា អកុសលា ឥមេសុ ធម្មេសុ ញាណំ ធម្មប្បដិ-
សម្ភិទា តេសំ វិបាកេ ញាណំ អត្ថប្បដិសម្ភិទា
យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ

ច្រឡំដោយសោមនស្ស ប្រាសចាកទិដ្ឋិ ។ បេ ។ ច្រឡំដោយសោមនស្ស ប្រាសចាកទិដ្ឋិ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយទិដ្ឋិ ។ បេ ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយទិដ្ឋិ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយឧបេក្ខា ប្រាសចាកទិដ្ឋិ ។បេ។ ច្រឡំដោយឧបេក្ខា ប្រាសចាកទិដ្ឋិ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយទោមនស្ស សម្បយុត្តដោយបដិឃៈ បេ ។ ច្រឡំដោយទោមនស្ស សម្បយុត្តដោយបដិឃៈ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយវិចិកិច្ឆា បេ ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយឧទ្ធច្ចៈ មានរូបជាអារម្មណ៍ក្តី ។ បេ ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្ស ក៏កើតមាន ។ បេ ។ សេចក្តីមិនរាយមាយក៏កើតមាន នេះពួកធម៌ជាអកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយទិរុត្តិណា

តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិបដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណបដិសម្ភិទា ។

(២០) តិស្សោ បដិសម្ភិទា អត្ថបដិសម្ភិទា និរុត្តិបដិសម្ភិទា បដិភាណបដិសម្ភិទា ។ កតមេ ធម្មា អព្យាកតា ។ យស្មឹ សមយេ កាមាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ ចក្ខុវិញ្ញាណំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ រូបា-រម្មណំ តស្មឹ សមយេ ផស្សោ ហោតិ វេទនា ហោតិ សញ្ញា ហោតិ ចេតនា ហោតិ ចិត្តំ ហោតិ ឧបេក្ខា ហោតិ ចិត្តស្ស ឯកគ្គតា ហោតិ មនិន្ទ្រិយំ ហោតិ ឧបេក្ខិន្ទ្រិយំ ហោតិ ជីវិតិន្ទ្រិយំ ហោតិ យេ វា បន តស្មឹ សមយេ អញ្ញេបិ អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា អព្យា-កតា ឥមេសុ ធម្មេសុ ញាណំ អត្ថបដិសម្ភិទា

## បដិសម្ភិទាវិភង្គ អភិធម្មភាជនីយ

សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិ-សម្ភិទា ។ សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

(៤០) បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភា-ណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា ចក្ខុវិញ្ញាណជាវិបាក ព្រោះកម្មជាកាមាវចរកុសល ដែលបុគ្គលធ្វើហើយ សន្សំហើយ ជាចក្ខុវិញ្ញាណ ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ កើតឡើងហើយ ក្នុងសម័យនោះ ផស្សៈ កើតមាន វេទនា កើតមាន សញ្ញា កើតមាន ចេតនា កើតមាន ចិត្ត កើតមាន ឧបេក្ខា កើតមាន ចិត្តេកគ្គតា កើតមាន មនិន្ទ្រិយ កើតមាន ឧបេក្ខិន្ទ្រិយ កើតមាន ជីវិតិន្ទ្រិយ កើតមាន ឬក៏ ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូបអាស្រ័យនឹងគ្នា ហើយកើតឡើង ក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា

យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។ តិស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ កតមេ ធម្មា អព្យាកតា ។ យស្មឹ សមយេ កាមាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ សោតវិញ្ញាណំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ សទ្ទារម្មណំ ។ បេ ។ ឃានវិញ្ញាណំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ គន្ធារម្មណំ ។ បេ ។ ជិវ្ហាវិញ្ញាណំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ រសារម្មណំ ។ បេ ។ កាយវិញ្ញាណំ ឧប្បន្នំ ហោតិ សុខសហគតំ ផោដ្ឋព្វារម្មណំ តស្មឹ សមយេ ផស្សោ ហោតិ វេទនា ហោតិ សញ្ញា ហោតិ ចេតនា ហោតិ ចិត្តំ ហោតិ សុខំ ហោតិ ចិត្តស្សេកគ្គតា ហោតិ

បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា សោតវិញ្ញាណ ជាវិបាក ព្រោះកម្មជាកាមាវចរកុសល ដែលបុគ្គលធ្វើហើយ សន្សំហើយ ជាសោតវិញ្ញាណ ប្រកបដោយឧបេក្ខា មានសំឡេងជាអារម្មណ៍ កើតឡើងហើយ ។ បេ ។ ឃានវិញ្ញាណ ប្រកបដោយឧបេក្ខា មានក្លិនជាអារម្មណ៍ កើតឡើងហើយ ។បេ។ ជិវ្ហាវិញ្ញាណ ប្រកបដោយឧបេក្ខា មានរសជាអារម្មណ៍ កើតឡើងហើយ ។បេ។ កាយវិញ្ញាណ ប្រកបដោយសុខ មានផ្សព្វជាអារម្មណ៍ កើតឡើងហើយ ក្នុងសម័យនោះ ផស្សៈ កើតមាន វេទនា កើតមាន សញ្ញា កើតមាន ចេតនា កើតមាន ចិត្ត កើតមាន សុខ កើតមាន ចិត្តេកគ្គតា កើតមាន

## បដិសម្ភិទាវិភង្គេ អភិធម្មភាជនីយំ

មនិន្ទ្រិយំ ហោតិ សុខិន្ទ្រិយំ ហោតិ ជីវិតិន្ទ្រិយំ
ហោតិ យេ វា បន តស្មឹ សមយេ អញ្ញេបិ
អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា
អព្យាកតា ឥមេសុ ធម្មេសុ ញាណំ អត្ថប្បដិ-
សម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ
ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិ-
សម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ
ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ
ញាណំ បដិភាណប្បដិសម្ភិទា ។ តិស្សោ បដិសម្ភិទា
អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិ-
សម្ភិទា ។ កតមេ ធម្មា អព្យាកតា ។ យស្មឹ
សមយេ កាមាវចរស្ស កុសលស្ស កម្មស្ស
កតត្តា ឧបចិតត្តា វិបាកា មនោធាតុ ឧប្បន្នា
ហោតិ ឧបេក្ខាសហគតា រូបារម្មណា វា ។ បេ ។
ផោដ្ឋព្វារម្មណា វា យំ យំ វា បនារព្ភ តស្មឹ សមយេ
ផស្សោ ហោតិ វេទនា ហោតិ សញ្ញា ហោតិ

## បដិសម្ភិទាវិភង្គ អភិធម្មភាជនីយ

មនិន្ទ្រិយ កើតមាន សុខិន្ទ្រិយ កើតមាន ជីវិតិន្ទ្រិយ កើតមាន ឬក៏ ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូប អាស្រ័យនឹងគ្នាហើយកើតឡើង ក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោធាតុ ជាវិបាក ព្រោះកម្មជាកាមាវចរកុសល ដែលបុគ្គលធ្វើហើយ សន្សំហើយ ជាមនោធាតុ ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។ បេ ។ មានផ្សព្វ ជាអារម្មណ៍ក្តី ឬក៏ ប្រារព្ធនូវអារម្មណ៍ណា ១ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈ កើតមាន វេទនា កើតមាន សញ្ញា កើតមាន

ចេតនា ហោតិ ចិត្តំ ហោតិ វិតក្កោ ហោតិ វិចារោ ហោតិ ឧបេក្ខា ហោតិ ចិត្តស្ស ឯកគ្គតា ហោតិ មនិន្ទ្រិយំ ហោតិ ឧបេក្ខិន្ទ្រិយំ ហោតិ ជីវិតិន្ទ្រិយំ ហោតិ យេ វា បន តស្មឹ សមយេ អញ្ញេបិ អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា អព្យាកតា ឥមេសុ ធម្មេសុ ញាណំ អត្ថប្បដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។ តិស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ កតមេ ធម្មា អព្យាកតា ។ យស្មឹ សមយេ កាមាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកា មនោវិញ្ញាណធាតុ ឧប្បន្នា ហោតិ សោមនស្សសហគតា រូបារម្មណា វា ។បេ។ ធម្មារម្មណា វា យំ យំ វា បនារព្ភ

ចេតនា កើតមាន ចិត្ត កើតមាន វិតក្កៈ កើតមាន វិចារៈ កើតមាន ឧបេក្ខា កើតមាន ចិត្តេកគ្គតា កើតមាន មនិន្ទ្រិយ កើតមាន ឧបេក្ខិន្ទ្រិយ កើតមាន ជីវិតិន្ទ្រិយ កើតមាន ឬក៏ ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូប អាស្រ័យនឹងគ្នាហើយកើតឡើង ក៏កើតមាន នេះពួកធម៌ ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោវិញ្ញាណធាតុ ជាវិបាកព្រោះកម្មជាកាមាវចរកុសល ដែលបុគ្គលធ្វើហើយ សន្សំហើយ ជាមនោវិញ្ញាណធាតុ ប្រកបដោយសោមនស្ស មានរូបជាអារម្មណ៍ក្តី ។ បេ ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ ប្រារព្ធនូវអារម្មណ៍ណាមួយ ហើយកើតឡើង

### បដិសម្ភិទាវិភង្គោ អភិធម្មភាជនីយំ

តស្មឹ សមយេ ផស្សោ ហោតិ វេទនា ហោតិ សញ្ញា ហោតិ ចេតនា ហោតិ ចិត្តំ ហោតិ វិតក្កោ ហោតិ វិចារោ ហោតិ បីតិ ហោតិ សុខំ ហោតិ ចិត្តស្ស ឯកគ្គតា ហោតិ មនិន្ទ្រិយំ ហោតិ សោមនស្សិន្ទ្រិយំ ហោតិ ជីវិតិន្ទ្រិយំ ហោតិ យេ វា បន តស្មឹ សមយេ អញ្ញេបិ អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា អព្យាកតា ឥមេសុ ធម្មេសុ ញាណំ អត្ថប្បដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។ តិស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ កតមេ ធម្មា អព្យាកតា ។ យស្មឹ សមយេ កាមាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកា មនោវិញ្ញាណធាតុ

## បដិសម្ភិទាវិភង្គ អភិធម្មភាជនីយ

ក្នុងសម័យនោះ ផស្សៈ កើតមាន វេទនា កើតមាន សញ្ញា កើតមាន ចេតនា កើតមាន ចិត្ត កើតមាន វិតក្កៈ កើតមាន វិចារៈ កើតមាន បីតិ កើតមាន សុខ កើតមាន ចិត្តេកគ្គតា កើតមាន មនិន្ទ្រិយ កើតមាន សោមនស្សិន្ទ្រិយ កើតមាន ជីវិតិន្ទ្រិយ កើតមាន ឬក៏ ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃ ណា មិនមានរូប អាស្រ័យនឹងគ្នាហើយកើតឡើង ក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្ដីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្ដីដឹងក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្ដីដឹងក្នុងញាណទាំងឡាយថា បុគ្គល ដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ ក្នុងសម័យណា មនោវិញ្ញាណធាតុ ជាវិបាក ព្រោះកម្មជាកាមាវចរកុសល

ឧប្បន្នា ហោតិ ឧបេក្ខាសហគតា រូបារម្មណា វា ។បេ។ ធម្មារម្មណា វា យំ យំ វា បនារព្ភ តស្មឹ សមយេ ផស្សោ ហោតិ វេទនា ហោតិ សញ្ញា ហោតិ ចេតនា ហោតិ ចិត្តំ ហោតិ វិតក្កោ ហោតិ វិចារោ ហោតិ ឧបេក្ខា ហោតិ ចិត្តស្ស ឯកគ្គតា ហោតិ មនិន្ទ្រិយំ ហោតិ ឧបេក្ខិន្ទ្រិយំ ហោតិ ជីវិតិន្ទ្រិយំ ហោតិ យេ វា បន តស្មឹ សមយេ អញ្ញេបិ អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា អព្យាកតា ។ ឥមេសុ ធម្មេសុ ញាណំ អត្ថប្ប-ដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្ប-ដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។ តិស្សោ បដិស-ម្ភិទា អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណ-ប្បដិសម្ភិទា ។ កតមេ ធម្មា អព្យាកតា ។

## អភិធម្មបិដក វិភង្គ

ដែលបុគ្គលធ្វើហើយ សន្សំហើយ ជាមនោវិញ្ញាណធាតុ ប្រកបដោយ ឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។ បេ ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ ប្រារព្ធ នូវអារម្មណ៍ណា ៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈ កើតមាន វេទនា កើតមាន សញ្ញា កើតមាន ចេតនា កើតមាន ចិត្ត កើតមាន វិតក្កៈ កើតមាន វិចារៈ កើតមាន ឧបេក្ខា កើតមាន ចិត្តេកគ្គតា កើតមាន មនិន្ទ្រិយ កើតមាន ឧបេក្ខិន្ទ្រិយ កើតមាន ជីវិតិន្ទ្រិយ កើតមាន ឬក៏ ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មានរូបអាស្រ័យនឹងគ្នាហើយកើតឡើង ក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹង ក្នុងការពោលនូវធម្មនិរុត្តិក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។

យស្មឹ សមយេ កាមាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកា មនោវិញ្ញាណធាតុ ឧប្បន្នា ហោតិ សោមនស្សសហគតា ញាណសម្បយុត្តា ។ បេ ។ សោមនស្សសហគតា ញាណសម្បយុត្តា សសង្ខារេន ។ បេ ។ សោមនស្សហគតា ញាណវិប្បយុត្តា ។ បេ ។ សោមនស្សសហគតា ញាណវិប្បយុត្តា សសង្ខារេន ។ បេ ។ ឧបេក្ខាសហគតា ញាណសម្បយុត្តា ។ បេ ។ ឧបេក្ខាសហតា ញាណសម្បយុត្តា សសង្ខារេន ។ បេ ។ ឧបេក្ខាសហគតា ញាណវិប្បយុត្តា ។ បេ ។ ឧបេក្ខាសហគតា ញាណវិប្បយុត្តា សសង្ខារេន រូបារម្មណា វា ។ បេ ។ ធម្មារម្មណា វា យំ យំ វា បនារព្ភ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា អព្យាកតា ឥមេសុ ធម្មេសុ ញាណំ អត្ថប្បដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា

ក្នុងសម័យណា មនោវិញ្ញាណធាតុ ជាវិបាក ព្រោះកម្មជាកាមាវចរកុសល ដែលបុគ្គលធ្វើហើយ សន្សំហើយ ជាធាតុច្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ ។ បេ ។ ច្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ។ បេ ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ។ បេ ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ។ បេ ។ ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។ បេ ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ ប្រារព្ធនូវអារម្មណ៍ណា ៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈ កើតមាន ។ បេ ។ សេចក្តីមិនរាយមាយ កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា

## អភិធម្មបិដកេ វិភង្គោ

យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។ តិស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ កតមេ ធម្មា អព្យាកតា ។ យស្មិំ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មិំ សមយេ ផស្សោ ហោតិ ។បេ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ រូបាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មិំ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា អព្យាកតា ឥមេសុ ធម្មេសុ ញាណំ អត្ថប្បដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា

## អភិធម្មបិដក វិភង្គ

សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គល ដឹងនូវញាណទាំងឡាយ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចំរើននូវមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ជាអារម្មណ៍ ក្នុងសម័យនោះ ផស្សៈ កើតមាន ។ បេ ។ សេចក្តីមិនរាយមាយ កើតមាន នេះពួកធម៌ជាកុសល ជាវិបាក ព្រោះកម្មជារូបាវចរកុសលនោះ ដែលបុគ្គលធ្វើហើយ សន្សំហើយ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ក្នុងសម័យនោះ ផស្សៈ កើតមាន ។ បេ ។ សេចក្តីមិនរាយមាយ កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹង ក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា

## បដិសម្ភិទាវិភង្គ អភិធម្មភាជនីយំ

យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។ តិស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ កតមេ ធម្មា អព្យាកតា ។ យស្មឹ សមយេ អរូបូបបត្តិយា មគ្គំ ភាវេតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនសញ្ញាសហគតំ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ អរូបាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនសញ្ញាសហគតំ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។

## បដិសម្ភិទាវិភង្គ អភិធម្មភាជនីយ

សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យកើត ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចំរើននូវមគ្គ ដើម្បីកើតក្នុងអរូបភព ព្រោះកិរិយាកន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយលះបង់នូវសុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ក្នុងសម័យនោះ ផស្សៈ កើតមាន ។ បេ ។ សេចក្តីមិនរាយមាយកើតមាន នេះពួកធម៌ជាកុសល ជាវិបាក ព្រោះកម្មជាអរូបាវចរ-កុសលនោះឯង ដែលបុគ្គលធ្វើហើយ សន្សំហើយ ព្រោះកិរិយាកន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយលះបង់នូវសុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយនេវសញ្ញា-នាសញ្ញាយតនសញ្ញា ក្នុងសម័យនោះ ផស្សៈ កើតមាន ។ បេ ។

អវិក្ខេបោ ហោតិ ឥមេ ធម្មា អព្យាកតា ឥមេសុ ធម្មេសុ ញាណំ អត្ថប្បដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។ តិស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ កតមេ ធម្មា អព្យាកតា ។ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។បេ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។បេ។

សេចក្ដីមិនពាយមាយ កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្ដីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំង-ឡាយនោះ ដោយនិរុត្តិណា សេចក្ដីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្ដីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំង-ឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិ-សម្ភិទា ។ បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិ-ភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ ក្នុងសម័យណា បុគ្គលចំរើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះបង់នូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈកើតមាន ។ បេ ។ សេចក្ដីមិនពាយមាយ កើតមាន ពួកធម៌ជាកុសល ជាវិបាក ព្រោះឈានជាលោកុត្តរកុសលនោះឯង ដែលបុគ្គលធ្វើហើយ ចំរើនហើយ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។

## បដិសម្ភិទាវិភង្គេ អភិធម្មភាជនីយំ

បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា អព្យាកតា ឥមេសុ ធម្មេសុ ញាណំ អត្ថប្បដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។ តិស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ កតមេ ធម្មា អព្យាកតា ។ យស្មឹ សមយេ អកុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ ចក្ខុវិញ្ញាណំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ រូបារម្មណំ ។ បេ ។ សោតវិញ្ញាណំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ សទ្ទារម្មណំ ។ បេ ។ ឃានវិញ្ញាណំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ គន្ធារម្មណំ ។ បេ ។

ចូលកាន់បឋមជ្ឈាន ជាសុញ្ញតៈ ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈ កើតមាន ។ បេ ។ សេចក្តីមិនរាយមាយ កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញ៉ាំងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា ចក្ខុវិញ្ញាណ ជាវិបាក ព្រោះកម្មជាអកុសល ដែលបុគ្គលធ្វើហើយ សន្សំហើយ ជាវិញ្ញាណ ប្រកបដោយទុក្ខ មានរូបជាអារម្មណ៍ កើតហើយ ។ បេ ។ សោតវិញ្ញាណ ប្រកបដោយទុក្ខ មានសំឡេងជាអារម្មណ៍ កើតហើយ ។ បេ ។ ឃានវិញ្ញាណ ប្រកបដោយទុក្ខ មានក្លិនជាអារម្មណ៍ កើតហើយ ។ បេ ។

ជិវ្ហាវិញ្ញាណំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ រសារម្មណំ ។បេ។ កាយវិញ្ញាណំ ឧប្បន្នំ ហោតិ ទុក្ខសហគតំ ផោដ្ឋព្វារម្មណំ តស្មឹ សមយេ ផស្សោ ហោតិ វេទនា ហោតិ សញ្ញា ហោតិ ចេតនា ហោតិ ចិត្តំ ហោតិ ទុក្ខំ ហោតិ ចិត្តស្ស ឯកគ្គតា ហោតិ មនិន្ទ្រិយំ ហោតិ ទុក្ខិន្ទ្រិយំ ហោតិ ជីវិត-ន្ទ្រិយំ ហោតិ យេ វា បន តស្មឹ សមយេ អញ្ញេបិ អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា អព្យាកតា ឥមេសុ ធម្មេសុ ញាណំ អត្ថប្បដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមា-និ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។ តិស្សោ បដិស-ម្ភិទា អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភា-ណប្បដិសម្ភិទា ។ កតមេ ធម្មា អព្យាកតា ។

ជិវ្ហាវិញ្ញាណ ប្រកបដោយឧបេក្ខា មានរសជាអារម្មណ៍ កើតហើយ ។បេ។ កាយវិញ្ញាណ ប្រកបដោយទុក្ខ មានផ្សព្វជាអារម្មណ៍ កើតហើយ ក្នុងសម័យនោះ ផស្សៈ កើតមាន វេទនា កើតមាន សញ្ញា កើតមាន ចេតនា កើតមាន ចិត្ត កើតមាន ទុក្ខ កើតមាន ចិត្តេកគ្គតា កើតមាន មនិន្ទ្រិយ កើតមាន ទុក្ខិន្ទ្រិយ កើតមាន ជីវិតិន្ទ្រិយ កើតមាន ឬក៏ ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូប ដែលអាស្រ័យនឹងគ្នា ហើយកើតឡើង ក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្ប-ដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។

## បដិសម្ភិទាវិភង្គោ អភិធម្មភាជនីយំ

យស្មឹ សមយេ អកុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកា មនោធាតុ ឧប្បន្នា ហោតិ ឧបេក្ខាសហគតា រូបារម្មណា វា ។បេ។ ផោដ្ឋព្វារម្មណា វា ។បេ។ មនោវិញ្ញាណធាតុ ឧប្បន្នា ហោតិ ឧបេក្ខាសហគតា រូបារម្មណា វា ។បេ។ ធម្មារម្មណា វា យំ យំ វា បនារព្ភ តស្មឹ សមយេ ផស្សោ ហោតិ វេទនា ហោតិ សញ្ញា ហោតិ ចេតនា ហោតិ ចិត្តំ ហោតិ វិតក្កោ ហោតិ វិចារោ ហោតិ ឧបេក្ខា ហោតិ ចិត្តស្ស ឯកគ្គតា ហោតិ មនិន្ទ្រិយំ ហោតិ ឧបេក្ខិន្ទ្រិយំ ហោតិ ជីវិតិន្ទ្រិយំ ហោតិ យេ វា បន តស្មឹ សមយេ អញ្ញេបិ អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា អព្យាកតា ឥមេសុ ធម្មេសុ ញាណំ អត្ថប្បដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។

ក្នុងសម័យណា មនោធាតុ ជាវិបាក ព្រោះកម្មជាអកុសល ដែលបុគ្គលធ្វើហើយ សន្សំហើយ ជាធាតុ ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។ បេ ។ មានផ្សព្វជាអារម្មណ៍ក្តី កើតឡើងហើយ ។ បេ ។ មនោវិញ្ញាណធាតុ ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។ បេ ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ ប្រារព្ធនូវអារម្មណ៍ណា ៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈ កើតមាន វេទនា កើតមាន សញ្ញា កើតមាន ចេតនា កើតមាន ចិត្ត កើតមាន វិតក្កៈ កើតមាន វិចារៈ កើតមាន ឧបេក្ខា កើតមាន ចិត្តេកគ្គតា កើតមាន មនិន្ទ្រិយ កើតមាន ឧបេក្ខិន្ទ្រិយ កើតមាន ជីវិតិន្ទ្រិយ កើតមាន ឬក៏ ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូប ដែលអាស្រ័យនឹងគ្នា ហើយកើតឡើងក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

## អភិធម្មបិដកេ វិភង្គោ

( ២១ ) តិស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ កតមេ ធម្មា អព្យាកតា ។ យស្មឹ សមយេ មនោធាតុ ឧប្បន្នា ហោតិ កិរិយា នេវ កុសលា នាកុសលា ន ច កម្មវិបាកា ឧបេក្ខាសហគតា រូបារម្មណា វា ។បេ។ ផោដ្ឋព្វារម្មណា វា យំ យំ វា បនារព្ភ តស្មឹ សមយេ ផស្សោ ហោតិ វេទនា ហោតិ សញ្ញា ហោតិ ចេតនា ហោតិ ចិត្តំ ហោតិ វិតក្កោ ហោតិ វិចារោ ហោតិ ឧបេក្ខា ហោតិ ចិត្តស្ស ឯកគ្គតា ហោតិ មនិន្ទ្រិយំ ហោតិ ឧបេក្ខិន្ទ្រិយំ ហោតិ ជីវិតិន្ទ្រិយំ ហោតិ យេ វា បន តស្មឹ សមយេ អញ្ញេបិ អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា អព្យាកតា ឥមេសុ ធម្មេសុ ញាណំ អត្ថប្បដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។

(៨១) បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោធាតុ ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានផ្សព្វជាអារម្មណ៍ក្តី ឬក៏ ប្រារព្ធនូវអារម្មណ៍ណា ៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈ កើតមាន វេទនា កើតមាន សញ្ញា កើតមាន ចេតនា កើតមាន ចិត្ត កើតមាន វិតក្កៈ កើតមាន វិចារៈ កើតមាន ឧបេក្ខា កើតមាន ចិត្តេកគ្គតា កើតមាន មនិន្ទ្រិយ កើតមាន ឧបេក្ខិន្ទ្រិយ កើតមាន ជីវិតិន្ទ្រិយ កើតមាន ឬក៏ ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូប ដែលអាស្រ័យនឹងគ្នាហើយកើតឡើងក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

តិស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា
បដិភាណប្បដិសម្ភិទា ។ កតមេ ធម្មា អព្យាកតា ។
យស្មឹ សមយេ មនោវិញ្ញាណធាតុ ឧប្បន្នា ហោតិ
កិរិយា នេវ កុសលា នាកុសលា ន ច កម្មវិបា-
កា សោមនស្សសហគតា រូបារម្មណា វា ។ បេ ។
ធម្មារម្មណា វា ។ បេ ។ មនោវិញ្ញាណធាតុ ឧប្បន្នា
ហោតិ កិរិយា នេវ កុសលា នាកុសលា ន
ច កម្មវិបាកា ឧបេក្ខាសហគតា រូបារម្មណា វា
។ បេ ។ ធម្មារម្មណា វា យំ យំ វា បនារព្ភ តស្មឹ
សមយេ ផស្សោ ហោតិ វេទនា ហោតិ សញ្ញា
ហោតិ ចេតនា ហោតិ ចិត្តំ ហោតិ វិតក្កោ ហោតិ
វិចារោ ហោតិ ឧបេក្ខា ហោតិ ចិត្តស្ស ឯកគ្គតា
ហោតិ វីរិយិន្ទ្រិយំ ហោតិ សមាធិន្ទ្រិយំ ហោតិ
មនិន្ទ្រិយំ ហោតិ ឧបេក្ខិន្ទ្រិយំ ហោតិ ជីវិតិ-
ន្ទ្រិយំ ហោតិ យេ វា បន តស្មឹ សមយេ អញ្ញេបិ
អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា
អព្យាកតា ឥមេសុ ធម្មេសុ ញាណំ អត្ថប្បដិសម្ភិទា

## បដិសម្ភិទាវិភង្គ អភិធម្មភាជនីយ

បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិ-សម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ ក្នុងសម័យណា មនោ-វិញ្ញាណធាតុ ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក ប្រកបដោយសោមនស្ស មានរូបជាអារម្មណ៍ក្ដី ។ បេ ។ មានធម៌ជាអារម្មណ៍ក្ដី កើតឡើង ។ បេ ។ មនោវិញ្ញាណធាតុ ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្ដី ។ បេ ។ មានធម៌ជាអារម្មណ៍ក្ដី ឬក៏ ប្រារព្ធនូវអារម្មណ៍ណា ៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈ កើតមាន វេទនា កើតមាន សញ្ញា កើតមាន ចេតនា កើតមាន ចិត្ត កើតមាន វិតក្កៈ កើតមាន វិចារៈ កើតមាន ឧបេក្ខា កើតមាន ចិត្តេកគ្គតា កើតមាន វីរិយិន្ទ្រិយ កើតមាន សមាធិន្ទ្រិយ កើតមាន មនិន្ទ្រិយ កើតមាន ឧបេក្ខិន្ទ្រិយ កើតមាន ជីវិតិន្ទ្រិយ កើតមាន ឬក៏ ក្នុងសម័យនោះ ធម៌ទាំងឡាយដទៃណា មិនមានរូបដែលអាស្រ័យនឹងគ្នាហើយកើតឡើងក៏កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្ដីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទា

យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។ តិស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ កតមេ ធម្មា អព្យាកតា ។ យស្មឹ សមយេ មនោវិញ្ញាណធាតុ ឧប្បន្នា ហោតិ កិរិយា នេវ កុសលា នាកុសលា ន ច កម្មវិបាកា សោមនស្សសហគតា ញាណសម្បយុត្តា ។ បេ ។ សោមនស្សសហគតា ញាណសម្បយុត្តា សសង្ខារេន ។ បេ ។ សោមនស្សសហគតា ញាណវិប្បយុត្តា ។ បេ ។ សោមនស្សសហគតា ញាណវិប្បយុត្តា សសង្ខារេន ។ បេ ។ ឧបេក្ខាសហគតា ញាណសម្បយុត្តា ។ បេ ។ ឧបេក្ខាសហគតា ញាណសម្បយុត្តា សសង្ខារេន ។ បេ ។ ឧបេក្ខាសហគតា ញាណវិប្បយុត្តា ។ បេ ។ ឧបេក្ខាសហគតា ញាណវិប្បយុត្តា សសង្ខារេន ។ បេ ។

បញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្ដីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្ដីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនោះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ គឺ អត្ថប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ? ក្នុងសម័យណា មនោវិញ្ញាណធាតុ ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក ច្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ ។ បេ ។ ច្រឡំដោយសោមនស្ស សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ។ បេ ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ។ បេ ។ ច្រឡំដោយឧបេក្ខា សម្បយុត្តដោយញាណ ប្រកបដោយសង្ខារ ។ បេ ។ ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ។ បេ ។ ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើងហើយ ។ បេ ។

## បដិសម្ភិទាវិភង្គ អភិធម្មភាជនីយំ

រូបាវចរំ ឈានំ ភាវេតិ ។បេ។ អរូបាវចរំ ឈានំ ភាវេតិ កិរិយំ នេវ កុសលំ នាកុសលំ ន ច កម្មវិបាកំ ទិដ្ឋធម្មសុខវិហារំ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនសញ្ញាសហគតំ សុខស្ស ច បហានា ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ តស្មឹ សមយេ ផស្សោ ហោតិ ។បេ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា អព្យាកតា ឥមេសុ ធម្មេសុ ញាណំ អត្ថប្បដិសម្ភិទា យាយ និរុត្តិយា តេសំ ធម្មានំ បញ្ញត្តិ ហោតិ តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា យេន ញាណេន តានិ ញាណានិ ជានាតិ ឥមានិ ញាណានិ ឥទមត្ថជោតកានីតិ ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។

(៤២) ចតស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ តិស្សោ បដិសម្ភិទា កាមាវចរកុសលតោ ចតូសុ ញាណសម្បយុត្តេសុ ចិត្តុប្បាទេសុ

បុគ្គលចំរើននូវរូបាវចរជ្ឈាន ។ បេ ។ បុគ្គលបំរើននូវអរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ព្រោះការកន្លងអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយលះបង់នូវសុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈានប្រកបដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ។ បេ ។ ក្នុងសម័យនោះផស្សៈ កើតមាន ។ បេ ។ សេចក្ដីមិនរាយមាយ កើតមាន នេះពួកធម៌ជាអព្យាក្រឹត សេចក្ដីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា អត្ថប្បដិសម្ភិទាបញ្ញត្តិនៃធម៌ទាំងឡាយនោះ ដោយនិរុត្តិណា សេចក្ដីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងនិរុត្តិនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្ដីដឹងក្នុងញាណទាំងឡាយថា បុគ្គលដឹងនូវញាណទាំងឡាយនោះ ដោយញាណណា ញាណទាំងឡាយនេះ ជាធម្មជាតញុំាងអត្ថនេះឲ្យភ្លឺ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

[២២] បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ បដិសម្ភិទា ៣ កើតក្នុងចិត្តុប្បាទ ៤ ជាញាណសម្បយុត្ត ខាងកាមាវចរកុសល កើតក្នុងចិត្តុប្បាទ ៤

កិរិយតោ ចតូសុ ញាណសម្បយុត្តេសុ ចិត្តុប្បាទេសុ ឧប្បជ្ជន្តិ អត្ថប្បដិសម្ភិទា ឯតេសុ ចេវ ឧប្បជ្ជតិ ចតូសុ ច មគ្គេសុ ចតូសុ ច ផលេសុ ឧប្បជ្ជតិ ។

អភិធម្មភាជនីយំ ។

(២៣) ចតស្សោ បដិសម្ភិទា អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិ-សម្ភិទា ។ ចតុន្នំ បដិសម្ភិទានំ កតិ កុសលា កតិ អកុសលា កតិ អព្យាកតា ។ បេ ។ កតិ សរណា កតិ អរណា ។

(២៤) សិយា កុសលា សិយា អព្យា-កតា សិយា សុខាយ វេទនាយ សម្បយុត្តា សិយា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ។ តិស្សោ បដិសម្ភិទា សិយា វិបាកធម្មធម្មា សិយា នេវវិបាកនវិបាកធម្មធម្មា អត្ថប្បដិសម្ភិទា សិយា វិបាកា សិយា វិបាកធម្មធម្មា សិយា នេវវិបាកនវិបាកធម្មធម្មា ។ តិស្សោ បដិស-ម្ភិទា អនុបាទិន្នុបាទានិយា អត្ថប្បដិសម្ភិទា សិយា

ជាញាណសម្បយុត្ត ខាងកិរិយា អត្ថប្បដិសម្ភិទា កើតក្នុងចិត្តុប្បាទ
ទាំងនុ៎ះផង កើតក្នុងមគ្គ ៤ ផល ៤ ផង ។

ចប់ អភិធម្មភាជនីយ ។

(៤៣) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ បណ្ដាបដិសម្ភិទាទាំង ៤ បដិសម្ភិទា ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។ បេ ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

(៤៤) បដិសម្ភិទា ជាកុសល ក៏មាន ជាអព្យាក្រឹត ក៏មាន ប្រកបដោយវេទនាជាសុខ ក៏មាន ប្រកបដោយវេទនាមិនមែនទុក្ខ មិនមែនសុខ ក៏មាន ។ បដិសម្ភិទា ៣ មានវិបាកធម៌ជាប្រក្រតី ក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ក៏មាន អត្ថប្បដិ-សម្ភិទាជាវិបាក ក៏មាន មានវិបាកធម៌ជាប្រក្រតី ក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ក៏មាន ។ បដិសម្ភិទា ៣ មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើម មិនកាន់យកហើយ ទាំងជាប្រ-យោជន៍ដល់ឧបាទាន អត្ថប្បដិសម្ភិទា មានកម្មប្រកបដោយកិលេសមាន

## បដិសម្ភិទាវិភង្គេ បញ្ហាបុច្ឆកំ

អនុបាទិន្នុបាទានិយា សិយា អនុបាទិន្នអនុបាទានិយា ។ តិស្សោ បដិសម្ភិទា អសង្កិលិដ្ឋសង្កិលេសិកា អត្ថប្បដិសម្ភិទា សិយា អសង្កិលិដ្ឋសង្កិលេសិកា សិយា អសង្កិលិដ្ឋាសង្កិលេសិកា ។ តិស្សោ បដិសម្ភិទា សវិតក្កសវិចារា អត្ថប្បដិសម្ភិទា សិយា សវិតក្កសវិចារា សិយា អវិតក្កវិចារមត្តា សិយា អវិតក្កាវិចារា ។ សិយា បីតិសហគតា សិយា សុខសហគតា សិយា ឧបេក្ខាសហគតា នេវ ទស្សនេន ន ភាវនាយ បហាតព្វា នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា ។ តិស្សោ បដិសម្ភិទា សិយា អាចយគាមិនោ សិយា នេវាចយគាមិនោ នាបចយគាមិនោ អត្ថប្បដិសម្ភិទា សិយា អាចយគាមិនី សិយា អបចយគាមិនី សិយា នេវាចយគាមិនី នាបចយគាមិនី ។

តណ្ហាជាដើមមិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ក៏មាន មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើម មិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ក៏មាន ។ បដិសម្ភិទា ៣ ជាធម៌មិនសៅហ្មង តែគួរដល់នូវសេចក្តីសៅហ្មង អត្ថប្បដិសម្ភិទា ជាធម៌មិនសៅហ្មង តែគួរដល់នូវសេចក្តីសៅហ្មង ក៏មាន ជាធម៌មិនសៅហ្មង ទាំងមិនគួរដល់នូវសេចក្តីសៅហ្មង ក៏មាន ។ បដិសម្ភិទា ៣ ប្រព្រឹត្តទៅ ជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ អត្ថប្បដិសម្ភិទា ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ក៏មាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ក៏មាន មិនមានវិតក្កៈ ទាំងមិនមានវិចារៈ ក៏មាន ។ បដិសម្ភិទា កើតព្រមដោយបីតិ ក៏មាន កើតព្រមដោយសុខ ក៏មាន កើតព្រមដោយឧបេក្ខាក៏មាន មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ក៏មាន ។ បដិសម្ភិទា ៣ ដល់នូវការសន្សំកពូនឡើង (ដោយកម្មកិលេស) ក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើង ក៏មាន អត្ថប្បដិសម្ភិទា ដល់នូវការសន្សំកពូនឡើង ក៏មាន ដល់នូវការមិនសន្សំកពូនឡើង ក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើង ក៏មាន ។

តិស្សោ បដិសម្ភិទា នេវសេក្ខា នាសេក្ខា អត្ថប-
ដិសម្ភិទា សិយា សេក្ខា សិយា អសេក្ខា សិយា
នេវសេក្ខា នាសេក្ខា ។ តិស្សោ បដិសម្ភិទា បរិត្តា
អត្ថបដិសម្ភិទា សិយា បរិត្តា សិយា អប្បមាណា ។
និរុត្តិបដិសម្ភិទា បរិត្តារម្មណា តិស្សោ បដិសម្ភិទា
សិយា បរិត្តារម្មណា សិយា មហគ្គតារម្មណា សិយា
អប្បមាណារម្មណា ។ តិស្សោ បដិសម្ភិទា មជ្ឈិមា
អត្ថបដិសម្ភិទា សិយា មជ្ឈិមា សិយា បណីតា ។
តិស្សោ បដិសម្ភិទា អនិយតា អត្ថបដិសម្ភិទា សិយា
សម្មត្តនិយតា សិយា អនិយតា ។ និរុត្តិបដិសម្ភិទា
ន វត្តព្វា មគ្គារម្មណាតិបិ មគ្គហេតុកាតិបិ មគ្គាធិប-
តិនីតិបិ អត្ថបដិសម្ភិទា ន មគ្គារម្មណា សិយា មគ្គ-
ហេតុកា សិយា មគ្គាធិបតិនី សិយា ន វត្តព្វា មគ្គ-
ហេតុកាតិបិ មគ្គាធិបតិនីតិបិ ទ្វេ បដិសម្ភិទា សិយា
មគ្គារម្មណា ន មគ្គហេតុកា សិយា មគ្គាធិបតិនោ
សិយា ន វត្តព្វា មគ្គារម្មណាតិបិ មគ្គាធិបតិនោតិបិ ។

បដិសម្ភិទា ៣ មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខ-បុគ្គល អត្ថប្បដិសម្ភិទា ជារបស់សេក្ខបុគ្គល ក៏មាន មិនមែនជារបស់អសេក្ខបុគ្គល ក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ក៏មាន ។ បដិសម្ភិទា ៣ មានសភាពតូចឆ្មារ អត្ថប្បដិសម្ភិទា មានសភាពតូចឆ្មារ ក៏មាន ប្រមាណមិនបាន ក៏មាន ។ និរុត្តិប្បដិសម្ភិទា មានអារម្មណ៍តូចឆ្មារ បដិសម្ភិទា៣ មានអារម្មណ៍តូចឆ្មារ ក៏មាន មានអា-រម្មណ៍ដល់នូវសភាពធំ ក៏មាន មានអារម្មណ៍ប្រមាណមិនបាន ក៏មាន ។ បដិសម្ភិទា ៣ ជាកណ្តាល អត្ថប្បដិសម្ភិទា ជាកណ្តាល ក៏មាន ឧត្តម ក៏មាន ។ បដិសម្ភិទា ៣ មានសភាពមិនទៀង អត្ថប្បដិសម្ភិទា មានសភាពត្រូវ និងទៀង ក៏មាន មានសភាពមិនទៀង ក៏មាន ។ និរុត្តិប្បដិ-សម្ភិទា មិនគួរពោលថា មានមគ្គជាអារម្មណ៍ផង ថា មានមគ្គជាហេតុផង ថា មានមគ្គជាអធិបតីផងឡើយ អត្ថប្បដិសម្ភិទា មិនមានមគ្គជាអារម្មណ៍ទេ តែមានមគ្គជាហេតុ ក៏មាន មានមគ្គជាអធិបតី ក៏មាន មិនគួរពោលថាមានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផង ក៏មាន បដិសម្ភិទា ២ មានមគ្គជាអារម្មណ៍ តែមិនមានមគ្គជាហេតុ ក៏មាន មានមគ្គជាអធិបតី ក៏មាន មិនគួរពោលថា មានមគ្គជាអារម្មណ៍ផង ថា មានមគ្គជាអធិបតីផង ក៏មាន ។

## បដិសម្ភិទាវិភង្គេ បញ្ហាបុច្ឆកំ

តិស្សោ បដិសម្ភិទា សិយា ឧប្បន្នា សិយា អនុប្បន្នា ន វត្តព្វា ឧប្បាទិនោតិ អត្ថប្បដិសម្ភិទា សិយា ឧប្បន្នា សិយា អនុប្បន្នា សិយា ឧប្បាទិនី ។ សិយា អតីតា សិយា អនាគតា សិយា បច្ចុប្បន្នា ។ និរុត្តិប្បដិសម្ភិទា បច្ចុប្បន្នារម្មណា ទ្វេ បដិសម្ភិទា សិយា អតីតារម្មណា សិយា អនាគតារម្មណា សិយា បច្ចុប្បន្នារម្មណា អត្ថប្បដិសម្ភិទា សិយា អតីតារម្មណា សិយា អនាគតារម្មណា សិយា បច្ចុប្បន្នារម្មណា សិយា ន វត្តព្វា អតីតារម្មណាតិបិ អនាគតារម្មណាតិបិ បច្ចុប្បន្នារម្មណាតិបិ ។ សិយា អជ្ឈត្តា សិយា ពហិទ្ធា សិយា អជ្ឈត្តពហិទ្ធា ។ និរុត្តិប្បដិសម្ភិទា ពហិទ្ធារម្មណា តិស្សោ បដិសម្ភិទា សិយា អជ្ឈត្តារម្មណា សិយា ពហិទ្ធារម្មណា សិយា អជ្ឈត្តពហិទ្ធារម្មណា ។ អនិទស្សនាអប្បដិឃា ។

## បដិសម្ភិទាវិភង្គ បញ្ហាបុច្ឆកៈ

បដិសម្ភិទា ៣ កើតឡើងហើយ ក៏មាន មិនទាន់កើតឡើង ក៏មាន មិនគួរពោលថា បម្រុងនឹងកើតឡើងទេ អត្ថប្បដិសម្ភិទា កើតឡើងហើយ ក៏មាន មិនទាន់កើតឡើង ក៏មាន បម្រុងនឹងកើតឡើង ក៏មាន ។ បដិសម្ភិទា ជាអតីត ក៏មាន ជាអនាគត ក៏មាន ជាបច្ចុប្បន្ន ក៏មាន ។ និរុត្តិប្បដិសម្ភិទា មានអារម្មណ៍ជាបច្ចុប្បន្ន បដិសម្ភិទា ២ មានអារម្មណ៍ជាអតីត ក៏មាន មានអារម្មណ៍ជាអនាគត ក៏មាន មានអារម្មណ៍ជាបច្ចុប្បន្ន ក៏មាន អត្ថប្បដិសម្ភិទា មានអារម្មណ៍ជាអតីត ក៏មាន មានអារម្មណ៍ជាអនាគត ក៏មាន មានអារម្មណ៍ជាបច្ចុប្បន្ន ក៏មាន មិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថា មានអារម្មណ៍ជាអនាគតផង ថា មានអារម្មណ៍ជាបច្ចុប្បន្នផង ក៏មាន ។ បដិសម្ភិទា ជាខាងក្នុង ក៏មាន ជាខាងក្រៅ ក៏មាន ជាខាងក្នុងនិងខាងក្រៅ ក៏មាន ។ និរុត្តិប្បដិសម្ភិទា មានអារម្មណ៍ខាងក្រៅ បដិសម្ភិទា ៣ មានអារម្មណ៍ខាងក្នុង ក៏មាន មានអារម្មណ៍ខាងក្រៅ ក៏មាន មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅ ក៏មាន ។ បដិសម្ភិទា មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ។

(២៥) ហេតូ សហេតុកា ហេតុសម្បយុត្តា ហេតូ ចេវ សហេតុកា ច ហេតូ ចេវ ហេតុសម្បយុត្តា ច ន វត្តព្វា ន ហេតូ សហេតុកាតិបិ ន ហេតូ អហេតុកាតិបិ ។ សប្បច្ចយា សង្ខតា អនិទស្សនា អប្បដិឃា អរូបា តិស្សោ បដិសម្ភិទា លោកិយា អត្ថប្បដិសម្ភិទា សិយា លោកិយា សិយា លោកុត្តរា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។

(២៦) នោ អាសវា ។ តិស្សោ បដិសម្ភិទា សាសវា អត្ថប្បដិសម្ភិទា សិយា សាសវា សិយា អនាសវា ។ អាសវវិប្បយុត្តា ។ តិស្សោ បដិសម្ភិទា ន វត្តព្វា អាសវា ចេវ សាសវា ចាតិ សាសវា ចេវ នោ ច អាសវា អត្ថប្បដិសម្ភិទា ន វត្តព្វា អាសវា ចេវ សាសវា ចាតិ សិយា សាសវា ចេវ នោ ច អាសវា សិយា ន វត្តព្វា សាសវា ចេវ នោ ច អាសវាតិ ។

(៦៥) បដិសម្ភិទាទាំងឡាយ ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង ជាហេតុផង ប្រកបដោយហេតុផង មិនគួរពោលថា មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ថា មិនមែនជាហេតុ ទាំងមិនមានហេតុផងទេឡើយ ។ បដិសម្ភិទា ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ មិនមានរូប បដិសម្ភិទា ៣ ជាលោកិយ អត្ថប្បដិសម្ភិទា ជាលោកិយ ក៏មាន ជាលោកុត្តរ ក៏មាន បុគ្គលគប្បីដឹងច្បាស់ដោយវិញ្ញាណណាមួយ មិនគប្បីដឹងច្បាស់ដោយវិញ្ញាណណាមួយ ។

(៦៦) បដិសម្ភិទាទាំងឡាយ មិនមែនអាសវៈ។ បដិសម្ភិទា ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ អត្ថប្បដិសម្ភិទា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ក៏មាន មិនមានអាសវៈ ក៏មាន ។ បដិសម្ភិទាទាំងឡាយ ប្រាសចាកអាសវៈ ។ បដិសម្ភិទា ៣ មិនគួរពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈទេឡើយ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈទេ អត្ថប្បដិសម្ភិទា មិនគួរពោលថាជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈទេ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈ ក៏មាន មិនគួរពោលថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈ ក៏មាន ។

## បដិសម្ភិទាវិភង្គេ បញ្ហាបុច្ឆកំ

ន វត្តព្វា អាសវា ចេវ អាសវសម្បយុត្តា ចាតិបិ អាសវសម្បយុត្តា ចេវ នោ ច អាសវាតិបិ ។ តិស្សោ បដិសម្ភិទា អាសវវិប្បយុត្តសាសវា អត្ថប្បដិ-សម្ភិទា សិយា អាសវវិប្បយុត្តសាសវា សិយា អាសវវិប្បយុត្តអនាសវា ។

(២៧) នោ សញ្ញោជនា ។បេ។ នោ គន្ថា ។បេ។ នោ ឱឃា ។បេ។ នោ យោគា ។បេ។ នោ នីវរណា ។បេ។ នោ បរាមាសា ។បេ។ សារម្មណា នោ ចិត្តា ចេតសិកា ចិត្តសម្បយុត្តា ចិត្តសំសដ្ឋា ចិត្តសមុដ្ឋានា ចិត្តសហភុនោ ចិត្តានុ-បរិវត្តិនោ ចិត្តសំសដ្ឋសមុដ្ឋានា ចិត្តសំសដ្ឋសមុដ្ឋា-នសហភុនោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ពាហិរា ឧបាទា អនុបាទិន្នា ។ ឧបាទានា ។បេ។ នោ កិលេសា ។បេ។

## បដិសម្ភិទាវិភង្គ បញ្ហាបុច្ឆកៈ

បដិសម្ភិទាទាំងឡាយ មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផងថា ប្រកបដោយអាសវៈតែមិនមែនជាអាសវៈផងឡើយ ។ បដិសម្ភិទា ៣ ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ អត្ថប្បដិសម្ភិទា ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ក៏មាន ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ក៏មាន ។

( ៤៧ ) បដិសម្ភិទាទាំងឡាយ មិនមែនសញ្ញោជនៈ ។បេ។ មិនមែនគន្ថៈ ។បេ។ មិនមែនឱឃៈ ។បេ។ មិនមែនយោគៈ ។បេ។ មិនមែននីវរណៈ ។បេ។ មិនមែនបរាមាសៈ ។បេ។ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ច្រឡូកច្រឡំដោយចិត្ត តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្ត ច្រឡំ ទាំងតាំងឡើងដោយចិត្ត ច្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ច្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនកាន់យកហើយ ។ មិនមែនឧបាទាន ។បេ។ មិនមែនកិលេស ។បេ។

(២៨) ន ទស្សនេន បហាតព្វា ន ភាវនាយ បហាតព្វា ន ទស្សនេន បហាតព្វហេតុកា ន ភាវនាយ បហាតព្វហេតុកា ។ តិស្សោ បដិសម្ភិទា សវិតក្កា អត្ថប្បដិសម្ភិទា សិយា សវិតក្កា សិយា អវិតក្កា ។ តិស្សោ បដិសម្ភិទា សវិចារា អត្ថប្បដិសម្ភិទា សិយា សវិចារា សិយា អវិចារា ។ សិយា សប្បីតិកា សិយា អប្បីតិកា សិយា បីតិសហគតា សិយា ន បីតិសហគតា សិយា សុខសហគតា សិយា ន សុខសហគតា សិយា ឧបេក្ខាសហគតា សិយា ន ឧបេក្ខាសហគតា ។ តិស្សោ បដិសម្ភិទា កាមាវចរា អត្ថប្បដិសម្ភិទា សិយា កាមាវចរា សិយា ន កាមាវចរា ។ ន រូបាវចរា ន អរូបាវចរា ។ តិស្សោ បដិសម្ភិទា បរិយាបន្នា អត្ថប្បដិសម្ភិទា សិយា បរិយាបន្នា សិយា អបរិយាបន្នា ។ តិស្សោ បដិសម្ភិទា អនិយ្យានិកា អត្ថប្បដិសម្ភិទា សិយា និយ្យានិកា សិយា អនិយ្យានិកា ។

(២៨) បដិសម្ភិទាទាំងឡាយ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះ ដោយទស្សនៈ មានហេតុមិនគួរលះដោយភាវនា ។ បដិសម្ភិទា ៣ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ អត្ថប្បដិសម្ភិទា ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ក៏មាន មិនមានវិតក្កៈ ក៏មាន ។ បដិសម្ភិទា ៣ ប្រព្រឹត្តទៅជាមួយនឹងវិចារៈ អត្ថប្បដិសម្ភិទា ប្រព្រឹត្តទៅជាមួយនឹងវិចារៈ ក៏មាន មិនមានវិចារៈ ក៏មាន ។ បដិសម្ភិទាទាំងឡាយ ប្រព្រឹត្តទៅជាមួយនឹងបីតិ ក៏មាន មិនមានបីតិ ក៏មាន ច្រឡំដោយបីតិ ក៏មាន មិនច្រឡំដោយបីតិ ក៏មាន ច្រឡំដោយសុខ ក៏មាន មិនច្រឡំដោយសុខ ក៏មាន ច្រឡំដោយឧបេក្ខា ក៏មាន មិនច្រឡំដោយឧបេក្ខា ក៏មាន ។ បដិសម្ភិទា ៣ ជាកាមាវចរ អត្ថប្បដិសម្ភិទា ជាកាមាវចរ ក៏មាន មិនមែនជាកាមាវចរ ក៏មាន ។ បដិសម្ភិទាទាំងឡាយ មិនមែនជារូបាវចរ មិនមែនអរូបាវចរ ។ បដិសម្ភិទា ៣ ជាបរិយាបន្នៈ អត្ថប្បដិសម្ភិទា ជាបរិយាបន្នៈ ក៏មាន ជាអបរិយាបន្នៈ ក៏មាន ។ បដិសម្ភិទា ៣ ជាអនិយ្យានិកៈ អត្ថប្បដិសម្ភិទា ជានិយ្យានិកៈ ក៏មាន ជាអនិយ្យានិកៈ ក៏មាន ។

## បដិសម្ភិទាវិភង្គេ បញ្ហាបុច្ឆកំ

តិស្សោ បដិសម្ភិទា អនិយតា អត្ថប្បដិសម្ភិទា សិយា និយតា សិយា អនិយតា ។ តិស្សោ បដិសម្ភិទា សឧត្តរា អត្ថប្បដិសម្ភិទា សិយា សឧត្តរា សិយា អនុត្តរា ។ អរណាតិ ។

បញ្ហាបុច្ឆកំ ។

បដិសម្ភិទាវិភង្គោ សមត្តោ ។

## បដិសម្ភិទាវិភង្គ បញ្ហាបុច្ឆកៈ

បដិសម្ភិទា ៣ មានសភាពមិនទៀង អត្ថប្បដិសម្ភិទា មានសភាពទៀង ក៏មាន មានសភាពមិនទៀង ក៏មាន ។ បដិសម្ភិទា ៣ ប្រកបដោយទុក្ខៈ (ការរើខ្លួន) អត្ថប្បដិសម្ភិទា ប្រកបដោយទុក្ខៈ ក៏មាន មិនមានទុក្ខៈ ក៏មាន ។ បដិសម្ភិទាទាំងឡាយ មិនមានសត្រូវទេ ។

ចប់ បញ្ហាបុច្ឆកៈ ។

ចប់ បដិសម្ភិទាវិភង្គ ។

# ញាណវិភង្គោ

(៨៩) ឯកវិធេន ញាណវត្ថុ បញ្ចវិញ្ញាណា ន ហេតូ អហេតុកា ហេតុវិប្បយុត្តា សប្បច្ចយា សង្ខតា អរូបា លោកិយា សាសវា សញ្ញោជនិយា គន្ថនិយា ឱឃនិយា យោគនិយា នីវរណិយា បរាមដ្ឋា ឧបាទានិយា សង្កិលេសិកា អព្យាកតា សារម្មណា អចេតសិកា វិបាកា ឧបាទិន្នុបាទានិយា អសង្កិលិដ្ឋសង្កិលេសិកា នសវិតក្កសវិចារា នអវិតក្កវិចារមត្តា អវិតក្កាវិចារា ន បីតិសហគតា នេវ ទស្សនេន ន ភាវនាយ បហាតព្វា នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា នេវាចយគាមិនោ នាបចយគាមិនោ នេវ សេក្ខា នាសេក្ខា បរិត្តា កាមាវចរា ន រូបាវចរា ន អរូបាវចរា

# ញាណវិភង្គ

(២៩) ញាណវត្ថុ មានប្រការ ១ គឺវិញ្ញាណ ៥ មិនមែនហេតុ មិនមានហេតុ ប្រាសចាកហេតុ ប្រកបដោយបច្ច័យ ត្រូវបច្ច័យប្រជុំតាក់តែង មិនមានរូប ជាលោកិយៈ ប្រកបដោយអាសវៈ ជាប្រយោជន៍ដល់សញ្ញោជនៈ ដែលគន្ថៈគប្បីដោតក្រង ដែលឱឃៈគប្បីប្រព្រឹត្តកន្លង ដែលយោគៈគប្បីប្រព្រឹត្តកន្លង ជាប្រយោជន៍ដល់នីវរណៈ ដែលបរាមាសៈស្ទាបអង្អែល ជាប្រយោជន៍ដល់ឧបាទាន គួរដល់នូវសេចក្តីសៅហ្មង ជាអព្យាក្រឹត ប្រកបដោយអារម្មណ៍ មិនមែនចេតសិក ជាវិបាក មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន មិនសៅហ្មង តែគួរដល់នូវសេចក្តីសៅហ្មង មិនប្រកបដោយវិតក្កៈ តែប្រកបដោយវិចារៈ មិនមែនមិនមានវិតក្កៈ មានត្រឹមតែវិចារៈ មិនមានវិតក្កៈ ទាំងមិនមានវិចារៈ មិនកើតព្រមដោយបីតិ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មិនដល់នូវការសន្សំ (កិលេសវដ្ដៈ) ទាំងមិនដល់ នូវការមិនសន្សំ មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល មានសភាពតូចឆ្មារ ជាកាមាវចរ មិនមែនជារូបាវចរ មិនមែនជាអរូបាវចរ

## ញាណវិភង្គ មាតិកា

បរិយាបន្នា នោ អបរិយាបន្នា អនិយតា អនិយ្យានិកា ឧប្បន្នា មនោវិញ្ញាណវិញ្ញេយ្យា អនិច្ចា ជរាភិភូតា ។ បញ្ច វិញ្ញាណា ឧប្បន្នវត្ថុកា ឧប្បន្នារម្មណា បុរេជាតវត្ថុកា បុរេជាតារម្មណា អជ្ឈត្តិកវត្ថុកា ពាហិរារម្មណា អសម្ភិន្នវត្ថុកា អសម្ភិន្នារម្មណា នានាវត្ថុកា នានារម្មណា ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តិ ន អសមន្នាហារា ឧប្បជ្ជន្តិ ន អមនសិការា ឧប្បជ្ជន្តិ ន អព្វោកិណ្ណា ឧប្បជ្ជន្តិ ន អបុព្វំ អចរិមំ ឧប្បជ្ជន្តិ ន អញ្ញមញ្ញស្ស សមនន្តរា ឧប្បជ្ជន្តិ បញ្ច វិញ្ញាណា អនាភោគា បញ្ចហិ វិញ្ញាណេហិ ន កញ្ចិ ធម្មំ បដិវិជានាតិ អញ្ញត្រ អភិនិបាតមត្តា បញ្ចន្នំ វិញ្ញាណានំ សមនន្តរាបិ ន កញ្ចិ ធម្មំ បដិវិជានាតិ បញ្ចហិ វិញ្ញាណេហិ ន កញ្ចិ ឥរិយាបថំ កប្បេតិ បញ្ចន្នំ វិញ្ញាណានំ សមនន្តរាបិ ន កញ្ចិ ឥរិយាបថំ កប្បេតិ បញ្ចហិ វិញ្ញាណេហិ

ញាណវិភង្គ មាតិកា

ជាបរិយាបន្នៈ មិនមែនជាអបរិយាបន្នៈ មិនទៀង មិនមែនជានិយ្យានិកៈ ដែលកើតឡើងហើយ ដែលគួរដឹងដោយមនោវិញ្ញាណ មិនទៀង ដែលត្រូវជរាគ្របសង្កត់ ៗ វិញ្ញាណ ៥ មានវត្ថុកើតហើយ មានអារម្មណ៍កើតហើយ មានវត្ថុកើតហើយក្នុងកាលមុន មានអារម្មណ៍កើតហើយក្នុងកាលមុន មានវត្ថុខាងក្នុង មានអារម្មណ៍ខាងក្រៅ មានវត្ថុមិនប្រឡំគ្នា មានអារម្មណ៍មិនប្រឡំគ្នា មានវត្ថុផ្សេង ៗ មានអារម្មណ៍ផ្សេង ៗ មិនរងអារម្មណ៍ជាទីគោចរ នៃគ្នានឹងគ្នាទេ មិនកើតឡើងព្រោះការមិនប្រមូលមក ( នូវអារម្មណ៍ ) មិនកើតឡើង ព្រោះការមិនធ្វើទុកក្នុងចិត្ត ( នូវអារម្មណ៍ ) មិនកើតឡើង ព្រោះការមិនប្រឡូកប្រឡំ ( ដោយវិញ្ញាណដទៃ ) មិនកើតឡើង មិនមុន មិនក្រោយ មិនកើតឡើងក្នុងលំដាប់នៃគ្នានឹងគ្នា វិញ្ញាណ ៥ មិនមានគ្រឿងអាងបុគ្គលបើរៀរចាកការប៉ះពាល់នូវអារម្មណ៍ ក៏មិនដឹងច្បាស់នូវធម៌ណាមួយដោយវិញ្ញាណទាំង ៥ ទាំងមិនដឹងច្បាស់នូវធម៌ណាមួយ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ មិនសម្រេចឥរិយាបថណាមួយ ដោយវិញ្ញាណទាំង ៥ ទាំងមិនសម្រេចឥរិយាបថណាមួយ ក្នុងលំដាប់នៃវិញ្ញាណទាំង៥

ន កាយកម្មំ ន វចីកម្មំ បដ្ឋបេតិ បញ្ចន្នំ វិញ្ញាណានំ សមនន្តរាបិ ន កាយកម្មំ ន វចីកម្មំ បដ្ឋបេតិ បញ្ចហិ វិញ្ញាណេហិ ន កុសលាកុសលំ ធម្មំ សមាទិយតិ បញ្ចន្នំ វិញ្ញាណានំ សមនន្តរាបិ ន កុសលាកុសលំ ធម្មំ សមាទិយតិ បញ្ចហិ វិញ្ញាណេហិ ន សមាបជ្ជតិ ន វុដ្ឋាតិ បញ្ចន្នំ វិញ្ញាណានំ សមនន្តរាបិ ន សមាបជ្ជតិ ន វុដ្ឋាតិ បញ្ចហិ វិញ្ញាណេហិ ន ចវតិ ន ឧបបជ្ជតិ បញ្ចន្នំ វិញ្ញាណានំ សមនន្តរាបិ ន ចវតិ ន ឧបបជ្ជតិ បញ្ចហិ វិញ្ញាណេហិ ន សុបតិ ន បដិពុជ្ឈតិ ន សុបិនំ បស្សតិ បញ្ចន្នំ វិញ្ញាណានំ សមនន្តរាបិ ន សុបតិ ន បដិពុជ្ឈតិ ន សុបិនំ បស្សតិ ។ យាថាវកវត្ថុវិភាវនា បញ្ញា ។ ឯវំ ឯកវិធេន ញាណវត្ថុ ។

(៣០) ទុវិធេន ញាណវត្ថុ លោកិយា បញ្ញា លោកុត្តរា បញ្ញា កេនចិ វិញ្ញេយ្យា បញ្ញា

មិនតាំងផ្ដើមកាយកម្ម មិនតាំងផ្ដើមវចីកម្ម ដោយវិញ្ញាណទាំង៤ ទាំងមិនតាំងផ្ដើមកាយកម្ម មិនតាំងផ្ដើមវចីកម្ម ក្នុងលំដាប់នៃវិញ្ញាណទាំង ៤ មិនកាន់យកនូវធម៌ជាកុសលនិងអកុសល ដោយវិញ្ញាណទាំង៤ ទាំងមិនកាន់យកនូវធម៌ជាកុសលនិងអកុសល ក្នុងលំដាប់នៃវិញ្ញាណទាំង ៤ មិនចូលឈាន មិនចេញចាកឈាន ដោយវិញ្ញាណទាំង ៤ ទាំងមិនចូលឈាន មិនចេញចាកឈាន ក្នុងលំដាប់នៃវិញ្ញាណទាំង ៤ មិនច្យុត មិនកើត ដោយវិញ្ញាណទាំង ៤ ទាំងមិនច្យុត មិនកើត ក្នុងលំដាប់នៃវិញ្ញាណទាំង ៤ មិនលក់ មិនភ្ញាក់ មិនឃើញសុបិន ដោយវិញ្ញាណទាំង ៤ ទាំងមិនលក់ មិនភ្ញាក់ មិនឃើញសុបិន ក្នុងលំដាប់នៃវិញ្ញាណទាំង ៤ ។ បញ្ញាជាគ្រឿងសំដែងនូវវត្ថុ តាមលំដាប់នៃមាតិកា ។ ញាណវត្ថុ មានប្រការ ១ យ៉ាងនេះឯង ។

[៣០] ញាណវត្ថុ មាន ២ គឺ បញ្ញាជាលោកិយៈ និងបញ្ញាជាលោកុត្តរៈ បញ្ញាដែលបុគ្គលគប្បីដឹង ដោយញាណណាមួយ

## ញាណវិភង្គេ មាតិកា

កេនចិ ន វិញ្ញេយ្យា បញ្ញា សាសវា បញ្ញា
អនាសវា បញ្ញា អាសវវិប្បយុត្តសាសវា បញ្ញា
អាសវវិប្បយុត្តអនាសវា បញ្ញា សញ្ញោជនិយា បញ្ញា
អសញ្ញោជនិយា បញ្ញា សញ្ញោជនវិប្បយុត្តសញ្ញោ-
ជនិយា បញ្ញា សញ្ញោជនវិប្បយុត្តអសញ្ញោជនិយា
បញ្ញា គន្ថនិយា បញ្ញា អគន្ថនិយា បញ្ញា
គន្ថវិប្បយុត្តគន្ថនិយា បញ្ញា គន្ថវិប្បយុត្តអគន្ថ-
និយា បញ្ញា ឱឃនិយា បញ្ញា អនោឃនិយា
បញ្ញា ឱឃវិប្បយុត្តឱឃនិយា បញ្ញា ឱឃវិប្បយុត្ត-
អនោឃនិយា បញ្ញា យោគនិយា បញ្ញា អយោគ-
និយា បញ្ញា យោគវិប្បយុត្តយោគនិយា បញ្ញា
យោគវិប្បយុត្តអយោគនិយា បញ្ញា នីវរណិយា
បញ្ញា អនីវរណិយា បញ្ញា នីវរណវិប្បយុត្តនីវរ-
ណិយា បញ្ញា នីវរណវិប្បយុត្តអនីវរណិយា បញ្ញា

## ញាណវិភង្គ មាតិកា

និងបញ្ញាដែលបុគ្គលមិនគប្បីដឹង ដោយវិញ្ញាណណាមួយ បញ្ញាប្រព្រឹត្តទៅជាមួយនឹងអាសវៈ និងបញ្ញាមិនមានអាសវៈ បញ្ញាប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ និងបញ្ញាប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ បញ្ញាជាប្រយោជន៍ដល់សញ្ញោជនៈ និងបញ្ញាមិនជាប្រយោជន៍ដល់សញ្ញោជនៈ បញ្ញាប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ និងបញ្ញាប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈ បញ្ញាដែលគន្ថៈគប្បីដោតក្រង និងបញ្ញាដែលគន្ថៈមិនគប្បីដោតក្រង បញ្ញាប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រង និងបញ្ញាប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីដោតក្រង បញ្ញាដែលឱឃៈគប្បីប្រព្រឹត្តកន្លង និងបញ្ញាដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លង បញ្ញាប្រាសចាកឱឃៈ តែឱឃៈគប្បីប្រព្រឹត្តកន្លង និងបញ្ញាប្រាសចាកឱឃៈ ទាំងឱឃៈមិនគប្បីប្រព្រឹត្តកន្លង បញ្ញាដែលយោគៈគប្បីប្រព្រឹត្តកន្លង និងបញ្ញាដែលយោគៈមិនគប្បីប្រព្រឹត្តកន្លង បញ្ញាប្រាសចាកយោគៈ តែយោគៈគប្បីប្រព្រឹត្តកន្លង និងបញ្ញាប្រាសចាកយោគៈ ទាំងយោគៈមិនគប្បីប្រព្រឹត្តកន្លង បញ្ញាជាប្រយោជន៍ដល់នីវរណៈ និងបញ្ញាមិនជាប្រយោជន៍ដល់នីវរណៈ បញ្ញាប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈ និងបញ្ញាប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈ

## អភិធម្មបិដកេ វិភង្គោ

បរាមដ្ឋា បញ្ញា អបរាមដ្ឋា បញ្ញា បរាមាសវិប្បយុត្តបរាមដ្ឋា បញ្ញា បរាមាសវិប្បយុត្តអបរាមដ្ឋា បញ្ញា ឧបាទិន្នា បញ្ញា អនុបាទិន្នា បញ្ញា ឧបាទានិយា បញ្ញា អនុបាទានិយា បញ្ញា ឧបាទានវិប្បយុត្តឧបាទានិយា បញ្ញា ឧបាទានវិប្បយុត្តអនុបាទានិយា បញ្ញា សង្កិលេសិកា បញ្ញា អសង្កិលេសិកា បញ្ញា កិលេសវិប្បយុត្តសង្កិលេសិកា បញ្ញា កិលេសវិប្បយុត្តអសង្កិលេសិកា បញ្ញា សវិតក្កា បញ្ញា អវិតក្កា បញ្ញា សវិចារា បញ្ញា អវិចារា បញ្ញា សប្បីតិកា បញ្ញា អប្បីតិកា បញ្ញា បីតិសហគតា បញ្ញា ន បីតិសហគតា បញ្ញា សុខសហគតា បញ្ញា ន សុខសហគតា បញ្ញា ឧបេក្ខាសហគតា បញ្ញា ន ឧបេក្ខាសហគតា បញ្ញា កាមាវចរា បញ្ញា ន កាមាវចរា បញ្ញា រូបាវចរា បញ្ញា ន រូបាវចរា បញ្ញា

បញ្ញាដែលបរាមាសៈស្ទាបអង្អែល និងបញ្ញាដែលបរាមាសៈមិនស្ទាបអង្អែល បញ្ញាប្រាសចាកបរាមាសៈ តែបរាមាសៈស្ទាបអង្អែល និងបញ្ញាប្រាសចាកបរាមាសៈ ទាំងបរាមាសៈមិនស្ទាបអង្អែល បញ្ញាដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ និងបញ្ញាដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ បញ្ញាជាប្រយោជន៍ដល់ឧបាទាន និងបញ្ញាមិនជាប្រយោជន៍ដល់ឧបាទាន បញ្ញាប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន និងបញ្ញាប្រាសចាកឧបាទាន ទាំងមិនជាប្រយោជន៍ដល់ឧបាទាន បញ្ញាគួរដល់សេចក្តីសៅហ្មង និងបញ្ញាមិនគួរដល់សេចក្តីសៅហ្មង បញ្ញាប្រាសចាកសេចក្តីសៅហ្មង តែគួរដល់សេចក្តីសៅហ្មង និងបញ្ញាប្រាសចាកសេចក្តីសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មង បញ្ញាប្រកបដោយវិតក្កៈ និងបញ្ញាមិនមានវិតក្កៈ បញ្ញាប្រកបដោយវិចារៈ និងបញ្ញាមិនមានវិចារៈ បញ្ញាប្រកបដោយបីតិ និងបញ្ញាមិនមានបីតិ បញ្ញាកើតព្រមដោយបីតិ និងបញ្ញាមិនកើតព្រមដោយបីតិ បញ្ញាកើតព្រមដោយសុខ និងបញ្ញាមិនកើតព្រមដោយសុខ បញ្ញាកើតព្រមដោយឧបេក្ខា និងបញ្ញាមិនកើតព្រមដោយឧបេក្ខា បញ្ញាជាកាមាវចរ និងបញ្ញាមិនមែនជាកាមាវចរ បញ្ញាជារូបាវចរ និងបញ្ញាមិនមែនជារូបាវចរ

## ញាណវិភង្គ មាតិកា

អរូបាវចរា បញ្ញា ន អរូបាវចរា បញ្ញា បរិយាបន្នា
បញ្ញា អបរិយាបន្នា បញ្ញា និយ្យានិកា បញ្ញា
អនិយ្យានិកា បញ្ញា និយតា បញ្ញា អនិយតា
បញ្ញា សឧត្តរា បញ្ញា អនុត្តរា បញ្ញា អត្ថជាបិកា
បញ្ញា ជាបិតត្ថា បញ្ញា ឯវំ ទុវិធេន ញាណវត្ថុ ។

(៣១) តិវិធេន ញាណវត្ថុ ចិន្តាមយា បញ្ញា
សុតាមយា បញ្ញា ភាវនាមយា បញ្ញា ទានមយា
បញ្ញា សីលមយា បញ្ញា ភាវនាមយា បញ្ញា
អធិសីលេ បញ្ញា អធិចិត្តេ បញ្ញា អធិប្បញ្ញាយ
បញ្ញា អាយកោសល្លំ អបាយកោសល្លំ ឧបាយ-
កោសល្លំ ។ វិបាកា បញ្ញា វិបាកធម្មធម្មា
បញ្ញា នេវវិបាកនវិបាកធម្មធម្មា បញ្ញា ឧបាទិន្នុ-
បាទានិយា បញ្ញា អនុបាទិន្នុបាទានិយា បញ្ញា

## ញាណវិភង្គ មាតិកា

បញ្ញាជាអរូបាវចរ និងបញ្ញាមិនមែនជាអរូបាវចរ បញ្ញាជាបរិយាបន្នៈ និងបញ្ញាជាអបរិយាបន្នៈ បញ្ញាជានិយ្យានិកៈ និងបញ្ញាជាអនិយ្យានិកៈ បញ្ញាទៀង និងបញ្ញាមិនទៀង បញ្ញាប្រកបដោយឧត្តរៈ និងបញ្ញាមិនមែនជាឧត្តរៈ បញ្ញាញុំាងប្រយោជន៍ឲ្យកើត និងបញ្ញាមានប្រ-យោជន៍កើតហើយ ញាណវត្ថុ មានប្រការ ៦ យ៉ាងនេះឯង ៗ

(៣១) ញាណវត្ថុ មាន ៣ គឺ ចិន្តាមយប្បញ្ញា (បញ្ញាសម្រេចដោយការគិត) សុតាមយប្បញ្ញា (បញ្ញាសម្រេចដោយការស្តាប់) និងភាវនាមយប្បញ្ញា (បញ្ញាសម្រេចដោយការចំរើន) ទានមយប្បញ្ញា (បញ្ញាសម្រេចដោយទាន) សីលមយប្បញ្ញា (បញ្ញាសម្រេចដោយសីល) និងភាវនាមយប្បញ្ញា (បញ្ញាសម្រេចដោយភាវនា) បញ្ញាក្នុងអធិសីល បញ្ញាក្នុងអធិចិត្ត និងបញ្ញាក្នុងអធិប្បញ្ញា សេចក្តីឆ្លាសក្នុងការចំរើន សេចក្តីឆ្លាសក្នុងការមិនចំរើន និងសេចក្តីឆ្លាសក្នុងឧបាយ ៗ បញ្ញាជាវិបាក បញ្ញាមានវិបាកធម៌ជាប្រក្រតី និងបញ្ញាមិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី បញ្ញាដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន បញ្ញាដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ

អនុបាទិន្នុបាទានិយា បញ្ញា សវិតក្កសវិចារា
បញ្ញា អវិតក្កវិចារមត្តា បញ្ញា អវិតក្កាវិចារា បញ្ញា
បីតិសហគតា បញ្ញា សុខសហគតា បញ្ញា ឧបេក្ខា-
សហគតា បញ្ញា អាចយគាមិនី បញ្ញា អបចយគា-
មិនី បញ្ញា នេវាចយគាមិនី នាបចយគាមិនី បញ្ញា
សេក្ខា បញ្ញា អសេក្ខា បញ្ញា នេវ សេក្ខា
នាសេក្ខា បញ្ញា បរិត្តា បញ្ញា មហគ្គតា បញ្ញា
អប្បមាណា បញ្ញា បរិត្តារម្មណា បញ្ញា មហគ្គតារ-
ម្មណា បញ្ញា អប្បមាណារម្មណា បញ្ញា មគ្គារម្មណា
បញ្ញា មគ្គហេតុកា បញ្ញា មគ្គាធិបតិនី បញ្ញា ឧប្បន្នា
បញ្ញា អនុប្បន្នា បញ្ញា ឧប្បាទិនី បញ្ញា អតីតា បញ្ញា
អនាគតា បញ្ញា បច្ចុប្បន្នា បញ្ញា អតីតារម្មណា បញ្ញា
អនាគតារម្មណា បញ្ញា បច្ចុប្បន្នារម្មណា បញ្ញា
អជ្ឈត្តា បញ្ញា ពហិទ្ធា បញ្ញា អជ្ឈត្តពហិទ្ធា បញ្ញា

តែជាប្រយោជន៍ដល់ឧបាទាន និងបញ្ញាដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន បញ្ញាប្រកបដោយវិតក្កៈទាំងប្រកបដោយវិចារៈ បញ្ញាមិនមានវិតក្កៈ មានត្រឹមតែវិចារៈ និងបញ្ញាមិនមានវិតក្កៈ ទាំងមិនមានវិចារៈ បញ្ញាកើតព្រមដោយបីតិ បញ្ញាកើតព្រមដោយសុខ និងបញ្ញាកើតព្រមដោយឧបេក្ខា បញ្ញាដល់នូវការសន្សំ (កម្មកិលេស) បញ្ញាដល់នូវការមិនសន្សំ (កម្មកិលេស) និងបញ្ញាមិនដល់នូវការសន្សំ ទាំងមិនដល់នូវការមិនសន្សំ បញ្ញាជារបស់សេក្ខបុគ្គល បញ្ញាជារបស់អសេក្ខបុគ្គល និងបញ្ញាមិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល បញ្ញាតូចឆ្មារ បញ្ញាមានសភាពធំ និងបញ្ញាមានប្រមាណមិនបាន បញ្ញាមានអារម្មណ៍តូចឆ្មារ បញ្ញាមានអារម្មណ៍ដល់នូវសភាពធំ និងបញ្ញាមានអារម្មណ៍មានប្រមាណមិនបាន បញ្ញាមានមគ្គជាអារម្មណ៍ បញ្ញាមានមគ្គជាហេតុ និងបញ្ញាមានមគ្គជាអធិបតី បញ្ញាដែលកើតឡើងហើយ បញ្ញាដែលមិនទាន់កើតឡើង និងបញ្ញាដែលប្រុងនឹងកើតឡើង បញ្ញាជាអតីត បញ្ញាជាអនាគត និងបញ្ញាជាបច្ចុប្បន្ន បញ្ញាមានអារម្មណ៍ជាអតីត បញ្ញាមានអារម្មណ៍ជាអនាគត និងបញ្ញាមានអារម្មណ៍ជាបច្ចុប្បន្ន បញ្ញាជាខាងក្នុង បញ្ញាជាខាងក្រៅ និងបញ្ញាជាខាងក្នុងនិងខាងក្រៅ

## ញាណវិភង្គ មាតិកា

អជ្ឈត្តារម្មណា បញ្ញា ពហិទ្ធារម្មណា បញ្ញា
អជ្ឈត្តពហិទ្ធារម្មណា បញ្ញា ។ សវិតក្កសវិចារ
បញ្ញា អត្ថិ វិបាកា អត្ថិ វិបាកធម្មធម្មា អត្ថិ
នេវវិបាកនវិបាកធម្មធម្មា អត្ថិ ឧបាទិន្នុបាទានិយា
អត្ថិ អនុបាទិន្នុបាទានិយា អត្ថិ អនុបាទិន្នានុបា-
ទានិយា អត្ថិ បីតិសហគតា អត្ថិ សុខសហគតា
អត្ថិ ឧបេក្ខាសហគតា អត្ថិ អាចយគាមិនី
អត្ថិ អបចយគាមិនី អត្ថិ នេវាចយគាមិនី នាប-
ចយគាមិនី អត្ថិ សេក្ខា អត្ថិ អសេក្ខា អត្ថិ នេវ
សេក្ខា នាសេក្ខា អត្ថិ បរិត្តា អត្ថិ មហគ្គតា
អត្ថិ អប្បមាណា អត្ថិ បរិត្តារម្មណា អត្ថិ មហគ្គ-
តារម្មណា អត្ថិ អប្បមាណារម្មណា អត្ថិ មគ្គា-
រម្មណា អត្ថិ មគ្គហេតុកា អត្ថិ មគ្គាធិបតិនី អត្ថិ

## ញាណវិភង្គ មាតិកា

បញ្ញាមានអារម្មណ៍ខាងក្នុង បញ្ញាមានអារម្មណ៍ខាងក្រៅ និងបញ្ញាមានអារម្មណ៍ខាងក្នុងនិងខាងក្រៅ ។ បញ្ញាប្រកបដោយវិតក្កៈ និងប្រកបដោយវិចារៈ ជាវិបាក ក៏មាន មានវិបាកធម៌ជាប្រក្រតី ក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ក៏មាន ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ក៏មាន ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ក៏មាន ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន កើតព្រមដោយបីតិ ក៏មាន កើតព្រមដោយសុខ ក៏មាន កើតព្រមដោយឧបេក្ខា ក៏មាន ដល់នូវការសន្សំ ( កម្មកិលេស ) ក៏មាន ដល់នូវការមិនសន្សំ ក៏មាន មិនមែនដល់នូវការសន្សំ ទាំងមិនដល់នូវការមិនសន្សំ ក៏មាន ជារបស់សេក្ខបុគ្គល ក៏មាន ជារបស់អសេក្ខបុគ្គល ក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ក៏មាន មានសភាពតូចឆ្មារ ក៏មាន ដល់នូវសភាពធំ ក៏មាន មានប្រមាណមិនបាន ក៏មាន មានអារម្មណ៍តូចឆ្មារ ក៏មាន មានអារម្មណ៍ដល់នូវសភាពធំ ក៏មាន មានអារម្មណ៍ប្រមាណមិនបាន ក៏មាន មានមគ្គជាអារម្មណ៍ ក៏មាន មានមគ្គជាហេតុ ក៏មាន មានមគ្គជាអធិបតី ក៏មាន

ឧប្បន្នា អត្ថិ អនុប្បន្នា អត្ថិ ឧប្បាទិនី អត្ថិ អតីតា អត្ថិ អនាគតា អត្ថិ បច្ចុប្បន្នា អត្ថិ អតីតារម្មណា អត្ថិ អនាគតារម្មណា អត្ថិ បច្ចុប្បន្នារម្មណា អត្ថិ អជ្ឈត្តា អត្ថិ ពហិទ្ធា អត្ថិ អជ្ឈត្តពហិទ្ធា អត្ថិ អជ្ឈត្តារម្មណា អត្ថិ ពហិទ្ធារម្មណា អត្ថិ អជ្ឈត្តពហិទ្ធារម្មណា ។ អវិតក្កវិចារមត្តា បញ្ញា អត្ថិ វិបាកា អត្ថិ វិបាកធម្មធម្មា អត្ថិ នេវវិបាកនវិបាកធម្មធម្មា អត្ថិ ឧបាទិន្នុបាទានិយា អត្ថិ អនុបាទិន្នុបាទានិយា អត្ថិ អនុបាទិន្នានុបាទានិយា អត្ថិ អាចយគាមិនី អត្ថិ អបចយគាមិនី អត្ថិ នេវាចយគាមិនី នាបចយគាមិនី អត្ថិ សេក្ខា អត្ថិ អសេក្ខា អត្ថិ នេវសេក្ខា នាសេក្ខា អត្ថិ

ដែលកើតឡើងហើយ ក៏មាន មិនទាន់កើតឡើង ក៏មាន ប្រុងនឹងកើតឡើង ក៏មាន ជាអតីត ក៏មាន ជាអនាគត ក៏មាន ជាបច្ចុប្បន្ន ក៏មាន មានអារម្មណ៍ជាអតីត ក៏មាន មានអារម្មណ៍ជាអនាគត ក៏មាន មានអារម្មណ៍ជាបច្ចុប្បន្ន ក៏មាន ជាខាងក្នុង ក៏មាន ជាខាងក្រៅ ក៏មាន ជាខាងក្នុងនិងខាងក្រៅ ក៏មាន មានអារម្មណ៍ជាខាងក្នុង ក៏មាន មានអារម្មណ៍ជាខាងក្រៅ ក៏មាន មានអារម្មណ៍ជាខាងក្នុងនិងខាងក្រៅ ក៏មាន ។ បញ្ញាមិនមានវិតក្កៈ មានត្រឹមតែវិចារៈ ជាវិបាក ក៏មាន មានវិបាកធម៌ជាប្រក្រតី ក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ក៏មាន ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ក៏មាន ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ក៏មាន ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ក៏មាន ដល់នូវការសន្សំ (កម្មកិលេស) ក៏មាន ដល់នូវការមិនសន្សំ ក៏មាន មិនដល់នូវការសន្សំ ទាំងមិនដល់នូវការមិនសន្សំ ក៏មាន ជារបស់សេក្ខបុគ្គល ក៏មាន ជារបស់អសេក្ខបុគ្គល ក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ក៏មាន

## ញាណវិភង្គ មាតិកា

ឧប្បន្នា អត្ថិ អនុប្បន្នា អត្ថិ ឧប្បាទិនី អត្ថិ អតីតា អត្ថិ អនាគតា អត្ថិ បច្ចុប្បន្នា អត្ថិ អជ្ឈត្តា អត្ថិ ពហិទ្ធា អត្ថិ អជ្ឈត្តពហិទ្ធា ។ អវិតក្កាវិចារា បញ្ញា អត្ថិ វិបាកា អត្ថិ វិបាកធម្មធម្មា អត្ថិ នេវ វិបាកនវិបាកធម្មធម្មា អត្ថិ ឧបាទិន្នុបាទានិយា អត្ថិ អនុបាទិន្នុបាទានិយា អត្ថិ អនុបាទិន្នានុបាទានិយា អត្ថិ បីតិសហគតា អត្ថិ សុខសហគតា អត្ថិ ឧបេក្ខាសហគតា អត្ថិ អាចយគាមិនី អត្ថិ អបចយគាមិនី អត្ថិ នេវាចយគាមិនី នាបចយគាមិនី អត្ថិ សេក្ខា អត្ថិ អសេក្ខា អត្ថិ នេវ សេក្ខា នាសេក្ខា អត្ថិ បរិត្តារម្មណា អត្ថិ មហគ្គតារម្មណា អត្ថិ អប្បមាណារម្មណា អត្ថិ មគ្គារម្មណា អត្ថិ មគ្គហេតុកា អត្ថិ មគ្គាធិបតិនី អត្ថិ

## ញាណវិភង្គ មាតិកា

កើតឡើងហើយ ក៏មាន មិនទាន់កើតឡើង ក៏មាន ប្រុងកើតឡើង ក៏មាន ជាអតីត ក៏មាន ជាអនាគត ក៏មាន ជាបច្ចុប្បន្ន ក៏មាន ជាខាងក្នុង ក៏មាន ជាខាងក្រៅ ក៏មាន ជាខាងក្នុងនិងខាងក្រៅ ក៏មាន ។ បញ្ញាមិនមានវិតក្កៈ មិនមានវិចារៈ ជាវិបាក ក៏មាន មានវិបាកធម៌ជាប្រក្រតី ក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ក៏មាន ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ក៏មាន ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ក៏មាន ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ក៏មាន កើតព្រមដោយបីតិ ក៏មាន កើតព្រមដោយសុខ ក៏មាន កើតព្រមដោយឧបេក្ខា ក៏មាន ដល់នូវការសន្សំ (កម្មកិលេស) ក៏មាន ដល់នូវការមិនសន្សំ ក៏មាន ដល់នូវការមិនសន្សំ ទាំងមិនដល់នូវការមិនសន្សំ ក៏មាន ជារបស់សេក្ខបុគ្គល ក៏មាន ជារបស់អសេក្ខបុគ្គល ក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ក៏មាន មានអារម្មណ៍តូចឆ្មារ ក៏មាន មានអារម្មណ៍ដល់នូវសភាពធំ ក៏មាន មានអារម្មណ៍ប្រមាណមិនបាន ក៏មាន មានមគ្គជាអារម្មណ៍ ក៏មាន មានមគ្គជាហេតុ ក៏មាន មានមគ្គជាអធិបតី ក៏មាន

ឧប្បន្នា អត្ថិ អនុប្បន្នា អត្ថិ ឧប្បាទិនី អត្ថិ
អតីតា អត្ថិ អនាគតា អត្ថិ បច្ចុប្បន្នា អត្ថិ
អតីតារម្មណា អត្ថិ អនាគតារម្មណា អត្ថិ បច្ចុ-
ប្បន្នារម្មណា អត្ថិ អជ្ឈត្តា អត្ថិ ពហិទ្ធា អត្ថិ
អជ្ឈត្តពហិទ្ធា អត្ថិ អជ្ឈត្តារម្មណា អត្ថិ ពហិទ្ធា-
រម្មណា អត្ថិ អជ្ឈត្តពហិទ្ធារម្មណា ។ បីតិសហគតា
បញ្ញា សុខសហគតា បញ្ញា អត្ថិ វិបាកា អត្ថិ
វិបាកធម្មធម្មា អត្ថិ នេវវិបាកនវិបាកធម្មធម្មា
អត្ថិ ឧបាទិន្នុបាទានិយា អត្ថិ អនុបាទិន្នុបាទានិយា
អត្ថិ អនុបាទិន្នានុបាទានិយា អត្ថិ សវិតក្កសវិចារា
អត្ថិ អវិតក្កវិចារមត្តា អត្ថិ អវិតក្កាវិចារា អត្ថិ
អាចយគាមិនី អត្ថិ អបចយគាមិនី អត្ថិ នេវា-
ចយគាមិនី នាបចយគាមិនី អត្ថិ សេក្ខា អត្ថិ

កើតឡើងហើយ ក៏មាន មិនទាន់កើតឡើង ក៏មាន ប្រុងនឹងកើតឡើង ក៏មាន ជាអតីត ក៏មាន ជាអនាគត ក៏មាន ជាបច្ចុប្បន្ន ក៏មាន មានអារម្មណ៍ ជាអតីត ក៏មាន មានអារម្មណ៍ ជាអនាគត ក៏មាន មានអារម្មណ៍ ជាបច្ចុប្បន្ន ក៏មាន ជាខាងក្នុង ក៏មាន ជាខាងក្រៅ ក៏មាន ជាខាងក្នុងនិងខាងក្រៅ ក៏មាន មានអារម្មណ៍ជាខាងក្នុង ក៏មាន មានអារម្មណ៍ជាខាងក្រៅ ក៏មាន មានអារម្មណ៍ជាខាងក្នុងនិងខាងក្រៅ ក៏មាន ។ បញ្ញា កើតព្រមដោយបីតិ បញ្ញា កើតព្រមដោយសុខ ជាវិបាក ក៏មាន មានវិបាកធម៌ជាប្រក្រតី ក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ក៏មាន ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ក៏មាន ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ក៏មាន ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ក៏មាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ ក៏មាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ក៏មាន មិនមានវិតក្កៈ ទាំងមិនមានវិចារៈ ក៏មាន ដល់នូវការសន្សំ ក៏មាន ដល់នូវការមិនសន្សំ ក៏មាន មិនដល់នូវការសន្សំ ទាំងមិនដល់នូវការមិនសន្សំ ក៏មាន ជារបស់សេក្ខបុគ្គល ក៏មាន

## ញាណវិភង្គ មាតិកា

អសេក្ខា អត្ថិ នេវ សេក្ខា នាសេក្ខា អត្ថិ បរិត្តា អត្ថិ មហគ្គតា អត្ថិ អប្បមាណា អត្ថិ បរិត្តារម្មណា អត្ថិ មហគ្គតារម្មណា អត្ថិ អប្បមាណារម្មណា អត្ថិ មគ្គារម្មណា អត្ថិ មគ្គហេតុកា អត្ថិ មគ្គាធិបតិនី អត្ថិ ឧប្បន្នា អត្ថិ អនុប្បន្នា អត្ថិ ឧប្បាទិនី អត្ថិ អតីតា អត្ថិ អនាគតា អត្ថិ បច្ចុប្បន្នា អត្ថិ អតីតារម្មណា អត្ថិ អនាគតារម្មណា អត្ថិ បច្ចុប្បន្នារម្មណា អត្ថិ អជ្ឈត្តា អត្ថិ ពហិទ្ធា អត្ថិ អជ្ឈត្តពហិទ្ធា អត្ថិ អជ្ឈត្តារម្មណា អត្ថិ ពហិទ្ធារម្មណា អត្ថិ អជ្ឈត្តពហិទ្ធារម្មណា ។ ឧបេក្ខាសហគតា បញ្ញា អត្ថិ វិបាកា អត្ថិ វិបាកធម្មធម្មា អត្ថិ នេវ វិបាកនវិបាកធម្មធម្មា អត្ថិ ឧបាទិន្នុបាទានិយា អត្ថិ អនុបាទិន្នុបាទានិយា អត្ថិ

## ញាណវិភង្គ មាតិកា

ជារបស់អសេក្ខបុគ្គល ក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ក៏មាន មានសភាពតូចឆ្មារ ក៏មាន ដល់នូវសភាពធំ ក៏មាន មានប្រមាណមិនបាន ក៏មាន មានអារម្មណ៍តូចឆ្មារ ក៏មាន មានអារម្មណ៍ដល់នូវសភាពធំ ក៏មាន មានអារម្មណ៍ប្រមាណមិនបាន ក៏មាន មានមគ្គជាអារម្មណ៍ ក៏មាន មានមគ្គជាហេតុ ក៏មាន មានមគ្គជាអធិបតី ក៏មាន កើតឡើងហើយ ក៏មាន មិនទាន់កើតឡើង ក៏មាន បម្រុងនឹងកើតឡើង ក៏មាន ជាអតីត ក៏មាន ជាអនាគត ក៏មាន ជាបច្ចុប្បន្ន ក៏មាន មានអារម្មណ៍ជាអតីត ក៏មាន មានអារម្មណ៍ជាអនាគត ក៏មាន មានអារម្មណ៍ជាបច្ចុប្បន្ន ក៏មាន ជាខាងក្នុង ក៏មាន ជាខាងក្រៅ ក៏មាន ជាខាងក្នុងនិងខាងក្រៅ ក៏មាន មានអារម្មណ៍ជាខាងក្នុង ក៏មាន មានអារម្មណ៍ជាខាងក្រៅ ក៏មាន មានអារម្មណ៍ជាខាងក្នុងនិងខាងក្រៅ ក៏មាន ។ បញ្ញា កើតព្រមដោយឧបេក្ខា ជាវិបាក ក៏មាន មានវិបាកធម៌ជាប្រក្រតី ក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ក៏មាន ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ក៏មាន ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទាន ក៏មាន

អភិធម្មបិដកេ វិភង្គោ

អនុបាទិន្នុបាទានិយា អត្ថិ អាចយគាមិនី អត្ថិ
អបចយគាមិនី អត្ថិ នេវាចយគាមិនី នាបចយគា-
មិនី អត្ថិ សេក្ខា អត្ថិ អសេក្ខា អត្ថិ នេវ
សេក្ខា នាសេក្ខា អត្ថិ បរិត្តា អត្ថិ មហគ្គតា
អត្ថិ អប្បមាណា អត្ថិ បរិត្តារម្មណា អត្ថិ មហគ្គ-
តារម្មណា អត្ថិ អប្បមាណារម្មណា អត្ថិ មគ្គា-
រម្មណា អត្ថិ មគ្គហេតុកា អត្ថិ មគ្គាធិបតិនី
អត្ថិ ឧប្បន្នា អត្ថិ អនុប្បន្នា អត្ថិ ឧប្បាទិនី អត្ថិ
អតីតា អត្ថិ អនាគតា អត្ថិ បច្ចុប្បន្នា អត្ថិ
អតីតារម្មណា អត្ថិ អនាគតារម្មណា អត្ថិ បច្ចុប្បន្នា-
រម្មណា អត្ថិ អជ្ឈត្តា អត្ថិ ពហិទ្ធា អត្ថិ អជ្ឈ-
ត្តពហិទ្ធា អត្ថិ អជ្ឈត្តារម្មណា អត្ថិ ពហិទ្ធារម្ម-
ណា អត្ថិ អជ្ឈត្តពហិទ្ធារម្មណា ។ ឯវំ តិវិធេន
ញាណវត្ថុ ។

ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ តាំងមិនជាប្រយោជន៍ដល់ឧបាទាន ក៏មាន ដល់នូវការសន្សំ ក៏មាន ដល់នូវការមិនសន្សំ ក៏មាន មិនដល់នូវការសន្សំ តាំងមិនដល់នូវការមិនសន្សំ ក៏មាន ជារបស់សេក្ខបុគ្គល ក៏មាន ជារបស់អសេក្ខបុគ្គល ក៏មាន មិនមែនជារបស់សេក្ខបុគ្គល តាំងមិនមែនជារបស់អសេក្ខបុគ្គល ក៏មាន មានសភាពតូចឆ្មារ ក៏មាន ដល់នូវសភាពធំ ក៏មាន ប្រមាណមិនបាន ក៏មាន មានអារម្មណ៍តូចឆ្មារ ក៏មាន មានអារម្មណ៍ដល់នូវសភាពធំ ក៏មាន មានអារម្មណ៍ប្រមាណមិនបាន ក៏មាន មានមគ្គជាអារម្មណ៍ ក៏មាន មានមគ្គជាហេតុ ក៏មាន មានមគ្គជាអធិបតី ក៏មាន កើតឡើងហើយ ក៏មាន មិនទាន់កើតឡើង ក៏មាន បម្រុងនឹងកើតឡើង ក៏មាន ជាអតីត ក៏មាន ជាអនាគត ក៏មាន ជាបច្ចុប្បន្ន ក៏មាន មានអារម្មណ៍ជាអតីត ក៏មាន មានអារម្មណ៍ជាអនាគត ក៏មាន មានអារម្មណ៍ជាបច្ចុប្បន្ន ក៏មាន ជាខាងក្នុង ក៏មាន ជាខាងក្រៅ ក៏មាន ជាខាងក្នុងនិងខាងក្រៅ ក៏មាន មានអារម្មណ៍ជាខាងក្នុង ក៏មាន មានអារម្មណ៍ជាខាងក្រៅ ក៏មាន មានអារម្មណ៍ជាខាងក្នុងនិងខាងក្រៅ ក៏មាន ។ ញាណវត្ថុ មានប្រការ ៣ យ៉ាងនេះឯង ។

## ញាណវិភង្គ មាតិកា

( ៣៦ ) ចតុព្វិធេន ញាណវត្ថុ កម្មស្សកតំ ញាណំ សច្ចានុលោមិកំ ញាណំ មគ្គសមង្គិស្ស ញាណំ ផលសមង្គិស្ស ញាណំ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ កាមាវចរា បញ្ញា រូបាវចរា បញ្ញា អរូបាវចរា បញ្ញា អបរិយាបន្នា បញ្ញា ធម្មេ ញាណំ អន្វយេ ញាណំ បរិច្ចេ ញាណំ សម្មុតិញាណំ អត្ថិ បញ្ញា អាចយាយ នោ អបចយាយ អត្ថិ បញ្ញា អបចយាយ នោ អាចយាយ អត្ថិ បញ្ញា អាចយាយ ចេវ អបចយាយ ច អត្ថិ បញ្ញា នេវាចយាយ នោ អបចយាយ អត្ថិ បញ្ញា និព្វិទាយ នោ បដិវេធាយ អត្ថិ បញ្ញា បដិវេធាយ នោ និព្វិទាយ អត្ថិ បញ្ញា និព្វិទាយ ចេវ បដិវេធាយ ច អត្ថិ បញ្ញា នេវ និព្វិទាយ នោ បដិវេធាយ ហានភាគិនី បញ្ញា ឋិតិភាគិនី បញ្ញា វិសេសភាគិនី បញ្ញា

## ញាណវិភង្គ មាតិកា

(៣២) ញាណវត្ថុ មាន ៤ គឺ កម្មស្សកតញ្ញាណ (សេចក្តីដឹងថាសត្វមានកម្មជារបស់ខ្លួន) សច្ចានុលោមិកញ្ញាណ (សេចក្តីដឹងប្រព្រឹត្តទៅតាមសច្ចៈ ៤) ញាណរបស់បុគ្គលអ្នកព្រមព្រៀងដោយមគ្គ ញាណរបស់បុគ្គលអ្នកព្រមព្រៀងដោយផល សេចក្តីដឹងក្នុងទុក្ខ សេចក្តីដឹងក្នុងហេតុដែលនាំឲ្យកើតទុក្ខ សេចក្តីដឹងក្នុងការរលត់នៃទុក្ខ សេចក្តីដឹងក្នុងបដិបទាជាដំណើរដល់នូវការរលត់នៃទុក្ខ បញ្ញាជាកាមាវចរ បញ្ញាជារូបាវចរ បញ្ញាជាអរូបាវចរ បញ្ញាជាអបរិយាបន្នៈ សេចក្តីដឹងក្នុងធម៌ សេចក្តីដឹងក្នុងការប្រព្រឹត្តទៅតាម សេចក្តីដឹងក្នុងការកំណត់ សេចក្តីដឹងក្នុងការសន្មតិ បញ្ញាក្នុងការសន្សំ (កម្មកិលេស) មិនមែនក្នុងការមិនសន្សំ ក៏មាន បញ្ញាក្នុងការមិនសន្សំ មិនមែនក្នុងការសន្សំ ក៏មាន បញ្ញាក្នុងការសន្សំផង ក្នុងការមិនសន្សំផង ក៏មាន បញ្ញាមិនមែនក្នុងការសន្សំ ទាំងមិនមែនក្នុងការមិនសន្សំ ក៏មាន បញ្ញាក្នុងសេចក្តីនឿយណាយ មិនមែនក្នុងការត្រាស់ដឹង ក៏មាន បញ្ញាក្នុងការត្រាស់ដឹង មិនមែនក្នុងសេចក្តីនឿយណាយ ក៏មាន បញ្ញាក្នុងសេចក្តីនឿយណាយផង ក្នុងការត្រាស់ដឹងផង ក៏មាន បញ្ញាមិនមែនក្នុងសេចក្តីនឿយណាយ មិនមែនក្នុងការត្រាស់ដឹង ក៏មាន បញ្ញាមានចំណែកនៃសេចក្តីសាបសូន្យ បញ្ញាមានចំណែកនៃការតាំងនៅ បញ្ញាមានចំណែកនៃសេចក្តីវិសេស

និរោធគាមិនី បញ្ញា ចតស្សោ បដិសម្ភិទា ចតស្សោ បដិបទា ចត្តារិ អារម្មណានិ ជរាមរណេ ញាណំ ជរាមរណសមុទយេ ញាណំ ជរាមរណនិរោធេ ញាណំ ជរាមរណនិរោធគាមិនិយា បដិបទាយ ញាណំ ជាតិយា ញាណំ ។បេ។ ភវេ ញាណំ ។បេ។ ឧបាទានេ ញាណំ ។បេ។ តណ្ហាយ ញាណំ ។បេ។ វេទនាយ ញាណំ ។បេ។ ផស្សេ ញាណំ ។បេ។ សឡាយតនេ ញាណំ ។បេ។ នាមរូបេ ញាណំ ។បេ។ វិញ្ញាណេ ញាណំ ។បេ។ សង្ខារេសុ ញាណំ សង្ខារសមុទយេ ញាណំ សង្ខារនិរោធេ ញាណំ សង្ខារនិរោធគាមិនិយា បដិ-បទាយ ញាណំ ឯវំ ចតុព្វិធេន ញាណវត្ថុ ។

(៣៣) បញ្ចវិធេន ញាណវត្ថុ បញ្ចង្គិកោ សម្មាសមាធិ បញ្ចញាណិកោ សម្មាសមាធិ ឯវំ បញ្ចវិធេន ញាណវត្ថុ ។ ឆព្វិធេន ញាណវត្ថុ ឆសុ អភិញ្ញាសុ បញ្ញា ឯវំ ឆព្វិធេន ញាណវត្ថុ ។ សត្តវិធេន ញាណវត្ថុ សត្តសត្តតិ ញាណវត្ថូនិ

បញ្ញាមានចំណែក នៃសេចក្តីនឿយណាយ បដិសម្ភិទា ៤ បដិបទា ៤ អារម្មណ៍ ៤ សេចក្តីដឹងក្នុងជរានិងមរណៈ សេចក្តីដឹងក្នុងការកើតឡើងនៃជរានិងមរណៈ សេចក្តីដឹងក្នុងការរលត់នៃជរានិងមរណៈ សេចក្តីដឹងក្នុងបដិបទាជាដំណើរដល់នូវការរលត់នៃជរានិងមរណៈ សេចក្តីដឹងក្នុងជាតិ ។ បេ ។ សេចក្តីដឹងក្នុងភព ។ បេ ។ សេចក្តីដឹងក្នុងឧបាទាន ។ បេ ។ សេចក្តីដឹងក្នុងតណ្ហា ។ បេ ។ សេចក្តីដឹងក្នុងវេទនា ។ បេ ។ សេចក្តីដឹងក្នុងផស្សៈ ។ បេ ។ សេចក្តីដឹងក្នុងសឡាយតនៈ ។ បេ ។ សេចក្តីដឹងក្នុងនាមរូប ។ បេ ។ សេចក្តីដឹងក្នុងវិញ្ញាណ ។ បេ ។ សេចក្តីដឹងក្នុងសង្ខារទាំងឡាយ សេចក្តីដឹងក្នុងការកើតឡើងនៃសង្ខារ សេចក្តីដឹងក្នុងការរលត់នៃសង្ខារ សេចក្តីដឹងក្នុងបដិបទាជាដំណើរដល់នូវការរលត់នៃសង្ខារ ញាណវត្ថុ មានប្រការ ៤ យ៉ាងនេះឯង ។

(៣៣) ញាណវត្ថុ មាន ៨ គឺ សម្មាសមាធិ ប្រកបដោយអង្គ ៨ សម្មាសមាធិ ប្រកបដោយញាណ ៨ ញាណវត្ថុមានប្រការ ៨ យ៉ាងនេះឯង ។ ញាណវត្ថុមាន ៦ គឺ បញ្ញាក្នុងអភិញ្ញា ៦ ញាណវត្ថុមានប្រការ ៦ យ៉ាងនេះឯង ។ ញាណវត្ថុមាន ៧៧ គឺ ញាណវត្ថុ ៧៧

## ញាណវិភង្គ មាតិកា

ឯវំ សត្តវិធេន ញាណវត្ថុ ។ អដ្ឋវិធេន ញាណវត្ថុ ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា ឯវំ អដ្ឋវិធេន ញាណវត្ថុ ។ នវវិធេន ញាណវត្ថុ នវសុ អនុបុព្វវិហារសមាបត្តីសុ បញ្ញា ឯវំ នវវិធេន ញាណវត្ថុ ។

(៣៤) ទសវិធេន ញាណវត្ថុ ទស តថាគតស្ស តថាគតពលានិ យេហិ ពលេហិ សមន្នាគតោ តថាគតោ អាសភណ្ឋានំ(១) បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ កតមានិ ទស ។ ឥធ តថាគតោ ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ បជានាតិ យម្បិ តថាគតោ ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ បជានាតិ ឥទម្បិ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ច បរំ តថាគតោ អតីតានាគតបច្ចុប្បន្នានំ កម្មសមាទានានំ ឋានតោ ហេតុសោ

---

១ ឱ. សព្វត្ថ អាសភដ្ឋានន្តិ ទិស្សតិយេវ ។

## ញាណវិភង្គ មាតិកា

ញាណវត្ថុ មានប្រការ ៧ យ៉ាងនេះឯង ។ ញាណវត្ថុមាន ៨ គឺ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ញាណវត្ថុមានប្រការ ៨ យ៉ាងនេះឯង ។ ញាណវត្ថុ មាន ៩ គឺ បញ្ញាក្នុងអនុបុព្វវិហារសមាបត្តិ ៩ ញាណវត្ថុមានប្រការ ៩ យ៉ាងនេះឯង ។

(៣៤) ញាណវត្ថុ មាន ១០ បានដល់ តថាគតពលៈ ១០ របស់ព្រះតថាគត ជាពលៈដែលព្រះតថាគតបានប្រកបហើយ ទើបប្ដេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញុំាងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ ពលៈ ១០ ដូចម្តេចខ្លះ ។ ព្រះតថាគតក្នុងលោកនេះ ជ្រាបច្បាស់តាមពិតនូវហេតុ ថាជាហេតុផង ជ្រាបច្បាស់តាមពិតនូវអំពើមិនមែនហេតុ ថាជាអំពើមិនមែនហេតុផង នេះឯងជាតថាគតពលៈ (ទី ១) របស់ព្រះតថាគត ជាពលៈដែលព្រះតថាគតអាស្រ័យហើយ ទើបប្ដេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញុំាងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគតជ្រាបច្បាស់តាមពិត នូវវិបាកនៃកម្មសមាទាន (ការកាន់យកកម្មជាកុសល) ជាអតីត អនាគតនិងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ

វិបាកំ យថាភូតំ បជានាតិ យម្បិ តថាគតោ អតីតានាគតបច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ ហេតុសោ វិបាកំ យថាភូតំ បជានាតិ ឥទម្បិ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ច បរំ តថាគតោ សព្វត្ថគាមិនឹ បដិបទំ យថាភូតំ បជានាតិ យម្បិ តថាគតោ សព្វត្ថគាមិនឹ បដិបទំ យថាភូតំ បជានាតិ ឥទម្បិ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ច បរំ តថាគតោ អនេកធាតុំ នានាធាតុំ លោកំ យថាភូតំ បជានាតិ យម្បិ តថាគតោ អនេកធាតុំ នានាធាតុំ លោកំ យថាភូតំ បជានាតិ ឥទម្បិ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។

ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់តាមពិត នូវវិបាកនៃកម្មសមាទាន ជាអតីត អនាគតនិងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ នេះឯង ជាតថាគតពលៈ ( ទី ២ ) របស់ព្រះតថាគត ជាពលៈដែលព្រះតថាគតអាស្រ័យហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគត ជ្រាបច្បាស់តាមពិត នូវបដិបទាជាដំណើរទៅ (កាន់សុគតិនិងទុគ្គតិ) ក្នុងទីទាំងពួង ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់តាមពិតនូវបដិបទាជាដំណើរទៅកាន់សុគតិនិងទុគ្គតិក្នុងទីទាំងពួង នេះឯង ជាតថាគតពលៈ ( ទី ៣ ) របស់ព្រះតថាគត ជាពលៈដែលព្រះតថាគតអាស្រ័យហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគត ជ្រាបច្បាស់តាមពិត នូវលោកដែលមានធាតុច្រើន មានធាតុផ្សេងៗគ្នា ត្រង់ដែលតថាគតជ្រាបច្បាស់តាមពិត នូវលោកដែលមានធាតុច្រើន មានធាតុផ្សេងៗគ្នា នេះឯង ជាតថាគតពលៈ ( ទី ៤ ) របស់ព្រះតថាគត ជាពលៈដែលព្រះតថាគតអាស្រ័យហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។

## ញាណវិភង្គ មាតិកា

បុន ច បរំ តថាគតោ សត្តានំ នានាធិមុត្តិកតំ
យថាភូតំ បជានាតិ យម្បិ តថាគតោ សត្តានំ
នានាធិមុត្តិកតំ យថាភូតំ បជានាតិ ឥទម្បិ
តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ
អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ
បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។
បុន ច បរំ តថាគតោ បរសត្តានំ បរបុគ្គលានំ
ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ បជានាតិ យម្បិ
តថាគតោ បរសត្តានំ បរបុគ្គលានំ ឥន្ទ្រិយបរោ-
បរិយត្តំ យថាភូតំ បជានាតិ ឥទម្បិ តថា-
គតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម
តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ
សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន
ច បរំ តថាគតោ ឈានវិមោក្ខសមាធិសមាបត្តីនំ
សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ បជានាតិ
យម្បិ តថាគតោ ឈានវិមោក្ខសមាធិសមាបត្តីនំ

ញាណវិភង្គ មាតិកា

មួយទៀត ព្រះតថាគត ជ្រាបច្បាស់តាមពិតនូវអធ្យាស្រ័យផ្សេងៗ គ្នា របស់សត្វទាំងឡាយ ត្រង់ដែលព្រះតថាគត ជ្រាបច្បាស់តាមពិតនូវអធ្យាស្រ័យផ្សេងៗ គ្នា របស់សត្វទាំងឡាយ នេះឯង ជាតថាគតពលៈ (ទី៥) របស់ព្រះតថាគត ជាពលៈដែលព្រះតថាគតអាស្រ័យហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញុំាងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគត ជ្រាបច្បាស់តាមពិតនូវឥន្ទ្រិយចាស់ក្លានិងខ្ចី របស់ពួកសត្វដទៃ របស់ពួកបុគ្គលដទៃ ត្រង់ដែលព្រះតថាគតជ្រាបច្បាស់តាមពិតនូវឥន្ទ្រិយចាស់ក្លានិងខ្ចី របស់ពួកសត្វដទៃ របស់ពួកបុគ្គលដទៃ នេះឯង ជាតថាគតពលៈ (ទី៦) របស់ព្រះតថាគត ជាពលៈដែលព្រះតថាគតអាស្រ័យហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញុំាងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគតជ្រាបច្បាស់តាមពិតនូវសេចក្តីសៅហ្មង នូវសេចក្តីផូរផង់ នូវការចេញ នៃឈាន វិមោក្ខ សមាធិ និងសមាបត្តិ ត្រង់ដែលព្រះតថាគតជ្រាបច្បាស់តាមពិត នូវសេចក្តីសៅហ្មង នូវសេចក្តីផូរផង់ នូវការចេញ នៃឈាន វិមោក្ខ សមាធិនិងសមាបត្តិ

សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ បជានាតិ យម្បិ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ច បរំ តថាគតោ បុព្វេនិវាសានុស្សតឹ យថាភូតំ បជានាតិ យម្បិ តថាគតោ បុព្វេនិវាសានុស្សតឹ យថាភូតំ បជានាតិ យម្បិ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ច បរំ តថាគតោ សត្តានំ ចុតូបបាតំ យថាភូតំ បជានាតិ យម្បិ តថាគតោ សត្តានំ ចុតូបបាតំ យថាភូតំ បជានាតិ យម្បិ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ បុន ច បរំ តថាគតោ អាសវានំ ខយំ យថាភូតំ បជានាតិ យម្បិ តថាគតោ អាសវានំ ខយំ

នេះឯង ជាតថាគតពលៈ (ទី៧) របស់ព្រះតថាគត ជាពលៈដែលព្រះតថាគតអាស្រ័យហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគត ជ្រាបច្បាស់តាមពិត នូវការរលឹកជាតិដែលនៅអាស្រ័យក្នុងកាលមុន ត្រង់ដែលព្រះតថាគតជ្រាបច្បាស់តាមពិត នូវការរលឹកជាតិដែលបាននៅអាស្រ័យក្នុងកាលមុន នេះឯង ជាតថាគតពលៈ (ទី៨) របស់ព្រះតថាគត ជាពលៈដែលព្រះតថាគតអាស្រ័យហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយទៀត ព្រះតថាគត ជ្រាបច្បាស់តាមពិត នូវការច្យុតិនិងការកើត របស់សត្វទាំងឡាយ ត្រង់ដែលព្រះតថាគតជ្រាបច្បាស់តាមពិត នូវការច្យុតិនិងការកើត របស់សត្វទាំងឡាយ នេះឯង ជាតថាគតពលៈ (ទី៩) របស់ព្រះតថាគត ជាពលៈដែលព្រះតថាគតអាស្រ័យហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ មួយវិញទៀត ព្រះតថាគតជ្រាបច្បាស់តាមពិត នូវការអស់នៃអាសវៈទាំងឡាយ ត្រង់ដែលព្រះតថាគតជ្រាបច្បាស់តាមពិត នូវការអស់នៃអាសវៈទាំងឡាយ

យថាភូតំ បជានាតិ ឥទម្បិ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ ឥមានិ ទស តថាគតស្ស តថាគតពលានិ យេហិ ពលេហិ សមន្នាគតោ តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ឯវំ ទសវិធេន ញាណវត្ថុ ។

### មាតិកា ។

(៣៨) បញ្ចវិញ្ញាណំ ន ហេតុមេវ អហេតុកមេវ ហេតុវិប្បយុត្តមេវ សប្បច្ចយមេវ សង្ខតមេវ អរូបមេវ លោកិយមេវ សាសវមេវ សញ្ញោជនិយមេវ គន្ថនិយមេវ ឱឃនិយមេវ យោគនិយមេវ នីវរណិយមេវ បរាមដ្ឋមេវ ឧបាទានិយមេវ សង្កិលេសិកមេវ អព្យាកតមេវ សារម្មណមេវ អចេតសិកមេវ វិបាកមេវ ឧបាទិន្នុបាទានិយមេវ អសង្កិលិដ្ឋសង្កិលេសិកមេវ ន សវិតក្កសវិចារមេវ ន អវិតក្កវិចារមត្តមេវ

## ញាណវិភង្គ ឯកកនិទ្ទេស

នេះឯង ជាតថាគតពលៈ ( ទី ១០ ) របស់ព្រះតថាគត ជាពលៈដែលព្រះតថាគតអាស្រ័យហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ។ តថាគតពលៈទាំង ១០ នេះ របស់ព្រះតថាគត ជាពលៈដែលព្រះតថាគតប្រកបហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបបន្លឺសីហនាទក្នុងពួកបរិស័ទ ទើបញ៉ាំងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ញាណវត្ថុមានប្រការ ១០ យ៉ាងនេះឯង ។

ចប់ មាតិកា ។

( ៣៩ ) វិញ្ញាណ ៥ មិនមែនហេតុ មិនមានហេតុ ប្រាសចាកហេតុ ប្រកបដោយបច្ច័យ ត្រូវបច្ច័យប្រជុំតាក់តែង ជាអរូប ជាលោកិយ ប្រកបដោយអាសវៈ ជាប្រយោជន៍ដល់សញ្ញោជនៈ ដែលគន្ថៈគប្បីដោតក្រង ដែលឱឃៈគប្បីប្រព្រឹត្តកន្លង ដែលយោគៈគប្បីប្រព្រឹត្តកន្លង ជាប្រយោជន៍ដល់នីវរណៈ ដែលបរាមាសៈស្ទាបអង្អែល ជាប្រយោជន៍ដល់ឧបាទាន គួរដល់នូវសេចក្តីសៅហ្មង ជាអព្យាក្រឹត ប្រកបដោយអារម្មណ៍ មិនមែនចេតសិក ជាវិបាក មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបា-ទាន មិនសៅហ្មង តែគួរដល់នូវសេចក្តីសៅហ្មង មិនប្រកបដោយវិតក្កៈ តែប្រកបដោយវិចារៈ មិនមែនជាមិនមានវិតក្កៈ មានត្រឹមតែវិចារៈ

អវិតក្កាវិចារមេវ ន បីតិសហគតមេវ នេវ ទស្សនេន ន ភាវនាយ បហាតព្វមេវ នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកមេវ នេវាចយគាមិនាបចយគាមិមេវ នេវ សេក្ខនាសេក្ខមេវ បរិត្តមេវ កាមាវចរមេវ ន រូបាវចរមេវ ន អរូបាវចរមេវ បរិយាបន្នមេវ នោ អបរិយាបន្នមេវ អនិយតមេវ អនិយ្យានិកមេវ ឧប្បន្នំ មនោវិញ្ញាណវិញ្ញេយ្យមេវ អនិច្ចមេវ ជរាភិភូតមេវ ។

(៣៦) បញ្ច វិញ្ញាណា ឧប្បន្នវត្ថុកា ឧប្បន្នារម្មណាតិ ឧប្បន្នស្មឹ វត្ថុស្មឹ អារម្មណេ ឧប្បជ្ជន្តិ ។ បុរេជាតវត្ថុកា បុរេជាតារម្មណាតិ បុរេ ជាតស្មឹ វត្ថុស្មឹ បុរេជាតេ អារម្មណេ ឧប្បជ្ជន្តិ ។ អជ្ឈត្តិកវត្ថុកា ពាហិរារម្មណាតិ បញ្ចន្នំ វិញ្ញាណានំ វត្ថុ អជ្ឈត្តិកា អារម្មណា ពាហិរា ។ អសម្ភិន្នវត្ថុកា អសម្ភិន្នារម្មណាតិ អសម្ភិន្នស្មឹ វត្ថុស្មឹ អសម្ភិន្នេ អារម្មណេ ឧប្បជ្ជន្តិ ។

មិនមានវិតក្កៈ ទាំងមិនមានវិចារៈ មិនកើតព្រមដោយបីតិ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មិនដល់នូវការសន្សំ (កម្មកិលេស) ទាំងមិនដល់នូវការមិនសន្សំ មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល មានសភាពតូចឆ្មារ ជាកាមាវចរ មិនមែនរូបាវចរ មិនមែនអរូបាវចរ ជាបរិយាបន្នៈ មិនមែនអបរិយាបន្នៈ ជាសភាពមិនទៀង ជាអនិយ្យានិកៈ ដែលកើតឡើងហើយ ដែលគួរដឹងដោយមនោវិញ្ញាណ មិនទៀង ដែលត្រូវជរាគ្របសង្កត់ ។

(៣៦) ត្រង់ពាក្យថា វិញ្ញាណ ៥ មានវត្ថុកើតហើយ មានអារម្មណ៍កើតហើយ គឺ កាលបើវត្ថុនិងអារម្មណ៍កើតហើយ វិញ្ញាណទាំងឡាយ ក៏កើតឡើងដែរ ។ ពាក្យថា (វិញ្ញាណ៥) មានវត្ថុកើតហើយក្នុងកាលមុន មានអារម្មណ៍កើតហើយក្នុងកាលមុន គឺ កាលបើវត្ថុកើតហើយក្នុងកាលមុននិងអារម្មណ៍កើតហើយក្នុងកាលមុន វិញ្ញាណទាំងឡាយ ក៏កើតឡើងដែរ ។ ពាក្យថា (វិញ្ញាណ ៥) មានវត្ថុខាងក្នុង មានអារម្មណ៍ខាងក្រៅ គឺវិញ្ញាណទាំង ៥ មានវត្ថុខាងក្នុង មានអារម្មណ៍ខាងក្រៅ ។ ពាក្យថា (វិញ្ញាណ ៥) មានវត្ថុមិនប្រឡំគ្នា មានអារម្មណ៍មិនប្រឡំគ្នា គឺ កាលបើវត្ថុមិនប្រឡំគ្នា កាលបើអារម្មណ៍មិនប្រឡំគ្នា វិញ្ញាណទាំងឡាយ ក៏កើតឡើងដែរ ។

## ញាណវិភង្គ ឯកកនិទ្ទេសោ

នានាវត្ថុកា នានារម្មណាតិ អញ្ញំ ចក្ខុវិញ្ញាណស្ស វត្ថុ ច អារម្មណញ្ច អញ្ញំ សោតវិញ្ញាណស្ស វត្ថុ ច អារម្មណញ្ច អញ្ញំ ឃានវិញ្ញាណស្ស វត្ថុ ច អារម្មណញ្ច អញ្ញំ ជិវ្ហាវិញ្ញាណស្ស វត្ថុ ច អារម្មណញ្ច អញ្ញំ កាយវិញ្ញាណស្ស វត្ថុ ច អារម្មណញ្ច ។ ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តីតិ ចក្ខុវិញ្ញាណស្ស គោចរវិសយំ សោតវិញ្ញាណំ ន បច្ចនុភោតិ សោតវិញ្ញាណស្ស គោចរវិសយំបិ ចក្ខុវិញ្ញាណំ ន បច្ចនុភោតិ ចក្ខុវិញ្ញាណស្ស គោចរវិសយំ ឃានវិញ្ញាណំ ន បច្ចនុភោតិ ឃានវិញ្ញាណស្ស គោចរវិសយំបិ ចក្ខុវិញ្ញាណំ ន បច្ចនុភោតិ ចក្ខុវិញ្ញាណស្ស គោចរវិសយំ ជិវ្ហាវិញ្ញាណំ ន បច្ចនុភោតិ ជិវ្ហាវិញ្ញាណស្ស គោចរវិសយំបិ ចក្ខុវិញ្ញាណំ ន បច្ចនុភោតិ កាយវិញ្ញាណស្ស គោចរវិសយំបិ ចក្ខុវិញ្ញាណំ ន បច្ចនុភោតិ សោតវិញ្ញាណស្ស ។បេ។ ឃានវិញ្ញាណស្ស ។បេ។ ជិវ្ហាវិញ្ញាណស្ស ។បេ។ កាយវិញ្ញាណស្ស គោចរវិសយំ ចក្ខុវិញ្ញាណំ

## ញាណវិភង្គ ឯកកនិទ្ទេស

ពាក្យថា (វិញ្ញាណ ៥) មានវត្ថុផ្សេងៗ មានអារម្មណ៍ផ្សេងៗ គឺ វត្ថុនិងអារម្មណ៍ របស់ចក្ខុវិញ្ញាណ ដោយឡែក វត្ថុនិងអារម្មណ៍របស់សោតវិញ្ញាណ ដោយឡែក វត្ថុនិងអារម្មណ៍របស់ឃានវិញ្ញាណ ដោយឡែក វត្ថុនិងអារម្មណ៍របស់ជិវ្ហាវិញ្ញាណ ដោយឡែក វត្ថុនិងអារម្មណ៍របស់កាយវិញ្ញាណ ដោយឡែកៗ ពាក្យថា (វិញ្ញាណ ៥) មិនរងអារម្មណ៍ជាទីគោចរនៃគ្នានិងគ្នាទេ គឺ សោតវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់ចក្ខុវិញ្ញាណ ចក្ខុវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់សោតវិញ្ញាណ ឃានវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់ចក្ខុវិញ្ញាណ ចក្ខុវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់ចក្ខុវិញ្ញាណ ចក្ខុវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់ជិវ្ហាវិញ្ញាណ ចក្ខុវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់កាយវិញ្ញាណ របស់សោតវិញ្ញាណ ។បេ។ របស់ឃានវិញ្ញាណ ។បេ។ របស់ជិវ្ហាវិញ្ញាណ ។បេ។ ចក្ខុវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់កាយវិញ្ញាណ

ន បច្ចនុភោតិ ចក្ខុវិញ្ញាណស្ស គោចរវិសយម្បិ កាយវិញ្ញាណំ ន បច្ចនុភោតិ កាយវិញ្ញាណស្ស គោចរវិសយំ សោតវិញ្ញាណំ ន បច្ចនុភោតិ សោតវិញ្ញាណស្ស គោចរវិសយម្បិ កាយវិញ្ញាណំ ន បច្ចនុភោតិ កាយវិញ្ញាណស្ស គោចរវិសយំ ឃានវិញ្ញាណំ ន បច្ចនុភោតិ ឃានវិញ្ញាណស្ស គោចរវិសយម្បិ កាយវិញ្ញាណំ ន បច្ចនុភោតិ កាយវិញ្ញាណស្ស គោចរវិសយំ ជិវ្ហាវិញ្ញាណំ ន បច្ចនុភោតិ ជិវ្ហាវិញ្ញាណស្ស គោចរវិសយម្បិ កាយវិញ្ញាណំ ន បច្ចនុភោតិ ។ ន អសមន្នាហារា ឧប្បជ្ជន្តិ សមន្នាហរន្តស្ស ឧប្បជ្ជន្តិ ។ ន អមនសិការា ឧប្បជ្ជន្តិ មនសិករោន្តស្ស ឧប្បជ្ជន្តិ ។ ន អព្វោកិណ្ណា ឧប្បជ្ជន្តិ ន បដិបាដិយា ឧប្បជ្ជន្តិ ។ ន អបុព្វំ អចរិមំ ឧប្បជ្ជន្តិ

កាយវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់ចក្ខុវិញ្ញាណ សោតវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់កាយវិញ្ញាណ កាយវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់សោតវិញ្ញាណ ឃានវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់កាយវិញ្ញាណ កាយវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់កាយវិញ្ញាណ កាយវិញ្ញាណ មិនរងអារម្មណ៍ជាទីគោចរ របស់ជិវ្ហាវិញ្ញាណ ៗ ពាក្យថា (វិញ្ញាណ ៥) មិនកើតឡើង ព្រោះការមិនប្រមូលមក (នូវអារម្មណ៍) គឺ កាលបុគ្គលប្រមូលមក (នូវអារម្មណ៍មានរូបារម្មណ៍ជាដើម) វិញ្ញាណទាំងឡាយក៏កើតឡើង ៗ ពាក្យថា (វិញ្ញាណ ៥) មិនកើតឡើង ព្រោះការមិនធ្វើទុកក្នុងចិត្ត (នូវអារម្មណ៍) គឺ កាលបុគ្គលធ្វើទុកក្នុងចិត្ត (នូវអារម្មណ៍) វិញ្ញាណទាំងឡាយ ក៏កើតឡើង ៗ ពាក្យថា (វិញ្ញាណ៥) មិនកើតឡើង ព្រោះការមិនប្រឡុំគ្នា គឺ មិនកើតឡើងតាមលំដាប់គ្នាទេ ៗ ពាក្យថា (វិញ្ញាណ ៥) មិនកើតឡើង មិនមុន មិនក្រោយ

## ញាណវិភង្គ ឯកកនិទ្ទេសោ

ន ឯកក្ខណេ ឧប្បជ្ជន្តិ ។ ន អញ្ញមញ្ញស្ស សមនន្តរា ឧប្បជ្ជន្តីតិ ចក្ខុវិញ្ញាណស្ស ឧប្បន្នសមនន្តរា សោតវិញ្ញាណំ ន ឧប្បជ្ជតិ សោតវិញ្ញាណស្ស ឧប្បន្នសមនន្តរាបិ ចក្ខុវិញ្ញាណំ ន ឧប្បជ្ជតិ ចក្ខុវិញ្ញាណស្ស ឧប្បន្នសមនន្តរា ឃានវិញ្ញាណំ ន ឧប្បជ្ជតិ ឃានវិញ្ញាណស្ស ឧប្បន្នសមនន្តរាបិ ចក្ខុវិញ្ញាណំ ន ឧប្បជ្ជតិ ចក្ខុវិញ្ញាណស្ស ឧប្បន្នសមនន្តរា ជិវ្ហាវិញ្ញាណំ ន ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណស្ស ឧប្បន្នសមនន្តរាបិ ចក្ខុវិញ្ញាណំ ន ឧប្បជ្ជតិ ចក្ខុវិញ្ញាណស្ស ឧប្បន្នសមនន្តរា កាយវិញ្ញាណំ ន ឧប្បជ្ជតិ កាយវិញ្ញាណស្ស ឧប្បន្នសមនន្តរាបិ ចក្ខុវិញ្ញាណំ ន ឧប្បជ្ជតិ សោតវិញ្ញាណស្ស ។បេ។ ឃានវិញ្ញាណស្ស ។បេ។ ជិវ្ហាវិញ្ញាណស្ស ។បេ។ កាយវិញ្ញាណស្ស ឧប្បន្នសមនន្តរា ចក្ខុវិញ្ញាណំ ន ឧប្បជ្ជតិ ចក្ខុវិញ្ញាណស្ស ឧប្បន្នសមនន្តរាបិ កាយវិញ្ញាណំ

គឺ មិនកើតក្នុងខណៈជាមួយគ្នាទេ ។ ពាក្យថា (វិញ្ញាណ ៥) មិនកើតឡើង ក្នុងលំដាប់នៃគ្នានិងគ្នា គឺ សោតវិញ្ញាណ មិនកើតក្នុងលំដាប់ នៃចក្ខុវិញ្ញាណដែលកើតហើយ ទាំងចក្ខុវិញ្ញាណ ក៏មិនកើតក្នុងលំដាប់នៃសោតវិញ្ញាណដែលកើតហើយដែរ ឃានវិញ្ញាណមិនកើតក្នុងលំដាប់នៃចក្ខុវិញ្ញាណដែលកើតហើយ ទាំងចក្ខុវិញ្ញាណ ក៏មិនកើតក្នុងលំដាប់នៃឃានវិញ្ញាណដែលកើតហើយដែរ ជិវ្ហាវិញ្ញាណ មិនកើតក្នុងលំដាប់នៃចក្ខុវិញ្ញាណដែលកើតហើយ ទាំងចក្ខុវិញ្ញាណ ក៏មិនកើតក្នុងលំដាប់នៃជិវ្ហាវិញ្ញាណដែលកើតហើយដែរ កាយវិញ្ញាណ មិនកើតក្នុងលំដាប់នៃចក្ខុវិញ្ញាណដែលកើតហើយ ទាំងចក្ខុវិញ្ញាណ ក៏មិនកើតក្នុងលំដាប់នៃកាយវិញ្ញាណដែលកើតហើយដែរ ចក្ខុវិញ្ញាណ មិនកើតក្នុងលំដាប់នៃសោតវិញ្ញាណ ។ បេ ។ នៃឃានវិញ្ញាណ ។ បេ ។ នៃជិវ្ហាវិញ្ញាណ ។ បេ ។ នៃកាយវិញ្ញាណដែលកើតហើយ ទាំងកាយវិញ្ញាណ ក៏មិនកើតក្នុងលំដាប់ នៃចក្ខុវិញ្ញាណដែលកើតហើយដែរ

ន ឧប្បជ្ជតិ កាយវិញ្ញាណស្ស ឧប្បន្នសមនន្តរា សោតវិញ្ញាណំ ន ឧប្បជ្ជតិ សោតវិញ្ញាណស្ស ឧប្បន្នសមនន្តរាបិ កាយវិញ្ញាណំ ន ឧប្បជ្ជតិ កាយវិញ្ញាណស្ស ឧប្បន្នសមនន្តរា ឃានវិញ្ញាណំ ន ឧប្បជ្ជតិ ឃានវិញ្ញាណស្ស ឧប្បន្នសមនន្តរាបិ កាយវិញ្ញាណំ ន ឧប្បជ្ជតិ កាយវិញ្ញាណស្ស ឧប្បន្នសមនន្តរា ជិវ្ហាវិញ្ញាណំ ន ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណស្ស ឧប្បន្នសមនន្តរាបិ កាយវិញ្ញាណំ ន ឧប្បជ្ជតិ ។ បញ្ច វិញ្ញាណា អនាភោគាតិ បញ្ចន្នំ វិញ្ញាណានំ នត្ថិ អាវជ្ជនា វា អាភោគោ វា សមន្នាហារោ វា មនសិការោ វា ។ បញ្ចហិ វិញ្ញាណេហិ ន កញ្ចិ ធម្មំ បដិវិជានាតីតិ បញ្ចហិ វិញ្ញាណេហិ ន កញ្ចិ ធម្មំ បដិវិជានាតិ ។ អញ្ញត្រ អភិនិបាតមត្តាតិ អញ្ញត្រ អាបាថមត្តា ។ បញ្ចន្នំ វិញ្ញាណានំ សមនន្តរាបិ ន កញ្ចិ ធម្មំ បដិវិជានាតីតិ បញ្ចន្នំ វិញ្ញាណានំ សមនន្តរា មនោធាតុយាបិ ន កញ្ចិ ធម្មំ បដិវិជានាតិ ។

សោតវិញ្ញាណ មិនកើតក្នុងលំដាប់ នៃកាយវិញ្ញាណដែលកើតហើយ ទាំងកាយវិញ្ញាណ ក៏មិនកើតក្នុងលំដាប់ នៃសោតវិញ្ញាណដែលកើតហើយដែរ ឃានវិញ្ញាណ មិនកើតក្នុងលំដាប់ នៃកាយវិញ្ញាណដែលកើតហើយ ទាំងកាយវិញ្ញាណ ក៏មិនកើតក្នុងលំដាប់ នៃឃានវិញ្ញាណដែលកើតហើយដែរ ជិវ្ហាវិញ្ញាណ មិនកើតក្នុងលំដាប់ នៃកាយវិញ្ញាណដែលកើតហើយ ទាំងកាយវិញ្ញាណ ក៏មិនកើតក្នុងលំដាប់ នៃជិវ្ហាវិញ្ញាណដែលកើតហើយដែរ ។ ពាក្យថា វិញ្ញាណ ៥ មិនមានគ្រឿងអាង គឺ វិញ្ញាណទាំង ៥ មិនមានការនឹក មិនមានគ្រឿងអាង មិនមានការប្រមូលមក មិនមានការធ្វើទុកក្នុងចិត្តទេ ។ ពាក្យថា បុគ្គលមិនដឹងច្បាស់នូវធម៌ណាមួយ ដោយវិញ្ញាណទាំង ៥ គឺ បុគ្គលមិនដឹងច្បាស់ នូវធម៌ណាមួយ ដោយវិញ្ញាណទាំង ៥ ។ ពាក្យថា បើវៀរចាកការប៉ះពាល់នូវអារម្មណ៍ គឺ បើវៀរចាកអារម្មណ៍មានរូបារម្មណ៍ជាដើម ដែលមកកាន់គន្លងនៃទ្វារមានចក្ខុទ្វារជាដើម ។ ពាក្យថា បុគ្គលមិនដឹងច្បាស់នូវធម៌ណាមួយ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ គឺ បុគ្គលមិនដឹងច្បាស់នូវធម៌ណាមួយ ដោយមនោធាតុ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ ។

## ញាណវិភង្គេ ឯកកនិទ្ទេសោ

បញ្ចហិ វិញ្ញាណេហិ ន កញ្ចិ ឥរិយាបថំ កប្បេតីតិ បញ្ចហិ វិញ្ញាណេហិ ន កញ្ចិ ឥរិយាបថំ កប្បេតិ គមនំ វា ឋានំ វា និសជ្ជំ វា សេយ្យំ វា ។ បញ្ចន្នំ វិញ្ញាណានំ សមនន្តរាបិ ន កញ្ចិ ឥរិយាបថំ កប្បេតីតិ បញ្ចន្នំ វិញ្ញាណានំ សមនន្តរា មនោធាតុយាបិ ន កញ្ចិ ឥរិយាបថំ កប្បេតិ គមនំ វា ឋានំ វា និសជ្ជំ វា សេយ្យំ វា ។ បញ្ចហិ វិញ្ញាណេហិ ន កាយកម្មំ ន វចីកម្មំ បដ្ឋបេតីតិ បញ្ចហិ វិញ្ញាណេហិ ន កាយកម្មំ វចីកម្មំ បដ្ឋបេតិ ។ បញ្ចន្នំ វិញ្ញាណានំ សមនន្តរាបិ ន កាយកម្មំ ន វចីកម្មំ បដ្ឋបេតីតិ បញ្ចន្នំ វិញ្ញាណានំ សមនន្តរា មនោធាតុយាបិ ន កាយកម្មំ វចីកម្មំ បដ្ឋបេតិ ។ បញ្ចហិ វិញ្ញាណេហិ ន កុសលាកុសលំ ធម្មំ សមាទិយតីតិ បញ្ចហិ វិញ្ញាណេហិ ន កុសលាកុសលំ ធម្មំ សមាទិយតិ ។ បញ្ចន្នំ វិញ្ញាណានំ សមនន្តរាបិ ន កុសលាកុសលំ ធម្មំ សមាទិយតីតិ

ពាក្យថា មិនសម្រេចនូវឥរិយាបថណាមួយ ដោយវិញ្ញាណទាំង ៥ ឥរិយាបថ សេចក្តីថា មិនសម្រេចឥរិយាបថណាមួយ គឺ ការដើរក្តី ការឈរក្តី ការអង្គុយក្តី ការដេកក្តី ដោយវិញ្ញាណទាំង ៥ ។ ពាក្យថា មិនសម្រេចឥរិយាបថណាមួយ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ សេចក្តីថា មិនសម្រេចឥរិយាបថណាមួយ គឺ ការដើរក្តី ការឈរក្តី ការអង្គុយក្តី ការដេកក្តី ដោយមនោធាតុ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ ។ ពាក្យថា មិនតាំងផ្តើមកាយកម្ម មិនតាំងផ្តើមវចីកម្ម ដោយវិញ្ញាណទាំង ៥ គឺ មិនតាំងផ្តើមនូវកាយកម្ម និងវចីកម្ម ដោយវិញ្ញាណទាំង ៥ ។ ពាក្យថា មិនតាំងផ្តើមកាយកម្ម មិនតាំងផ្តើមវចីកម្មក្នុងលំដាប់នៃវិញ្ញាណទាំង ៥ គឺ មិនតាំងផ្តើមនូវកាយកម្ម និងវចីកម្ម ដោយមនោធាតុ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ ។ ពាក្យថា មិនកាន់យកនូវធម៌ជាកុសលនិងអកុសល ដោយវិញ្ញាណទាំង ៥ គឺ មិនសមាទាននូវធម៌ជាកុសលនិងអកុសល ដោយវិញ្ញាណទាំង ៥ ។ ពាក្យថា មិនកាន់យកនូវធម៌ជាកុសលនិងអកុសល ក្នុងលំដាប់នៃវិញ្ញាណទាំង ៥

បញ្ចន្នំ វិញ្ញាណានំ សមនន្តរា មនោធាតុយាបិ ន
កុសលាកុសលំ ធម្មំ សមាទិយតិ ។ បញ្ចហិ
វិញ្ញាណេហិ ន សមាបជ្ជតិ ន វុដ្ឋាតីតិ បញ្ចហិ
វិញ្ញាណេហិ ន សមាបជ្ជតិ ន វុដ្ឋាតិ ។ បញ្ចន្នំ
វិញ្ញាណានំ សមនន្តរាបិ ន សមាបជ្ជតិ ន វុដ្ឋាតីតិ
បញ្ចន្នំ វិញ្ញាណានំ សមនន្តរា មនោធាតុយាបិ ន
សមាបជ្ជតិ ន វុដ្ឋាតិ ។ បញ្ចហិ វិញ្ញាណេហិ ន
ចវតិ ន ឧបបជ្ជតីតិ បញ្ចហិ វិញ្ញាណេហិ ន ចវតិ
ន ឧបបជ្ជតិ ។ បញ្ចន្នំ វិញ្ញាណានំ សមនន្តរាបិ ន
ចវតិ ន ឧបបជ្ជតីតិ បញ្ចន្នំ វិញ្ញាណានំ សមនន្តរា
មនោធាតុយាបិ ន ចវតិ ន ឧបបជ្ជតិ ។ បញ្ចហិ
វិញ្ញាណេហិ ន សុបតិ ន បដិពុជ្ឈតិ ន សុបិនំ បស្ស-
តីតិ បញ្ចហិ វិញ្ញាណេហិ ន សុបតិ ន បដិពុជ្ឈតិ
ន សុបិនំ បស្សតិ ។ បញ្ចន្នំ វិញ្ញាណានំ សមនន្ត-
រាបិ ន សុបតិ ន បដិពុជ្ឈតិ ន សុបិនំ បស្សតីតិ

គឺមិនសមាទាន នូវធម៌ជាកុសលនិងអកុសល ដោយមនោធាតុ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ ៗ ពាក្យថា មិនចូលឈាន មិនចេញចាកឈាន ដោយវិញ្ញាណទាំង៥ គឺ មិនចូល មិនចេញ ដោយវិញ្ញាណទាំង ៥ ៗ ពាក្យថា មិនចូលឈាន មិនចេញចាកឈាន ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ គឺមិនចូល មិនចេញ ដោយមនោធាតុ ក្នុងលំដាប់នៃវិញ្ញាណទាំង៥ ៗ ពាក្យថា មិនច្យុត មិនកើត ដោយវិញ្ញាណទាំង៥ គឺ មិនឃ្លាត មិនកកើត ដោយវិញ្ញាណទាំង៥ ៗ ពាក្យថា មិនច្យុត មិនកើត ក្នុងលំដាប់នៃវិញ្ញាណទាំង៥ គឺ មិនឃ្លាត មិនកកើត ដោយមនោធាតុ ក្នុងលំដាប់នៃវិញ្ញាណទាំង ៥ ៗ ពាក្យថា មិនលក់ មិនភ្ញាក់ មិនឃើញសុបិន ដោយវិញ្ញាណទាំង ៥ គឺ មិនដេកលក់ មិនដឹងស្មារតី មិនយល់សប្តិ ដោយវិញ្ញាណទាំង ៥ ៗ ពាក្យថា មិនលក់ មិនភ្ញាក់ មិនឃើញសុបិន ក្នុងលំដាប់នៃវិញ្ញាណទាំង ៥

## ញាណវិភង្គ ទុកនិទ្ទេសោ

បញ្ចន្នំ វិញ្ញាណានំ សមនន្តរា មនោធាតុយាបិ ន សុបតិ ន បដិពុជ្ឈតិ ន សុបិនំ បស្សតិ ។

ឯវំ យាថាវកវត្ថុវិភាវនា បញ្ញា ។

**ឯវំ ឯកវិធេន ញាណវត្ថុ ។**

(៣៧) តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា លោកិយា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា លោកុត្តរា បញ្ញា ។ សព្វាវ បញ្ញា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា សាសវា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា អនាសវា បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា អាសវវិប្បយុត្តសាសវា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា អាសវវិប្បយុត្តអនាសវា បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា សញ្ញោជនិយា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា អសញ្ញោជនិយា បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា

## ញាណវិភង្គ ទុកនិទ្ទេស

គឺ មិនដេកលក់ មិនដឹងស្មារតី មិនយល់សប្តិ ដោយមនោធាតុ ក្នុង លំដាប់នៃវិញ្ញាណទាំង ៩ ។

បញ្ញាជាគ្រឿងសំដែងតាមលំដាប់នៃមាតិកា យ៉ាងនេះឯង ។

ញាណវត្ថុ មានប្រការ ១ យ៉ាងនេះ ។

(៣៧) បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ជាលោកិយ បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា ជាលោកុត្តរ ។ បញ្ញាទាំងអស់ បុគ្គលត្រូវដឹងដោយវិញ្ញាណទីមួយ មិនត្រូវដឹងដោយវិញ្ញាណទីមួយ ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ប្រកបដោយអាសវៈ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា មិនមានអាសវៈ ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ជាប្រយោជន៍ដល់សញ្ញោជនៈ បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាមិនជាប្រយោជន៍ដល់សញ្ញោជនៈ ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣

សញ្ញោជនវិប្បយុត្តសញ្ញោជនិយា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា សញ្ញោជនវិប្បយុត្តអសញ្ញោជនិយា បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា គន្ថនិយា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា អគន្ថនិយា បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា គន្ថវិប្បយុត្តគន្ថនិយា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា គន្ថវិប្បយុត្តអគន្ថនិយា បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា ឱឃនិយា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា អនោឃនិយា បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា ឱឃវិប្បយុត្តឱឃនិយា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា ឱឃវិប្បយុត្តអនោឃនិយា បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា យោគនិយា បញ្ញា

ឈ្មោះថា បញ្ញា ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា ប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈ ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ដែលគន្ថៈគប្បីដោតក្រង បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា ដែលគន្ថៈមិនគប្បីដោតក្រង ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រង បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាប្រាសចាកគន្ថៈ ទាំងគន្ថៈ មិនគប្បីដោតក្រង ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ដែលឱឃៈគប្បីប្រព្រឹត្តកន្លង បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លង ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ប្រាសចាកឱឃៈ តែឱឃៈគប្បីប្រព្រឹត្តកន្លង បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាប្រាសចាកឱឃៈ ទាំងឱឃៈមិនគប្បីប្រព្រឹត្តកន្លង ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ដែលយោគៈគប្បីប្រព្រឹត្តកន្លង

## ញាណវិភង្គេ ទុកនិទ្ទេសោ

ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា អយោគនិយា បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា យោគវិប្បយុត្តយោគនិយា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា យោគវិប្បយុត្តអយោគនិយា បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា នីវរណិយា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា អនីវរណិយា បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា នីវរណវិប្បយុត្តនីវរណិយា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា នីវរណវិប្បយុត្តអនីវរណិយា បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា បរាមដ្ឋា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា អបរាមដ្ឋា បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា បរាមាសវិប្បយុត្តបរាមដ្ឋា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា បរាមាសវិប្បយុត្តអបរាមដ្ឋា បញ្ញា ។

## ញាណវិភង្គ ទុកនិទ្ទេស

បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា ដែលយោគៈមិនគប្បីប្រព្រឹត្តកន្ទុង ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ប្រាសចាកយោគៈ តែយោគៈគប្បីប្រព្រឹត្តកន្ទុង បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា ប្រាសចាកយោគៈ ទាំងយោគៈមិនគប្បីប្រព្រឹត្តកន្ទុង ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ជាប្រយោជន៍ដល់និវរណៈ បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា មិនជាប្រយោជន៍ដល់និវរណៈ ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់និវរណៈ បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា ប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់និវរណៈ ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាដែលបរាមាសៈស្ទាបអង្អែល បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា ដែលបរាមាសៈមិនស្ទាបអង្អែល ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ប្រាសចាកបរាមាសៈ តែបរាមសៈស្ទាបអង្អែល បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាប្រាសចាកបរាមាសៈ ទាំងបរាមាសៈមិនស្ទាបអង្អែល ។

តីសុ ភូមីសុ វិបាកោ បញ្ញា ឧបាទិន្នា បញ្ញា
តីសុ ភូមីសុ កុសលេ តីសុ ភូមីសុ កិរិយា-
ព្យាកតេ ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា
អនុបាទិន្នា បញ្ញា ។ តីសុ ភូមីសុ កុសលា-
ព្យាកតេ បញ្ញា ឧបាទានិយា បញ្ញា ចតូសុ មគ្គេសុ
ចតូសុ ផលេសុ បញ្ញា អនុបាទានិយា បញ្ញា ។
តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា ឧបាទាន-
វិប្បយុត្តឧបាទានិយា បញ្ញា ចតូសុ មគ្គេសុ ចតូសុ
ផលេសុ បញ្ញា ឧបាទានវិប្បយុត្តអនុបាទានិយា
បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា
សង្កិលេសិកា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ
បញ្ញា អសង្កិលេសិកា បញ្ញា ។ តីសុ ភូមីសុ
កុសលាព្យាកតេ បញ្ញា កិលេសវិប្បយុត្តសង្កិលេ-
សិកា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ
បញ្ញា កិលេសវិប្បយុត្តអសង្កិលេសិកា បញ្ញា ។

បញ្ញា ក្នុងវិបាក ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ដែលកិលេសមានតណ្ហាជាដើមកាន់យកហើយ បញ្ញា ក្នុងកុសល ប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងកិរិយានិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា ដែលកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាជាប្រយោជន៍ដល់ឧបាទាន បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាមិនជាប្រយោជន៍ដល់ឧបាទាន ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាប្រាសចាកឧបាទាន ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា គួរដល់នូវសេចក្តីសៅហ្មង បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាមិនគួរដល់នូវសេចក្តីសៅហ្មង ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញាប្រាសចាកសេចក្តីសៅហ្មង តែគួរដល់នូវសេចក្តីសៅហ្មង បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាប្រាសចាកសេចក្តីសៅហ្មង ទាំងមិនគួរដល់នូវសេចក្តីសៅហ្មង ។

## ញាណវិភង្គ ទុកនិទ្ទេសោ

វិតក្កសម្បយុត្តា បញ្ញា សវិតក្កា បញ្ញា វិតក្កវិប្ប-
យុត្តា បញ្ញា អវិតក្កា បញ្ញា ។ វិចារសម្បយុត្តា
បញ្ញា សវិចារា បញ្ញា វិចារវិប្បយុត្តា បញ្ញា អវិចារា
បញ្ញា ។ បីតិសម្បយុត្តា បញ្ញា សប្បីតិកា បញ្ញា
បីតិវិប្បយុត្តា បញ្ញា អប្បីតិកា បញ្ញា ។ បីតិសម្ប-
យុត្តា បញ្ញា បីតិសហគតា បញ្ញា បីតិវិប្បយុត្តា
បញ្ញា ន បីតិសហគតា បញ្ញា ។ សុខសម្បយុត្តា
បញ្ញា សុខសហគតា បញ្ញា សុខវិប្បយុត្តា បញ្ញា
ន សុខសហគតា បញ្ញា ។ ឧបេក្ខាសម្បយុត្តា
បញ្ញា ឧបេក្ខាសហគតា បញ្ញា ឧបេក្ខាវិប្បយុត្តា
បញ្ញា ន ឧបេក្ខាសហគតា បញ្ញា ។ កាមាវចរ-
កុសលាព្យាកតេ បញ្ញា កាមាវចរា បញ្ញា រូបាវចរា
បញ្ញា អរូបាវចរា បញ្ញា អបរិយាបន្នា បញ្ញា ន
កាមាវចរា បញ្ញា ។ រូបាវចរកុសលាព្យាកតេ
បញ្ញា រូបាវចរា បញ្ញា កាមាវចរា បញ្ញា អរូបាវចរា
បញ្ញា អបរិយាបន្នា បញ្ញា ន រូបាវចរា បញ្ញា ។

## ញាណវិភង្គ ទុកនិទ្ទេស

បញ្ញា សម្បយុត្តដោយវិតក្កៈ ឈ្មោះថា បញ្ញាប្រកបដោយវិតក្កៈ បញ្ញាប្រាសចាកវិតក្កៈ ឈ្មោះថា បញ្ញា មិនមានវិតក្កៈ ។ បញ្ញាសម្បយុត្តដោយវិចារៈ ឈ្មោះថា បញ្ញា ប្រកបដោយវិចារៈ បញ្ញា ប្រាសចាកវិចារៈ ឈ្មោះថា បញ្ញា មិនមានវិចារៈ ។ បញ្ញា សម្បយុត្តដោយបីតិ ឈ្មោះថា បញ្ញា ប្រកបដោយបីតិ បញ្ញា ប្រាសចាកបីតិ ឈ្មោះថា បញ្ញា មិនមានបីតិ ។ បញ្ញាសម្បយុត្តដោយបីតិ ឈ្មោះថា បញ្ញា កើតព្រមដោយបីតិ បញ្ញាប្រាសចាកបីតិ ឈ្មោះថា បញ្ញា មិនកើតព្រមដោយបីតិ ។ បញ្ញា សម្បយុត្តដោយសុខ ឈ្មោះថា បញ្ញា កើតព្រមដោយសុខ បញ្ញា ប្រាសចាកសុខ ឈ្មោះថា បញ្ញា មិនកើតព្រមដោយសុខ ។ បញ្ញា សម្បយុត្តដោយឧបេក្ខា ឈ្មោះថា បញ្ញា កើតព្រមដោយឧបេក្ខា បញ្ញា ប្រាសចាកឧបេក្ខា ឈ្មោះថា បញ្ញា មិនកើតព្រមដោយឧបេក្ខា ។ បញ្ញា ក្នុងកាមាវចរកុសលនិងអព្យាក្រឹត ឈ្មោះថា បញ្ញា ជាកាមាវចរ ឯបញ្ញា ជារូបាវចរ បញ្ញា ជាអរូបាវចរ បញ្ញាជាអបរិយាបន្នៈ មិនឈ្មោះថា បញ្ញា ជាកាមាវចរទេ ។ បញ្ញា ក្នុងរូបាវចរកុសលនិងអព្យាក្រឹត ឈ្មោះថា បញ្ញាជារូបាវចរ ឯបញ្ញាជាកាមាវចរ បញ្ញាជាអរូបាវចរ បញ្ញាជាអបរិយាបន្នៈ មិនឈ្មោះថា បញ្ញាជារូបាវចរទេ ។

អរូបាវចរកុសលាព្យាកតេ បញ្ញា អរូបាវចរា បញ្ញា
កាមាវចរា បញ្ញា រូបាវចរា បញ្ញា អបរិយាបន្នា
បញ្ញា ន អរូបាវចរា បញ្ញា ។ តីសុ ភូមីសុ
កុសលាព្យាកតេ បញ្ញា បរិយាបន្នា បញ្ញា ចតូសុ
មគ្គេសុ ចតូសុ ផលេសុ បញ្ញា អបរិយាបន្នា
បញ្ញា ។ ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា
និយ្យានិកា បញ្ញា តីសុ ភូមីសុ កុសលេ ចតូសុ
ភូមីសុ វិបាកេ តីសុ ភូមីសុ កិរិយាព្យាកតេ បញ្ញា
អនិយ្យានិកា បញ្ញា ។ ចតូសុ មគ្គេសុ បញ្ញា និយតា
បញ្ញា តីសុ ភូមីសុ កុសលេ ចតូសុ ភូមីសុ វិបាកេ
តីសុ ភូមីសុ កិរិយាព្យាកតេ បញ្ញា អនិយតា
បញ្ញា ។ តីសុ ភូមីសុ កុសលាព្យាកតេ បញ្ញា
សឧត្តរា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ
បញ្ញា អនុត្តរា បញ្ញា ។ តត្ថ កតមា អត្ថជាបិកា
បញ្ញា ។ ចតូសុ ភូមីសុ កុសលេ អរហតោ

បញ្ញា ក្នុងអរូបាវចរកុសលនិងអព្យាក្រឹត ឈ្មោះថា បញ្ញា ជាអរូបាវចរ ឯបញ្ញា ជាកាមាវចរ បញ្ញា ជារូបាវចរ បញ្ញា ជាអបរិយាបន្នៈ មិនឈ្មោះថា បញ្ញា ជាអរូបាវចរទេ ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ជាបរិយាបន្នៈ បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា ជាអបរិយាបន្នៈ ។ បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា ជានិយ្យានិកៈ បញ្ញា ក្នុងកុសល ប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងវិបាកប្រព្រឹត្តទៅ ក្នុងភូមិ ៤ ក្នុងកិរិយានិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ជាអនិយ្យានិកៈ ។ បញ្ញាក្នុងមគ្គ ៤ ឈ្មោះថា បញ្ញា ទៀង បញ្ញាក្នុងកុសល ប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងវិបាកប្រព្រឹត្តក្នុងភូមិ ៤ ក្នុងកិរិយាអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា មិនទៀង ។ បញ្ញា ក្នុងកុសលនិងអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា បញ្ញា ប្រកបដោយឧត្តរៈ បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញា ជាអនុត្តរៈ ។ បណ្ដាបញ្ញាទាំងនោះ បញ្ញា ញុំាងប្រយោជន៍ឲ្យកើត តើដូចម្ដេច ។ បញ្ញា ជាកិរិយាអព្យាក្រឹត ក្នុងកុសលប្រព្រឹត្តទៅក្នុងភូមិ ៤ របស់ព្រះអរហន្ត

## ញាណវិភង្គេ ទុកនិទ្ទេសោ

អភិញ្ញំ ឧប្បាទេន្តស្ស សមាបត្តឹ ឧប្បាទេន្តស្ស កិរិយាព្យាកតា[១] បញ្ញា អត្ថជាបិកា បញ្ញា ចតូសុ ភូមីសុ វិបាកេ អរហតោ ឧប្បន្នាយ អភិញ្ញាយ ឧប្បន្នាយ សមាបត្តិយា កិរិយាព្យាកតា[២] បញ្ញា ជាបិតត្ថា បញ្ញា ។

ឯវំ ទុវិធេន ញាណវត្ថុ ។

(៣៨) តត្ថ កតមា ចិន្តាមយា បញ្ញា ។ យោគវិហិតេសុ វា កម្មាយតនេសុ យោគវិហិតេសុ វា សិប្បាយតនេសុ យោគវិហិតេសុ វា វិជ្ជដ្ឋានេសុ កម្មស្សកតំ វា សច្ចានុលោមិកំ វា រូបំ អនិច្ចន្តិ វា វេទនា អនិច្ចាតិ វា សញ្ញា អនិច្ចាតិ វា សង្ខារា អនិច្ចាតិ វា វិញ្ញាណំ អនិច្ចន្តិ វា យំ ឯវរូបឹ អនុលោមិកំ ខន្តឹ ទិដ្ឋឹ រុចឹ មុតឹ បេក្ខំ ធម្មនិជ្ឈានក្ខន្តឹ បរតោ អស្សុត្វា បដិលភតិ អយំ វុច្ចតិ ចិន្តាមយា បញ្ញា ។

---

១ ឱ. ម. កិរិយាព្យាកតេ ។ ២ ឱ. ម. កិរិយាព្យាកតេ ។

កាលញុំាងអភិញ្ញាឲ្យកើតឡើង កាលញុំាងសមាបត្តិឲ្យកើតឡើង ឈ្មោះថា បញ្ញាញុំាងប្រយោជន៍ឲ្យកើត បញ្ញាជាកិរិយាអព្យាក្រឹត ក្នុងអភិញ្ញាដែលកើតហើយ ក្នុងសមាបត្តិដែលកើតហើយ របស់ព្រះអរហន្ត ក្នុងវិបាកប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា បញ្ញាមានប្រយោជន៍កើតហើយ ។

ញាណវត្ថុ មានប្រការ ២ យ៉ាងនេះឯង ។

( ៣៨ ) បណ្តាបញ្ញាទាំងនោះ ចិន្តាមយបញ្ញា តើដូចម្តេច ។ បុគ្គលមិនបានស្តាប់ ( នូវពាក្យពន្យល់ ) អំពីសំណាក់បុគ្គលដទៃទេ តែបាន នូវសេចក្តីគាប់ចិត្ត នូវសេចក្តីយល់ឃើញ នូវសេចក្តីពេញចិត្ត នូវការឈ្វេងយល់ នូវសេចក្តីពិនិត្យឃើញ នូវការចូលចិត្តក្នុងការសំឡឹងមើលនូវធម៌ ដ៏សមគួរ ណា យ៉ាងនេះ ក្នុងការងារប្រកបដោយឧបាយបញ្ញាក្តី ក្នុងសិល្បសាស្ត្រ ប្រកបដោយឧបាយបញ្ញាក្តី ក្នុងវិជ្ជាស្ថាន ប្រកបដោយឧបាយបញ្ញាក្តី ថា សត្វមានកម្ម ជារបស់ខ្លួនក្តី ថា សត្វប្រព្រឹត្តទៅតាមមគ្គសច្ចក្តី ថា រូបមិនទៀងក្តី ថា វេទនាមិនទៀងក្តី ថា សញ្ញាមិនទៀងក្តី ថា សង្ខារទាំងឡាយមិនទៀងក្តី ថា វិញ្ញាណមិនទៀងក្តី នេះហៅថា ចិន្តាមយបញ្ញា ។

តត្ថ កតមា សុតមយា បញ្ញា ។ យោគវិហិតេសុ
វា កម្មាយតនេសុ យោគវិហិតេសុ វា សិប្បាយត-
នេសុ យោគវិហិតេសុ វា វិជ្ជាដ្ឋានេសុ កម្មស្សកតំ
វា សច្ចានុលោមិកំ វា រូបំ អនិច្ចន្តិ វា វេទនា
អនិច្ចាតិ វា សញ្ញា អនិច្ចាតិ វា សង្ខារា អនិច្ចាតិ
វា វិញ្ញាណំ អនិច្ចន្តិ វា យំ ឯវរូបឹ អនុលោមិកំ
ខន្តឹ ទិដ្ឋឹ រុចឹ មុតឹ បេក្ខំ ធម្មនិជ្ឈានក្ខន្តឹ បរតោ
សុត្វា បដិលភតិ អយំ វុច្ចតិ សុតមយា បញ្ញា ។
សព្វាបិ សមាបន្នស្ស បញ្ញា ភាវនាមយា បញ្ញា ។

(៣៩) តត្ថ កតមា ទានមយា បញ្ញា ។
ទានំ អារព្ភ ទានាធិគច្ឆ យា ឧប្បជ្ជតិ បញ្ញា
បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មា-
ទិដ្ឋិ អយំ វុច្ចតិ ទានមយា បញ្ញា ។ តត្ថ កតមា
សីលមយា បញ្ញា ។ សីលំ អារព្ភ សីលាធិគច្ឆ
យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ

បណ្ដាបញ្ញាទាំងនោះ សុតមយបញ្ញា តើដូចម្ដេច ។ បុគ្គលបានស្ដាប់ (នូវពាក្យពន្យល់) អំពីសំណាក់នៃបុគ្គលដទៃ ហើយបាន នូវសេចក្ដីគាប់ចិត្ត នូវសេចក្ដីយល់ឃើញ នូវសេចក្ដីពេញចិត្ត នូវការឈ្វេងយល នូវសេចក្ដីពិនិត្យឃើញ នូវការចូលចិត្តក្នុងការសម្លឹងមើលនូវធម៌ដ៏សមគួរ យ៉ាងនេះ ក្នុងការងារប្រកបដោយឧបាយប្រាជ្ញាក្ដី ក្នុងសិល្ប-សាស្ត្រប្រកបដោយឧបាយប្រាជ្ញាក្ដី ក្នុងវិជ្ជាស្ថានប្រកបដោយឧបាយប្រាជ្ញាក្ដី ថា សត្វមានកម្មជារបស់ខ្លួនក្ដី ថា សត្វប្រព្រឹត្តទៅតាមមគ្គ-សច្ចក្ដី ថា រូបមិនទៀងក្ដី ថា វេទនាមិនទៀងក្ដី ថា សញ្ញា មិនទៀងក្ដី ថា សង្ខារទាំងឡាយមិនទៀងក្ដី ថា វិញ្ញាណមិនទៀងក្ដី នេះហៅថា សុតមយបញ្ញា ។ បញ្ញាទាំងអស់ របស់បុគ្គលចូលកាន់សមាបត្តិ ឈ្មោះថាភាវនាមយបញ្ញា ។

(៣៩) បណ្ដាបញ្ញាទាំងនោះ ទានមយបញ្ញា តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធទាន ព្រោះបានទាន នេះហៅថា ទានមយបញ្ញា ។ បណ្ដាបញ្ញាទាំងនោះ សីលមយបញ្ញា តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង

ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ សីលមយា បញ្ញា ។
សព្វាបិ សមាបន្នស្ស បញ្ញា ភាវនាមយា បញ្ញា ។

(៨០) តត្ថ កតមា អធិសីលេ បញ្ញា ។
បាតិមោក្ខសំវរសំវុតស្ស យា ឧប្បជ្ជតិ បញ្ញា
បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មា-
ទិដ្ឋិ អយំ វុច្ចតិ អធិសីលេ បញ្ញា ។ តត្ថ កតមា
អធិចិត្តេ បញ្ញា ។ រូបាវចរារូបាវចរសមាបត្តឹ សមា-
បន្នស្ស យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។
អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ អធិចិត្តេ
បញ្ញា ។ តត្ថ កតមា អធិបញ្ញាយ បញ្ញា ។
ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា អយំ
វុច្ចតិ អធិបញ្ញាយ បញ្ញា ។

(៨១) តត្ថ កតមំ អាយកោសល្លំ ។ ឥមេ ធម្មេ
មនសិករោតោ អនុប្បន្នា ចេវ អកុសលា ធម្មា
ន ឧប្បជ្ជន្តិ ឧប្បន្នា ច អកុសលា ធម្មា បហីយន្តិ

ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធសីល ព្រោះបានសីល នេះហៅថា សីលមយប្បញ្ញា ។ បញ្ញា ទាំងអស់ របស់បុគ្គល ដែលចូលកាន់សមាបត្តិ ឈ្មោះថាភាវនាមយប្បញ្ញា ។

(៤០) បណ្ដាបញ្ញាទាំងនោះ បញ្ញា ក្នុងអធិសីល តើដូចម្ដេច ។ កាលដែលបុគ្គលសង្រួមក្នុងបាតិមោក្ខសំវរៈ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង នេះ ហៅថា បញ្ញា ក្នុងអធិសីល ។ បណ្ដាបញ្ញាទាំងនោះ បញ្ញា ក្នុង អធិចិត្ត តើដូចម្ដេច ។ កាលបុគ្គលចូលកាន់រូបាវចរសមាបត្តិ និង អរូបាវចរសមាបត្តិ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការ ពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង នេះហៅថា បញ្ញា ក្នុង អធិចិត្ត ។ បណ្ដាបញ្ញាទាំងនោះ បញ្ញា ក្នុងអធិប្បញ្ញា តើដូចម្ដេច ។ បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ នេះហៅថា បញ្ញា ក្នុងអធិប្បញ្ញា ។

(៤១) បណ្ដាបញ្ញាទាំងនោះ សេចក្ដីឈ្លាសក្នុងការចំរើន តើដូច ម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា ក្នុងធម៌ទាំងឡាយនោះថា កាលបុគ្គលធ្វើទុកក្នុង ចិត្ត នូវធម៌ពួកនេះ ធម៌ទាំងឡាយជាអកុសលដែលមិនទាន់កើត ក៏មិន កើតឡើង ទាំងពួកធម៌ជាអកុសលដែលកើតហើយ ក៏សាបសូន្យទៅវិញ

ឥមេ វា បនិមេ ធម្មេ មនសិការោតោ អនុប្បន្នា ចេវ កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច កុសលា ធម្មា ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តន្តិ យា តត្ថ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ អាយកោសល្លំ ។ តត្ថ កតមំ អបាយកោសល្លំ ។ ឥមេ ធម្មេ មនសិការោតោ អនុប្បន្នា ចេវ កុសលា ធម្មា ន ឧប្បជ្ជន្តិ ឧប្បន្នា ច កុសលា ធម្មា និរុជ្ឈន្តិ ឥមេ វា បនិមេ ធម្មេ មនសិការោតោ អនុប្បន្នា ចេវ អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច អកុសលា ធម្មា ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ យា តត្ថ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ អបាយកោសល្លំ ។ សព្វាបិ តត្រុបាយា បញ្ញា ឧបាយកោសល្លំ ។

ពុំនោះសោត កាលបុគ្គលធ្វើទុកក្នុងចិត្តនូវធម៌ពួកនេះ ៗ ធម៌ទាំងឡាយជាកុសល ដែលមិនទាន់កើត ក៏កើតឡើង ទាំងពួកធម៌ជាកុសលដែលកើតហើយ ក៏ប្រព្រឹត្តទៅ ដើម្បីភាពដ៏ក្រៃលែង ដើម្បីធំទូលាយ ដើម្បីសេចក្តីចំរើន ដើម្បីពេញលេញ នេះហៅថា សេចក្តីឈ្លាសក្នុងការចំរើន ។ បណ្តាបញ្ញាទាំងនោះ សេចក្តីឈ្លាសក្នុងការមិនចំរើន តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា ក្នុងធម៌ទាំងឡាយនោះ ថា កាលបុគ្គលធ្វើទុកក្នុងចិត្តនូវធម៌ពួកនេះ ធម៌ទាំងឡាយជាកុសល ដែលមិនទាន់កើត ក៏មិនកើតឡើង ទាំងពួកធម៌ជាកុសលដែលកើតហើយ ក៏រលត់ទៅវិញ ពុំនោះសោត កាលបុគ្គលធ្វើទុកក្នុងចិត្តនូវធម៌ពួកនេះ ៗ ធម៌ទាំងឡាយជាអកុសល ដែលមិនទាន់កើត ក៏កើតឡើង ទាំងពួកធម៌ជាអកុសល ដែលកើតហើយ ក៏ប្រព្រឹត្តទៅ ដើម្បីភាពដ៏ក្រៃលែង ដើម្បីធំទូលាយ នេះហៅថា សេចក្តីឈ្លាស ក្នុងការមិនចំរើន ។ បញ្ញាទាំងអស់ ជាឧបាយក្នុងធម៌ទាំងនោះ ឈ្មោះថា សេចក្តីឈ្លាសក្នុងឧបាយ ។

## ញាណវិភង្គ តិកនិទ្ទេសោ

( ៤២ ) ចតូសុ ភូមីសុ វិបាកេ បញ្ញា វិបាកា បញ្ញា ចតូសុ ភូមីសុ កុសលេ បញ្ញា វិបាកធម្មធម្មា បញ្ញា តីសុ ភូមីសុ កិរិយាព្យាកតេ បញ្ញា នេវវិបាកនវិបាកធម្មធម្មា បញ្ញា ។

( ៤៣ ) តីសុ ភូមីសុ វិបាកេ បញ្ញា ឧបាទិន្នុបាទានិយា បញ្ញា តីសុ ភូមីសុ កុសលេ តីសុ ភូមីសុ កិរិយាព្យាកតេ បញ្ញា អនុបាទិន្នុបាទានិយា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា អនុបាទិន្នានុបាទានិយា បញ្ញា ។

( ៤៤ ) វិតក្កវិចារសម្បយុត្តា បញ្ញា សវិតក្កសវិចារា បញ្ញា វិតក្កវិប្បយុត្តា វិចារសម្បយុត្តា បញ្ញា អវិតក្កវិចារមត្តា បញ្ញា វិតក្កវិចារវិប្បយុត្តា បញ្ញា អវិតក្កាវិចារា បញ្ញា ។

## ញាណវិភង្គ តិកនិទ្ទេស

(៤២) បញ្ញា ក្នុងវិបាក ប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថាបញ្ញាជាវិបាក បញ្ញា ក្នុងកុសលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថាបញ្ញាមានវិបាកធម៌ជាប្រក្រតី បញ្ញា ក្នុងកិរិយាអព្យាក្រឹតប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថាបញ្ញាមិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ។

(៤៣) បញ្ញា ក្នុងវិបាកប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថាបញ្ញាដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន បញ្ញា ក្នុងកុសលប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងកិរិយាអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថាបញ្ញាដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថាបញ្ញាដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ។

(៤៤) បញ្ញា សម្បយុត្តដោយវិតក្កៈ និងវិចារៈ ឈ្មោះថាបញ្ញាប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈ បញ្ញា ប្រាសចាកវិតក្កៈ តែសម្បយុត្តដោយវិចារៈ ឈ្មោះថាបញ្ញា មិនមានវិតក្កៈ មានត្រឹមតែវិចារៈ បញ្ញា ប្រាសចាកវិតក្កៈ និងវិចារៈ ឈ្មោះថាបញ្ញាមិនមានវិតក្កៈ ទាំងមិនមានវិចារៈ ។

## អភិធម្មបិដកេ វិភង្គោ

(៤៥) បីតិសម្បយុត្តា បញ្ញា បីតិសហគតា បញ្ញា សុខសម្បយុត្តា បញ្ញា សុខសហគតា បញ្ញា ឧបេក្ខាសម្បយុត្តា បញ្ញា ឧបេក្ខាសហគតា បញ្ញា ។

(៤៦) តីសុ ភូមីសុ កុសលេ បញ្ញា អាចយគាមិនី បញ្ញា ចតូសុ មគ្គេសុ បញ្ញា អបចយគាមិនី បញ្ញា ចតូសុ ភូមីសុ វិបាកេ តីសុ ភូមីសុ កិរិយាព្យាកតេ បញ្ញា នេវាចយគាមិនី នាបចយគាមិនី បញ្ញា ។

(៤៧) ចតូសុ មគ្គេសុ តីសុ ផលេសុ បញ្ញា សេក្ខា បញ្ញា ឧបរិដ្ឋិមេ អរហត្តផលេ បញ្ញា អសេក្ខា បញ្ញា តីសុ ភូមីសុ កុសលេ តីសុ ភូមីសុ វិបាកេ តីសុ ភូមីសុ កិរិយាព្យាកតេ បញ្ញា នេវ សេក្ខា នាសេក្ខា បញ្ញា ។

(៤៨) កាមាវចរកុសលាព្យាកតេ បញ្ញា បរិត្តា បញ្ញា រូបាវចរារូបាវចរកុសលាព្យាកតេ បញ្ញា មហគ្គតា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា អប្បមាណា បញ្ញា ។

(៦៥) បញ្ញា សម្បយុត្តដោយបីតិ ឈ្មោះថា បញ្ញា កើតព្រមដោយបីតិ បញ្ញា សម្បយុត្តដោយសុខ ឈ្មោះថាបញ្ញា កើតព្រមដោយសុខ បញ្ញាសម្បយុត្តដោយឧបេក្ខា ឈ្មោះថាបញ្ញា កើតព្រមដោយឧបេក្ខា ។

(៦៦) បញ្ញា ក្នុងកុសលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថាបញ្ញា ដល់នូវការសន្សំ (កម្មកិលេស) បញ្ញា ក្នុងមគ្គ ៤ ឈ្មោះថាបញ្ញា ដល់នូវការមិនសន្សំ បញ្ញា ក្នុងវិបាកប្រព្រឹត្តទៅក្នុងភូមិ ៤ និងក្នុងកិរិយាអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថាបញ្ញា មិនដល់នូវការសន្សំ ទាំងមិនដល់នូវការមិនសន្សំ ។

(៦៧) បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៣ ឈ្មោះថាបញ្ញា ជារបស់សេក្ខបុគ្គល បញ្ញា ក្នុងអរហត្តផលជាន់លើ ឈ្មោះថាបញ្ញា ជារបស់អសេក្ខបុគ្គល បញ្ញា ក្នុងកុសលប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងវិបាកប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងកិរិយាអព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថាបញ្ញា មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ។

(៦៨) បញ្ញា ក្នុងកាមាវចរកុសលនិងអព្យាក្រឹត ឈ្មោះថាបញ្ញា តូចឆ្មារ បញ្ញា ក្នុងរូបាវចរកុសល អរូបាវចរកុសល និងអព្យាក្រឹត ឈ្មោះថាបញ្ញា មានសភាពធំ បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថាបញ្ញា មានប្រមាណមិនបាន ។

## ញាណវិភង្គ តិកនិទ្ទេសោ

( ៨៩ ) តត្ថ កតមា បរិត្តារម្មណា បញ្ញា ។ បរិត្តេ ធម្មេ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ បរិត្តារម្មណា បញ្ញា ។ តត្ថ កតមា មហគ្គតារម្មណា បញ្ញា ។ មហគ្គតេ ធម្មេ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ មហគ្គតារម្មណា បញ្ញា ។ តត្ថ កតមា អប្បមាណារម្មណា បញ្ញា ។ អប្បមាណេ ធម្មេ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ អប្បមាណារម្មណា បញ្ញា ។

( ៩០ ) តត្ថ កតមា មគ្គារម្មណា បញ្ញា ។ អរិយមគ្គំ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ មគ្គារម្មណា បញ្ញា ។ ចតូសុ មគ្គេសុ បញ្ញា

## ញាណវិភង្គ តិកនិទ្ទេស

(៤៩) បណ្ដាបញ្ញាទាំងនោះ បញ្ញា មានអារម្មណ៍តូចឆ្មារ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធធម៌ទាំង-ឡាយតូចឆ្មារ នេះហៅថា បញ្ញា មានអារម្មណ៍តូចឆ្មារ ។ បណ្ដាបញ្ញា ទាំងនោះ បញ្ញា មានអារម្មណ៍ដល់នូវសភាពធំ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធធម៌ទាំងឡាយដល់នូវស-ភាពធំ នេះហៅថា បញ្ញា មានអារម្មណ៍ដល់នូវសភាពធំ ។ បណ្ដាបញ្ញា ទាំងនោះ បញ្ញា មានអារម្មណ៍ប្រមាណមិនបាន តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធធម៌មានប្រមាណមិនបាន នេះហៅថា បញ្ញា មានអារម្មណ៍ប្រមាណមិនបាន ។

(៥០) បណ្ដាបញ្ញាទាំងនោះ បញ្ញាមានមគ្គជាអារម្មណ៍ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ សេចក្ដីមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធអរិយមគ្គ នេះហៅថា បញ្ញាមានមគ្គជាអារម្មណ៍ ។ បញ្ញាក្នុងមគ្គ ៤

មគ្គហេតុកា បញ្ញា ។ តត្ថ កតមា មគ្គាធិបតិនី បញ្ញា ។ អរិយមគ្គំ អធិបតឹ ករិត្វា យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ មគ្គាធិបតិនី បញ្ញា ។

(៨១) ចតូសុ ភូមីសុ វិបាកេ បញ្ញា សិយា ឧប្បន្នា សិយា ឧប្បាទិនី ន វត្តព្វា អនុប្បន្នាតិ ចតូសុ ភូមីសុ កុសលេ តីសុ ភូមីសុ កិរិយា-ព្យាកតេ បញ្ញា សិយា ឧប្បន្នា សិយា អនុប្បន្នា ន វត្តព្វា ឧប្បាទិនីតិ ។

(៨២) សព្វា បញ្ញា សិយា អតីតា សិយា អនាគតា សិយា បច្ចុប្បន្នា ។

(៨៣) តត្ថ កតមា អតីតារម្មណា បញ្ញា ។ អតីតេ ធម្មេ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ អតីតារម្មណា បញ្ញា ។ តត្ថ កតមា អនាគតារម្មណា បញ្ញា ។ អនាគតេ ធម្មេ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។

ឈ្មោះថាបញ្ញា មានមគ្គជាហេតុ ។ បណ្ដាបញ្ញាទាំងនោះ បញ្ញា មានមគ្គជាអធិបតី តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើងព្រោះធ្វើអរិយមគ្គឲ្យជាអធិបតី នេះហៅថា បញ្ញា មានមគ្គជាអធិបតី ។

( ៩១ ) បញ្ញា ក្នុងវិបាកប្រព្រឹត្តទៅក្នុងភូមិ ៤ កើតឡើងហើយ ក៏មាន បម្រុងនឹងកើតឡើង តែមិនគួរពោលថា មិនទាន់កើតឡើង ក៏មាន បញ្ញា ក្នុងកុសលប្រព្រឹត្តទៅក្នុងភូមិ ៤ និងក្នុងកិរិយាអព្យាក្រឹតប្រព្រឹត្តទៅក្នុងភូមិ ៣ កើតឡើងហើយ ក៏មាន មិនទាន់កើតឡើង តែមិនគួរពោលថា បម្រុងនឹងកើតឡើង ក៏មាន ។

( ៩២ ) បញ្ញាទាំងអស់ ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ។

( ៩៣ ) បណ្ដាបញ្ញាទាំងនោះ បញ្ញា មានអារម្មណ៍ជាអតីត តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើងព្រោះប្រារព្ធធម៌ទាំងឡាយជាអតីត នេះហៅថា បញ្ញា មានអារម្មណ៍ជាអតីត ។ បណ្ដាបញ្ញាទាំងនោះ បញ្ញា មានអារម្មណ៍ជាអនាគត តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។

ញាណវិភង្គេ តិកនិទ្ទេសោ

អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ អនាគតារម្មណា បញ្ញា ។ តត្ថ កតមា បច្ចុប្បន្នារម្មណា បញ្ញា ។ បច្ចុប្បន្នេ ធម្មេ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ បច្ចុប្បន្នារម្មណា បញ្ញា ។

(៩៨) សព្វាវ បញ្ញា សិយា អជ្ឈត្តា សិយា ពហិទ្ធា សិយា អជ្ឈត្តពហិទ្ធា ។

(៩៩) តត្ថ កតមា អជ្ឈត្តារម្មណា បញ្ញា ។ អជ្ឈត្តេ ធម្មេ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ អជ្ឈត្តារម្មណា បញ្ញា ។ តត្ថ កតមា ពហិទ្ធារម្មណា បញ្ញា ។ ពហិទ្ធា ធម្មេ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ ពហិទ្ធារម្មណា បញ្ញា ។ តត្ថ កតមា អជ្ឈត្តពហិទ្ធារម្មណា បញ្ញា ។ អជ្ឈត្តពហិទ្ធា ធម្មេ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។

ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធនូវធម៌ទាំងឡាយជាអនាគត នេះហៅថា បញ្ញាមានអារម្មណ៍ជាអនាគត ។ បណ្ដាបញ្ញាទាំងនោះ បញ្ញា មានអារម្មណ៍ជាបច្ចុប្បន្ន តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធនូវធម៌ទាំងឡាយជាបច្ចុប្បន្ន នេះហៅថា បញ្ញា មានអារម្មណ៍ជាបច្ចុប្បន្ន ។

(៩៨) បញ្ញាទាំងអស់ ជាខាងក្នុង ក៏មាន ជាខាងក្រៅ ក៏មាន ជាខាងក្នុងនិងខាងក្រៅ ក៏មាន ។

(៩៩) បណ្ដាបញ្ញាទាំងនោះ បញ្ញាមានអារម្មណ៍ខាងក្នុង តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធនូវធម៌ទាំងឡាយជាខាងក្នុង នេះហៅថា បញ្ញា មានអារម្មណ៍ខាងក្នុង ។ បណ្ដាបញ្ញាទាំងនោះ បញ្ញាមានអារម្មណ៍ខាងក្រៅ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង កាពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធនូវធម៌ទាំងឡាយជាខាងក្រៅ នេះហៅថា បញ្ញា មានអារម្មណ៍ខាងក្រៅ ។ បណ្ដាបញ្ញាទាំងនោះ បញ្ញា មានអារម្មណ៍ខាងក្នុងនិងខាងក្រៅ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។

អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ អជ្ឈត្តពហិទ្ធារម្មណា បញ្ញា ។

ឯវំ តិវិធេន ញាណវត្ថុ ។

(៨៦) តត្ថ កតមំ កម្មស្សកតំ ញាណំ ។ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ សុកដទុក្កដានំ កម្មានំ ផលវិបាកោ អត្ថិ អយំ លោកោ អត្ថិ បរោ លោកោ អត្ថិ មាតា អត្ថិ បិតា អត្ថិ សត្តា ឱបបាតិកា អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ យា ឯវរូបា បញ្ញា បជានា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ កម្មស្សកតំ ញាណំ ឋបេត្វា សច្ចានុលោមិកំ ញាណំ សព្វាបិ សាសវា កុសលា បញ្ញា កម្មស្សកតំ ញាណំ ។

ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធនូវធម៌ទាំងឡាយ ជាខាងក្នុងនិងខាងក្រៅ នេះហៅថា បញ្ញា មានអារម្មណ៍ខាងក្នុងនិងខាងក្រៅ ។

ញាណវត្ថុ មានប្រការ ៣ យ៉ាងនេះឯង ។

(៨៦) បណ្ដាញាណទាំងនោះ កម្មស្សកតញ្ញាណ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា មានសភាពយ៉ាងនេះ ថា ទានដែលបុគ្គលឲ្យហើយមានផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាករបស់កម្មទាំងឡាយ ដែលបុគ្គលធ្វើល្អធ្វើអាក្រក់មាន លោកនេះមាន លោកខាងមុខមាន ការប្រព្រឹត្តិខុសឬត្រូវក្នុងមាតាមានផល (បាបបុណ្យ) ការប្រព្រឹត្តិខុសឬត្រូវក្នុងបិតាមានផល (បាបបុណ្យ) ពួកសត្វជាឧបបាតិកៈកំណើតមាន ពួកសមណព្រាហ្មណ៍ ក្នុងលោក ដែលប្រព្រឹត្តត្រឹមត្រូវ ប្រតិបត្តិប្រពៃ ធ្វើឲ្យជាក់ច្បាស់ នូវលោកនេះនិងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួន ហើយប្រកាស ក៏មាន នេះហៅថា កម្មស្សកតញ្ញាណ សូម្បីបញ្ញាជាកុសល ដែលប្រកបដោយអាសវៈទាំងអស់ វៀរលែងតែសច្ចានុលោមិកញ្ញាណចេញ ក៏ឈ្មោះថា កម្មស្សកតញ្ញាណដែរ ។

ញាណវិភង្គេ ចតុក្កនិទ្ទេសោ

តត្ថ កតមំ សច្ចានុលោមិកំ ញាណំ ។ រូបំ អនិច្ចន្តិ វា វេទនា អនិច្ចាតិ វា សញ្ញា អនិច្ចាតិ វា សង្ខារា អនិច្ចាតិ វា វិញ្ញាណំ អនិច្ចន្តិ វា យា ឯវរូបី អនុលោមិកា ខន្តិ ទិដ្ឋិ រុចិ មុតិ បេក្ខា ធម្មនិជ្ឈានក្ខន្តិ ឥទំ វុច្ចតិ សច្ចានុលោមិកំ ញាណំ ។ ចតូសុ មគ្គេសុ បញ្ញា មគ្គសមង្គិស្ស ញាណំ ។ ចតូសុ ផលេសុ បញ្ញា ផលសមង្គិស្ស ញាណំ ។

( ៨៧ ) មគ្គសមង្គិស្ស ញាណំ ទុក្ខេបេតំ ញាណំ ទុក្ខសមុទយេបេតំ ញាណំ ទុក្ខនិរោធេបេតំ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយបេតំ ញាណំ ។ តត្ថ កតមំ ទុក្ខេ ញាណំ ។ ទុក្ខំ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ ទុក្ខេ ញាណំ ។ ទុក្ខសមុទយំ អារព្ភ ។បេ។

## ញាណវិភង្គ ចតុក្កនិទ្ទេស

បណ្ដាញាណទាំងនោះ សច្ចានុលោមិកញ្ញាណ តើដូចម្ដេច ។ សេចក្ដីចូលចិត្ត សេចក្ដីយល់ឃើញ សេចក្ដីពេញចិត្ត ការឈ្វេងយល់ ការពិនិត្យឃើញ សេចក្ដីចូលចិត្តក្នុងការសំឡឹងមើលនូវធម៌ ដ៏សមគួរ ណា មានសភាពយ៉ាងនេះ ថា រូបមិនទៀងក្ដី ថា វេទនាមិនទៀងក្ដី ថា សញ្ញាមិនទៀងក្ដី ថា សង្ខារទាំងឡាយមិនទៀងក្ដី ថា វិញ្ញាណមិនទៀងក្ដី នេះហៅថា សច្ចានុលោមិកញ្ញាណ ។ បញ្ញា ក្នុងមគ្គ ៤ ឈ្មោះថា ញាណរបស់បុគ្គលអ្នកព្រមព្រៀងដោយមគ្គ ។ បញ្ញា ក្នុងផល ៤ ឈ្មោះថា ញាណរបស់បុគ្គលអ្នកព្រមព្រៀងដោយផល ។

(៨៧) ញាណរបស់បុគ្គលអ្នកព្រមព្រៀងដោយមគ្គ ឈ្មោះថា សេចក្ដីដឹងក្នុងកងទុក្ខ ឈ្មោះថា សេចក្ដីដឹងក្នុងហេតុនាំឲ្យកើតកងទុក្ខ ឈ្មោះថា សេចក្ដីដឹងក្នុងធម៌ជាទីរលត់នៃកងទុក្ខ ឈ្មោះថា សេចក្ដីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ បណ្ដាញាណទាំងនោះ សេចក្ដីដឹងក្នុងកងទុក្ខ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង ព្រោះប្រារព្ធនូវទុក្ខ នេះហៅថា សេចក្ដីដឹងក្នុងកងទុក្ខ ។ ព្រោះប្រារព្ធនូវហេតុនាំឲ្យកើតកងទុក្ខ ។ បេ ។

ទុក្ខនិរោធំ អារព្ភ ។ បេ ។ ទុក្ខនិរោធគាមិនឹ បដិបទំ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជានានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ ។

(៩៨) កាមាវចរកុសលាព្យាកតេ បញ្ញា កាមាវចរា បញ្ញា រូបាវចរកុសលាព្យាកតេ បញ្ញា រូបាវចរា បញ្ញា អរូបាវចរកុសលាព្យាកតេ បញ្ញា អរូបាវចរា បញ្ញា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា អបរិយាបន្នា បញ្ញា ។

(៩៩) តត្ថ កតមំ ធម្មេ ញាណំ ។ ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា ធម្មេ ញាណំ ។ សោ ឥមិនា ធម្មេន ញាណេន ទិដ្ឋេន បត្តេន វិទិតេន បរិយោគាឡ្ហេន អតីតានាគតេន នយំ នេតិ យេ ហិ កេចិ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា ទុក្ខំ អព្ភញ្ញឹសុ ទុក្ខសមុទយំ អព្ភញ្ញឹសុ ទុក្ខនិរោធំ អព្ភញ្ញឹសុ ទុក្ខនិរោធគាមិនឹ បដិបទំ

ព្រោះប្រារព្ធ នូវធម៌ជាទីរលត់នៃកងទុក្ខ ។ បេ ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណាកើតឡើង ព្រោះប្រារព្ធ នូវបដិបទា ជាដំណើរទៅកាន់ទីរលត់កងទុក្ខ នេះហៅថា សេចក្ដីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

(៧៨) បញ្ញា ក្នុងកាមាវចរកុសលនិងអព្យាក្រឹត ឈ្មោះថា បញ្ញាជាកាមាវចរ បញ្ញា ក្នុងរូបាវចរកុសលនិងអព្យាក្រឹត ឈ្មោះថា បញ្ញាជារូបាវចរ បញ្ញា ក្នុងអរូបាវចរកុសលនិងអព្យាក្រឹត ឈ្មោះថា បញ្ញាជាអរូបាវចរ បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា បញ្ញាជាអបរិយាបន្នៈ ។

(៥៩) បណ្ដាញាណទាំងនោះ សេចក្ដីដឹងក្នុងធម៌ តើដូចម្ដេច ។ បញ្ញា ក្នុងមគ្គ ៤ ក្នុងផល ៤ ឈ្មោះថា សេចក្ដីដឹងក្នុងធម៌ ។ អ្នកផងតែងណែនាំនូវសេចក្ដីពន្យល់ ក្នុងកាលជាអតីតនិងកាលជាអនាគត តាមធម៌នេះ ដែលខ្លួនបានដឹង បានឃើញ បានសម្រេច បានដឹងច្បាស់ បានជឿជាក់ហើយ មែនពិត បុគ្គលណាមួយ ទោះជាសមណៈក្ដី ព្រាហ្មណ៍ក្ដី ក្នុងកាលជាអតីត បានដឹងច្បាស់នូវទុក្ខ បានដឹងច្បាស់នូវទុក្ខសមុទ័យ បានដឹងច្បាស់នូវទុក្ខនិរោធ បានដឹងច្បាស់នូវទុក្ខនិរោធគាមិនីបដិបទា

## ញាណវិភង្គេ ចតុក្កនិទ្ទេសោ

អព្ភញ្ញឹសុ ឥមញ្ញេវ តេ ទុក្ខំ អព្ភញ្ញឹសុ ឥមញ្ញេវ តេ ទុក្ខសមុទយំ អព្ភញ្ញឹសុ ឥមញ្ញេវ តេ ទុក្ខនិរោធំ អព្ភញ្ញឹសុ ឥមញ្ញេវ តេ ទុក្ខនិរោធគាមិនឹ បដិបទំ អព្ភញ្ញឹសុ យេ ហិ កេចិ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា ទុក្ខំ អភិជានិស្សន្តិ ទុក្ខសមុទយំ អភិជានិស្សន្តិ ទុក្ខនិរោធំ អភិជានិស្សន្តិ ទុក្ខនិរោធគាមិនឹ បដិបទំ អភិជានិស្សន្តិ ឥមញ្ញេវ តេ ទុក្ខំ អភិជានិស្សន្តិ ឥមញ្ញេវ តេ ទុក្ខសមុទយំ អភិជានិស្សន្តិ ឥមញ្ញេវ តេ ទុក្ខនិរោធំ អភិជានិស្សន្តិ ឥមញ្ញេវ តេ ទុក្ខនិរោធគាមិនឹ បដិបទំ អភិជានិស្សន្តីតិ យា តត្ថ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ អន្វយេ ញាណំ ។

តត្ថ កតមំ បរិច្ចេ ញាណំ ។ ឥធ ភិក្ខុ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានាតិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ

បុគ្គលទាំងនោះ បានដឹងច្បាស់នូវទុក្ខនេះឯង បានដឹងច្បាស់នូវទុក្ខសមុទ័យនេះឯង បានដឹងច្បាស់នូវទុក្ខនិរោធនេះឯង បានដឹងច្បាស់នូវទុក្ខនិរោធគាមិនីបដិបទានេះឯង បុគ្គលណាមួយ ទោះជាសមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងកាលជាអនាគត នឹងដឹងច្បាស់នូវទុក្ខ នឹងដឹងច្បាស់នូវទុក្ខសមុទ័យ នឹងដឹងច្បាស់នូវទុក្ខនិរោធ នឹងដឹងច្បាស់នូវទុក្ខនិរោធគាមិនីបដិបទា បុគ្គលទាំងនោះ នឹងដឹងច្បាស់នូវទុក្ខនេះឯង នឹងដឹងច្បាស់នូវទុក្ខសមុទ័យនេះឯង នឹងដឹងច្បាស់នូវទុក្ខនិរោធនេះឯង នឹងដឹងច្បាស់នូវទុក្ខនិរោធគាមិនីបដិបទានេះឯង ព្រោះហេតុនោះ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា ក្នុងធម៌ទាំងឡាយនោះ នេះហៅថា សេចក្តីដឹងក្នុងការប្រព្រឹត្តទៅតាម ។ បណ្តាញាណទាំងនោះ សេចក្តីដឹងក្នុងការកំណត់ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ស្ទាបស្ទង់មើលនូវចិត្ត របស់សត្វដទៃ របស់បុគ្គលដទៃ ដោយចិត្តរបស់ខ្លួនឯង តែងដឹងច្បាស់ គឺ ចិត្តប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ ថា ចិត្តប្រកបដោយរាគៈ ចិត្តប្រាសចាករាគៈក្តី ក៏ដឹងច្បាស់ ថា ចិត្តប្រាសចាករាគៈ

សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាតិ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាតិ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាតិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានាតិ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានាតិ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាតិ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានាតិ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាតិ អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានាតិ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតីតិ យា តត្ថ បញ្ញា បជាននា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ បរិច្ចេ ញាណំ ។ ឋបេត្វា ធម្មេ ញាណំ អន្វយេ ញាណំ បរិច្ចេ ញាណំ អវសេសា បញ្ញា សម្មតិញ្ញាណំ ។

ចិត្តប្រកបដោយទោសៈក្តី ក៏ដឹងច្បាស់ ថា ចិត្តប្រកបទោសៈ ចិត្តប្រាសចាកទោសៈក្តី ក៏ដឹងច្បាស់ ថា ចិត្តប្រាសចាកទោសៈ ចិត្តប្រកបដោយមោហៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តប្រាសចាកមោហៈក្តី ក៏ដឹងច្បាស់ ថា ចិត្តប្រាសចាកមោហៈ ចិត្តរួញរាក្តី ក៏ដឹងច្បាស់ ថា ចិត្តរួញរា ចិត្តរាយមាយក្តី ក៏ដឹងច្បាស់ ថា ចិត្តរាយមាយ ចិត្តដល់នូវភាពដ៏ប្រសើរក្តី ក៏ដឹងច្បាស់ ថា ចិត្តដល់នូវភាពដ៏ប្រសើរ ចិត្តដល់នូវភាពមិនប្រសើរក្តី ក៏ដឹងច្បាស់ ថា ចិត្តដល់នូវភាពមិនប្រសើរ ចិត្តប្រកបដោយឧត្តរៈក្តី ក៏ដឹងច្បាស់ ថា ចិត្តប្រកបដោយឧត្តរៈ ចិត្តមិនមានឧត្តរៈក្តី ក៏ដឹងច្បាស់ ថា ចិត្តមិនមានឧត្តរៈ ចិត្តតំកល់មាំក្តី ក៏ដឹងច្បាស់ ថា ចិត្តតំកល់មាំ ចិត្តមិនតំកល់មាំក្តី ក៏ដឹងច្បាស់ ថា ចិត្តមិនតំកល់មាំ ចិត្តផុតស្រឡះក្តី ក៏ដឹងច្បាស់ ថា ចិត្តផុតស្រឡះ ចិត្តមិនផុតស្រឡះក្តី ក៏ដឹងច្បាស់ ថា ចិត្តមិនផុតស្រឡះ ព្រោះហេតុនោះ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា ក្នុងធម៌ទាំងឡាយនោះ នេះហៅថា សេចក្តីដឹងក្នុងការកំណត់ ។ បញ្ញា ដ៏សេស វៀរលែងតែសេចក្តីដឹងក្នុងធម៌ សេចក្តីដឹងក្នុងការប្រព្រឹត្តទៅតាម ទិនសេចក្តីដឹងក្នុងការកំណត់ចេញ ឈ្មោះថា សេចក្តីដឹងក្នុងការសន្ទូតំ ។

[៦០] តត្ថ កតមា បញ្ញា អាចយាយ នោ អបចយាយ ។ កាមាវចរកុសលេ បញ្ញា អាចយាយ នោ អបចយាយ ។ ចតូសុ មគ្គេសុ បញ្ញា អបចយាយ នោ អាចយាយ ។ រូបាវចរា-រូបាវចរកុសលេ បញ្ញា អាចយាយ ចេវ អបចយាយ ច ។ អវសេសា បញ្ញា នេវាចយាយ នោ អបចយាយ ។

[៦១] តត្ថ កតមា បញ្ញា និព្វិទាយ នោ បដិវេធាយ ។ យាយ បញ្ញាយ កាមេសុ វីតរា-គោ ហោតិ ន ច អភិញ្ញាយោ បដិវិជ្ឈតិ ន ច សច្ចានិ អយំ វុច្ចតិ បញ្ញា និព្វិទាយ នោ បដិ-វេធាយ ។ ស្វេវ បញ្ញាយ កាមេសុ វីតរាគោ សមានោ អភិញ្ញាយោ បដិវិជ្ឈតិ ន ច សច្ចានិ អយំ វុច្ចតិ បញ្ញា បដិវេធាយ នោ និព្វិទាយ ។

## ញាណវិភង្គ បតុក្កនិទ្ទេស

(៦០) បណ្ដាញាណទាំងនោះ បញ្ញា ក្នុងការសន្សំ (កម្មក្កិលេស) មិនមែនក្នុងការមិនសន្សំ តើដូចម្ដេច ។ បញ្ញា ក្នុងកាមាវចរកុសល ឈ្មោះថា បញ្ញា ក្នុងការសន្សំ (កម្មក្កិលេស) មិនមែនក្នុងការមិនសន្សំ ។ បញ្ញា ក្នុងមគ្គ ៤ ឈ្មោះថា បញ្ញាក្នុងការមិនសន្សំ មិនមែនក្នុងការសន្សំ ។ បញ្ញា ក្នុងរូបាវចរកុសលនិងអរូបាវចរកុសល ឈ្មោះថា បញ្ញា ក្នុងការសន្សំផង ក្នុងការមិនសន្សំផង ។ បញ្ញាដ៏សេស ឈ្មោះថា បញ្ញាមិនមែនក្នុងការសន្សំ ទាំងមិនមែនក្នុងការមិនសន្សំ ។

(៦១) បណ្ដាញាណទាំងនោះ បញ្ញា ក្នុងសេចក្ដីនឿយណាយ មិនមែនក្នុងការត្រាស់ដឹង តើដូចម្ដេច ។ បុគ្គលជាអ្នកប្រាសចាកតម្រេក ក្នុងកាមទាំងឡាយ ដោយបញ្ញា ណា តែមិនត្រាស់ដឹងនូវអភិញ្ញាទាំងឡាយ ទាំងមិនត្រាស់ដឹងនូវសច្ចៈទាំងឡាយទេ នេះហៅថា បញ្ញា ក្នុងសេចក្ដីនឿយណាយ មិនមែនក្នុងការត្រាស់ដឹង ។ បុគ្គលនោះ កាលបើប្រាសចាកតម្រេក ក្នុងកាមទាំងឡាយហើយ រមែងត្រាស់ដឹងនូវអភិញ្ញាទាំងឡាយ តែមិនត្រាស់ដឹងនូវសច្ចៈទាំងឡាយ ដោយប្រាជ្ញានេះហៅថា បញ្ញា ក្នុងការត្រាស់ដឹង មិនមែនក្នុងសេចក្ដីនឿយណាយ ។

ចតូសុ មគ្គេសុ បញ្ញា និព្វេធាយ ចេវ បដិវេធាយ ច ។ អវសេសា បញ្ញា នេវ និព្វេធាយ នោ បដិវេធាយ ។

[៦២] តត្ថ កតមា ហានភាគិនី បញ្ញា ។ បឋមស្ស ឈានស្ស លាភី[១] កាមសហគតា សញ្ញាមនសិការា សមុទាចរន្តិ ហានភាគិនី បញ្ញា តទនុធម្មតា សតិ សន្តិដ្ឋតិ ឋិតិភាគិនី បញ្ញា អវិតក្កសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិសេសភាគិនី បញ្ញា និព្វិទាសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិរាគូបសញ្ហិតា និព្វេធភាគិនី បញ្ញា ។ ទុតិយស្ស ឈានស្ស លាភី វិតក្កសហគតា សញ្ញាមនសិការា សមុទាចរន្តិ ហានភាគិនី បញ្ញា តទនុធម្មតា សតិ សន្តិដ្ឋតិ ឋិតិភាគិនី បញ្ញា

១ ម. សព្វត្ថ លាភីតិ ទិស្សតិយេវ ។

បញ្ញា ក្នុងមគ្គ ៤ ឈ្មោះថា បញ្ញា ក្នុងសេចក្តីនឿយណាយផង ក្នុងការត្រាស់ដឹងផង ។ បញ្ញា ដ៏សេស ឈ្មោះថា បញ្ញា មិនមែនក្នុងសេចក្តីនឿយណាយ មិនមែនក្នុងការត្រាស់ដឹង ។

(៦៤) បណ្តាញាណទាំងនោះ បញ្ញា មានចំណែកនៃសេចក្តីសាបសូន្យ តើដូចម្តេច ។ ការធ្វើទុកក្នុងចិត្ត ដោយសញ្ញា ប្រកបដោយកាម រមែងដាស់តឿននូវបុគ្គលដែលបានបឋមជ្ឈាន ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីសាបសូន្យ សតិមានសភាពដ៏សមគួរដល់បញ្ញានោះ តាំងនៅស៊ប់ ឈ្មោះថា បញ្ញា មានចំណែកនៃការតាំងនៅ ការធ្វើទុកក្នុងចិត្តដោយសញ្ញា មិនប្រកបដោយវិតក្កៈ រមែងដាស់តឿន (នូវបុគ្គលដែលបានបឋមជ្ឈាននោះ) ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីវិសេស ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយនិព្វិទា ប្រកបដោយវិរាគៈ រមែងដាស់តឿន (នូវបុគ្គលដែលបានបឋមជ្ឈាននោះ) ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីនឿយណាយ ។ ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយវិតក្កៈ រមែងដាស់តឿននូវបុគ្គលដែលបានទុតិយជ្ឈាន ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីសាបសូន្យ សតិ មានសភាពដ៏សមគួរ ដល់បញ្ញានោះ តាំងនៅស៊ប់ ឈ្មោះថា បញ្ញា មានចំណែក នៃការតាំងនៅ

## ញាណវិភង្គេ ចតុក្កនិទ្ទេសោ

ឧបេក្ខាសហគតា សញ្ញាមនសិការា សមុទាចរន្តិ
វិសេសភាគិនី បញ្ញា និព្វិទាសហគតា សញ្ញា-
មនសិការា សមុទាចរន្តិ វិរាគូបសញ្ហិតា និព្វេធ-
ភាគិនី បញ្ញា ។ តតិយស្ស ឈានស្ស លាភី
បីតិសហគតា សញ្ញាមនសិការា សមុទាចរន្តិ
ហានភាគិនី បញ្ញា តទនុធម្មតា សតិ សន្តិដ្ឋតិ
ឋិតិភាគិនី បញ្ញា អទុក្ខមសុខសហគតា សញ្ញាម-
នសិការា សមុទាចរន្តិ វិសេសភាគិនី បញ្ញា
និព្វិទាសហគតា សញ្ញាមនសិការា សមុទាចរន្តិ
វិរាគូបសញ្ហិតា និព្វេធភាគិនី បញ្ញា ។ ចតុត្ថស្ស
ឈានស្ស លាភី សុខសហគតា(១) សញ្ញា-
មនសិការា សមុទាចរន្តិ ហានភាគិនី បញ្ញា
តទនុធម្មតា សតិ សន្តិដ្ឋតិ ឋិតិភាគិនី បញ្ញា

១ ម. ឧបេក្ខាសហគតា ។

## ញាណវិភង្គ ចតុក្កនិទ្ទេស

ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយឧបេក្ខា រមែងដាស់តឿន (នូវបុគ្គលដែលបានទុតិយជ្ឈាននោះ) ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីវិសេស ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយនិព្វិទា ប្រកបដោយវិរាគៈ រមែងដាស់តឿន (នូវបុគ្គលដែលបានទុតិយជ្ឈាននោះ) ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីនឿយណាយ ។ ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយបីតិ រមែងដាស់តឿន នូវបុគ្គលដែលបានតតិយជ្ឈាន ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីសាបសូន្យ សតិមានសភាពដ៏សមគួរដល់បញ្ញានោះ តាំងនៅស្មើ ឈ្មោះថា បញ្ញា មានចំណែកនៃការតាំងនៅ ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយអទុក្ខមសុខវេទនា រមែងដាស់តឿន (នូវបុគ្គលដែលបានតតិយជ្ឈាននោះ) ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីវិសេស ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយនិព្វិទា ប្រកបដោយវិរាគៈ រមែងដាស់តឿន (នូវបុគ្គលដែលបានតតិយជ្ឈាននោះ) ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីនឿយណាយ ។ ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយសុខ រមែងដាស់តឿននូវបុគ្គលដែលបានចតុត្ថជ្ឈាន ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីសាបសូន្យ សតិមានសភាពដ៏សមគួរដល់បញ្ញានោះ តាំងនៅស្មើ ឈ្មោះថា បញ្ញាមានចំណែកនៃការតាំងនៅ

អាកាសានញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិសេសភាគិនី បញ្ញា និព្វិទាសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិរាគូបសញ្ហិតា និព្វេធភាគិនី បញ្ញា ។ អាកាសានញ្ចាយតនស្ស លាភឹ រូបសហគតា សញ្ញាមនសិការា សមុទាចរន្តិ ហានភាគិនី បញ្ញា តទនុធម្មតា សតិ សន្តិដ្ឋតិ ឋិតិភាគិនី បញ្ញា វិញ្ញាណញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិសេសភាគិនី បញ្ញា និព្វិទាសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិរាគូបសញ្ហិតា និព្វេធភាគិនី ញ្ញា ។ វិញ្ញាណញ្ចា-យតនស្ស លាភឹ អាកាសានញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ ហានភាគិនី បញ្ញា

ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយអាកាសានញ្ចាយតនៈ រមែងដាស់តឿន (នូវបុគ្គលដែលបានបឋមជ្ឈាននោះ) ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្ដីវិសេស ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយនិព្វិទា ប្រកបដោយវិរាគៈ រមែងដាស់តឿន (នូវបុគ្គលដែលបានបឋមជ្ឈាននោះ) ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្ដីទម្លាយ ។ ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយរូប រមែងដាស់តឿននូវបុគ្គល ដែលបានអាកាសានញ្ចាយតនៈ ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្ដីសាបសូន្យ សតិ មានសភាពដ៏សមគួរដល់បញ្ញានោះ តាំងនៅស៊ប់ ឈ្មោះថា បញ្ញា មានចំណែកនៃការតាំងនៅ ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយវិញ្ញាណញ្ចាយតនៈ រមែងដាស់តឿន (នូវបុគ្គលដែលបានអាកាសានញ្ចាយតនៈនោះ) ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្ដីវិសេស ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយនិព្វិទា ប្រកបដោយវិរាគៈ រមែងដាស់តឿន (នូវបុគ្គលដែលបានអាកាសានញ្ចាយតនៈ) ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្ដីទម្លាយ ។ ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយអាកាសានញ្ចាយតនៈ រមែងដាស់តឿននូវបុគ្គលដែលបានវិញ្ញាណញ្ចាយតនៈ ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្ដីសាបសូន្យ

## ញាណវិភង្គ ចតុក្កនិទ្ទេសោ

តទនុធម្មតា សតិ សន្តិដ្ឋតិ ឋិតិភាគិនី បញ្ញា អាកិញ្ចញ្ញាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិសេសភាគិនី បញ្ញា និព្វិទាសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិរាគូបសញ្ហិតា និព្វេធភាគិនី បញ្ញា ។ អាកិញ្ចញ្ញាយតនស្ស លាភី វិញ្ញាណញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ ហានភាគិនី បញ្ញា តទនុធម្មតា សតិ សន្តិដ្ឋតិ ឋិតិភាគិនី បញ្ញា នេវសញ្ញានាសញ្ញាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិសេសភាគិនី បញ្ញា និព្វិទាសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិរាគូបសញ្ហិតា និព្វេធភាគិនី បញ្ញា ។

ញាណវិភង្គ ចតុក្កនិទ្ទេស

សតិ មានសភាពដ៏សមគួរដល់បញ្ញានោះ តាំងនៅស៊ប់ ឈ្មោះថា បញ្ញា មានចំណែកនៃការតាំងនៅ ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយអាកិញ្ចញ្ញាយតនៈ រមែងដាស់តឿន ( នូវបុគ្គលដែលបានវិញ្ញាណញ្ចាយតនៈ ) ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្ដីវិសេស ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយនិព្វិទា ប្រកបដោយវិរាគៈ រមែងដាស់តឿន នូវបុគ្គលដែលបានវិញ្ញាណញ្ចាយតនៈ ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្ដីនឿយណាយ ។ ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយវិញ្ញាណញ្ចាយតនៈ រមែងដាស់តឿននូវបុគ្គលដែលបានអាកិញ្ចញ្ញាយតនៈ ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្ដីសាបសូន្យ សតិ មានសភាពដ៏សមគួរដល់បញ្ញានោះ តាំងនៅស៊ប់ ឈ្មោះថា បញ្ញា មានចំណែកនៃការតាំងនៅ ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយនេវសញ្ញានាសញ្ញាយតនៈ រមែងដាស់តឿន ( នូវបុគ្គលដែលបានអាកិញ្ចញ្ញាយតនៈ ) ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្ដីវិសេស ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយនិព្វិទា ប្រកបដោយវិរាគៈ រមែងដាស់តឿន ( នូវបុគ្គលដែលបានអាកិញ្ចញ្ញាយតនៈ ) ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្ដីនឿយណាយ ។

( ៦៣ ) តត្ថ កតមា ចតស្សោ បដិសម្ភិទា ។ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ។ អត្ថេ ញាណំ អត្ថប្បដិសម្ភិទា ធម្មេ ញាណំ ធម្មប្បដិសម្ភិទា តត្រ ធម្មនិរុត្តាភិលាបេ ញាណំ និរុត្តិប្បដិសម្ភិទា ញាណេសុ ញាណំ បដិភាណប្បដិសម្ភិទា ។ ឥមា ចតស្សោ បដិសម្ភិទា ។

( ៦៤ ) តត្ថ កតមា ចតស្សោ បដិបទា ។ ទុក្ខា បដិបទា ទន្ធាភិញ្ញា បញ្ញា ទុក្ខា បដិបទា ខិប្បាភិញ្ញា បញ្ញា សុខា បដិបទា ទន្ធាភិញ្ញា បញ្ញា សុខា បដិបទា ខិប្បាភិញ្ញា បញ្ញា ។ តត្ថ កតមា ទុក្ខា បដិបទា ទន្ធាភិញ្ញា បញ្ញា ។ កិច្ឆេន កសិរេន សមាធឹ ឧប្បាទេន្តស្ស ទន្ធំ តណ្ឋានំ អភិជានន្តស្ស យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ ទុក្ខា បដិបទា ទន្ធាភិញ្ញា បញ្ញា ។

( ៦៣ ) បណ្ដាញាណទាំងនោះ បដិសម្ភិទា ៤ តើដូចម្ដេច ។ អត្ថប្បដិសម្ភិទា ១ ធម្មប្បដិសម្ភិទា ១ និរុត្តិប្បដិសម្ភិទា ១ បដិភាណប្បដិសម្ភិទា ១ ។ ការដឹងក្នុងអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទា ការដឹងក្នុងធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទា ការដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថនិងធម៌ទាំងនោះ ឈ្មោះថា និរុត្តិប្បដិសម្ភិទា ការដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ នេះ បដិសម្ភិទា ៤ ។

( ៦៤ ) បណ្ដាញាណទាំងនោះ បដិបទា ៤ តើដូចម្ដេច ។ បញ្ញា ដែលប្រតិបត្តិលំបាកមានការត្រាស់ដឹងយូរ ១ បញ្ញា ដែលប្រតិបត្តិលំបាកមានការត្រាស់ដឹងឆាប់ ១ បញ្ញា ដែលប្រតិបត្តិងាយមានការត្រាស់ដឹងយូរ ១ បញ្ញា ដែលប្រតិបត្តិងាយមានការត្រាស់ដឹងឆាប់ ១ ។ បណ្ដាបញ្ញា ទាំង ៤ នោះ បញ្ញា ដែលប្រតិបត្តិលំបាកមានការត្រាស់ដឹងយូរ តើដូចម្ដេច ។ កាលបុគ្គល ញុំាងលោកុត្តរសមាធិឲ្យកើតដោយលំបាក ដោយកម្រ កាលត្រាស់ដឹងនូវហេតុ គឺ លោកុត្តរសមាធិនោះ ដោយយឺតយូរ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង នេះហៅថា បញ្ញា ដែលប្រតិបត្តិលំបាកមានការត្រាស់ដឹងយូរ ។

## ញាណវិភង្គេ ចតុក្កនិទ្ទេសោ

តត្ថ កតមា ទុក្ខា បដិបទា ខិប្បាភិញ្ញា បញ្ញា ។
កិច្ឆេន កសិរេន សមាធឹ ឧប្បាទេន្តស្ស ខិប្បំ
តណ្ឋានំ អភិជានន្តស្ស យា ឧប្បជ្ជតិ បញ្ញា បជា-
ននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ
អយំ វុច្ចតិ ទុក្ខា បដិបទា ខិប្បាភិញ្ញា បញ្ញា ។
តត្ថ កតមា សុខា បដិបទា ទន្ធាភិញ្ញា បញ្ញា ។
អកិច្ឆេន អកសិរេន សមាធឹ ឧប្បាទេន្តស្ស ទន្ធំ
តណ្ឋានំ អភិជានន្តស្ស យា ឧប្បជ្ជតិ បញ្ញា
បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ
អយំ វុច្ចតិ សុខា បដិបទា ទន្ធាភិញ្ញា បញ្ញា ។
តត្ថ កតមា សុខា បដិបទា ខិប្បាភិញ្ញា បញ្ញា ។
អកិច្ឆេន អកសិរេន សមាធឹ ឧប្បាទេន្តស្ស ខិប្បំ
តណ្ឋានំ អភិជានន្តស្ស យា ឧប្បជ្ជតិ បញ្ញា បជាននា
។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ
វុច្ចតិ សុខា បដិបទា ខិប្បាភិញ្ញា បញ្ញា ។ ឥមា
ចតស្សោ បដិបទា ។

## ញាណវិភង្គ ចតុក្កនិទ្ទេស

បណ្ដាបញ្ញាទាំងនោះ បញ្ញា ដែលប្រតិបត្តិលំបាកមានការត្រាស់ដឹងឆាប់ តើដូចម្ដេច ។ កាលបុគ្គលញុំាងលោកុត្តរសមាធិឲ្យកើត ដោយលំបាក ដោយកម្រ កាលត្រាស់ដឹងនូវហេតុ គឺ លោកុត្តរសមាធិនោះ ដោយឆាប់ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង នេះហៅថា បញ្ញា ដែលប្រតិបត្តិលំបាកមានការត្រាស់ដឹងឆាប់ ។ បណ្ដាបញ្ញាទាំងនោះ បញ្ញា ដែលប្រតិបត្តិងាយមានការត្រាស់ដឹងយូរ តើដូចម្ដេច ។ កាលបុគ្គលញុំាងលោកុត្តរ-សមាធិឲ្យកើត ដោយមិនលំបាក ដោយមិនក្រ កាលដឹងច្បាស់នូវហេតុ គឺលោកុត្តរសមាធិនោះ ដោយយឺតយូរ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង នេះហៅថា បញ្ញា ដែលប្រតិបត្តិងាយមានការត្រាស់ដឹងយូរ ។ បណ្ដាបញ្ញាទាំងនោះ បញ្ញា ដែលប្រតិបត្តិងាយមានការត្រាស់ដឹងឆាប់ តើដូចម្ដេច ។ កាលបុគ្គល ញុំាងលោកុត្តរសមាធិឲ្យកើតដោយមិនលំបាក ដោយមិនក្រ កាលដឹងច្បាស់នូវហេតុ គឺ លោកុត្តរសមាធិនោះដោយឆាប់ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង នេះហៅថា បញ្ញាដែលប្រតិបត្តិងាយមានការត្រាស់ដឹងឆាប់ ។ នេះ បដិបទា ៤ ។

(៦៨) តត្ថ កតមានិ ចត្តារិ អារម្មណានិ ។ បរិត្តា បរិត្តារម្មណា បញ្ញា បរិត្តា អប្បមាណារម្មណា បញ្ញា អប្បមាណា បរិត្តារម្មណា បញ្ញា អប្បមាណា អប្បមាណារម្មណា បញ្ញា ។ តត្ថ កតមា បរិត្តា បរិត្តារម្មណា បញ្ញា ។ សមាធិស្ស ន និកាមលាភិស្ស អារម្មណំ ថោកំ ផរន្តស្ស យា ឧប្បជ្ជតិ បញ្ញា បជានានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ បរិត្តា បរិត្តារម្មណា បញ្ញា ។ តត្ថ កតមា បរិត្តា អប្បមាណារម្មណា បញ្ញា ។ សមាធិស្ស ន និកាមលាភិស្ស អារម្មណំ វិបុលំ ផរន្តស្ស យា ឧប្បជ្ជតិ បញ្ញា បជានានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ បរិត្តា អប្បមាណារម្មណា បញ្ញា ។

(៦៥) បណ្ដាញាណទាំងនោះ អារម្មណ៍ ៤ តើដូចម្ដេច ។ បញ្ញា មានសភាពតូចឆ្មារ ទាំងមានអារម្មណ៍តូចឆ្មារ ១ បញ្ញា មានសភាពតូចឆ្មារ តែមានអារម្មណ៍ប្រមាណមិនបាន ១ បញ្ញា ប្រមាណមិនបាន តែមានអារម្មណ៍តូចឆ្មារ ១ បញ្ញា ប្រមាណមិនបាន ទាំងមានអារម្មណ៍ប្រមាណមិនបាន ១ ។ បណ្ដាបញ្ញាទាំងនោះ បញ្ញា មានសភាពតូចឆ្មារ ទាំងមានអារម្មណ៍តូចឆ្មារ តើដូចម្ដេច ។ កាលបុគ្គល មិនបាននូវសមាធិតាមសេចក្ដីប្រាថ្នា ទាំងផ្សាយទៅនូវអារម្មណ៍តិចតួច បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង នេះហៅថា បញ្ញា មានសភាពតូចឆ្មារ ទាំងមានអារម្មណ៍តូចឆ្មារ ។ បណ្ដាបញ្ញាទាំងនោះ បញ្ញា មានសភាពតូចឆ្មារ តែមានអារម្មណ៍ប្រមាណមិនបាន តើដូចម្ដេច ។ កាលបុគ្គល មិនបាននូវសមាធិតាមសេចក្ដីប្រាថ្នា តែផ្សាយទៅនូវអារម្មណ៍ដ៏ធំទូលាយ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង នេះហៅថា បញ្ញាមានសភាពតូចឆ្មារ តែមានអារម្មណ៍ប្រមាណមិនបាន ។

តត្ថ កតមា អប្បមាណា បរិត្តារម្មណា បញ្ញា ។ សមាធិស្ស និកាមលាភិស្ស អារម្មណំ ថោកំ ផរន្តស្ស យា ឧប្បជ្ជតិ បញ្ញា បជានានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ អប្បមាណា បរិត្តារម្មណា បញ្ញា ។ តត្ថ កតមា អប្បមាណា អប្បមាណារម្មណា បញ្ញា ។ សមាធិស្ស និកាមលាភិស្ស អារម្មណំ វិបុលំ ផរន្តស្ស យា ឧប្បជ្ជតិ បញ្ញា បជានានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ អប្បមាណា អប្បមាណារម្មណា បញ្ញា ។ ឥមានិ ចត្តារិ អារម្មណានិ ។

(៦៦) មគ្គសមង្គិស្ស ញាណំ ជរាមរណេបេតំ ញាណំ ជរាមរណសមុទយេបេតំ ញាណំ ជរាមរណនិរោធេបេតំ ញាណំ ជរាមរណនិរោធគាមិនិយា បដិបទាយបេតំ ញាណំ ។

បណ្ដាបញ្ញាទាំងនោះ បញ្ញា ប្រមាណមិនបាន តែមានអារម្មណ៍តូចឆ្មារ តើដូចម្ដេច ។ កាលបុគ្គល បាននូវសមាធិដូចសេចក្ដីប្រាថ្នា តែផ្សាយទៅនូវអារម្មណ៍តិចតួច បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង នេះហៅថា បញ្ញា ប្រមាណមិនបាន តែមានអារម្មណ៍តូចឆ្មារ ។ បណ្ដាបញ្ញាទាំងនោះ បញ្ញា ប្រមាណមិនបាន ទាំងមានអារម្មណ៍ប្រមាណមិនបាន តើដូចម្ដេច ។ កាលបុគ្គលបាននូវសមាធិដូចសេចក្ដីប្រាថ្នា ទាំងផ្សាយទៅនូវអារម្មណ៍ដ៏ធំទូលាយ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណានូវធម៌ ការឃើញត្រូវ ណា កើតឡើង នេះហៅថា បញ្ញា ប្រមាណមិនបាន ទាំងមានអារម្មណ៍ប្រមាណមិនបាន ។ នេះ អារម្មណ៍ ៤ ។

(៦៦) សេចក្ដីដឹងរបស់បុគ្គលព្រមព្រៀងដោយមគ្គ ឈ្មោះថា សេចក្ដីដឹងក្នុងជរាមរណៈ ឈ្មោះថា សេចក្ដីដឹងក្នុងហេតុដែលឲ្យកើតជរាមរណៈ ឈ្មោះថា សេចក្ដីដឹងក្នុងការរលត់ជរាមរណៈ ឈ្មោះថា សេចក្ដីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់ជរាមរណៈ ។

តត្ថ កតមំ ជរាមរណេ ញាណំ ។ ជរាមរណំ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ ជរាមរណេ ញាណំ ។ ជរាមរណសមុទយំ អារព្ភ ។ បេ ។ ជរាមរណនិរោធំ អារព្ភ ។ បេ ។ ជរាមរណនិរោធគាមិនឹ បដិបទំ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ ជរាមរណនិរោធគាមិនិយា បដិបទាយ ញាណំ ។ មគ្គសមង្គិស្ស ញាណំ ជាតិយាបេតំ ញាណំ ។ បេ ។ ភវេបេតំ ញាណំ ។ បេ ។ ឧបាទានេបេតំ ញាណំ ។ បេ ។ តណ្ហាយបេតំ ញាណំ ។ បេ ។ វេទនាយបេតំ ញាណំ ។ បេ ។ ផស្សេបេតំ ញាណំ ។ បេ ។ សឡាយតនេបេតំ ញាណំ ។ បេ ។ នាមរូបេបេតំ ញាណំ ។ បេ ។ វិញ្ញាណេបេតំ ញាណំ ។ បេ ។ សង្ខារេសុបេតំ ញាណំ សង្ខារសមុទយេបេតំ ញាណំ សង្ខារនិរោធេបេតំ ញាណំ

បណ្ដាញាណទាំងនោះ សេចក្ដីដឹងក្នុងជរាមរណៈ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធជរាមរណៈ នេះហៅថា សេចក្ដីដឹងក្នុងជរាមរណៈ ។ ព្រោះប្រារព្ធហេតុដែលឲ្យកើតជរាមរណៈ ។ បេ ។ ព្រោះប្រារព្ធការរលត់ជរាមរណៈ ។ បេ ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធបដិបទាជាដំណើរទៅកាន់ទីរលត់ជរ-មរណៈ នេះហៅថា សេចក្ដីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ជរាមរណៈ ។ សេចក្ដីដឹងរបស់បុគ្គលអ្នកព្រមព្រៀងដោយមគ្គ ឈ្មោះថា សេចក្ដីដឹងក្នុងជាតិ ។ បេ ។ ឈ្មោះថា សេចក្ដីដឹងក្នុងភព ។ បេ ។ ឈ្មោះថា សេចក្ដីដឹងក្នុងឧបាទាន ។ បេ ។ ឈ្មោះថា សេចក្ដីដឹងក្នុងតណ្ហា ។ បេ ។ ឈ្មោះថា សេចក្ដីដឹងក្នុងវេទនា ។ បេ ។ ឈ្មោះថា សេចក្ដីដឹងក្នុងផស្សៈ ។ បេ ។ ឈ្មោះថា សេចក្ដីដឹងក្នុងសឡាយតនៈ ។ បេ ។ ឈ្មោះថា សេចក្ដីដឹងក្នុងនាមរូប ។ បេ ។ ឈ្មោះថា សេចក្ដីដឹងក្នុងវិញ្ញាណ ។ បេ ។ ឈ្មោះថា សេចក្ដីដឹងក្នុងសង្ខារទាំងឡាយ ឈ្មោះថា សេចក្ដីដឹងក្នុងហេតុដែលឲ្យកើតសង្ខារ ឈ្មោះថា សេចក្ដីដឹងក្នុងការរលត់នៃសង្ខារ

សង្ខារនិរោធគាមិនិយា បដិបទាយបេតំ ញាណំ ។ តត្ថ កតមំ សង្ខារេសុ ញាណំ ។ សង្ខារេ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ សង្ខារេសុ ញាណំ ។ សង្ខារសមុទយំ អារព្ភ ។ បេ ។ សង្ខារនិរោធំ អារព្ភ ។ បេ ។ សង្ខារនិរោធគាមិនឹ បដិបទំ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ សង្ខារនិរោធគាមិនិយា បដិបទាយ ញាណំ ។

ឯវំ ចតុព្វិធេន ញាណវត្ថុ ។

(៦៧) តត្ថ កតមោ បញ្ចង្គិកោ សម្មាសមាធិ ។ បីតិផរណតា សុខផរណតា ចេតោផរណតា អាលោកផរណតា បច្ចវេក្ខណានិមិត្តំ ។

ឈ្មោះថា សេចក្ដីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់សង្ខារ ។ បណ្ដាញាណទាំងនោះ សេចក្ដីដឹងក្នុងសង្ខារទាំងឡាយ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធនូវសង្ខារទាំងឡាយ នេះហៅថា សេចក្ដីដឹងក្នុងសង្ខារទាំងឡាយ ។ ព្រោះប្រារព្ធហេតុដែលឲ្យកើតសង្ខារ ។ បេ ។ ព្រោះប្រារព្ធការរលត់នៃសង្ខារ ។ បេ ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា កើតឡើង ព្រោះប្រារព្ធនូវបដិបទា ជាដំណើរទៅកាន់ទីរលត់នៃសង្ខារ នេះហៅថា សេចក្ដីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ។

ញាណវត្ថុមានប្រការ ៤ យ៉ាងនេះឯង ។

(៦៧) បណ្ដាញាណទាំងនោះ សម្មាសមាធិ ប្រកបដោយអង្គ ៥ តើដូចម្ដេច ។ បីតិផរណតា (ការផ្សាយបីតិ) ១ សុខផរណតា (ការផ្សាយសុខ) ១ ចេតោផរណតា (ការផ្សាយចិត្ត) ១ អាលោកផរណតា (ការផ្សាយពន្លឺ) ១ បច្ចវេក្ខណានិមិត្ត (ការកំណត់ការពិចារណា) ១ ។

ទ្វីសុ ឈានេសុ បញ្ញា បីតិផរណតា តីសុ ឈានេសុ បញ្ញា សុខផរណតា បរចិត្តេ ញាណំ ចេតោផរណតា ទិព្វចក្ខុ អាលោកផរណតា តម្ហា តម្ហា សមាធិម្ហា វុដ្ឋិតស្ស បច្ចវេក្ខណាញាណំ បច្ចវេក្ខណានិមិត្តំ ។ អយំ វុច្ចតិ បញ្ចង្គិកោ សម្មាសមាធិ ។

(៦៨) តត្ថ កតមោ បញ្ចញាណិកោ សម្មាសមាធិ ។ អយំ សមាធិ បច្ចុប្បន្នសុខោ ចេវ អាយតឹ ច សុខវិបាកោតិ បច្ចត្តញ្ញេវ ញាណំ ឧប្បជ្ជតិ អយំ សមាធិ អរិយោ និរាមិសោតិ បច្ចត្តញ្ញេវ ញាណំ ឧប្បជ្ជតិ អយំ សមាធិ អកាបុរិសសេវិតោតិ[1] បច្ចត្តញ្ញេវ ញាណំ ឧប្បជ្ជតិ អយំ សមាធិ សន្តោ បណីតោ បដិប្បស្សទ្ធិលទ្ធោ ឯកោទិភាវាធិគតោ ន ច សសង្ខារនិគ្គយ្ហវារិតវតោតិ[2] បច្ចត្តញ្ញេវ ញាណំ ឧប្បជ្ជតិ សោ ខោ បនាហំ ឥមំ សមាធឹ សតោវ សមាបជ្ជាមិ សតោវ វុដ្ឋហាមីតិ បច្ចត្តញ្ញេវ ញាណំ ឧប្បជ្ជតិ ។

---

១ ម. មហាបុរិសសេវិតោតីតិ ទិស្សតិ ។ ២ ម. សសង្ខារនិគ្គយ្ហវារិតគតោតីតិ ទិស្សតិ ។

បញ្ញា ក្នុងឈាន ២ ឈ្មោះថា បីតិផរណតា បញ្ញា ក្នុងឈាន ៣ ឈ្មោះថា សុខផរណតា បញ្ញា ផ្សាយទៅក្នុងចិត្តនៃបុគ្គលដទៃ ឈ្មោះថា ចេតោផរណតា ទិព្វចក្ខុ ឈ្មោះថា អាលោកផរណតា បច្ចវេក្ខណាញ្ញាណ របស់បុគ្គលដែលចេញចាកសមាធិនោះ ៗ ឈ្មោះថា បច្ចវេក្ខណានិមិត្ត ៗ នេះហៅថា សម្មាសមាធិ ប្រកបដោយអង្គ ៥ ៗ

(៦៨) បណ្តាញាណទាំងនោះ សម្មាសមាធិ ប្រកបដោយញាណ ៥ តើដូចម្តេច ៗ ញាណកើតឡើង ជាក់ច្បាស់ថា សមាធិនេះ មានសេចក្តីសុខក្នុងបច្ចុប្បន្នផង មានសេចក្តីសុខ ជាវិបាកក្នុងខាងមុខផង ១ ញាណកើតឡើងជាក់ច្បាស់ថា សមាធិនេះ ប្រសើរ មិនមានអាមិសៈ ១ ញាណកើតឡើងជាក់ច្បាស់ថា សមាធិនេះ មិនមែនបុរសលាមកសេពឡើយ ១ ញាណកើតឡើង ជាក់ច្បាស់ថា សមាធិនេះ ជាធម៌ស្ងប់ ដ៏ឧត្តម បាននូវសេចក្តីស្ងប់រម្ងាប់ បាននូវភាពនៃចិត្តដ៏ខ្ពស់ឯក តែមិនដល់នូវការសង្កត់សង្កិន (ធម៌ជាសត្រូវ) និងការពាំង (កិលេស) ដោយចិត្ត ដែលប្រកបដោយសង្ខារ គឺ ព្យាយាម ១ ញាណកើតឡើងជាក់ច្បាស់ថា អាត្មាអញនោះ មានស្មារតី ចូលកាន់សមាធិនេះ មានស្មារតី ចេញចាកសមាធិនេះ ១ ៗ

អយំ បញ្ចញាណិកោ សម្មាសមាធិ ៕

ឯវំ បញ្ចវិធេន ញាណវត្ថុ ៕

(៦៩) តត្ថ កតមា ឆសុ អភិញ្ញាសុ បញ្ញា ៕ ឥទ្ធិវិធេ ញាណំ សោតធាតុវិសុទ្ធិយា ញាណំ បរចិត្តេ ញាណំ បុព្វេនិវាសានុស្សតិញាណំ សត្តានំ ចុតូបបាតេ ញាណំ អាសវានំ ខយេ ញាណំ ឥមា ឆសុ អភិញ្ញាសុ បញ្ញា ៕

ឯវំ ឆព្វិធេន ញាណវត្ថុ ៕

(៧០) តត្ថ កតមានិ សត្តសត្តតិ ញាណវត្ថូនិ ៕ ជាតិប្បច្ចយា ជរាមរណន្តិ ញាណំ អសតិ ជាតិយា នត្ថិ ជរាមរណន្តិ ញាណំ អតីតម្បិ អទ្ធានំ ជាតិប្បច្ចយា ជរាមរណន្តិ ញាណំ អសតិ ជាតិយា នត្ថិ ជរាមរណន្តិ ញាណំ អនាគតម្បិ អទ្ធានំ ជាតិប្បច្ចយា ជរាមរណន្តិ ញាណំ អសតិ ជាតិយា នត្ថិ ជរាមរណន្តិ ញាណំ

នេះឈ្មោះថា សម្មាសមាធិ ប្រកបដោយញាណ ៩ ។

ញាណវត្ថុ មានប្រការ ៩ យ៉ាងនេះឯង ។

[៦៩] បណ្តាញាណទាំងនោះ បញ្ញា ក្នុងអភិញ្ញា ៦ តើដូចម្តេច ។ សេចក្តីដឹងក្នុងចំណែកនៃឫទ្ធិ ១ សេចក្តីដឹងក្នុងសោតធាតុដ៏បរិសុទ្ធិ ១ សេចក្តីដឹងក្នុងការកំណត់ចិត្តរបស់សត្វដទៃ ១ សេចក្តីដឹងប្រកបដោយការរឭកឃើញនូវខន្ធរបស់សត្វដទៃ ដែលនៅអាស្រ័យក្នុងកាលមុន ១ សេចក្តីដឹងក្នុងការច្យុតនិងការកើតរបស់សត្វទាំងឡាយ ១ សេចក្តីដឹងក្នុងការអស់អាសវៈទាំងឡាយ ១ នេះឈ្មោះថា បញ្ញាក្នុងអភិញ្ញា ៦ ។

ញាណវត្ថុ មានប្រការ ៦ យ៉ាងនេះឯង ។

[៧០] បណ្តាញាណទាំងនោះ ញាណវត្ថុ ៧៧ តើដូចម្តេច ។ សេចក្តីដឹងថា ជរាមរណៈ (កើតមាន) ព្រោះជាតិជាបច្ច័យ ១ សេចក្តីដឹងថា កាលបើជាតិមិនមាន ជរាមរណៈក៏មិនមាន ១ សេចក្តីដឹងថា ជរាមរណៈ (កើតមាន) ព្រោះជាតិជាបច្ច័យ ក្នុងកាលអតីត ១ សេចក្តីដឹងថា កាលបើជាតិមិនមាន ជរាមរណៈក៏មិនមាន ១ សេចក្តីដឹងថា ជរាមរណៈ (កើតមាន) ព្រោះជាតិជាបច្ច័យ ក្នុងកាលអនាគត ១ សេចក្តីដឹងថា កាលបើជាតិមិនមាន ជរាមរណៈ ក៏មិនមាន ១

យម្បិស្ស តំ ធម្មដ្ឋិតិញាណំ តម្បិ ខយធម្មំ វយ-
ធម្មំ វិរាគធម្មំ និរោធធម្មន្តិ ញាណំ ។ ភវប្បច្ចយា
ជាតីតិ ញាណំ ។ បេ ។ ឧបាទានប្បច្ចយា ភវោតិ
ញាណំ ។ បេ ។ តណ្ហាបច្ចយា ឧបាទានន្តិ ញាណំ
។ បេ ។ វេទនាបច្ចយា តណ្ហាតិ ញាណំ ។ បេ ។
ផស្សប្បច្ចយា វេទនាតិ ញាណំ ។ បេ ។ សឡា-
យតនប្បច្ចយា ផស្សោតិ ញាណំ ។ បេ ។ នាម-
រូបប្បច្ចយា សឡាយតនន្តិ ញាណំ ។ បេ ។ វិញ្ញា-
ណប្បច្ចយា នាមរូបន្តិ ញាណំ ។ បេ ។ សង្ខារប្ប
ច្ចយា វិញ្ញាណន្តិ ញាណំ ។ បេ ។ អវិជ្ជាបច្ចយា
សង្ខារាតិ ញាណំ អសតិ អវិជ្ជាយ នត្ថិ សង្ខារាតិ
ញាណំ អតីតម្បិ អទ្ធានំ អវិជ្ជាបច្ចយា សង្ខារាតិ
ញាណំ អសតិ អវិជ្ជាយ នត្ថិ សង្ខារាតិ ញាណំ

សេចក្តីដឹងថា ធម្មដ្ឋិតិញ្ញាណ ណា របស់បុគ្គលនោះ ធម្មដ្ឋិតិញ្ញាណ នោះ មានសភាពអស់ទៅ មានសភាពសូន្យទៅ មានសភាពប្រាសចាកតម្រេក មានសភាពរលត់ ១ ។ សេចក្តីដឹងថា ជាតិ (កើតមាន) ព្រោះភពជាបច្ច័យ ១ ។ បេ ។ សេចក្តីដឹងថា ភព (កើតមាន) ព្រោះឧបាទានជាបច្ច័យ ១ ។ បេ ។ សេចក្តីដឹងថា ឧបាទាន (កើតមាន) ព្រោះតណ្ហាជាបច្ច័យ ១ ។ បេ ។ សេចក្តីដឹងថា តណ្ហា (កើតមាន) ព្រោះវេទនាជាបច្ច័យ ១ ។ បេ ។ សេចក្តីដឹងថា វេទនា (កើតមាន) ព្រោះផស្សៈជាបច្ច័យ ១ ។ បេ ។ សេចក្តីដឹងថា ផស្សៈ (កើតមាន) ព្រោះសឡាយតនៈជាបច្ច័យ ១ ។ បេ ។ សេចក្តីដឹងថា សឡាយតនៈ (កើតមាន) ព្រោះនាមរូបជាបច្ច័យ ១ ។ បេ ។ សេចក្តីដឹងថា នាមរូប (កើតមាន) ព្រោះវិញ្ញាណជាបច្ច័យ ១ ។ បេ ។ សេក្តីដឹងថា វិញ្ញាណ (កើតមាន) ព្រោះសង្ខារជាបច្ច័យ ១ ។ បេ ។ សេចក្តីដឹងថា សង្ខារ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យ ១ សេចក្តីដឹងថា កាលបើអវិជ្ជាមិនមាន សង្ខារទាំងឡាយ ក៏មិនមាន ១ សេចក្តីដឹងថា សង្ខារទាំងឡាយ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យក្នុងកាលអតីត ១ សេចក្តីដឹងថា កាលបើអវិជ្ជា មិនមាន សង្ខារទាំងឡាយ ក៏មិនមាន ១

## ញាណវិភង្គ នវកនិទ្ទេសោ

អនាគតម្បិ អទ្ធានំ អវិជ្ជាបច្ចយា សង្ខារាតិ ញាណំ អសតិ អវិជ្ជាយ នត្ថិ សង្ខារាតិ ញាណំ យម្បិស្ស តំ ធម្មដ្ឋិតិញាណំ តម្បិ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មន្តិ ញាណំ ។ ឥមានិ សត្តសត្តតិ ញាណវត្ថូនិ ។

ឯវំ សត្តវិធេន ញាណវត្ថុ ។

(៧១) តត្ថ កតមា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា ។ សោតាបត្តិមគ្គេ បញ្ញា សោតាបត្តិផលេ បញ្ញា សកទាគាមិមគ្គេ បញ្ញា សកទាគាមិផលេ បញ្ញា អនាគាមិមគ្គេ បញ្ញា អនាគាមិផលេ បញ្ញា អរហត្តមគ្គេ បញ្ញា អរហត្តផលេ បញ្ញា ឥមា ចតូសុ មគ្គេសុ ចតូសុ ផលេសុ បញ្ញា ។

ឯវំ អដ្ឋវិធេន ញាណវត្ថុ ។

(៧២) តត្ថ កតមា នវសុ អនុបុព្វវិហារសមាបត្តីសុ បញ្ញា ។ បឋមជ្ឈានសមាបត្តិយា បញ្ញា ទុតិយជ្ឈានសមាបត្តិយា បញ្ញា តតិយជ្ឈានសមាបត្តិយា បញ្ញា

សេចក្តីដឹងថា សង្ខារទាំងឡាយ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យក្នុងកាលអនាគត ១ សេចក្តីដឹងថា កាលបើអវិជ្ជាមិនមាន សង្ខារទាំងឡាយក៏មិនមាន ១ សេចក្តីដឹងថា ធម្មដ្ឋិតិញាណ ណា របស់បុគ្គលនោះ ធម្មដ្ឋិតិញាណនោះ មានសភាពអស់ទៅ មានសភាពសូន្យទៅ មានសភាពប្រាសចាកតម្រេក មានសភាពរលត់ ១ ។ នេះ ឈ្មោះថា ញាណវត្ថុ ៧៧ ។

ញាណវត្ថុ មានប្រការ ៧ យ៉ាងនេះឯង ។

(៧១) បណ្តាញាណទាំងនោះ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ តើដូចម្តេច ។ បញ្ញាក្នុងសោតាបត្តិមគ្គ ១ បញ្ញាក្នុងសោតាបត្តិផល ១ បញ្ញាក្នុងសកទាគាមិមគ្គ ១ បញ្ញាក្នុងសកទាគាមិផល ១ បញ្ញាក្នុងអនាគាមិមគ្គ ១ បញ្ញាក្នុងអនាគាមិផល ១ បញ្ញាក្នុងអរហត្តមគ្គ ១ បញ្ញាក្នុងអរហត្តផល ១ នេះ បញ្ញាក្នុងមគ្គ ៤ ក្នុងផល ៤ ។

ញាណវត្ថុ មានប្រការ ៨ យ៉ាងនេះឯង ។

(៧២) បណ្តាញាណទាំងនោះ បញ្ញាក្នុងអនុបុព្វវិហារសមាបត្តិ ៩ តើដូចម្តេច ។ បញ្ញាក្នុងបឋមជ្ឈានសមាបត្តិ ១ បញ្ញាក្នុងទុតិយជ្ឈានសមាបត្តិ ១ បញ្ញាក្នុងតតិយជ្ឈានសមាបត្តិ ១

ចតុត្ថជ្ឈានសមាបត្តិយា បញ្ញា អាកាសានញ្ចាយតនសមាបត្តិយា បញ្ញា វិញ្ញាណញ្ចាយតនសមាបត្តិយា បញ្ញា អាកិញ្ចញ្ញាយតនសមាបត្តិយា បញ្ញា នេវសញ្ញានាសញ្ញាយតនសមាបត្តិយា បញ្ញា សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋិតស្ស បច្ចវេក្ខណាញាណំ ឥមា នវសុ អនុបុព្វវិហារសមាបត្តីសុ បញ្ញា ។

ឯវំ នវវិធេន ញាណវត្ថុ ។

(៧៣) តត្ថ កតមំ តថាគតស្ស ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ ញាណំ ។ ឥធ តថាគតោ អដ្ឋានមេតំ អនវកាសោ យំ ទិដ្ឋិសម្បន្នោ បុគ្គលោ កញ្ចិ សង្ខារំ និច្ចតោ ឧបគច្ឆេយ្យ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ បុថុជ្ជនោ កញ្ចិ សង្ខារំ និច្ចតោ ឧបគច្ឆេយ្យ ឋានមេតំ វិជ្ជតីតិ បជានាតិ ។

បញ្ញា ក្នុងចតុត្ថជ្ឈានសមាបត្តិ ១ បញ្ញា ក្នុងអាកាសានញ្ចាយតនសមាបត្តិ ១ បញ្ញា ក្នុងវិញ្ញាណញ្ចាយតនសមាបត្តិ ១ បញ្ញា ក្នុងអាកិញ្ចញ្ញាយតនសមាបត្តិ ១ បញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនសមាបត្តិ ១ បច្ចវេក្ខណាញាណ របស់បុគ្គល ដែលចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិ ១ នេះ បញ្ញា ក្នុងអនុបុព្វវិហារសមាបត្តិ ៩ ។

ញាណវត្ថុ មានប្រការ ៩ យ៉ាងនេះឯង ។

(៧៣) បណ្ដាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវហេតុ ថា ជាហេតុផង នូវអំពើមិនមែនហេតុ ថា ជាអំពើមិនមែនហេតុផង តើដូចម្ដេច ។ ព្រះតថាគត ក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គលដល់ព្រមដោយទិដ្ឋិ (សម្មាទិដ្ឋិ) ហើយ ប្រកាន់នូវសង្ខារណាមួយ ថាទៀង ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះមានប្រាកដ ត្រង់ដែលបុគ្គលជាបុថុជ្ជន តែងប្រកាន់នូវសង្ខារណាមួយ ថាទៀង ការណ៍នុ៎ះ ទើបមាន ។

អដ្ឋានមេតំ អនវកាសោ យំ ទិដ្ឋិសម្បន្នោ បុគ្គលោ
កញ្ចិ សង្ខារំ សុខតោ ឧបគច្ឆេយ្យ នេតំ ឋានំ
វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ បុថុជ្ជ-
នោ កញ្ចិ សង្ខារំ សុខតោ ឧបគច្ឆេយ្យ ឋានមេតំ
វិជ្ជតីតិ បជានាតិ ។ អដ្ឋានមេតំ អនវកាសោ
យំ ទិដ្ឋិសម្បន្នោ បុគ្គលោ កញ្ចិ ធម្មំ អត្តតោ
ឧបគច្ឆេយ្យ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច
ខោ ឯតំ វិជ្ជតិ យំ បុថុជ្ជនោ កញ្ចិ ធម្មំ អត្តតោ
ឧបគច្ឆេយ្យ ឋានមេតំ វិជ្ជតីតិ បជានាតិ ។ អដ្ឋា-
នមេតំ អនវកាសោ យំ ទិដ្ឋិសម្បន្នោ បុគ្គលោ
មាតរំ ជីវិតា វោរោបេយ្យ នេតំ ឋានំ វិជ្ជតីតិ
បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ បុថុជ្ជនោ
មាតរំ ជីវិតា វោរោបេយ្យ ឋានមេតំ វិជ្ជតីតិ
បជានាតិ ។ អដ្ឋានមេតំ អនវកាសោ យំ
ទិដ្ឋិសម្បន្នោ បុគ្គលោ បិតរំ ជីវិតា វោរោបេយ្យ
។ បេ ។ អរហន្តំ ជីវិតា វោរោបេយ្យ ។ បេ ។

ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គលដល់ព្រមដោយទិដ្ឋិ ហើយប្រកាន់នូវសង្ខារណាមួយ ថាជាសុខ ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះ មានប្រាកដ ត្រង់ដែលបុគ្គលជាបុថុជ្ជន តែងប្រកាន់នូវសង្ខារណាមួយ ថាជាសុខ ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គលដល់ព្រមដោយទិដ្ឋិ ហើយប្រកាន់នូវធម៌ណាមួយ ថាជាខ្លួន ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះមានប្រាកដ ត្រង់ដែលបុគ្គលជាបុថុជ្ជន តែងប្រកាន់នូវធម៌ណាមួយ ថាជាខ្លួន ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គលដល់ព្រមដោយទិដ្ឋិ ហើយផ្តាច់បង់នូវមាតាចាកជីវិត ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះមានប្រាកដ ត្រង់ដែលបុគ្គលជាបុថុជ្ជន រមែងផ្តាច់បង់នូវមាតាចាកជីវិត ការណ៍នុ៎ះទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គដល់ព្រមដោយទិដ្ឋិ ហើយផ្តាច់បង់នូវបិតាចាកជីវិត ។បេ។ ផ្តាច់បង់នូវព្រះអរហន្តចាកជីវិត ។បេ។

ទុដ្ឋេន ចិត្តេន តថាគតស្ស លោហិតំ ឧប្បាទេយ្យ ។ បេ ។ សង្ឃំ ភិន្ទេយ្យ ។ បេ ។ អញ្ញំ សត្ថារំ ឧទ្ទិសេយ្យ ។ បេ ។ អដ្ឋមំ ភវំ និព្វត្តេយ្យ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ បុថុជ្ជនោ អដ្ឋមំ ភវំ និព្វត្តេយ្យ ឋានមេតំ វិជ្ជតីតិ បជានាតិ ។ អដ្ឋានមេតំ អនវកាសោ យំ ឯកិស្សា លោកធាតុយា ទ្វេ អរហន្តោ សម្មាសម្ពុទ្ធា អបុព្វំ អចរិមំ ឧប្បជ្ជេយ្យុំ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ ឯកិស្សា លោកធាតុយា ឯកោ អរហំ សម្មាសម្ពុទ្ធោ ឧប្បជ្ជេយ្យ ឋានមេតំ វិជ្ជតីតិ បជានាតិ ។ អដ្ឋានមេតំ អនវកាសោ យំ ឯកិស្សា លោកធាតុយា ទ្វេ រាជានោ ចក្កវត្តិនោ អបុព្វំ អចរិមំ ឧប្បជ្ជេយ្យុំ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ ឯកិស្សា លោកធាតុយា ឯកោ រាជា ចក្កវត្តិ ឧប្បជ្ជេយ្យ ឋានមេតំ វិជ្ជតីតិ បជានាតិ ។

ញុំាងព្រះលោហិតរបស់ព្រះតថាគត ឲ្យកើតឡើង ដោយចិត្តប្រទុស្ត ។ បេ ។ បំបែកសង្ឃ ។ បេ ។ ឧទ្ទិសទូវគ្រូដទៃ ។ បេ ។ ធ្វើភពទី ៨ ឲ្យកើតឡើង ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះមានប្រាកដ ត្រង់ដែលបុគ្គលជាបុថុជ្ជន តែងញុំាងភពទី ៨ ឲ្យកើត ការណ៍នុ៎ះទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលព្រះអរហន្តសម្មាសម្ពុទ្ធពីរព្រះអង្គ កើតឡើងក្នុងលោកធាតុមួយ មិនមុន មិនក្រោយ ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះមានប្រាកដ ត្រង់ដែលព្រះអរហន្តសម្មាសម្ពុទ្ធ មួយព្រះអង្គ កើតឡើងក្នុងលោកធាតុមួយ ការណ៍នុ៎ះទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលស្តេចចក្រពត្តិពីរព្រះអង្គ កើតឡើងក្នុងលោកធាតុមួយ មិនមុន មិនក្រោយ ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះមានប្រាកដ ត្រង់ដែលស្តេចចក្រ-ពត្តិ មួយព្រះអង្គ កើតឡើងក្នុងលោកធាតុមួយ ការណ៍នុ៎ះទើបមាន ។

អដ្ឋានមេតំ អនវកាសោ យំ ឥត្ថី អរហំ អស្ស សម្មាសម្ពុទ្ធោ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ បុរិសោ អរហំ អស្ស សម្មាសម្ពុទ្ធោ ឋានមេតំ វិជ្ជតីតិ បជានាតិ ។ អដ្ឋានមេតំ អនវកាសោ យំ ឥត្ថី រាជា អស្ស ចក្កវត្តិ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ បុរិសោ រាជា អស្ស ចក្កវត្តិ ឋានមេតំ វិជ្ជតីតិ បជានាតិ ។ អដ្ឋានមេតំ អនវកាសោ យំ ឥត្ថី សក្កត្តំ ការេយ្យ មារត្តំ ការេយ្យ ព្រហ្មត្តំ ការេយ្យ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ បុរិសោ សក្កត្តំ ការេយ្យ មារត្តំ ការេយ្យ(១) ព្រហ្មត្តំ ការេយ្យ ឋានមេតំ វិជ្ជតីតិ បជានាតិ ។ អដ្ឋានមេតំ អនវកាសោ យំ កាយទុច្ចរិតស្ស ឥដ្ឋោ កន្តោ មនាបោ វិបាកោ និព្វត្តេយ្យ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ កាយទុច្ចរិតស្ស អនិដ្ឋោ អកន្តោ អមនាបោ វិបាកោ និព្វត្តេយ្យ ឋានមេតំ វិជ្ជតីតិ បជានាតិ ។

---

១ ឱ. សក្កត្តំ ការេយ្យ មារត្តំ ការេយ្យាតិ ន ទិស្សន្តិ ។

ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលស្ត្រី បានជាព្រះអរហន្តសម្មាសម្ពុទ្ធ ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះមានប្រាកដ ត្រង់ដែលបុរស បានជាព្រះអរហន្តសម្មាសម្ពុទ្ធ ការណ៍នុ៎ះទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលស្ត្រីបានជាស្តេចចក្រពត្តិ ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះមានប្រាកដ ត្រង់ដែលបុរសបានជាស្តេចចក្រពត្តិ ការណ៍នុ៎ះទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលស្ត្រីបានអត្តភាពជាព្រះឥន្ទ្រ បានអត្តភាពជាមារ បានអត្តភាពជាព្រហ្ម ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះមានប្រាកដ ត្រង់ដែលបុរសបានអត្តភាពជាព្រះឥន្ទ្រ បានអត្តភាពជាមារ បានអត្តភាពជាព្រហ្ម ការណ៍នុ៎ះទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលវិបាករបស់កាយទុច្ចរិត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនុ៎ះមានប្រាកដ ត្រង់ដែលវិបាករបស់កាយទុច្ចរិត មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះទើបមាន ។

អដ្ឋានមេតំ អនវកាសោ យំ វចីទុច្ចរិតស្ស យំ មនោទុច្ចរិតស្ស ឥដ្ឋោ កន្តោ មនាបោ វិបាកោ និព្វត្តេយ្យ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ វចីទុច្ចរិតស្ស(១) យំ មនោទុច្ចរិតស្ស អនិដ្ឋោ អកន្តោ អមនាបោ វិបាកោ និព្វត្តេយ្យ ឋានមេតំ វិជ្ជតីតិ បជានាតិ ។ អដ្ឋានមេតំ អនវកាសោ យំ កាយសុចរិតស្ស អនិដ្ឋោ អកន្តោ អមនាបោ វិបាកោ និព្វត្តេយ្យ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ កាយសុចរិតស្ស ឥដ្ឋោ កន្តោ មនាបោ វិបាកោ និព្វត្តេយ្យ ឋានមេតំ វិជ្ជតីតិ បជានាតិ ។ អដ្ឋានមេតំ អនវកាសោ យំ វចីសុចរិតស្ស យំ មនោសុចរិតស្ស អនិដ្ឋោ អកន្តោ អមនាបោ វិបាកោ និព្វត្តេយ្យ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ

១ ឱ. យំ វចីទុច្ចរិតស្សាតិ ន ទិស្សន្តិ ។

ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលវិបាក របស់វចីទុច្ចរិត និងមនោទុច្ចរិត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះមានប្រាកដ ត្រង់ដែលវិបាករបស់វចីទុច្ចរិត និងមនោទុច្ចរិត មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលវិបាក របស់កាយសុចរិត មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះមានប្រាកដ ត្រង់ដែលវិបាក របស់កាយសុចរិត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលវិបាក របស់វចីសុចរិត និងមនោសុចរិត មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះមានប្រាកដ

វចីសុចរិតស្ស[១] យំ មនោសុចរិតស្ស ឥដ្ឋោ កន្តោ មនាបោ វិបាកោ និព្វត្តេយ្យ ឋានមេតំ វិជ្ជតីតិ បជានាតិ ។ អដ្ឋានមេតំ អនវកាសោ យំ កាយទុច្ចរិតសមង្គី តន្និទានំ[២] តប្បច្ចយា កាយស្ស ភេទា បរំ មរណា សុគតិំ សគ្គំ លោកំ ឧបបជ្ជេយ្យ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ កាយទុច្ចរិតសមង្គី តន្និទានំ តប្បច្ចយា កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ឋានមេតំ វិជ្ជតីតិ បជានាតិ ។ អដ្ឋានមេតំ អនវកាសោ យំ វចីទុច្ចរិតសមង្គី យំ មនោទុច្ចរិតសមង្គី តន្និទានំ តប្បច្ចយា កាយស្ស ភេទា បរំ មរណា សុគតិំ សគ្គំ លោកំ ឧបបជ្ជេយ្យ នេតំ ឋានំ វិជ្ជតីតិ បជានាតិ

១ ឱ. យំ វចីសុចរិតស្សាតិ ន ទិស្សន្តិ ។ ២ ឱ. តន្និទានាតិ សព្វត្ថ ទិស្សតិយេវ ។

## ញាណវិភង្គ ទសកនិទ្ទេស

ត្រង់ដែលវិបាក របស់វចីសុចរិត និងមនោសុចរិត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត គប្បីកើតឡើង ការណ៍នុ៎ះ ទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គល ប្រកបដោយកាយទុច្ចរិត លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ នឹងទៅកើតក្នុងលោក គឺមនុស្សសុគតិ និងស្ថានសួគ៌ ព្រោះមានកាយទុច្ចរិត នោះជាហេតុ ព្រោះមានកាយទុច្ចរិតនោះជាបច្ច័យ ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះមានប្រាកដ ត្រង់ដែលបុគ្គល ប្រកបដោយកាយទុច្ចរិត លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះមានកាយទុច្ចរិតនោះជាហេតុ ព្រោះមានកាយទុច្ចរិតនោះជាបច្ច័យ ការណ៍នុ៎ះទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គល ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ នឹងទៅកើតក្នុងលោក គឺមនុស្សសុគតិ និងស្ថានសួគ៌ ព្រោះមានវចីទុច្ចរិត និងមនោទុច្ចរិតនោះជាហេតុ ព្រោះមានវចីទុច្ចរិត និងមនោទុច្ចរិតនោះជាបច្ច័យ ការណ៍នុ៎ះមិនមានឡើយ

ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ វចីទុច្ចរិតសមង្គី(១) យំ មនោទុច្ចរិតសមង្គី តង្ខណំ តប្បច្ចយា កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ឋានមេតំ វិជ្ជតីតិ បជានាតិ ។ អដ្ឋានមេតំ អនវកាសោ យំ កាយសុចរិតសមង្គី តង្ខណំ តប្បច្ចយា កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ កាយសុចរិតសមង្គី តង្ខណំ តប្បច្ចយា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យ ឋានមេតំ វិជ្ជតីតិ បជានាតិ ។ អដ្ឋាន-មេតំ អនវកាសោ យំ វចីសុចរិតសមង្គី យំ មនោ-សុចរិតសមង្គី(២) តង្ខណំ តប្បច្ចយា កាយស្ស ភេទា

---

១ ឱ. យំ វចីទុច្ចរិតសមង្គីតិ ន ខាយតិ ។ ២ ឱ. យំ មនោសុចរិតសមង្គីតិ ន ខាយតិ ។

ទ្រង់ជ្រាបច្បាស់ថា ហេតុនេះមានប្រាកដ ត្រង់ដែលបុគ្គល ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះមានវចីទុច្ចរិត និងមនោទុច្ចរិតនោះជាហេតុ ព្រោះមានវចីទុច្ចរិត និងមនោទុច្ចរិតនោះជាបច្ច័យ ការណ៍នុ៎ះទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គល ប្រកបដោយកាយសុចរិត លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះមានកាយសុចរិតនោះជាហេតុ ព្រោះមានកាយសុចរិតនោះជាបច្ច័យ ការណ៍នុ៎ះ មិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះមានប្រាកដ ត្រង់ដែលបុគ្គល ប្រកបដោយកាយសុចរិត លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ នឹងទៅកើតក្នុងលោក គឺមនុស្សសុគតិ និងស្ថានសួគ៌ ព្រោះមានកាយសុចរិតនោះជាហេតុ ព្រោះមានកាយសុចរិតនោះជាបច្ច័យ ការណ៍នុ៎ះទើបមាន ។ ទ្រង់ជ្រាបច្បាស់ថា ដំណើរនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ ត្រង់ដែលបុគ្គល ប្រកបដោយវចីសុចរិត ប្របដោយមនោសុចរិត លុះបែកធ្លាយរាងកាយ

បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យុ នេតំ ឋានំ វិជ្ជតីតិ បជានាតិ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ វចីសុចរិតសមង្គី យំ មនោសុចរិតសមង្គី តន្និទានំ តប្បច្ចយា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យ ឋានមេតំ វិជ្ជតីតិ បជានាតិ ។ យេ យេ ធម្មា យេសំ យេសំ ធម្មានំ ហេតូ បច្ចយា ឧប្បាទាយ តំ តំ ឋានំ យេ យេ ធម្មា យេសំ យេសំ ធម្មានំ ន ហេតូ ន បច្ចយា ឧប្បាទាយ តំ តំ អដ្ឋានន្តិ យា តត្ថ បញ្ញា បជានានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ តថាគតស្ស ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ ញាណំ ។

## ញាណវិភង្គ ទសកនិទ្ទេស

ខាងមុខអំពីសេចក្តីស្លាប់ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះមានវចីសុចរិត និងមនោសុចរិតនោះជាហេតុ ព្រោះមានវចីសុចរិត និងមនោសុចរិតនោះជាបច្ច័យ ការណ៍នុ៎ះមិនមានឡើយ ទ្រង់ជ្រាបច្បាស់ថា ហេតុនេះមានប្រាកដ ត្រង់ដែលបុគ្គលប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ នឹងទៅកើតក្នុងលោក គឺមនុស្សសុគតិ និងស្ថានសួគ៌ ព្រោះមានវចីសុចរិត និងមនោសុចរិតនោះជាហេតុ ព្រោះមានវចីសុចរិត និងមនោសុចរិតនោះជាបច្ច័យ ការណ៍នុ៎ះទើបមាន ៗ ពួកធម៌ណា ៗ ជាហេតុ ជាបច្ច័យ ដើម្បីកើតឡើងនៃពួកធម៌ណា ៗ ពួកធម៌នោះ ៗ ឈ្មោះថាជាហេតុ ពួកធម៌ណា ៗ មិនមែនហេតុ មិនមែនបច្ច័យ ដើម្បីកើតឡើងនៃពួកធម៌ណា ៗ ទេ ពួកធម៌នោះ ៗ ឈ្មោះថា មិនមែនហេតុ ព្រោះហេតុនោះ បញ្ញា ការដឹងច្បាស់ ៗ បេ ៗ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណាក្នុងធម៌ទាំងឡាយនោះ នេះ ឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវហេតុ ថា ជាហេតុផង នូវអំពើមិនមែនហេតុ ថា ជាអំពើមិនមែនហេតុផង ៗ

## អភិធម្មបិដកេ វិភង្គោ

[៧៨] តត្ថ កតមំ តថាគតស្ស អតីតានាគតប្បច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ ហេតុសោ វិបាកំ យថាភូតំ ញាណំ ។ ឥធ តថាគតោ បជានាតិ អត្ថេកច្ចានិ បាបកានិ កម្មសមាទានានិ គតិសម្បត្តិប្បដិពាឡ្ហានិ ន វិបច្ចន្តិ អត្ថេកច្ចានិ បាបកានិ កម្មសមាទានានិ ឧបធិសម្បត្តិប្បដិពាឡ្ហានិ ន វិបច្ចន្តិ អត្ថេកច្ចានិ បាបកានិ កម្មសមាទានានិ កាលសម្បត្តិប្បដិពាឡ្ហានិ ន វិបច្ចន្តិ អត្ថេកច្ចានិ បាបកានិ កម្មសមាទានានិ បយោគសម្បត្តិប្បដិពាឡ្ហានិ ន វិបច្ចន្តិ អត្ថេកច្ចានិ បាបកានិ កម្មសមាទានានិ គតិវិបត្តឹ អាគម្ម វិបច្ចន្តិ អត្ថេកច្ចានិ បាបកានិ កម្មសមាទានានិ ឧបធិវិបត្តឹ អាគម្ម វិបច្ចន្តិ អត្ថេកច្ចានិ បាបកានិ កម្មសមាទានានិ កាលវិបត្តឹ អាគម្ម វិបច្ចន្តិ អត្ថេកច្ចានិ បាបកានិ កម្មសមាទានានិ បយោគវិបត្តឹ អាគម្ម វិបច្ចន្តិ អត្ថេកច្ចានិ កល្យាណានិ កម្មសមាទានានិ គតិវិបត្តិប្បដិពាឡ្ហានិ ន វិបច្ចន្តិ

អភិធម្មបិដក វិភង្គ

(៧៤) បណ្ដាញាណទាំងនោះ ព្រះតថាគត មានការជ្រាប ច្បាស់តាមពិត នូវវិបាក របស់កម្មសមាទាន (ការកាន់យកនូវកម្មជាកុសលនិងអកុសល) ជាអតីត អនាគត និងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ តើដូចម្ដេច ។ ព្រះតថាគតក្នុងលោកនេះ ទ្រង់ជ្រាប ច្បាស់ថា កម្មសមាទានដ៏លាមកពួកខ្លះ មានគតិសម្បត្តិពាំង មិនឲ្យផល ក៏មាន កម្មសមាទាន ដ៏លាមកពួកខ្លះ មានឧបធិសម្បត្តិពាំង មិនឲ្យផល ក៏មាន កម្មសមាទានដ៏លាមកពួកខ្លះ មានកាលសម្បត្តិពាំង មិនឲ្យផល ក៏មាន កម្មសមាទានដ៏លាមកពួកខ្លះ មានបយោគសម្បត្តិពាំង មិនឲ្យផលក៏មាន កម្មសមាទានដ៏លាមកពួកខ្លះ ឲ្យផល ព្រោះអាស្រ័យនូវគតិវិបត្តិ ក៏មាន កម្មសមាទានដ៏លាមកពួកខ្លះ ឲ្យផល ព្រោះអាស្រ័យ នូវឧបធិវិបត្តិ ក៏មាន កម្មសមាទាន ដ៏លាមកពួកខ្លះ ឲ្យផល ព្រោះអាស្រ័យ នូវកាលវិបត្តិ ក៏មាន កម្មសមាទានដ៏លាមកពួកខ្លះ ឲ្យផល ព្រោះអាស្រ័យនូវបយោគវិបត្តិ ក៏មាន កម្មសមាទានដ៏ល្អពួកខ្លះ មានគតិវិបត្តិពាំង មិនឲ្យផល ក៏មាន

## ញាណវិភង្គេ ទសកនិទ្ទេសោ

អត្ថេកច្ចានិ កល្យាណានិ កម្មសមាទានានិ ឧប-
ធិវិបត្តិប្បដិពាឡ្ហានិ ន វិបច្ចន្តិ អត្ថេកច្ចានិ កល្យា-
ណានិ កម្មសមាទានានិ កាលវិបត្តិប្បដិពាឡ្ហានិ
ន វិបច្ចន្តិ អត្ថេកច្ចានិ កល្យាណានិ កម្មសមា-
ទានានិ បយោគវិបត្តិប្បដិពាឡ្ហានិ ន វិបច្ចន្តិ អត្ថេ-
កច្ចានិ កល្យាណានិ កម្មសមាទានានិ គតិ-
សម្បត្តឹ អាគម្ម វិបច្ចន្តិ អត្ថេកច្ចានិ កល្យាណានិ
កម្មសមាទានានិ ឧបធិសម្បត្តឹ អាគម្ម វិបច្ចន្តិ
អត្ថេកច្ចានិ កល្យាណានិ កម្មសមាទានានិ
កាលសម្បត្តឹ អាគម្ម វិបច្ចន្តិ អត្ថេកច្ចានិ កល្យា-
ណានិ កម្មសមាទានានិ បយោគសម្បត្តឹ អាគម្ម
វិបច្ចន្តីតិ ។ យា តត្ថ បញ្ញា បជានានា ។បេ។
អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ តថាគតស្ស
អតីតានាគតប្បច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ
ហេតុសោ វិបាកំ យថាភូតំ ញាណំ ។

## ញាណវិភង្គ ទសកនិទ្ទេស

កម្មសមាទានដ៏ល្អពួកខ្លះ មានឧបធិវិបត្តិពាំង មិនឲ្យផល ក៏មាន កម្មសមាទានដ៏ល្អពួកខ្លះ មានកាលវិបត្តិពាំង មិនឲ្យផល ក៏មាន កម្មសមាទានដ៏ល្អពួកខ្លះ មានបយោគវិបត្តិពាំង មិនឲ្យផល ក៏មាន កម្មសមាទានដ៏ល្អពួកខ្លះ ឲ្យផល ព្រោះអាស្រ័យ នូវគតិសម្បត្តិ ក៏មាន កម្មសមាទានដ៏ល្អពួកខ្លះ ឲ្យផល ព្រោះអាស្រ័យ នូវឧបធិសម្បត្តិ ក៏មាន កម្មសមាទានដ៏ល្អពួកខ្លះ ឲ្យផល ព្រោះអាស្រ័យ នូវកាលសម្បត្តិ ក៏មាន កម្មសមាទានដ៏ល្អពួកខ្លះ ឲ្យផល ព្រោះអាស្រ័យ នូវបយោគសម្បត្តិ ក៏មាន ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវវិបាករបស់កម្មសមាទាន ជាអតីត អនាគត និងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ ។

(៧៥) តត្ថ កតមំ តថាគតស្ស សព្វត្ថគាមិនី បដិបទំ យថាភូតំ ញាណំ ។ ឥធ តថាគតោ អយំ មគ្គោ អយំ បដិបទា និរយគាមិនីតិ បជានាតិ អយំ មគ្គោ អយំ បដិបទា តិរច្ឆានគាមិនីតិ(១) បជានាតិ អយំ មគ្គោ អយំ បដិបទា បិត្តិវិសយគាមិនីតិ បជានាតិ អយំ មគ្គោ អយំ បដិបទា មនុស្សលោកគាមិនីតិ បជានាតិ អយំ មគ្គោ អយំ បដិបទា ទេវលោកគាមិនីតិ បជានាតិ អយំ មគ្គោ អយំ បដិបទា និព្វានគាមិនីតិ បជានាតិ ។ យា តត្ថ បញ្ញា បជាននា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ តថាគតស្ស សព្វត្ថគាមិនី បដិបទំ យថាភូតំ ញាណំ ។

(៧៦) តត្ថ កតមំ តថាគតស្ស អនេកធាតុំ នានាធាតុំ លោកំ យថាភូតំ ញាណំ ។

---

១ ម. តិរច្ឆានយោនិគាមិនីតិ ទិស្សតិ ។

(៧៥) បណ្ដាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវបដិបទាជាដំណើរទៅកាន់ទីទាំងពួង តើដូចម្ដេច ។ ព្រះតថាគតក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់ថា នេះផ្លូវ នេះសេចក្ដីប្រតិបត្តិ ជាដំណើរទៅកាន់នរក ទ្រង់ជ្រាបច្បាស់ថា នេះផ្លូវ នេះសេចក្ដីប្រតិបត្តិ ជាដំណើរទៅកាន់តិរច្ឆាន ទ្រង់ជ្រាបច្បាស់ថា នេះផ្លូវ នេះសេចក្ដីប្រតិបត្តិ ជាដំណើរទៅកាន់ប្រេតវិស័យ ទ្រង់ជ្រាបច្បាស់ថា នេះផ្លូវ នេះសេចក្ដីប្រតិបត្តិ ជាដំណើរទៅកាន់មនុស្សលោក ទ្រង់ជ្រាបច្បាស់ថា នេះផ្លូវ នេះសេចក្ដីប្រតិបត្តិ ជាដំណើរទៅកាន់ទេវលោក ទ្រង់ជ្រាបច្បាស់ថា នេះផ្លូវ នេះសេចក្ដីប្រតិបត្តិ ជាដំណើរទៅកាន់ព្រះនិព្វាន ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណានូវធម៌ ការឃើញត្រូវ ណា ក្នុងធម៌ទាំងឡាយនោះ នេះ ឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវបដិបទា ជាដំណើរទៅកាន់ទីទាំងពួង ។

(៧៦) បណ្ដាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវលោកដែលមានធាតុច្រើន មានធាតុផ្សេងៗគ្នា តើដូចម្ដេច ។

ឥធ តថាគតោ ខន្ធនានត្តំ បជានាតិ អាយតននានត្តំ បជានាតិ ធាតុនានត្តំ បជានាតិ អនេកធាតុំ នានាធាតុំ លោកំ បជានាតិ ។ យា តត្ថ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ តថាគតស្ស អនេកធាតុំ នានាធាតុំ លោកំ យថាភូតំ ញាណំ ។

(៧៧) តត្ថ កតមំ តថាគតស្ស សត្តានំ នានាធិមុត្តិកតំ យថាភូតំ ញាណំ ។ ឥធ តថាគតោ បជានាតិ សន្តិ សត្តា ហីនាធិមុត្តិកា សន្តិ សត្តា បណីតាធិមុត្តិកា ហីនាធិមុត្តិកា សត្តា ហីនាធិមុត្តិកេ សត្តេ សេវន្តិ ភជន្តិ បយិរុបាសន្តិ បណីតាធិមុត្តិកា សត្តា បណីតាធិមុត្តិកេ សត្តេ សេវន្តិ ភជន្តិ បយិរុបាសន្តិ អតីតម្បិ អទ្ធានំ ហីនាធិមុត្តិកា សត្តា ហីនាធិមុត្តិកេ សត្តេ សេវឹសុ ភជឹសុ

ព្រះតថាគត ក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់នូវសេចក្តីផ្សេងគ្នានៃខន្ធ ទ្រង់ជ្រាបច្បាស់ នូវសេចក្តីផ្សេងគ្នានៃអាយតនៈ ទ្រង់ជ្រាបច្បាស់ នូវសេចក្តីផ្សេងគ្នានៃធាតុ ឈ្មោះថា ជ្រាបច្បាស់នូវលោកដែលមានធាតុច្រើន មានធាតុផ្សេង ៗ ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវលោកដែលមានធាតុច្រើន មានធាតុផ្សេងៗគ្នា ។

(៧៧) បណ្តាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវអធ្យាស្រ័យផ្សេងៗ គ្នា នៃពួកសត្វ តើដូចម្តេច ។ ព្រះតថាគត ក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់ថា ពួកសត្វមានអធ្យាស្រ័យថោកទាប ក៏មាន ពួកសត្វមានអធ្យាស្រ័យខ្ពង់ខ្ពស់ ក៏មាន ក្នុងបច្ចុប្បន្នកាល ពួកសត្វមានអធ្យាស្រ័យថោកទាប តែងសេពគប់ គប់រក ចូលទៅអង្គុយជិតនឹងពួកសត្វ ដែលមានអធ្យាស្រ័យថោកទាបដូចគ្នា ពួកសត្វមានអធ្យាស្រ័យខ្ពង់ខ្ពស់ តែងសេពគប់ គប់រក ចូលទៅអង្គុយជិតនឹងពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ដូចគ្នា សូម្បីក្នុងអតីតកាល ពួកសត្វមានអធ្យាស្រ័យថោកទាប បានសេពគប់ គប់រក ចូលទៅអង្គុយជិត នឹងពួកសត្វ ដែលមានអធ្យាស្រ័យថោកទាបដូចគ្នា

បយិរុបាសឹសុ បណីតាធិមុត្តិកា សត្តា បណីតា-
ធិមុត្តិកេ សត្តេ សេវឹសុ ភជឹសុ បយិរុបាសឹសុ
អនាគតម្បិ អទ្ធានំ ហីនាធិមុត្តិកា សត្តា ហីនាធិ-
មុត្តិកេ សត្តេ សេវិស្សន្តិ ភជិស្សន្តិ បយិរុបាសិស្សន្តិ
បណីតាធិមុត្តិកា សត្តា បណីតាធិមុត្តិកេ សត្តេ
សេវិស្សន្តិ ភជិស្សន្តិ បយិរុបាសិស្សន្តីតិ ។ យា
តត្ថ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិ-
ចយោ សម្មាទិដ្ឋិ ឥទំ តថាគតស្ស សត្តានំ នា-
នាធិមុត្តិកតំ យថាភូតំ ញាណំ ។

(៧៨) តត្ថ កតមំ តថាគតស្ស បរសត្តានំ
បរបុគ្គលានំ ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ ញាណំ ។
ឥធ តថាគតោ សត្តានំ អាសយំ បជានាតិ អនុ-
សយំ បជានាតិ ចរិតំ បជានាតិ អធិមុត្តឹ បជានាតិ

ពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ បានសេពគប់ គប់រក ចូលទៅអង្គុយជិតហើយនឹងពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ដូចគ្នា សូម្បីក្នុងអនាគតកាល ពួកសត្វ ដែលមានអធ្យាស្រ័យថោកទាប នឹងសេពគប់ គប់រក ចូលទៅអង្គុយជិតនឹងពួកសត្វ ដែលមានអធ្យាស្រ័យថោកទាបដូចគ្នា ពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ នឹងសេពគប់ គប់រក ចូលទៅអង្គុយជិតនឹងពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ដូចគ្នា ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា ក្នុងធម៌ទាំងឡាយនោះ នេះ ឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវអធ្យាស្រ័យផ្សេង ៗ គ្នានៃពួកសត្វ ។

[៧៨] បណ្ដាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវឥន្ទ្រិយចាស់ក្លានិងទន់ របស់ពួកសត្វដទៃ របស់ពួកបុគ្គលដទៃ តើដូចម្ដេច ។ ព្រះតថាគត ក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់នូវអាសយៈ (ធម៌ជាទីនៅអាស្រ័យរបស់ពួកសត្វ) ទ្រង់ជ្រាបច្បាស់នូវអនុសយៈ (កិលេសដែលដេកត្រាំនៅក្នុងសន្ដានរបស់ពួកសត្វ) ទ្រង់ជ្រាបច្បាស់នូវចរិតរបស់ពួកសត្វ ទ្រង់ជ្រាបច្បាស់នូវអធ្យាស្រ័យរបស់ពួកសត្វ

អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ ភព្វាភព្វេ សត្តេ បជានាតិ ។ កតមោ ច សត្តានំ អាសយោ ។ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា ឥតិ ភវទិដ្ឋិសន្និស្សិតា វា សត្តា ហោន្តិ វិភវទិដ្ឋិសន្និស្សិតា វា ឯតេ វា បន ឧភោ អន្តេ អនុបគម្ម ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អនុលោមិកា ខន្តិ បដិលទ្ធា ហោតិ យថាភូតំ វា ញាណំ អយំ សត្តានំ អាសយោ ។

ទ្រង់ជ្រាបច្បាស់នូវពួកសត្វ ដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយចាស់ក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ដែលឲ្យត្រាស់ដឹងងាយ ដែលឲ្យត្រាស់ដឹងក្រ មានភ័ព្វនិងឥតភ័ព្វ ។ ចុះអាសយៈ ( ធម៌ជាទីនៅអាស្រ័យ ) របស់ពួកសត្វ តើដូចម្តេច ។ សត្វទាំងឡាយ អាស្រ័យនូវភវទិដ្ឋិ (សេចក្តីយល់ថា មាន) ក្តី អាស្រ័យនូវវិភវទិដ្ឋិ (សេចក្តីយល់ថា មិនមាន) ក្តី ដូច្នេះថា លោកទៀងខ្លះ ថា លោកមិនទៀងខ្លះ ថា លោកមានទីបំផុតខ្លះ ថា លោកមិនមានទីបំផុតខ្លះ ថា ជីវិតនោះក៏គឺសរីរៈនោះខ្លះ ថា ជីវិតដទៃសរីរៈក៏ដទៃខ្លះ ថា សត្វស្លាប់ហើយកើតទៀតខ្លះ ថា សត្វស្លាប់ហើយមិនកើតទៀតខ្លះ ថា សត្វស្លាប់ហើយកើតទៀត ក៏មាន មិនកើតទៀត ក៏មានខ្លះ ថា សត្វស្លាប់ហើយកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែនខ្លះ ឬក៏ សេចក្តីពេញចិត្តដែលអនុលោមទៅក្នុងធម៌ទាំងឡាយ ដែលកើតឡើង ព្រោះអាស្រ័យនូវធម៌នេះ ជាបច្ច័យក្តី សេចក្តីដឹងតាមពិតក្តី ជាការណ៍ដែលសត្វទាំងឡាយ បានបំពោះហើយ ព្រោះមិនពឹងផ្អែក នូវអន្តធម៌ទាំងពីរគឺភវទិដ្ឋិ និងវិភវទិដ្ឋិទុះទេ នេះ ឈ្មោះថា អាសយៈរបស់ពួកសត្វ ។

កតមោ ច សត្តានំ អនុសយោ ។ សត្តានុសយា កាមរាគានុសយោ បដិឃានុសយោ មានានុសយោ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ ភវរាគានុសយោ អវិជ្ជានុសយោ ។ យំ លោកេ បិយរូបំ សាតរូបំ ឯត្ថ សត្តានំ រាគានុសយោ អនុសេតិ យំ លោកេ អប្បិយរូបំ អសាតរូបំ ឯត្ថ សត្តានំ បដិឃានុស-យោ អនុសេតិ ឥតិ ឥមេសុ ទ្វីសុ ធម្មេសុ អវិជ្ជា អនុបតិតា តទេកដ្ឋោ មានោ ច ទិដ្ឋិ ច វិចិកិច្ឆា ច ទដ្ឋព្វា អយំ សត្តានំ អនុសយោ ។ កតមំ ច សត្តានំ ចរិតំ ។ បុញ្ញាភិសង្ខារោ អបុញ្ញាភិសង្ខារោ អានេញ្ជាភិសង្ខារោ បរិត្តភូមកោ វា មហាភូមកោ វា ឥទំ សត្តានំ ចរិតំ ។ ក-តមា ច សត្តានំ អធិមុត្តិ ។ សន្តិ សត្តា ហី-នាធិមុត្តិកា សន្តិ សត្តា បណីតាធិមុត្តិកា ហីនា-ធិមុត្តិកា សត្តា ហីនាធិមុត្តិកេ សត្តេ សេវន្តិ ភជន្តិ

ចុះអនុសយៈរបស់ពួកសត្វ តើដូចម្ដេច ។ អនុសយៈ ៧ គឺ កាម-រាគានុសយៈ ១ បដិឃានុសយៈ ១ មានានុសយៈ ១ ទិដ្ឋានុសយៈ ១ វិចិកិច្ឆានុសយៈ ១ ភវរាគានុសយៈ ១ អវិជ្ជានុសយៈ ១ ។ ឥដ្ឋា-រម្មណ៍ណា ក្នុងលោក មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ រាគានុសយៈរបស់ពួកសត្វ រមែងដេកត្រាំក្នុងឥដ្ឋារម្មណ៍នោះ អនិដ្ឋារម្មណ៍ ណា ក្នុងលោក មានសភាពមិនគួរស្រឡាញ់ មានសភាពមិនគួរត្រេកអរ បដិឃានុសយៈរបស់ពួកសត្វ រមែងដេកត្រាំក្នុងអនិដ្ឋារម្មណ៍នោះ ព្រោះហេតុនោះ អវិជ្ជា រមែងធ្លាក់ចុះតាម ក្នុងធម៌ទាំងពីរនេះ មានះក្តី ទិដ្ឋិក្តី វិចិកិច្ឆាក្តី បុគ្គលគប្បីឃើញថា តាំងនៅក្នុងទីជាមួយគ្នានឹងអវិជ្ជានោះ នេះ ឈ្មោះថា អនុសយៈ របស់ពួកសត្វ ។ ចុះចរិតរបស់ពួកសត្វ តើដូចម្ដេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ និងអនេញ្ជាភិសង្ខារ មានជាន់តូចតាចក្តី មានជាន់ធំដុំក្តី នេះ ឈ្មោះថា ចរិតរបស់ពួកសត្វ ។ ចុះអធ្យាស្រ័យរបស់ពួកសត្វ តើដូចម្ដេច ។ ពួកសត្វ មានអធ្យាស្រ័យថោកទាប ក៏មាន ពួកសត្វ មានអធ្យាស្រ័យខ្ពង់ខ្ពស់ ក៏មាន ក្នុងបច្ចុប្បន្ន-កាល ពួកសត្វ មានអធ្យាស្រ័យថោកទាប រមែងសេពគប់ គប់រក ចូលទៅអង្គុយជិត នឹងពួកសត្វ ដែលមានអធ្យាស្រ័យថោកទាបដូចគ្នា

បយិរុបាសន្តិ បណីតាធិមុត្តិកា សត្តា បណីតាធិមុត្តិកេ សត្តេ សេវន្តិ ភជន្តិ បយិរុបាសន្តិ អតីតម្បិ អទ្ធានំ ហីនាធិមុត្តិកា សត្តា ហីនាធិមុត្តិកេ សត្តេ សេវឹសុ ភជឹសុ បយិរុបាសឹសុ បណីតាធិមុត្តិកា សត្តា បណីតាធិមុត្តិកេ សត្តេ សេវឹសុ ភជឹសុ បយិរុបាសឹសុ អនាគតម្បិ អទ្ធានំ ហីនាធិមុត្តិកា សត្តា ហីនាធិមុត្តិកេ សត្តេ សេវិស្សន្តិ ភជិស្សន្តិ បយិរុបាសិស្សន្តិ បណីតាធិមុត្តិកា សត្តា បណីតាធិមុត្តិកេ សត្តេ សេវិស្សន្តិ ភជិស្សន្តិ បយិរុបាសិស្សន្តិ អយំ សត្តានំ អធិមុត្តិ ។ កតមេ តេ សត្តា មហារជក្ខា ។ ទស កិលេសវត្ថូនិ លោភោ ទោសោ មោហោ មានោ ទិដ្ឋិ វិចិកិច្ឆា ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ យេសំ សត្តានំ ឥមានិ ទស កិលេសវត្ថូនិ អាសេវិតានិ ភាវិតានិ ពហុលីកតានិ ឧស្សទគតានិ ឥមេ តេ សត្តា មហារជក្ខា ។ កតមេ តេ សត្តា អប្បរជក្ខា ។

## ញាណវិភង្គ ទសកនិទ្ទេស

ពួកសត្វ មានអធ្យាស្រ័យខ្ពង់ខ្ពស់ រមែងសេពគប់ គប់រក ចូលទៅអង្គុយជិត នឹងពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ដូចគ្នា សូម្បីក្នុងអតីតកាល ពួកសត្វ មានអធ្យាស្រ័យថោកទាប បានសេពគប់ គប់រក ចូលទៅអង្គុយជិតហើយ នឹងពួកសត្វ ដែលមានអធ្យាស្រ័យថោកទាប ដូចគ្នា ពួកសត្វមានអធ្យាស្រ័យខ្ពង់ខ្ពស់ បានសេពគប់ គប់រក ចូលទៅអង្គុយជិតហើយនឹងពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ដូចគ្នា សូម្បីក្នុងអនាគតកាល ពួកសត្វ មានអធ្យាស្រ័យថោកទាប នឹងសេពគប់ គប់រក ចូលទៅអង្គុយជិតនឹងពួកសត្វ ដែលមានអធ្យាស្រ័យថោកទាប ដូចគ្នា ពួកសត្វមានអធ្យាស្រ័យខ្ពង់ខ្ពស់ នឹងសេពគប់ គប់រក ចូលទៅអង្គុយជិតនឹងពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ដូចគ្នា នេះ ឈ្មោះថា អធ្យាស្រ័យរបស់ពួកសត្វ ។ ចុះពួកសត្វ មានធូលីច្រើនក្នុងភ្នែកនោះ តើដូចម្តេច ។ កិលេសវត្ថុ ១០ គឺ លោភៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ កិលេសវត្ថុទាំង ១០ នេះ ពួកសត្វ ណា បានសេពគប់ បានអប់រំ បានធ្វើឲ្យច្រើន បានធ្វើឲ្យដុះដាលហើយ ពួកសត្វនោះ ឈ្មោះថា មានធូលីច្រើនក្នុងភ្នែក ។ ពួកសត្វ មានធូលីតិចក្នុងភ្នែកនោះ តើដូចម្តេច ។

យេសំ សត្តានំ ឥមានិ ទស កិលេសវត្ថូនិ អនាសេវិតានិ អភាវិតានិ អពហុលីកតានិ អនុស្សទគតានិ ឥមេ តេ សត្តា អប្បរជក្ខា ។ កតមេ តេ សត្តា មុទិន្ទ្រិយា ។ បញ្ចិន្ទ្រិយានិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ យេសំ សត្តានំ ឥមានិ បញ្ចិន្ទ្រិយានិ អនាសេវិតានិ អភាវិតានិ អពហុលីកតានិ អនុស្សទគតានិ ឥមេ តេ សត្តា មុទិន្ទ្រិយា ។ កតមេ តេ សត្តា តិក្ខិន្ទ្រិយា ។ យេសំ សត្តានំ ឥមានិ បញ្ចិន្ទ្រិយានិ អាសេវិតានិ ភាវិតានិ ពហុលីកតានិ ឧស្សទគតានិ ឥមេ តេ សត្តា តិក្ខិន្ទ្រិយា ។ កតមេ តេ សត្តា ទ្វាការា ។ យេ តេ សត្តា បាបាសយា បាបានុសយា បាបចរិតា បាបាធិមុត្តិកា មហារជក្ខា មុទិន្ទ្រិយា ឥមេ តេ សត្តា ទ្វាការា ។ កតមេ តេ សត្តា ស្វាការា ។

កិលេសវត្ថុ ១០ នេះ ពួកសត្វណា មិនបានសេពគប់ មិនបានអប់រំ មិនបានធ្វើឲ្យច្រើន មិនបានធ្វើឲ្យជុះដាលហើយ ពួកសត្វនោះឯង ឈ្មោះថា មានធូលីតិចក្នុងភ្នែក ។ ពួកសត្វមានឥន្ទ្រិយទន់នោះ តើដូចម្តេច ។ ឥន្ទ្រិយ ៥ គឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ឥន្ទ្រិយទាំង ៥ នេះ ពួកសត្វណា មិនបានសេពគប់ មិនបានអប់រំ មិនបានធ្វើឲ្យច្រើន មិនបានធ្វើឲ្យជុះដាលហើយ ពួកសត្វនោះឯង ឈ្មោះថា មានឥន្ទ្រិយទន់ ។ ពួកសត្វមានឥន្ទ្រិយចាស់ក្លានោះ តើដូចម្តេច ។ ឥន្ទ្រិយទាំង ៥ នេះ ពួកសត្វណា បានសេពគប់ បានអប់រំ បានធ្វើឲ្យច្រើន បានធ្វើឲ្យជុះដាលហើយ ពួកសត្វនោះឯង ឈ្មោះថា មានឥន្ទ្រិយចាស់ក្លា ។ ពួកសត្វមានអាការអាក្រក់នោះ តើដូចម្តេច ។ ពួកសត្វណា មានអាសយៈអាក្រក់ មានអនុសយៈអាក្រក់ មានចរិតអាក្រក់ មានអធ្យាស្រ័យអាក្រក់ មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយទន់ ពួកសត្វនោះឯង ឈ្មោះថា មានអាការអាក្រក់ ។ ពួកសត្វមានអាការល្អនោះ តើដូចម្តេច ។

យេ តេ សត្តា កល្យាណាសយា កល្យាណ-
ចរិតា កល្យាណាធិមុត្តិកា អប្បរជក្ខា តិក្ខិន្ទ្រិយា
ឥមេ តេ សត្តា ស្វាការា ។ កតមេ តេ
សត្តា ទុវិញ្ញាបយា ។ យេ ច តេ សត្តា
ទ្វាការា តេវ តេ សត្តា ទុវិញ្ញាបយា យេ ច តេ
សត្តា ស្វាការា តេវ តេ សត្តា សុវិញ្ញាបយា ។
កតមេ តេ សត្តា អភព្វា ។ យេ តេ សត្តា
កម្មាវរណេន សមន្នាគតា កិលេសាវរណេន ស-
មន្នាគតា វិបាកាវរណេន សមន្នាគតា អស្សទ្ធា
អច្ឆន្ទិកា ទុប្បញ្ញា អភព្វា និយាមំ ឱក្កមតុំ កុស-
លេសុ ធម្មេសុ សម្មត្តំ ឥមេ តេ សត្តា អភព្វា ។
កតមេ តេ សត្តា ភព្វា ។ យេ តេ សត្តា ន
កម្មាវរណេន សមន្នាគតា ន កិលេសាវរណេន
សមន្នាគតា ន វិបាកាវរណេន សមន្នាគតា សទ្ធា
ឆន្ទិកា បញ្ញវន្តោ ភព្វា និយាមំ ឱក្កមិតុំ កុស-
លេសុ ធម្មេសុ សម្មត្តំ ឥមេ តេ សត្តា ភព្វាតិ

## ញាណវិភង្គ ទសកនិទ្ទេស

ពួកសត្វណា មានអាសយៈល្អ មានចរិតល្អ មានអធ្យាស្រ័យល្អ មានធូលីតិចក្នុងភ្នែក មានឥន្ទ្រិយចាស់ក្លា ពួកសត្វនោះឯង ឈ្មោះថា មានអាការល្អ ។ ពួកសត្វដែលឲ្យត្រាស់ដឹងក្រនោះ តើដូចម្តេច ។ ពួកសត្វណា មានអាការអាក្រក់ ពួកសត្វនោះ ឈ្មោះថា ឲ្យត្រាស់ដឹងក្រ ពួកសត្វណា មានអាការល្អ ពួកសត្វនោះ ឈ្មោះថា ឲ្យត្រាស់ដឹងងាយ ។ ពួកសត្វឥតភ័ព្វនោះ តើដូចម្តេច ។ ពួកសត្វណា ប្រកបដោយការពាំងគឺអនន្តរិយកម្ម ប្រកបដោយការពាំងគឺនិយតមិច្ឆាទិដ្ឋិ ប្រកបដោយការពាំងគឺអហេតុកបដិសន្ធិ ជាអ្នកមិនមានសទ្ធា មិនមានសេចក្តីប្រាថ្នា ឥតប្រាជ្ញា មិនគួរចុះកាន់សម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយ ពួកសត្វនោះឯង ឈ្មោះថា ឥតភ័ព្វ ។ ពួកសត្វមានភ័ព្វនោះ តើដូចម្តេច ។ ពួកសត្វណា ជាអ្នកមិនប្រកបដោយការពាំងគឺអនន្តរិយកម្ម មិនប្រកបដោយការពាំងគឺនិយតមិច្ឆាទិដ្ឋិ មិនប្រកបដោយការពាំងគឺអហេតុកបដិសន្ធិ ជាអ្នកមានសទ្ធា មានសេចក្តីប្រាថ្នា មានប្រាជ្ញា គួរចុះកាន់សម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយ ពួកសត្វនោះឯង ឈ្មោះថា មានភ័ព្វ

យា តត្ថ បញ្ញា បជានានា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ តថាគតស្ស បរសត្តានំ បរបុគ្គលានំ ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ ញាណំ ។

(៧៩) តត្ថ កតមំ តថាគតស្ស ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ ញាណំ ។ ឈាយីតិ ចត្តារោ ឈាយី អត្ថេកច្ចោ ឈាយី សម្បត្តិយេវ សមានំ វិបត្តីតិ បច្ចេតិ អត្ថេកច្ចោ ឈាយី វិបត្តិយេវ សមានំ សម្បត្តីតិ បច្ចេតិ អត្ថេកច្ចោ ឈាយី សម្បត្តិយេវ សមានំ សម្បត្តីតិ បច្ចេតិ អត្ថេកច្ចោ ឈាយី វិបត្តិយេវ សមានំ វិបត្តីតិ បច្ចេតិ ឥមេ ចត្តារោ ឈាយី ។ អបរេបិ ចត្តារោ ឈាយី អត្ថេកច្ចោ ឈាយី ទន្ធំ សមាបជ្ជតិ ខិប្បំ វុដ្ឋាតិ អត្ថេកច្ចោ ឈាយី ខិប្បំ សមាបជ្ជតិ ទន្ធំ វុដ្ឋាតិ អត្ថេកច្ចោ ឈាយី ទន្ធំ សមាបជ្ជតិ ទន្ធំ វុដ្ឋាតិ អត្ថេកច្ចោ

ព្រោះហេតុនោះ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាទូវធម៌ ការឃើញត្រូវ ណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវឥន្រ្ទិយ ចាស់ក្លាខ្ចីទន់ របស់ពួកសត្វដទៃ របស់ពួកបុគ្គលដទៃ ។

[៧៩] បណ្តាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវសេចក្តីសៅហ្មង នូវសេចក្តីផូរផង់ នូវការចេញនៃឈាន វិមោក្ខ សមាធិ និងសមាបត្តិ តើដូចម្តេច ។ ពាក្យថា បុគ្គលមានឈាន បានដល់បុគ្គលមានឈាន ៤ ពួក គឺបុគ្គលមានឈានពួកមួយ សំគាល់នូវសម្បត្តិ ថាជាវិបត្តិ ក៏មាន បុគ្គលមានឈានពួកមួយ សំគាល់នូវវិបត្តិ ថាជាសម្បត្តិ ក៏មាន បុគ្គលមានឈានពួកមួយ សំគាល់នូវសម្បត្តិ ថាជាសម្បត្តិ ក៏មាន បុគ្គលមានឈានពួកមួយ សំគាស់នូវវិបត្តិ ថាជាវិបត្តិ ក៏មាន នេះ ឈ្មោះថា បុគ្គលមានឈាន ៤ ពួក ។ បុគ្គលមានឈាន ៤ ពួក ដទៃទៀត គឺបុគ្គលមានឈានពួកមួយ ចូលឈានយឺតយូរ តែចេញរហ័ស ក៏មាន បុគ្គលមានឈានពួកមួយ ចូលឈានរហ័ស តែចេញយឺតយូរ ក៏មាន បុគ្គលមានឈានពួកមួយ ចូលឈានយឺតយូរ ចេញក៏យឺតយូរ ក៏មាន បុគ្គលមានឈាន

ឈាយី ខិប្បំ សមាបជ្ជតិ ខិប្បំ វុដ្ឋាតិ ឥមេ
ចត្តារោ ឈាយី ។ អបរេបិ ចត្តារោ ឈាយី
អត្ថេកច្ចោ ឈាយី សមាធិស្មឹ សមាធិកុសលោ
ហោតិ ន សមាធិស្មឹ សមាបត្តិកុសលោ អត្ថេ-
កច្ចោ ឈាយី សមាធិស្មឹ សមាបត្តិកុសលោ ហោតិ
ន សមាធិស្មឹ សមាធិកុសលោ អត្ថេកច្ចោ ឈាយី
សមាធិស្មឹ សមាធិកុសលោ ច ហោតិ សមាធិស្មឹ
សមាបត្តិកុសលោ ច អត្ថេកច្ចោ ឈាយី នេវ
សមាធិស្មឹ សមាធិកុសលោ ហោតិ ន សមាធិស្មឹ
សមាបត្តិកុសលោ ឥមេ ចត្តារោ ឈាយី ។ ឈានន្តិ
ចត្តារិ ឈានានិ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ
ឈានំ ចតុត្ថំ ឈានំ ។ វិមោក្ខាតិ អដ្ឋ វិមោក្ខា
រូបី រូបានិ បស្សតិ អយំ បឋមោ វិមោក្ខោ អជ្ឈត្តំ
អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ អយំ ទុតិ-
យោ វិមោក្ខោ សុភន្តេវ អធិមុត្តោ ហោតិ អយំ
តតិយោ វិមោក្ខោ សព្វសោ រូបសញ្ញានំ សម-
តិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ

## ញាណវិភង្គ ទសកនិទ្ទេស

ពួកមួយ ចូលឈានហើស ចេញក៏ហើស ក៏មាន នេះឈ្មោះថា បុគ្គលមានឈាន ៤ ពួក ។ បុគ្គលមានឈាន ៤ ពួក ដទៃទៀត គឺបុគ្គលមានឈានពួកមួយ ជាអ្នកឈ្លាសក្នុងការធ្វើចិត្តឲ្យនឹងធឹង ក្នុងសមាធិ តែមិនឈ្លាសក្នុងការចូលក្នុងសមាធិ ក៏មាន បុគ្គលមានឈានពួកមួយ ជាអ្នកឈ្លាសក្នុងការចូលក្នុងសមាធិ តែមិនឈ្លាសក្នុងការធ្វើចិត្តឲ្យនឹងធឹង ក្នុងសមាធិ ក៏មាន បុគ្គលមានឈានពួកមួយ ជាអ្នកឈ្លាសក្នុងការធ្វើចិត្តឲ្យនឹងធឹងក្នុងសមាធិផង ជាអ្នកឈ្លាសក្នុងការចូលក្នុងសមាធិផង ក៏មាន បុគ្គលមានឈានពួកមួយ ជាអ្នកមិនឈ្លាសក្នុងការធ្វើចិត្តឲ្យនឹងធឹង ក្នុងសមាធិ ទាំងមិនឈ្លាសក្នុងការចូលក្នុងសមាធិ ក៏មាន នេះឈ្មោះថា បុគ្គលមានឈាន ៤ ពួក ។ ពាក្យថា ឈាន បានដល់ឈាន ៤ គឺ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ។ ពាក្យថា វិមោក្ខ បានដល់វិមោក្ខ ៨ គឺបុគ្គលមានរូប ឃើញនូវរូប នេះវិមោក្ខទី ១ បុគ្គលមានសេចក្ដីសំគាល់ថា មិនមានរូបខាងក្នុង ឃើញនូវរូបខាងក្រៅ នេះវិមោក្ខទី ២ បុគ្គលមានអធ្យាស្រ័យ (សំគាល់) ថារូបល្អ នេះវិមោក្ខទី ៣ បុគ្គលកន្លងបង់នូវរូបសញ្ញា ដល់នូវការរលត់បដិឃសញ្ញា មិនធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា ដោយប្រការទាំងពួង

អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ចតុត្ថោ វិមោក្ខោ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ បញ្ចមោ វិមោក្ខោ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ឆដ្ឋោ វិមោក្ខោ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ សត្តមោ វិមោក្ខោ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ អយំ អដ្ឋមោ វិមោក្ខោ ។ សមាធីតិ តយោ សមាធី សវិតក្កសវិចារោ សមាធិ អវិតក្កវិចារមត្តោ សមាធិ អវិតក្កាវិចារោ សមាធិ ។ សមាបត្តីតិ នវ អនុបុព្វវិហារសមាបត្តិយោ បឋមជ្ឈានសមាបត្តិ ទុតិយជ្ឈានសមាបត្តិ តតិយជ្ឈានសមាបត្តិ ចតុត្ថជ្ឈានសមាបត្តិ

ក៏ចូលអាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត នេះវិមោក្ខទី ៤ បុគ្គលកន្លងបង់ នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលវិញ្ញាណញ្ចាយតនៈ ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត នេះវិមោក្ខទី ៥ បុគ្គលកន្លងបង់ នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន នេះវិមោក្ខទី ៦ បុគ្គលកន្លង នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន នេះវិមោក្ខទី ៧ បុគ្គលកន្លង នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលសញ្ញាវេទយិតនិរោធ នេះវិមោក្ខទី ៨ ។ ពាក្យថា សមាធិ បានដល់សមាធិ ៣ គឺ សមាធិប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈ សមាធិមិនមានវិតក្កៈមានត្រឹមតែវិចារៈ សមាធិមិនមានទាំងវិតក្កៈមិនមានទាំងវិចារៈ ។ ពាក្យថា សមាបត្តិ បានដល់អនុបុព្វវិហារសមាបត្តិ ៩ គឺបឋមជ្ឈានសមាបត្តិ ទុតិយជ្ឈានសមាបត្តិ តតិយជ្ឈានសមាបត្តិ ចតុត្ថជ្ឈានសមាបត្តិ

អាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតន-
សមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ នេវសញ្ញា-
នាសញ្ញាយតនសមាបត្តិ សញ្ញាវេទយិតនិរោធស-
មាបត្តិ ។ សង្កិលេសន្តិ ហានភាគិយោ ធម្មោ ។
វោទានន្តិ វិសេសភាគិយោ ធម្មោ ។ វុដ្ឋានន្តិ
វោទានម្បិ វុដ្ឋានំ តម្ហា តម្ហា សមាធិម្ហា វុដ្ឋានម្បិ
វុដ្ឋានន្តិ យា តត្ថ បញ្ញា បជានា ។ បេ ។
អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ តថាគតស្ស
យានវិមោក្ខសមាធិសមាបត្តីនំ(១) សង្កិលេសំ វោ-
ទានំ វុដ្ឋានំ យថាភូតំ ញាណំ ។

(៨០) តត្ថ កតមំ តថាគតស្ស បុព្វេនិវាសា-
នុស្សតិ យថាភូតំ ញាណំ ។ ឥធ តថាគតោ
អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ
ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិ-
យោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ
ទសបិ ជាតិយោ វីសំបិ ជាតិយោ តឹសំបិ ជាតិយោ

១ ឱ.ម. ឈានវិមោក្ខសមាធិសមាបត្តីនន្តិ ទិស្សតិ ។

ញាណវិភង្គ ទសកនិទ្ទេស

អាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ នេវសញ្ញានាសញ្ញាយតនសមាបត្តិ សញ្ញាវេទយិតនិរោធសមាបត្តិ ។ ពាក្យថា សេចក្តីសៅហ្មង បានដល់ធម៌ជាចំណែកនៃសេចក្តីសាបសូន្យ ។ ពាក្យថា សេចក្តីផូរផង់ បានដល់ធម៌ ជាចំណែកនៃគុណវិសេស ។ ពាក្យថា ការចេញ គឺសេចក្តីផូរផង់ ឈ្មោះថា ការចេញ ទាំងការចេញចាកសមាធិនោះ ។ ក៏ឈ្មោះថា ការចេញដែរ ព្រោះហេតុនោះ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវសេចក្តីសៅហ្មង នូវសេចក្តីផូរផង់ នូវការចេញ នៃឈាន វិមោក្ខ សមាធិនិងសមាបត្តិ ។

(៨០) បណ្តាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវការរលឹកជាតិដែលនៅអាស្រ័យក្នុងកពមុន តើដូចម្តេច ។ ព្រះតថាគត ក្នុងលោកនេះ រលឹកជាតិដែលបាននៅអាស្រ័យក្នុងកពមុន ជាអនេកជាតិ គឺរលឹកបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ

ចត្តាឡីសំបិ ជាតិយោ បញ្ញាសំបិ ជាតិយោ ជាតិសតំបិ ជាតិសហស្សំបិ ជាតិសតសហស្សំបិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ យា តត្ថ បញ្ញា បជានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ តថាគតស្ស បុព្វេនិវាសានុស្សតឹ យថាភូតំ ញាណំ ។

៦០ ជាតិ ៨០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិ ក៏បាន រលឹកបានច្រើនសំវដ្តកប្បៈ ច្រើនវិវដ្តកប្បៈ ច្រើនសំវដ្តវិវដ្តកប្បៈ ក៏បាន ដូច្នេះថា តថាគត បានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ តថាគត លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ តថាគត ក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ តថាគតនោះ លុះច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងភពនេះ ព្រះតថាគត រលឹកតាមនូវជាតិ ដែលនៅអាស្រ័យក្នុងភពមុន បានច្រើនជាតិ ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេសយ៉ាងនេះ ។ បញ្ញា ការដឹងច្បាស់ ។ល។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិតនូវការរលឹកជាតិដែលនៅអាស្រ័យក្នុងភពមុន ។

## ញាណវិភង្គេ ទសកនិទ្ទេសោ

(៨១) តត្ថ កតមំ តថាគតស្ស សត្តានំ ចុតូបបាតំ យថាភូតំ ញាណំ ? ឥធ តថាគតោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ

## ញាណវិភង្គ ទសកនិទ្ទេស

[៨១] បណ្ដាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវការច្យុតិ និងការកើតរបស់ពួកសត្វ តើដូចម្ដេច ។ ព្រះតថាគត ក្នុងលោកនេះ មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា រមែងឃើញពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានគតិល្អ មានគតិអាក្រក់ ក៏ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្ម (របស់ខ្លួន) ថា អើហ្ន៎ សត្វទាំងឡាយនេះ ប្រកបដោយកាយ-ទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវពួកព្រះអរិយបុគ្គល មានសេចក្ដីយល់ខុស ប្រកាន់នូវអំពើតាមសេចក្ដីយល់ខុស សត្វទាំងនោះលុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ ក៏បានចូលទៅកាន់កំណើតអបាយ ទុគ្គតិ វិនិបាតនរក មួយទៀត អើហ្ន៎ សត្វទាំងឡាយអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលនូវពួកព្រះអរិយៈ មានសេចក្ដីយល់ត្រូវ ប្រកាន់នូវអំពើតាមសេចក្ដីយល់ត្រូវ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ ក៏បានចូលទៅកាន់លោក គឺមនុស្សសុគតិ និងស្ថានសួគ៌

ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។ យា តត្ថ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ តថាគតស្ស សត្តានំ ចុតូបបាតំ យថាភូតំ ញាណំ ។

(៨២) តត្ថ កតមំ តថាគតស្ស អាសវានំ ខយំ យថាភូតំ ញាណំ ។ ឥធ តថាគតោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ យា តត្ថ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ តថាគតស្ស អាសវានំ ខយំ យថាភូតំ ញាណន្តិ ។

ញាណវិភង្គោ សមត្តោ ។

ព្រះតថាគត មានទិព្វចក្ខុ ដ៏បរិសុទ្ធ កន្លងហួសចក្ខុ របស់មនុស្ស ធម្មតា រមែងឃើញពួកសត្វ ដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានគតិល្អ មានគតិអាក្រក់ ក៏ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្ម (របស់ខ្លួន) ដោយប្រការដូច្នេះ ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវការច្យុតិ និងការកើត របស់ពួកសត្វ ។

(៨២) បណ្ដាញាណទាំងនោះ ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវការអស់ទៅនៃអាសវៈទាំងឡាយ តើដូចម្ដេច ។ ព្រះតថាគត ក្នុងលោកនេះ ព្រោះការអស់ទៅនៃអាសវៈ ក៏ធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ដោយប្រាជ្ញាដ៏ឧត្ដមរបស់ខ្លួន ក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា ព្រះតថាគត មានការជ្រាបច្បាស់តាមពិត នូវការអស់ទៅនៃអាសវៈទាំងឡាយ ។

ចប់ ញាណវិភង្គ ។

## ខុទ្ទកវត្ថុវិភង្គោ

(៨៣) ជាតិមទោ គោត្តមទោ អារោគ្យមទោ យោព្វនមទោ ជីវិតមទោ លាភមទោ សក្ការមទោ គរុការមទោ បុរេក្ខារមទោ បរិវារមទោ ភោគមទោ វណ្ណមទោ សុតមទោ បដិភាណមទោ រត្តញ្ញុមទោ បិណ្ឌបាតិកមទោ អនវញ្ញាតមទោ(១) ឥរិយាបថមទោ ឥទ្ធិមទោ យសមទោ សីលមទោ ឈានមទោ សិប្ប-មទោ អារោហមទោ បរិណាហមទោ សណ្ឋានមទោ បារិបូរិមទោ មទោ បមាទោ ថម្ភោ សារម្ភោ អ-តិច្ឆតា មហិច្ឆតា បាបិច្ឆតា សិង្គំ តិន្តិណំ ចាបល្យំ អសភាគវុត្តិ អរតិ តន្ទិ វិជម្ភិតា ភត្តសម្មទោ

---

១ ម. អនវញ្ញាតមទោតិបិ បាឋោ ។

# ខុទ្ទកវត្ថុវិភង្គ

(៨៣) សេចក្តីស្រវឹង ព្រោះជាតិ សេចក្តីស្រវឹង ព្រោះគោត្រ សេចក្តីស្រវឹង ព្រោះការមិនមានរោគ សេចក្តីស្រវឹង ព្រោះវ័យ សេចក្តីស្រវឹង ព្រោះជីវិត សេចក្តីស្រវឹង ព្រោះលាភ សេចក្តីស្រវឹង ព្រោះសក្ការៈ សេចក្តីស្រវឹង ព្រោះការគោរព សេចក្តីស្រវឹង ព្រោះខ្លួនជាប្រធាន សេចក្តីស្រវឹង ព្រោះបរិវារ សេចក្តីស្រវឹង ព្រោះភោគៈ សេចក្តីស្រវឹង ព្រោះវណ្ណៈ សេចក្តីស្រវឹង ព្រោះការចេះដឹង សេចក្តីស្រវឹង ព្រោះបញ្ញា សេចក្តីស្រវឹង ព្រោះដឹងរាត្រី សេចក្តីស្រវឹង ព្រោះប្រព្រឹត្តបិណ្ឌបាត សេចក្តីស្រវឹង ព្រោះការណ៍គេមើលងាយមិនបាន សេចក្តីស្រវឹង ព្រោះឥរិយាបថ សេចក្តីស្រវឹង ព្រោះឫទ្ធិ សេចក្តីស្រវឹង ព្រោះយស សេចក្តីស្រវឹង ព្រោះសីល សេចក្តីស្រវឹង ព្រោះឈាន សេចក្តីស្រវឹង ព្រោះសិល្បសាស្ត្រ សេចក្តីស្រវឹង ព្រោះកំពស់ សេចក្តីស្រវឹង ព្រោះទំហំ សេចក្តីស្រវឹង ព្រោះទ្រង់ទ្រាយ សេចក្តីស្រវឹង ព្រោះសរីរៈពេញលេញ សេចក្តីស្រវឹង សេចក្តីប្រមាទ សេចក្តីបាបេស សេចក្តីប្រណាំងរាស្កា សេចក្តីប្រាថ្នាក្រៃពេក សេចក្តីប្រាថ្នាធំ សេចក្តីប្រាថ្នាលាមក កិលេសជាតដូចស្នែង សេចក្តីតិះដៀល ការឃ្មេងឃ្មាង (ហឹហា) សេចក្តីប្រព្រឹត្តមិនស្មោះស្មើ សេចក្តីមិនត្រេកអរ សេចក្តីខ្ជិលប្រអូស សេចក្តីមិតពត់ សេចក្តីស្រវឹង ព្រោះភត្ត

ចេតសោ លីនត្តំ(១) កុហនា លបនា នេមិត្តិកតា និប្បេសិកតា លាភេន លាភំ និជិគីសនតា(២) សេយ្យោហមស្មីតិ មានោ សទិសោហមស្មីតិ មានោ ហីនោហមស្មីតិ មានោ សេយ្យស្ស សេយ្យោហមស្មីតិ មានោ សេយ្យស្ស សទិសោហមស្មីតិ មានោ សេយ្យស្ស ហីនោហមស្មីតិ មានោ សទិសស្ស សេយ្យោហមស្មីតិ អានោ សទិសស្ស សទិសោហមស្មីតិ មានោ សទិសស្ស ហីនោហមស្មីតិ មានោ ហីនស្ស សេយ្យោហមស្មីតិ មានោ ហីនស្ស សទិសោហមស្មីតិ មានោ ហីនស្ស ហីនោហមស្មីតិ មានោ មានោ អតិមានោ មានាតិមានោ ឱមានោ អធិមានោ អស្មិមានោ មិច្ឆាមានោ ញាតិវិតក្កោ ជនបទវិតក្កោ អមរវិតក្កោ បរានុទ្ទយតាបដិសំយុត្តោ វិតក្កោ

---

១ ម. ចេតសោ ប លីនត្តំ ។ ២ ម. លាភេន លាភំ និជិគីសនតា ។

ភាពនៃចិត្តរួញរា ការកុហក ការរួសរាយ ការធ្វើនូវនិមិត្ត ការធ្វើនូវសេចក្តីគំរាម ការទាក់លាភដោយលាភ សេចក្តីប្រកាន់ថា អញប្រសើរជាងគេ សេចក្តីប្រកាន់ថា អញស្មើនឹងគេ សេចក្តីប្រកាន់ថា អញថោកទាបជាងគេ សេចក្តីប្រកាន់នៃបុគ្គលប្រសើរជាងគេថា អញប្រសើរជាងគេ សេចក្តីប្រកាន់នៃបុគ្គលប្រសើរជាងគេថា អញស្មើនឹងគេ សេចក្តីប្រកាន់នៃបុគ្គលប្រសើរជាងគេថា អញថោកទាបជាងគេ សេចក្តីប្រកាន់នៃបុគ្គលស្មើនឹងគេថា អញប្រសើរជាងគេ សេចក្តីប្រកាន់នៃបុគ្គលស្មើនឹងគេថា អញស្មើនឹងគេ សេចក្តីប្រកាន់នៃបុគ្គលស្មើនឹងគេថា អញថោកទាបជាងគេ សេចក្តីប្រកាន់នៃបុគ្គលថោកទាបជាងគេថា អញប្រសើរជាងគេ សេចក្តីប្រកាន់នៃបុគ្គលថោកទាបជាងគេថា អញស្មើនឹងគេ សេចក្តីប្រកាន់នៃបុគ្គលថោកទាបជាងគេថា អញថោកទាបជាងគេ សេចក្តីប្រកាន់ សេចក្តីមើលងាយគេ សេចក្តីប្រកាន់ក្រៃលែង សេចក្តីប្រកាន់ថោកថយ សេចក្តីប្រកាន់លើសលុប សេចក្តីប្រកាន់ថា អញមាន សេចក្តីប្រកាន់ខុស សេចក្តីនឹកដល់ញាតិ សេចក្តីនឹកដល់ជនបទ សេចក្តីនឹកដល់ការមិនស្លាប់ សេចក្តីនឹកប្រកបដោយសេចក្តីអាណិត អាសូរដល់អ្នកដទៃ

លាភសក្ការសិលោកប្បដិសំយុត្តោ វិតក្កោ អនវញ្ញត្តិប្បដិសំយុត្តោ វិតក្កោ ។

(៨៤) កោធោ ច ឧបនាហោ ច មក្ខោ ច បឡាសោ ច ឥស្សា ច មច្ឆរិយញ្ច មាយា ច សាឋេយ្យញ្ច អវិជ្ជា ច ភវតណ្ហា ច ភវទិដ្ឋិ ច វិភវទិដ្ឋិ ច សស្សតទិដ្ឋិ ច ឧច្ឆេទទិដ្ឋិ ច អន្តវាទិដ្ឋិ ច អនន្តវាទិដ្ឋិ ច បុព្វន្តានុទិដ្ឋិ ច អបរន្តានុទិដ្ឋិ ច អហិរិកញ្ច អនោត្តប្បញ្ច ទោវចស្សតា ច បាបមិត្តតា ច អនជ្ជវោ ច អមទ្ទវោ ច អក្ខន្តិ ច អសោរច្ចញ្ច អសាខល្យញ្ច អប្បដិសន្ថារោ ច ឥន្ទ្រិយេសុ អគុត្តទ្វារតា ច ភោជនេ អមត្តញ្ញុតា ច មុដ្ឋស្សច្ចញ្ច អសម្បជញ្ញញ្ច សីលវិបត្តិ ច ទិដ្ឋិវិបត្តិ ច អជ្ឈត្តំ សញ្ញោជនញ្ច ពហិទ្ធា សញ្ញោជនញ្ច ។

## ខុទ្ទកវត្ថុវិភង្គ មាតិកា

សេចក្តីទឹក ប្រកបដោយលាភសក្ការៈ និងសេចក្តីសរសើរ សេចក្តីទឹក ប្រកបដោយការណ៍ដែលគេមើលឆាយមិនបាន ។

( ៨៤ ) សេចក្តីក្រោធ ១ ការចងសេចក្តីក្រោធទុក ១ សេចក្តីលុបគុណ ១ ការរ៉ាយឫកស្មើ ១ សេចក្តីប្រណែន ១ សេចក្តីកំណាញ់ ១ សេចក្តីបិទបាំងទោសរបស់ខ្លួន ១ សេចក្តីអួតអាង ១ អវិជ្ជា ១ ភវតណ្ហា ១ ភវទិដ្ឋិ ១ វិភវទិដ្ឋិ ១ សស្សតទិដ្ឋិ ១ ឧច្ឆេទទិដ្ឋិ ១ អន្តវាទិដ្ឋិ ១ អនន្តវាទិដ្ឋិ ១ បុព្វន្តានុទិដ្ឋិ ១ អបរន្តានុទិដ្ឋិ ១ សេចក្តីមិនខ្មាសបាប ១ សេចក្តីមិនក្តៅទឹងបាប ១ ការប្រដៅក្រ ១ ភាពអ្នកមានមិត្តអាក្រក់ ១ អាការមិនត្រង់ ១ សេចក្តីមិនទន់ភ្លន់ ១ សេចក្តីមិនអត់សង្កត់ ១ សេចក្តីមិនស្លូតបូត ១ សំដីមិនពីរោះ ១ ការមិនទទួលរាក់ទាក់ ១ ភាពអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ១ ភាពអ្នកមិនដឹងប្រមាណក្នុងភោជន ១ ភាពអ្នកភ្លេចស្មារតី ១ ភាពអ្នកមិនដឹងខ្លួន ១ វិបត្តិនៃសីល ១ វិបត្តិនៃទិដ្ឋិ ១ សញ្ញោជនៈខាងក្នុង ១ សញ្ញោជនៈខាងក្រៅ ១ ។

## អភិធម្មបិដកេ វិភង្គោ

(៨៨) តីណិ អកុសលមូលានិ តយោ អកុសលវិតក្កា តិស្សោ អកុសលសញ្ញា តិស្សោ អកុសលធាតុយោ តីណិ ទុច្ចរិតានិ តយោ អាសវា តីណិ សញ្ញោជនានិ តិស្សោ តណ្ហា អបរាបិ តិស្សោ តណ្ហា អបរាបិ តិស្សោ តណ្ហា(១) តិស្សោ ឯសនា តិស្សោ វិធា តីណិ ភយានិ តីណិ តមានិ តីណិ តិត្ថាយតនានិ តយោ កិញ្ចនា តីណិ អង្គណានិ តីណិ មលានិ តីណិ វិសមានិ អបរានិបិ តីណិ វិសមានិ តយោ អគ្គី តយោ កសាវា អបរេបិ តយោ កសាវា អស្សាទទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ អរតិ វិហេសា អធម្មចរិយា ទោវចស្សតា បាបមិត្តតា នានត្តសញ្ញា ឧទ្ធច្ចំ កោសជ្ជំ បមាទោ អសន្តុដ្ឋិតា អសម្បជញ្ញតា មហិច្ឆតា អហិរិកំ អនោត្តប្បំ បមាទោ អនាទរិយំ ទោវចស្សតា បាបមិត្តតា អស្សទ្ធិយំ អវទញ្ញុតា កោសជ្ជំ ឧទ្ធច្ចំ អសំវរោ ទុស្សីល្យំ អរិយានំ

១ ម. អបរាបិ តិស្សោ តណ្ហាតិ ន ទិស្សតិ ។

(៨៩) អកុសលមូល ៣ អកុសលវិតក្កៈ ៣ អកុសលសញ្ញា ៣ អកុសលធាតុ ៣ ទុច្ចរិត ៣ អាសវៈ ៣ សញ្ញោជនៈ ៣ តណ្ហា ៣ តណ្ហាដទៃទៀត ៣ តណ្ហាដទៃទៀត ៣ ការស្វែងរក ៣ ការធ្វើងៃខ្ព ៣ ភ័យ ៣ ងងឹត ៣ លទ្ធិដូចជាកំពង់ ៣ កង្វល់ ៣ ទីទួល ៣ មន្ទិល ៣ ធម្មជាតមិនរាបស្មើ ៣ ធម្មជាតមិនរាបស្មើដទៃទៀត ៣ ភ្លើង ៣ ទឹកបត់ ៣ ទឹកបត់ដទៃទៀត ៣ សេចក្តីយល់ឃើញថាគួរត្រេកអរ សេចក្តីយល់ឃើញថាជាខ្លួន សេចក្តីយល់ឃើញខុស សេចក្តីមិនត្រេកអរ សេចក្តីបៀតបៀន ការប្រព្រឹត្តិនូវអំពើមិនមែនធម៌ ការប្រដៅក្រ ភាពអ្នកមានមិត្តអាក្រក់ សញ្ញាផ្សេងៗ សេចក្តីរាយមាយ សេចក្តីខ្ជិល សេចក្តីប្រមាទ សេចក្តីមិនសន្តោស សេចក្តីមិនដឹងខ្លួន សេចក្តីប្រាថ្នាធំ សេចក្តីមិនខ្មាសបាប សេចក្តីមិនក្តៅទឹងបាប សេចក្តីប្រមាទ សេចក្តីមិនអើពើ ការប្រដៅក្រ ភាពនៃបុគ្គលមានមិត្តអាក្រក់ សេចក្តីមិនជឿ ការមិនធ្វើដឹងនូវពាក្យ (ស្ទូម) សេចក្តីខ្ជិល សេចក្តីរាយមាយ សេចក្តីមិនសង្រួម សេចក្តីទ្រុស្តសីល សេចក្តីមិនប្រាថ្នាដើម្បីឃើញព្រះអរិយៈ

ខុទ្ទកវត្ថុវិភង្គ មាតិកា

អទស្សនកម្យតា សទ្ធម្មំ អសោតុកម្យតា ឧបារម្ភ-
ចិត្តតា មុដ្ឋស្សច្ចំ អសម្បជញ្ញំ ចេតសោ វិក្ខេបោ
អយោនិសោ មនសិការោ កុម្មគ្គសេវនា ចេតសោ
លីនត្តំ ។

(៨៦) ចត្តារោ អាសវា ចត្តារោ គន្ថា
ចត្តារោ ឱឃា ចត្តារោ យោគា ចត្តារិ ឧបាទានានិ
ចត្តារោ តណ្ហុប្បាទា ចត្តារិ អគតិគមនានិ ចត្តារោ
វិបរិយេសា ចត្តារោ អនរិយវោហារា អបរេបិ ចត្តារោ
អនរិយវោហារា ចត្តារិ ទុច្ចរិតានិ អបរានិបិ ចត្តារិ
ទុច្ចរិតានិ ចត្តារិ ភយានិ អបរានិបិ ចត្តារិ ភយានិ
អបរានិបិ ចត្តារិ ភយានិ អបរានិបិ ចត្តារិ ភយានិ
ចតស្សោ ទិដ្ឋិយោ ។

(៨៧) បញ្ចោរម្ភាគិយានិ សញ្ញោជនានិ
បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ បញ្ច មច្ឆរិយានិ
បញ្ច សង្គា បញ្ច សល្លា បញ្ច ចេតោខីលា
បញ្ច ចេតសោ វិនិពន្ធា បញ្ច នីវរណានិ
បញ្ច កម្មានិ អានន្តរិកានិ បញ្ច ទិដ្ឋិយោ

ខុទ្ទកវត្ថុវិភង្គ មាតិកា

សេចក្ដីមិនប្រាថ្នាដើម្បីស្ដាប់ព្រះសទ្ធម្ម ភាពនៃបុគ្គលមានចិត្តប្រណាំងប្រជែង សេចក្ដីភ្លេចស្មារតី សេចក្ដីមិនដឹងខ្លួន សេចក្ដីកាយមាយនៃចិត្ត ការធ្វើទុកក្នុងចិត្តដោយខុសឧបាយ ការសេពផ្លូវខុស ភាពនៃចិត្តរួញរា ។

(៨៦) អាសវៈ ៤ គន្ថៈ ៤ ឱឃៈ ៤ យោគៈ ៤ ឧបាទាន ៤ តណ្ហុប្បាទ ៤ ការលុះក្នុងអគតិ ៤ ការស្វែងរកខុស ៤ វោហារមិនប្រសើរ ៤ វោហារមិនប្រសើរដទៃទៀត ៤ ទុច្ចរិត ៤ ទុច្ចរិតដទៃទៀត ៤ ភ័យ ៤ ភ័យដទៃទៀត ៤ ភ័យដទៃទៀត ៤ ភ័យដទៃទៀត ៤ ទិដ្ឋិ ៤ ។

(៨៧) សញ្ញោជនៈជាចំណែកខាងក្រោម ៥ សញ្ញោជនៈជាចំណែកខាងលើ ៥ មច្ឆរិយៈ ៥ កិលេសជាគ្រឿងជំពាក់ ៥ សរ ៥ បង្គោលចិត្ត ៥ ចំណងរបស់ចិត្ត ៥ នីវរណៈ ៥ អនន្តរិយកម្ម ៥ ទិដ្ឋិ ៥

បញ្ច វេរា បញ្ច ព្យសនា បញ្ច អក្ខន្តិយា អាទីនវា បញ្ច ភយានិ បញ្ច ទិដ្ឋធម្មនិព្វានវាទា ។

(៨៨) ឆ វិវាទមូលានិ ឆ ឆន្ទរាគា គេហសិតា ធម្មា ឆ វិរោធវត្ថូនិ ឆ តណ្ហាកាយា ឆ អគារវា ឆ បរិហានិយា ធម្មា អបរេបិ ឆ បរិហានិយា ធម្មា ឆ សោមនស្សុបវិចារា ឆ ទោមនស្សុបវិចារា ឆ ឧបេក្ខុបវិចារា ឆ គេហសិតានិ សោមនស្សានិ ឆ គេហសិតានិ ទោមនស្សានិ ឆ គេហសិតា ឧបេក្ខា ឆ ទិដ្ឋិយោ ។

(៨៩) សត្ត អនុសយា សត្ត បរិយុដ្ឋានានិ សត្ត សញ្ញោជនានិ សត្ត អសទ្ធម្មា សត្ត ទុច្ចរិតានិ សត្ត មានា សត្ត ទិដ្ឋិយោ ។

(៩០) អដ្ឋ កិលេសវត្ថូនិ អដ្ឋ កុសីតវត្ថូនិ អដ្ឋសុ លោកធម្មេសុ ចិត្តស្ស បដិឃាតោ អដ្ឋ អនរិយវោហារា អដ្ឋ មិច្ឆត្តា អដ្ឋ បុរិសទោសា អដ្ឋ អសញ្ញិវាទា អដ្ឋ នេវសញ្ញីនាសញ្ញិវាទា ។

ពៀរ ៨ សេចក្ដីវិនាស ៨ ទោសនៃសេចក្ដីមិនអត់ធន់ ៨ ភ័យ ៨ ទិដ្ឋធម្មនិព្វានវាទ ៨ ។

(៨៨) មូលនៃវាទ ៦ ឆន្ទរាគ ៦ ជាធម៌អាស្រ័យនូវផ្ទះ គឺកាមគុណ វិរោធវត្ថុ (ហេតុនៃសេចក្ដីក្រោធ) ៦ ពួកនៃតណ្ហា ៦ អគារវៈ (សេចក្ដីមិនគោរព) ៦ បរិហានិយធម៌ (ធម៌ដែលនាំឲ្យសាបសូន្យ) ៦ បរិហានិយធម៌ដទៃទៀត ៦ ធម៌ជាទីពិចារណាដោយសោមនស្ស ៦ ធម៌ជាទីពិចារណាដោយទោមនស្ស ៦ ធម៌ជាទីពិចារណាដោយឧបេក្ខា ៦ សោមនស្ស ៦ ដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ទោមនស្ស ៦ ដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ឧបេក្ខា ៦ ដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ទិដ្ឋិ ៦ ។

(៨៩) អនុសយកិលេស ៧ បរិយុដ្ឋានកិលេស ៧ សញ្ញោជនៈ ៧ អសទ្ធម្ម ៧ ទុច្ចរិត ៧ មានះ ៧ ទិដ្ឋិ ៧ ។

(៩០) កិលេសវត្ថុ ៨ កុសីតវត្ថុ ៨ សេចក្ដីបង្អៀតបង្អល់ចិត្ត ព្រោះលោកធម៌ ៨ វោហារមិនប្រសើរ ៨ មិច្ឆត្តធម៌ ៨ ទោសរបស់បុរស ៨ អសញ្ញីវាទ ៨ នេវសញ្ញីនាសញ្ញីវាទ ៨ ។

## ខុទ្ទកវត្ថុវិភង្គ មាតិកា

(៩១) នវ អាឃាតវត្ថូនិ នវ បុរិសមលានិ នវវិធា មានា នវ តណ្ហាមូលកា ធម្មា នវ ឥញ្ជិតានិ នវ មញ្ញិតានិ នវ ផន្ទិតានិ នវ បបញ្ចិតានិ នវ សង្ខតានិ ។

(៩២) ទស កិលេសវត្ថូនិ ទស អាឃាតវត្ថូនិ ទស អកុសលកម្មបថា ទស សញ្ញោជនានិ ទស មិច្ឆត្តា ទសវត្ថុកា មិច្ឆាទិដ្ឋិ ទសវត្ថុកា អន្តគ្គាហិកា ទិដ្ឋិ ។

(៩៣) អដ្ឋារស តណ្ហាវិចរិតានិ អជ្ឈត្តិកស្ស ឧបាទាយ អដ្ឋារស តណ្ហាវិចរិតានិ ពាហិរស្ស ឧបាទាយ តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា ឆត្តឹស តណ្ហាវិចរិតានិ ហោន្តិ ឥតិ អតីតានិ ឆត្តឹស តណ្ហាវិចរិតានិ អនាគតានិ ឆត្តឹស តណ្ហាវិចរិតានិ បច្ចុប្បន្នានិ ឆត្តឹស តណ្ហាវិចរិតានិ តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អដ្ឋសតំ តណ្ហាវិចរិតំ ហោតិ យានិ ច ទ្វាសដ្ឋិទិដ្ឋិគតានិ ព្រហ្មជាលេ វេយ្យាករណេ វុត្តានិ ភគវតា ។

មាតិកា ។

## ខុទ្ទកវត្ថុវិភង្គ មាតិកា

(៩១) អាឃាតវត្ថុ (ហេតុនៃគំនុំ) ៩ មន្ទិលរបស់បុរស ៩ មានះ ៩ ធម៌មានតណ្ហាជាមូល ៩ សេចក្តីញាប់ញ័រ ៩ សេចក្តីសំគាល់ ៩ សេចក្តីឃ្វេងឃ្វាង ៩ សេចក្តីយឺតយូរ ៩ សង្ខតធម៌ ៩ ។

(៩២) កិលេសវត្ថុ ១០ អាឃាតវត្ថុ ១០ អកុសលកម្មបថ ១០ សញ្ញោជនៈ ១០ មិច្ឆត្តធម៌ ១០ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ អន្តគ្គាហិក-ទិដ្ឋិ មានវត្ថុ ១០ ។

(៩៣) តណ្ហាវិចរិត (ការប្រព្រឹត្តិនៃតណ្ហា) ១៨ អាស្រ័យខន្ធបញ្ចកៈខាងក្នុង តណ្ហាវិចរិត ១៨ អាស្រ័យខន្ធបញ្ចកៈខាងក្រៅ ត្រូវជាតណ្ហាវិចរិត ៣៦ ព្រោះប្រមូលរួបរួមតណ្ហាវិចរិតទាំងពីរពួកនោះ ក្នុងទីជាមួយគ្នា តណ្ហាវិចរិត ជាអតីត ៣៦ តណ្ហាវិចរិត ជាអនាគត ៣៦ តណ្ហាវិចរិត ជាបច្ចុប្បន្ន ៣៦ ត្រូវជាតណ្ហាវិចរិត ១០៨ ព្រោះប្រមូលរួបរួមតណ្ហាវិចរិតទាំងអស់នោះ ក្នុងទីជាមួយគ្នា ដោយប្រការដូច្នេះ មួយវិញទៀត ទិដ្ឋិទាំង ៦២ ណា ទិដ្ឋិទាំង ៦២ នោះ ព្រះមានព្រះភាគបានសំដែងហើយ ក្នុងវេយ្យាករណ៍ ក្នុងព្រហ្មជាល-សូត្រ ។

ចប់មាតិកា ។

(៩៤) តត្ថ កតមោ ជាតិមទោ ។ ជាតឹ បដិច្ច មទោ មជ្ជនា មជ្ជិតត្តំ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ ជាតិមទោ ។

(៩៥) តត្ថ កតមោ គោត្តមទោ ។ គោត្តំ បដិច្ច ។ បេ ។ អារោគ្យំ បដិច្ច ។ បេ ។ យោព្វនំ បដិច្ច ។ បេ ។ ជីវិតំ បដិច្ច ។ បេ ។ លាភំ បដិច្ច ។ បេ ។ សក្ការំ បដិច្ច ។ បេ ។ គរុការំ បដិច្ច ។ បេ ។ បុរេក្ខារំ បដិច្ច ។ បេ ។ បរិវារំ បដិច្ច ។ បេ ។ ភោគំ បដិច្ច ។ បេ ។ វណ្ណំ បដិច្ច ។ បេ ។ សុតំ បដិច្ច ។ បេ ។ បដិភាណំ បដិច្ច ។ បេ ។ រត្តញ្ញុតំ បដិច្ច ។ បេ ។ បិណ្ឌបាតិកត្តំ បដិច្ច ។ បេ ។

[៩៤] បណ្ដាសេចក្ដីស្រវឹងទាំងនោះ សេចក្ដីស្រវឹង ព្រោះជាតិ តើដូចម្ដេច ។ ការស្រវឹង អាការស្រវឹង ភាពនៃសេចក្ដីស្រវឹង ការមើលងាយ អាការមើលងាយ ភាពនៃសេចក្ដីមើលងាយ ការធ្វើឫកខ្ពស់ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្ដីប្រាថ្នានៃចិត្តដូចជាទង់ ព្រោះអាស្រ័យជាតិ នេះហៅថា សេចក្ដីស្រវឹង ព្រោះជាតិ ។

[៩៥] បណ្ដាសេចក្ដីស្រវឹងទាំងនោះ សេចក្ដីស្រវឹង ព្រោះគោត្រ តើដូចម្ដេច ។ ព្រោះអាស្រ័យគោត្រ ។ បេ ។ ព្រោះអាស្រ័យភាពមិនមានរោគ ។ បេ ។ ព្រោះអាស្រ័យវ័យ ។ បេ ។ ព្រោះអាស្រ័យជីវិត ។ បេ ។ ព្រោះអាស្រ័យលាភ ។ បេ ។ ព្រោះអាស្រ័យសក្ការៈ ។ បេ ។ ព្រោះអាស្រ័យការគោរព ។ បេ ។ ព្រោះអាស្រ័យការប្រកាន់ខ្លួនថា ជាប្រធាន ។ បេ ។ ព្រោះអាស្រ័យបរិវារ ។ បេ ។ ព្រោះអាស្រ័យភោគៈ ។ បេ ។ ព្រោះអាស្រ័យវណ្ណៈ ។ បេ ។ ព្រោះអាស្រ័យការចេះដឹង ។ បេ ។ ព្រោះអាស្រ័យបញ្ញា ។ បេ ។ ព្រោះអាស្រ័យការដឹងរាត្រី ។ បេ ។ ព្រោះអាស្រ័យ ភាពអ្នកប្រព្រឹត្តបិណ្ឌបាត ។ បេ ។

អនវញ្ញត្តឹ(១) បដិច្ច ។ បេ ។ ឥរិយាបថំ បដិច្ច ។ បេ ។ ឥទ្ធឹ បដិច្ច ។ បេ ។ យសំ បដិច្ច ។ បេ ។ សីលំ បដិច្ច ។ បេ ។ ឈានំ បដិច្ច ។ បេ ។ សិប្បំ បដិច្ច ។ បេ ។ អារោហំ បដិច្ច ។ បេ ។ បរិណាហំ បដិច្ច ។ បេ ។ សណ្ឋានំ បដិច្ច ។ បេ ។ ចារិបូរឹ បដិច្ច មទោ មជ្ជនា មជ្ជិតត្តំ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ ចារិបូរិមទោ ។

(៩៦) តត្ថ កតមោ មទោ ។ យោ មទោ មជ្ជនា មជ្ជិតត្តំ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ មទោ ។

(៩៧) តត្ថ កតមោ បមាទោ ។ កាយទុច្ចរិតេ វា

១ ម. អនវញ្ញាតំ ។

ព្រោះអាស្រ័យការមិនមានគេមើលងាយ ។ បេ ។ ព្រោះអាស្រ័យឥរិយាបថ ។ បេ ។ ព្រោះអាស្រ័យឫទ្ធិ ។ បេ ។ ព្រោះអាស្រ័យយស ។ បេ ។ ព្រោះអាស្រ័យសីល ។ បេ ។ ព្រោះអាស្រ័យឈាន ។ បេ ។ ព្រោះអាស្រ័យសិល្បសាស្ត្រ ។ បេ ។ ព្រោះអាស្រ័យកំពស់ ។ បេ ។ ព្រោះអាស្រ័យទំហំ ។ បេ ។ ព្រោះអាស្រ័យទ្រង់ទ្រាយ ។ បេ ។ ការស្រវឹង អាការស្រវឹង ភាពនៃសេចក្តីស្រវឹង ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ ការធ្វើងធ្វៃ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ ព្រោះអាស្រ័យការពេញលេញ នេះហៅថា សេចក្តីស្រវឹង ព្រោះការពេញលេញ ។

(៩៦) បណ្តាធម៌ទាំងនោះ សេចក្តីស្រវឹង តើដូចម្តេច ។ ការស្រវឹង អាការស្រវឹង ភាពនៃសេចក្តីស្រវឹង ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ ការធ្វើងធ្វៃ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ ណា នេះហៅថា សេចក្តីស្រវឹង ។

(៩៧) បណ្តាធម៌ទាំងនោះ សេចក្តីប្រមាទ តើដូចម្តេច ។ ការបណ្តោយចិត្ត ការឲ្យកម្លាំងដល់ការបណ្តោយចិត្ត ក្នុងកាយទុច្ចរិតក្តី

វចីទុច្ចរិតេ វា មនោទុច្ចរិតេ វា បញ្ចសុ វា កាមគុណេសុ ចិត្តស្ស វោស្សគ្គោ វោស្សគ្គានុប្បទានំ កុសលានំ វា ធម្មានំ ភាវនាយ អសក្កច្ចកិរិយតា អសាតច្ចកិរិយតា អនដ្ឋិតកិរិយតា[១] ឱលីនវុត្តិតា និក្ខិត្តច្ឆន្ទតា និក្ខិត្តធុរតា អនាសេវនា អភាវនា អពហុលីកម្មំ អនធិដ្ឋានំ អននុយោគោ បមាទោ យោ ឯវរូបោ បមាទោ បមជ្ជនា បមជ្ជិតត្តំ អយំ វុច្ចតិ បមាទោ ។

(៩៨) តត្ថ កតមោ ថម្ភោ ។ យោ ថម្ភោ ថម្ភនា ថម្ភិតត្តំ កក្ខឡិយំ ផារុសិយំ ឧជុចិត្តតា អមុទុតា អយំ វុច្ចតិ ថម្ភោ ។

(៩៩) តត្ថ កតមោ សារម្ភោ ។ យោ សារម្ភោ បដិសារម្ភោ សារម្ភនា បដិសារម្ភនា បដិសារម្ភិតត្តំ អយំ វុច្ចតិ សារម្ភោ ។

---

១ ឱ. អនិដ្ឋិតកិរិយតា ។

ក្នុងវចីទុច្ចរិតក្តី ក្នុងមនោទុច្ចរិតក្តី ក្នុងកាមគុណ ៥ ក្តី ឬ ការធ្វើដោយមិនគោរព ការធ្វើមិនឲ្យរឿយ ៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តិទំរេទំ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិនប្រកបរឿយ ៗ ការធ្វេសប្រហែស ក្នុងការចំរើននូវពួកធម៌ជាកុសល ការធ្វេសប្រហែស អាការធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រមាទ ។

(៩៨) បណ្តាធម៌ទាំងនោះ សេចក្តីចចេស តើដូចម្តេច ។ ការចចេស អាការចចេស ភាពនៃសេចក្តីចចេស សេចក្តីរឹងរូស សេចក្តីអាក្រក់ ភាពនៃចិត្តរឹងកំព្រឹស ភាពនៃចិត្តមិនទន់ភ្លន់ ណា នេះហៅថា សេចក្តីចចេស ។

(៩៩) បណ្តាធម៌ទាំងនោះ សេចក្តីប្រណាំងវាស្នា តើដូចម្តេច ។ ការប្រណាំងប្រដែង ការប្រណាំងប្រដែងតប អាការប្រណាំងប្រដែង អាការប្រណាំងប្រដែងតប ភាពនៃសេចក្តីប្រណាំងប្រដែងតប ណា នេះហៅថា សេចក្តីប្រណាំងវាស្នា ។

[១០០] តត្ថ កតមា អតិច្ឆតា(១) ។ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារេហិ បញ្ចហិ វា កាមគុណេហិ អសន្តុដ្ឋស្ស ភិយ្យោកម្យតា យា ឯវរូបា ឥច្ឆា ឥច្ឆាគតំ(២) អតិច្ឆតា(១) រាគោ សារាគោ ។ បេ ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ អតិច្ឆតា ។

[១០១] តត្ថ កតមា មហិច្ឆតា ។ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារេហិ បញ្ចហិ វា កាមគុណេហិ អសន្តុដ្ឋស្ស ភិយ្យោកម្យតា យា ឯវរូបា ឥច្ឆា ឥច្ឆាគតំ(២) មហិច្ឆតា រាគោ សារាគោ ។បេ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ មហិច្ឆតា ។

---

១ ម. អត្រិច្ឆតា ។ ២ ម. ឥច្ឆាគតា ។

(១០០) បណ្ដាធម៌ទាំងនោះ សេចក្ដីប្រាថ្នាដ៏ក្រៃលែង តើដូចម្ដេច ។ សេចក្ដីប្រាថ្នាដ៏ក្រៃលែង នៃបុគ្គលមិនសន្ដោស ដោយចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ និងគិលានប្បច្ច-យភេសជ្ជបរិក្ខារ តាមមាន តាមបាន ឬដោយកាមគុណទាំង ៥ សេចក្ដីប្រាថ្នា ការប្រព្រឹត្តទៅដោយសេចក្ដីប្រាថ្នា សេចក្ដីប្រាថ្នាដ៏ក្រៃលែង តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្ដីប្រាថ្នាដ៏ក្រៃលែង ។

(១០១) បណ្ដាធម៌ទាំងនោះ សេចក្ដីប្រាថ្នាធំ តើដូចម្ដេច ។ សេចក្ដីប្រាថ្នាដ៏ក្រៃលែង នៃបុគ្គលមិនសន្ដោស ដោយចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបាន ឬដោយកាមគុណទាំង ៥ សេចក្ដីប្រាថ្នា ការប្រព្រឹត្តទៅដោយសេចក្ដីប្រាថ្នា សេចក្ដីប្រាថ្នាធំ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្ដីប្រាថ្នាធំ ។

(១០២) តត្ថ កតមា បាបិច្ឆតា ។ ឥធេកច្ចោ អស្សទ្ធោ សមានោ សទ្ធោតិ មំ ជនោ ជានាតូតិ ឥច្ឆតិ ទុស្សីលោ សមានោ សីលវាតិ មំ ជនោ ជានាតូតិ ឥច្ឆតិ អប្បស្សុតោ សមានោ ពហុស្សុតោតិ មំ ជនោ ជានាតូតិ ឥច្ឆតិ សង្គណិការាមោ សមានោ បវិវិត្តោតិ មំ ជនោ ជានាតូតិ ឥច្ឆតិ កុសីតោ សមានោ អារទ្ធវីរិយោតិ មំ ជនោ ជានាតូតិ ឥច្ឆតិ មុដ្ឋស្សតិ សមានោ ឧបដ្ឋិតស្សតីតិ មំ ជនោ ជានាតូតិ ឥច្ឆតិ អសមាហិតោ សមានោ សមាហិតោតិ មំ ជនោ ជានាតូតិ ឥច្ឆតិ ទុប្បញ្ញោ សមានោ បញ្ញវាតិ មំ ជនោ ជានាតូតិ ឥច្ឆតិ អខីណាសវោ សមានោ ខីណាសវោតិ មំ ជនោ ជានាតូតិ ឥច្ឆតិ យា ឯវរូបា ឥច្ឆា ឥច្ឆាគតា បាបិច្ឆតា រាគោ សារាគោ ។បេ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ បាបិច្ឆតា ។

(១០២) បណ្ដាធម៌ទាំងនោះ សេចក្ដីប្រាថ្នាដ៏លាមក តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនមានសទ្ធា ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកមានសទ្ធា ជាអ្នកទ្រុស្ដសីល ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកមានសីល ជាអ្នកចេះដឹងតិច ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកចេះដឹងច្រើន ជាអ្នកត្រេកអរក្នុងការប្រឡុកប្រឡល់ដោយពួក ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកស្ងប់ស្ងាត់ ជាអ្នកខ្ជិលច្រអូស ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកមានព្យាយាមប្រឹងប្រែង ជាអ្នកភ្លេចស្មារតី ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកមានស្មារតីតម្កល់ខ្ជាប់ ជាអ្នកមានចិត្តមិនតម្កល់មាំ ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកឥតបញ្ញា ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកមានបញ្ញា ជាអ្នកមិនទាន់អស់អាសវៈ ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកអស់អាសវៈ សេចក្ដីប្រាថ្នា ការប្រព្រឹត្តទៅដោយសេចក្ដីប្រាថ្នា សេចក្ដីប្រាថ្នាដ៏លាមក តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្ដីប្រាថ្នាដ៏លាមក ។

(១០៣) តត្ថ កតមំ សិង្គំ ។ យំ សិង្គំ សិង្គារតា ចតុរតា ចាតុរិយំ បរិក្ខតតា បារិក្ខត្តិយំ ឥទំ វុច្ចតិ សិង្គំ ។

(១០៤) តត្ថ កតមំ តិន្តិណំ ។ យំ តិន្តិណំ តិន្តិណាយនា តិន្តិណាយិតត្តំ លោលុប្បំ លោលុប្បាយនា លោលុប្បាយិតត្តំ បុញ្ជិកតា សាធុកម្យតា ឥទំ វុច្ចតិ តិន្តិណំ ។

(១០៥) តត្ថ កតមំ ចាបល្យំ ។ ចីវរមណ្ឌនា បត្តមណ្ឌនា សេនាសនមណ្ឌនា ឥមស្ស វា បូតិកាយស្ស ពាហិរានំ វា បរិក្ខារានំ មណ្ឌនា វិភូសនា កេឡនា បរិកេឡនា គិទ្ធិកតា គិទ្ធិកត្តំ ចបលតា ចាបល្យំ ឥទំ វុច្ចតិ ចាបល្យំ ។

ខុទ្ទកវត្ថុវិភង្គ ឯកកនិទ្ទេស

(១០៣) បណ្ដាធម៌ទាំងនោះ កិលេសជាតដូចស្នែង តើដូចម្ដេច ។ កិលេសជាតដូចស្នែង សេចក្ដីស្រឡាញ់ ការឈ្លាសវៃ សេចក្ដីឆ្លៀវឆ្លាស អាការប៉ិនប្រសប់ សេចក្ដីប៉ិនប្រសប់ ណា នេះហៅថា កិលេសជាតដូចស្នែង ។

(១០៤) បណ្ដាធម៌ទាំងនោះ សេចក្ដីតិះដៀល តើដូចម្ដេច ។ ការតិះដៀល អាការតិះដៀល ភាពនៃសេចក្ដីតិះដៀល ការលោភ អាការលោភ ភាពនៃសេចក្ដីលោភ ការស្វិតស្វាញ សេចក្ដីប្រាថ្នាល្អ ណា នេះហៅថា សេចក្ដីតិះដៀល ។

(១០៥) បណ្ដាធម៌ទាំងនោះ ការឃ្វេងឃ្វោង (ហ៊ឺហា) តើដូចម្ដេច ។ ការតាក់តែងចីវរ ការតាក់តែងបាត្រ ការតាក់តែងសេនាសនៈ ការតាក់តែង ការស្អិតស្អាង នូវកាយដ៏ស្អុយនេះក្ដី នូវបរិក្ខារទាំងឡាយខាងក្រៅក្ដី ការលេង ការប្រឡែង ការជាប់ចំពាក់ សេចក្ដីជាប់ចំពាក់ ការឃ្វេងឃ្វោង សេចក្ដីឃ្វេងឃ្វោង នេះហៅថា ការឃ្វេងឃ្វោង ។

(១០៦) តត្ថ កតមា អសភាគវុត្តិ ។ មាតរិ វា បិតរិ វា ជេដ្ឋេ វា ភាតរិ វា អាចរិយេសុ វា ឧបជ្ឈាយេ វា ពុទ្ធេ វា សាវកេសុ វា អញ្ញតរញ្ញតរេសុ គរុដ្ឋានិយេសុ វិប្បដិកូលគាហិតា វិបច្ចនីកសាតតា អនាទរិយំ អនាទរតា(១) អគារវតា អប្បដិស្សវតា អយំ វុច្ចតិ អសភាគវុត្តិ ។

(១០៧) តត្ថ កតមា អរតិ ។ បន្តេសុ វា សេនាសនេសុ អញ្ញតរញ្ញតរេសុ វា អធិកុសលេសុ ធម្មេសុ អរតិ អរតិតា អនភិរតិ អនភិរមនា ឧក្កណ្ឋិតា បរិតសិតា អយំ វុច្ចតិ អរតិ ។

(១០៨) តត្ថ កតមា តន្ទី ។ យា តន្ទី តន្ទិយនា តន្ទិមនកតា អាលស្យំ អាលសាយនា អាលសាយិតត្តំ អយំ វុច្ចតិ តន្ទី ។

(១០៩) តត្ថ កតមា វិជម្ភិកា ។ យា កាយស្ស ជម្ភនា វិជម្ភនា អានមនា វិនមនា

១ ម. អនាទរិយតា ។

[១០៦] បណ្ដាធម៌ទាំងនោះ សេចក្ដីប្រព្រឹត្តមិនស្មោះស្មើ តើដូចម្ដេច ។ ការកាន់យកដោយមិនអនុលោម ការញុំាងសុខឲ្យប្រព្រឹត្តទៅដោយកិរិយាធ្វើឲ្យជាសត្រូវ ការមិនអើពើ សេចក្ដីមិនអើពើ សេចក្ដីមិនគោរព សេចក្ដីមិនកោតក្រែង ក្នុងមាតាក្ដី ក្នុងបិតាក្ដី ក្នុងបុគ្គលច្បងក្ដី ក្នុងបងប្អូនក្ដី ក្នុងអាចារ្យទាំងឡាយក្ដី ក្នុងឧបជ្ឈាយ៍ក្ដី ក្នុងព្រះពុទ្ធក្ដី ក្នុងសាវកទាំងឡាយក្ដី ក្នុងបុគ្គលដែលគួរគោរពទាំងឡាយណាមួយក្ដី នេះហៅថា សេចក្ដីប្រព្រឹត្តមិនស្មោះស្មើ ។

[១០៧] បណ្ដាធម៌ទាំងនោះ សេចក្ដីមិនត្រេកអរ តើដូចម្ដេច ។ ការមិនត្រេកអរ អាការមិនត្រេកអរ សេចក្ដីមិនត្រេកអរចំពោះ អាការមិនត្រេកអរចំពោះ ការអផ្សុក សេចក្ដីសោប់សល់ ក្នុងសេនាសនៈដ៏ស្ងាត់ក្ដី ក្នុងធម៌ទាំងឡាយ ជាកុសលដ៏លើសលុបណាមួយក្ដី នេះហៅថា សេចក្ដីមិនត្រេកអរ ។

[១០៨] បណ្ដាធម៌ទាំងនោះ សេចក្ដីខ្ជិលច្រអូស តើដូចម្ដេច ។ ការច្រអូស អាការច្រអូស សេចក្ដីច្រអូសនៃចិត្ត ការខ្ជិល អាការខ្ជិល ភាពនៃសេចក្ដីខ្ជិល ណា នេះហៅថា សេចក្ដីខ្ជិលច្រអូស ។

[១០៩] បណ្ដាធម៌ទាំងនោះ សេចក្ដីមិតពត់ តើដូចម្ដេច ។ ការមិតពត់ ការមិតពត់រឿយៗ ការមិតពត់ទៅមុខ ការមិតពត់ទៅក្រោយ

សន្នមនា បណាមនា ព្យាធិយកំ អយំ វុច្ចតិ វិជម្ភិកា ។

(១១០) តត្ថ កតមោ ភត្តសម្មទោ ។ យា ភុត្តាវិស្ស ភត្តមុច្ឆា ភត្តកិលមថោ ភត្តបរិឡាហោ កាយទុដ្ឋុល្លំ អយំ វុច្ចតិ ភត្តសម្មទោ ។

(១១១) តត្ថ កតមំ ចេតសោ លីនត្តំ ។ យា ចិត្តស្ស អកល្យតា អកម្មញ្ញតា ឱលីយនា សល្លីយនា លីនំ លីយនា លីយិតត្តំ ថីនំ ថីយនា ថីយិតត្តំ ចិត្តស្ស ឥទំ វុច្ចតិ ចេតសោ លីនត្តំ ។

(១១២) តត្ថ កតមា កុហនា ។ លាភសក្ការសិលោកសន្និស្សិតស្ស បាបិច្ឆស្ស ឥច្ឆាបកតស្ស បច្ចយប្បដិសេវនសង្ខាតេន វា សាមន្តជប្បិតេន វា ឥរិយាបថស្ស វា(១) អដ្ឋបនា ឋបនា សណ្ឋបនា ភាកុដិកា ភាកុដិយំ កុហនា កុហាយនា កុហិតត្តំ អយំ វុច្ចតិ កុហនា ។

---

១ វាសទ្ទោ ឥធ ន ទិស្សតិ ។

ការមិតពត់ជុំវិញ ការមិតពត់ឲ្យត្រង់ ការឈឺចាប់នៃកាយ ណា នេះហៅថា សេចក្តីមិតពត់ ។

(១១០) បណ្តាធម៌ទាំងនោះ សេចក្តីស្រវឹង ព្រោះភត្ត តើដូចម្តេច ។ បុគ្គលអ្នកបរិភោគ មានសេចក្តីជ្រប់ ព្រោះភត្ត មានសេចក្តីលំបាក ព្រោះភត្ត មានសេចក្តីហេលហាល់ ព្រោះភត្ត មានភាពនៃកាយមិនគួរដល់ការងារ (ព្រោះអាស្រ័យភត្ត) ណា នេះហៅថា សេចក្តីស្រវឹង ព្រោះភត្ត ។

(១១១) បណ្តាធម៌ទាំងនោះ ភាពនៃចិត្តរួញរា តើដូចម្តេច ។ ភាពនៃចិត្តមិនគួរ ភាពនៃចិត្តមិនគួរដល់ការងារ ការរួញថយ ការរួញចូល ការលឹបល អាការលឹបល ភាពនៃសេចក្តីលឹបល ការក្រាញនៅ អាការក្រាញនៅ ភាពនៃសេចក្តីក្រាញនៅ នៃចិត្ត ណា នេះហៅថា ភាពនៃចិត្តរួញរា ។

(១១២) បណ្តាធម៌ទាំងនោះ ការកុហក តើដូចម្តេច ។ ការប្រុងប្រៀបខាងដើម អាការប្រុងប្រៀប ការរៀបចំនូវឥរិយាបថ ការធ្វើមុខស្រពោន ការមានមុខស្រពោន ការធ្វើគេឲ្យស្ញើច អាការធ្វើគេឲ្យស្ញើច ភាពនៃសេចក្តីធ្វើគេឲ្យស្ញើច ដោយការសេពនូវបច្ច័យក្តី ដោយការខ្សឹបខ្សៀវក្តី របស់ភិក្ខុអ្នកអាស្រ័យលាភសក្ការៈនិងការសរសើរ មានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា ការកុហក ។

(១១៣) តត្ថ កតមា លបនា ។ លាភសក្ការសិលោកសន្និស្សិតស្ស បាបិច្ឆស្ស ឥច្ឆាបកតស្ស យា បរេសំ អាលបនា លបនា សល្លបនា ឧល្លបនា សមុល្លបនា ឧន្នហនា សមុន្នហនា ឧក្កាបនា[១] សមុក្កាបនា[២] អនុប្បិយភាណិតា ចាដុកម្យតា មុគ្គសូប្យតា បារិភដ្យតា អយំ វុច្ចតិ លបនា ។

(១១៤) តត្ថ កតមា នេមិត្តិកតា ។ លាភសក្ការសិលោកសន្និស្សិតស្ស បាបិច្ឆស្ស ឥច្ឆាបកតស្ស យំ បរេសំ និមិត្តំ និមិត្តកម្មំ ឱភាសោ ឱភាសកម្មំ សាមន្តជប្បា បរិកថា អយំ វុច្ចតិ នេមិត្តិកតា ។

(១១៥) តត្ថ កតមា និប្បេសិកតា ។

---

១ ឱ. ម. ឧក្កាបនា ។ ២ ឱ. ម. សមុក្កាបនា ។

(១១៣) បណ្ដាធម៌ទាំងនោះ ការរួសរាយ តើដូចម្ដេច ។ ការរាក់ទាក់រក ការនិយាយរាក់ទាក់ ចំពោះជនដទៃ ការនិយាយល្បួង ការនិយាយលើក ការនិយាយបញ្ជោរ ការនិយាយចងចិត្តត្រកូល ការបញ្ចើច ការបញ្ជោរត្រកូល ការបញ្ចើចបញ្ជោរត្រកូលរឿយ ៗ ការនិយាយចាក់បណ្ដោយ ការប្រព្រឹត្តិបន្ទោរបន្ទន់កាយ ការប្រើវាចាដូចសម្លសណ្ដែកបាយ ការបីពារករបស់ត្រកូល ណា នៃភិក្ខុអ្នកអាស្រ័យលាភសក្ការៈនិងសេចក្ដីសរសើរ មានសេចក្ដីប្រាថ្នាលាមក មានសេចក្ដីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា ការរួសរាយ ។

(១១៤) បណ្ដាធម៌ទាំងនោះ ការធ្វើនូវនិមិត្ត តើដូចម្ដេច ។ និមិត្ត ការធ្វើនូវនិមិត្ត ការនិយាយបំភ្លឺ ការធ្វើនូវសេចក្ដីបញ្ចិតបញ្ចៀង ការនិយាយខ្សឹបខ្សៀវ ការនិយាយរាំសរាង ចំពោះពួកជនដទៃ ណា របស់ភិក្ខុអ្នកអាស្រ័យលាភសក្ការៈនិងការសរសើរ មានសេចក្ដីប្រាថ្នាលាមក មានសេចក្ដីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា ការធ្វើនូវនិមិត្ត ។

(១១៥) បណ្ដាធម៌ទាំងនោះ ការធ្វើនូវសេចក្ដីគម្រាម តើដូចម្ដេច ។

លាភសក្ការសិលោកសន្និស្សិតស្ស បាបិច្ឆស្ស ឥច្ឆា-
បកតស្ស យា បរេសំ អក្កោសនា វម្ភនា គរហណា
ឧក្ខេបនា សមុក្ខេបនា ខិបនា សង្ខិបនា បាបនា
សម្បាបនា អវណ្ណហារិកា បរបិដ្ឋិមំសិកតា អយំ
វុច្ចតិ និប្បេសិកតា ។

[ ១១៦ ] តត្ថ កតមា លាភេន លាភំ និជិគី-
សនតា ។ លាភសក្ការសិលោកសន្និស្សិតោ បា-
បិច្ឆោ ឥច្ឆាបកតោ ឥតោ លទ្ធំ អាមិសំ អមុត្រ
ហរតិ អមុត្រ វា លទ្ធំ អាមិសំ ឥធ អាហរតិ
យា ឯវរូបា អាមិសេន អាមិសស្ស ឯដ្ឋិ គវេដ្ឋិ
បរិយេដ្ឋិ ឯសនា គវេសនា បរិយេសនា អយំ
វុច្ចតិ លាភេន លាភំ និជិគីសនតា ។

ការដេរ (ដោយអក្ខរាសវត្ថុ ១០) ការបន្ទុះបង្អាប់ ការតិះដៀល ការនិយាយយាត់ ការនិយាយយាត់រឿយ ៗ ការនិយាយបំអកឡកឡឺយ ការនិយាយបំអកឡកឡឺយរឿយ ៗ បំពោះជនដទៃ ការញុំាងទាយកឲ្យដល់នូវទោស ការញុំាងទាយកឲ្យដល់នូវទោសរឿយ ៗ ការដឹកនាំនូវទោស ការពោលពាក្យដូចជាស៊ីសាច់ខ្នងនៃជនដទៃ ណា របស់ភិក្ខុអ្នកអាស្រ័យលាភសក្ការៈ និងសេចក្តីសរសើរ មានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា ការធ្វើនូវសេចក្តីគម្រាម ។

(១១៦) បណ្តាធម៌ទាំងនោះ ការទាក់លាភដោយលាភ តើដូចម្តេច ។ ភិក្ខុអ្នកអាស្រ័យលាភសក្ការៈនិងសេចក្តីសរសើរ មានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់ហើយ នាំយកនូវអាមិសៈដែលខ្លួនបានហើយ អំពីផ្ទះនេះទៅឲ្យផ្ទះឯណោះ ឬនាំយកនូវអាមិសៈដែលខ្លួនបានហើយ អំពីផ្ទះឯណោះ មកឲ្យផ្ទះនេះ ការប្រាថ្នា ការស្វែងរក ការស្វែងរករឿយ ៗ ការគន់រក ការរិះរក ការស្វែងរកញឹកញាប់ នូវអាមិសៈដោយអាមិសៈ មានសភាពយ៉ាងនេះ ណា នេះហៅថា ការទាក់លាភដោយលាភ ។

(១១៧) តត្ថ កតមោ សេយ្យោហមស្មីតិ មានោ ។ ឥធេកច្ចោ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជាដ្ឋានេន វា សុតេន វា បដិភាណេន វា អញ្ញតរញ្ញតរេន វត្ថុនា មានំ ជប្បេតិ យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ សេយ្យោហមស្មីតិ មានោ ។

(១១៨) តត្ថ កតមោ សទិសោហមស្មីតិ មានោ ។ ឥធេកច្ចោ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជាដ្ឋានេន វា សុតេន វា បដិភាណេន វា អញ្ញតរញ្ញតរេន វត្ថុនា មានំ ជប្បេតិ

(១១៧) បណ្ដាធម៌ទាំងនោះ សេចក្ដីប្រកាន់ថា អញប្រសើរជាងគេ តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដំឡើងមានះឲ្យប្រព្រឹត្តទៅ ដោយជាតិក្ដី ដោយគោត្រក្ដី ដោយភាពនៃខ្លួនជាកុលបុត្រក្ដី ដោយភាពនៃខ្លួនមានសម្បុរល្អក្ដី ដោយទ្រព្យក្ដី ដោយការរៀនមន្តក្ដី ដោយការងារក្ដី ដោយសិល្បសាស្ត្រក្ដី ដោយទីតាំងនៃវិជ្ជាក្ដី ដោយការចេះដឹងក្ដី ដោយបញ្ញាក្ដី ដោយវត្ថុណាមួយក្ដី ការមើលងាយគេ អាការមើលងាយគេ ភាពនៃសេចក្ដីមើលងាយគេ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្ដីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះ ណានេះហៅថា សេចក្ដីប្រកាន់ថា អញប្រសើរជាងគេ ។

(១១៨) បណ្ដាធម៌ទាំងនោះ សេចក្ដីប្រកាន់ថា អញស្មើនឹងគេ តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដំឡើងមានះឲ្យប្រព្រឹត្តទៅ ដោយជាតិក្ដី ដោយគោត្រក្ដី ដោយភាពនៃខ្លួនជាកុល-បុត្រក្ដី ដោយភាពនៃខ្លួនមានសម្បុរល្អក្ដី ដោយទ្រព្យក្ដី ដោយការរៀនមន្តក្ដី ដោយការងារក្ដី ដោយសិល្បសាស្ត្រក្ដី ដោយទីតាំងនៃវិជ្ជាក្ដី ដោយការចេះដឹងក្ដី ដោយបញ្ញាក្ដី ដោយវត្ថុណាមួយក្ដី

យោ ឯវរូបា មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ សទិសោហមស្មីតិ មានោ ។

(១១៩) តត្ថ កតមោ ហីនោហមស្មីតិ មានោ ។ ឥធេកច្ចោ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា សុតេន វា បដិភាណេន វា អញ្ញតរញ្ញតរេន វត្ថុនា ឱមានំ ជប្បេតិ យោ ឯវរូបោ ឱមានោ ឱមញ្ញនា ឱមញ្ញិតត្តំ ហីឡនា ឱហីឡនា ឱហីឡិតត្តំ អត្តុញ្ញា អត្តាវញ្ញា អត្តបរិភវោ អយំ វុច្ចតិ ហីនោហមស្មីតិ មានោ ។

ការមើលងាយគេ អាការមើលងាយគេ ភាពនៃសេចក្តីមើលងាយគេ ការធ្មេចផ្កៃ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រកាន់ថា អញស្មើនឹងគេ ។

(១១៩) បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់ថា អញថោកទាបជាងគេ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ញ៉ាំងមានះថោកថយឲ្យប្រព្រឹត្តទៅ ដោយជាតិក្តី ដោយគោត្រក្តី ដោយភាពនៃខ្លួនជាកុលបុត្រក្តី ដោយភាពនៃខ្លួនមានសម្បុរល្អក្តី ដោយទ្រព្យក្តី ដោយការរៀនមន្តក្តី ដោយការងារក្តី ដោយសិល្បសាស្ត្រក្តី ដោយទីតាំងនៃវិជ្ជាក្តី ដោយការចេះដឹងក្តី ដោយបញ្ញាក្តី ដោយវត្ថុណាមួយក្តី ការប្រកាន់ថោកថយ អាការប្រកាន់ថោកថយ ភាពនៃសេចក្តីប្រកាន់ថោកថយ ការអៀនអន់ អាការអៀនអន់ ភាពនៃសេចក្តីអៀនអន់ ការមើលងាយខ្លួន អាការមើលងាយខ្លួន ភាពនៃសេចក្តីមើលងាយខ្លួន មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រកាន់ថា អញថោកទាបជាងគេ ។

( ១២០ ) តត្ថ កតមោ សេយ្យស្ស សេយ្យោហមស្មីតិ មានោ ។ ឥធេកច្ចោ សេយ្យោ ហោតិ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា សុតេន វា បដិភាណេន វា អញ្ញតរញ្ញតរេន វត្ថុនា បរេហិ សេយ្យំ អត្តានំ ទហតិ សោ តំ និស្សាយ មានំ ជប្បេតិ យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ សេយ្យស្ស សេយ្យោហមស្មីតិ មានោ ។

( ១២១ ) តត្ថ កតមោ សេយ្យស្ស សទិសោហមស្មីតិ មានោ ។ ឥធេកច្ចោ សេយ្យោ ហោតិ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា

## អភិធម្មបិដក វិភង្គ

(១២០) បណ្ដាធម៌ទាំងនោះ សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេ ថា អញប្រសើរជាងគេ តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រសើរជាងគេ ដោយជាតិក្ដី ដោយគោត្រក្ដី ដោយភាពនៃខ្លួនជាកុលបុត្រក្ដី ដោយភាពនៃខ្លួនមានសម្បុរល្អក្ដី ដោយទ្រព្យក្ដី ដោយការរៀនមន្តក្ដី ដោយការងារក្ដី ដោយសិល្បសាស្ត្រក្ដី ដោយទីតាំងនៃវិជ្ជាក្ដី ដោយការចេះដឹងក្ដី ដោយបញ្ញាក្ដី ដោយវត្ថុណាមួយក្ដី តម្កល់ខ្លួនទុក ថា ប្រសើរជាងជនដទៃ បុគ្គលនោះញ៉ាំងមានះឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុក ថា ប្រសើរជាងជនដទៃនោះ ការមើលងាយ អាការមើលងាយ ភាពនៃសេចក្ដីមើលងាយ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្ដីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេ ថា អញប្រសើរជាងគេ ។

(១២១) បណ្ដាធម៌ទាំងនោះ សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេ ថា អញស្មើនឹងគេ តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រសើរជាងគេ ដោយជាតិក្ដី ដោយគោត្រក្ដី ដោយភាពនៃខ្លួនជាកុលបុត្រក្ដី ដោយភាពនៃខ្លួនមានសម្បុរល្អក្ដី ដោយទ្រព្យក្ដី ដោយការរៀនមន្តក្ដី ដោយការងារក្ដី ដោយសិល្បសាស្ត្រក្ដី

វិជ្ជដ្ឋានេន វា សុតេន វា បដិភាណេន វា អញ្ញ-
តរញ្ញតរេន វត្ថុនា បរេហិ សទិសំ អត្តានំ ទហតិ
សោ តំ និស្សាយ មានំ ជប្បេតិ យោ ឯវរូបោ
មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ
ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ
វុច្ចតិ សេយ្យស្ស សទិសោហមស្មីតិ មានោ ។

(១៤៤) តត្ថ កតមោ សេយ្យស្ស ហីនោ-
ហមស្មីតិ មានោ ។ ឥធេកច្ចោ សេយ្យោ
ហោតិ ជាតិយា វា គោត្តេន វា កោលបុត្តិ-
យេន វា វណ្ណបោក្ខរតាយ វា ធនេន វា
អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន
វា វិជ្ជដ្ឋានេន វា សុតេន វា បដិភាណេន វា
អញ្ញតរញ្ញតរេន វត្ថុនា បរេហិ ហីនំ អត្តានំ
ទហតិ សោ តំ និស្សាយ ឱមានំ ជប្បេតិ

ដោយទីតាំងនៃវិជ្ជាក្តី ដោយការចេះដឹងក្តី ដោយបញ្ញាក្តី ដោយវត្ថុណាមួយក្តី តម្កល់ខ្លួនទុក ថា ស្មើនឹងជនដទៃ បុគ្គលនោះញ៉ាំងមានះឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុក ថា ស្មើនឹងជនដទៃនោះ ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ ការធ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះ ណា នេះហៅ ថា សេចក្តីប្រកាន់នៃបុគ្គលប្រសើរជាងគេ ថា អញស្មើនឹងគេ ។

(១៤២) បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់នៃបុគ្គលប្រសើរជាងគេ ថា អញថោកទាបជាងគេ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រសើរជាងគេ ដោយជាតិក្តី ដោយគោត្រក្តី ដោយភាពនៃខ្លួនជាកុលបុត្រក្តី ដោយភាពនៃខ្លួនមានសម្បុរល្អក្តី ដោយទ្រព្យក្តី ដោយការរៀនមន្តក្តី ដោយការងារក្តី ដោយសិល្បសាស្ត្រក្តី ដោយទីតាំងនៃវិជ្ជាក្តី ដោយការចេះដឹងក្តី ដោយបញ្ញាក្តី ដោយវត្ថុណាមួយក្តី តម្កល់ខ្លួនទុក ថា ថោកទាបជាងជនដទៃវិញ បុគ្គលនោះ ញ៉ាំងមានះថោកទាប ឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុក ថា ថោកទាបជាងជនដទៃនោះ

យោ ឯវរូបោ ឱមានោ ឱមញ្ញនា ឱមញ្ញិតត្តំ ហីឡនា ឱហីឡនា ឱហីឡិតត្តំ អត្តុញ្ញា អត្តាវញ្ញា អត្តបរិភវោ អយំ វុច្ចតិ សេយ្យស្ស ហីនោហ-មស្មីតិ មានោ ។

[ ១២៣ ] តត្ថ កតមោ សទិសស្ស សេយ្យោហ-មស្មីតិ មានោ ។ ឥធេកច្ចោ សទិសោ ហោតិ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា ។ បេ ។ អញ្ញតរញ្ញតរេន វត្ថុនា បរេហិ សេយ្យំ អត្តានំ ទហតិ សោ តំ និស្សាយ មានំ ជប្បេតិ យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ សទិសស្ស សេយ្យោហមស្មីតិ មានោ ។

ការមើលងាយថោកទាប អាការមើលងាយថោកទាប ភាពនៃសេចក្តីមើលងាយថោកទាប ការអៀនអន់ អាការអៀនអន់ ភាពនៃសេចក្តីអៀនអន់ ការមើលងាយខ្លួន អាការមើលងាយខ្លួន ភាពនៃសេចក្តីមើលងាយខ្លួន មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រកាន់នៃបុគ្គលប្រសើរជាងគេ ថា អញថោកទាបជាងគេ ។

( ១៤៣ ) បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់នៃបុគ្គលស្មើនឹងគេ ថា អញប្រសើរជាងគេ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកស្មើនឹងគេ ដោយជាតិក្តី ដោយគោត្រក្តី ដោយភាពនៃខ្លួនជាកុលបុត្រក្តី ។ បេ ។ ដោយវត្ថុណាមួយក្តី តម្កល់ខ្លួនទុក ថា ប្រសើរជាងជនដទៃ បុគ្គលនោះញុំាងមានះឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុក ថា ប្រសើរជាងគេនោះ ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ សេចក្តីឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រកាន់នៃបុគ្គលស្មើនឹងគេ ថា អញប្រសើរជាងគេ ។

## ខុទ្ទកវត្ថុវិភង្គោ ឯកកនិទ្ទេសោ

(១២៨) តត្ថ កតមោ សទិសស្ស សទិសោហមស្មីតិ មានោ ។ ឥធេកច្ចោ សទិសោ ហោតិ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា ។បេ។ អញ្ញតរញ្ញតរេន វត្ថុនា បរេហិ សទិសំ អត្តានំ ទហតិ សោ តំ និស្សាយ មានំ ជប្បេតិ យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ សទិសស្ស សទិសោហមស្មីតិ មានោ ។

(១២៩) តត្ថ កតមោ សទិសស្ស ហីនោហមស្មីតិ មានោ ។ ឥធេកច្ចោ សទិសោ ហោតិ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា ។បេ។ អញ្ញតរញ្ញតរេន វត្ថុនា បរេហិ ហីនំ អត្តានំ ទហតិ សោ តំ និស្សាយ ឱមានំ ជប្បេតិ

## ខុទ្ទកវត្ថុវិភង្គ ឯកកនិទ្ទេស

(១២៧) បណ្ដាធម៌ទាំងនោះ សេចក្ដីប្រកាន់នៃបុគ្គលស្មើនឹងគេ ថា អញស្មើនឹងគេ តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកស្មើនឹងគេ ដោយជាតិក្ដី ដោយគោត្រក្ដី ដោយភាពនៃខ្លួនជាកុលបុត្រក្ដី ។ បេ ។ ដោយវត្ថុណាមួយក្ដី តម្កល់ខ្លួនទុក ថា ស្មើនឹងជនដទៃ បុគ្គលនោះញុំាងមានះឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុក ថា ស្មើនឹងជនដទៃនោះ ការមើលងាយ អាការមើលងាយ ភាពនៃសេចក្ដីមើលងាយ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្ដីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្ដីប្រកាន់នៃបុគ្គលស្មើនឹងគេ ថា អញស្មើនឹងគេ ។

(១២៨) បណ្ដាធម៌ទាំងនោះ សេចក្ដីប្រកាន់នៃបុគ្គលស្មើនឹងគេ ថា អញថោកទាបជាងគេ តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកស្មើនឹងគេ ដោយជាតិក្ដី ដោយគោត្រក្ដី ដោយភាពនៃខ្លួនជាកុលបុត្រក្ដី ។ បេ ។ ដោយវត្ថុណាមួយក្ដី តម្កល់ខ្លួនទុក ថា ថោកទាបជាងជនដទៃវិញ បុគ្គលនោះញុំាងមានះថោកទាបឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុក ថា ថោកទាបជាងជនដទៃនោះ

យោ ឯវរូបោ ឱមានោ ឱមញ្ញនា ឱមញ្ញិតត្តំ ហីឡនា ឱហីឡនា ឱហីឡិតត្តំ អត្តុញ្ញា អត្តាវញ្ញា អត្តបរិភវោ អយំ វុច្ចតិ សទិសស្ស ហីនោហមស្មីតិ មានោ ។

(១៦៦) តត្ថ កតមោ ហីនស្ស សេយ្យោហមស្មីតិ មានោ ។ ឥធេកច្ចោ ហីនោ ហោតិ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា ។បេ។ អញ្ញតរញ្ញតរេន វត្ថុនា បរេហិ សេយ្យំ អត្តានំ ទហតិ សោ តំ និស្សាយ មានំ ជប្បេតិ យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ ហីនស្ស សេយ្យោហមស្មីតិ មានោ ។

ការមើលងាយថោកទាប អាការមើលងាយថោកទាប ភាពនៃសេចក្តីមើលងាយថោកទាប ការអៀនអន់ អាការអៀនអន់ ភាពនៃសេចក្តីអៀនអន់ ការមើលងាយខ្លួន អាការមើលងាយខ្លួន ភាពនៃសេចក្តីមើលងាយខ្លួន មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រកាន់ នៃបុគ្គលស្មើនឹងគេ ថា អញថោកទាបជាងគេ ។

( ១២៦ ) បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់នៃបុគ្គលថោកទាបជាងគេ ថា អញប្រសើរជាងគេ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកថោកទាបជាងគេ ដោយជាតិក្តី ដោយគោត្រក្តី ដោយភាពនៃខ្លួនជាកុលបុត្រក្តី ។ បេ ។ ដោយវត្ថុណាមួយក្តី តម្កល់ខ្លួនទុក ថា ប្រសើរជាងជនដទៃ បុគ្គលនោះ ញុំាងមានះឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យ នូវការតម្កល់ខ្លួនទុក ថា ប្រសើរជាងជនដទៃនោះ ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ ការធ្វើឫក អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រកាន់ នៃបុគ្គលថោកទាបជាងគេ ថា អញប្រសើរជាងគេ ។

(១៤៧) តត្ថ កតមោ ហីនស្ស សទិសោហមស្មីតិ មានោ ។ ឥធេកច្ចោ ហីនោ ហោតិ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា ។ បេ ។ អញ្ញតរញ្ញតរេន វត្ថុនា បរេហិ សទិសំ អត្តានំ ទហតិ សោ តំ និស្សាយ មានំ ជប្បេតិ យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ ហីនស្ស សទិសោហមស្មីតិ មានោ ។

(១៤៨) តត្ថ កតមោ ហីនស្ស ហីនោហមស្មីតិ មានោ ។ ឥធេកច្ចោ ហីនោ ហោតិ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា ។ បេ ។ អញ្ញតរញ្ញតរេន វត្ថុនា បរេហិ ហីនំ អត្តានំ ទហតិ

## ខុទ្ទកវត្ថុវិភង្គ ឯកកនិទ្ទេស

( ១៦៧ ) បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់ នៃបុគ្គលថោកទាបជាងគេ ថា អញស្មើនឹងគេ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកថោកទាបជាងគេ ដោយជាតិក្តី ដោយគោត្រក្តី ដោយភាពនៃខ្លួនជាកុលបុត្រក្តី ។ បេ ។ ដោយវត្ថុណាមួយក្តី តម្កល់ខ្លួនទុក ថា ស្មើនឹងជនដទៃ បុគ្គលនោះ ញុំាងមានះឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុក ថា ស្មើនឹងជនដទៃនោះ ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រកាន់នៃបុគ្គលថោកទាបជាងគេ ថា អញស្មើនឹងគេ ។

( ១៦៨ ) បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់ នៃបុគ្គលថោកទាបជាងគេ ថា អញថោកទាបជាងគេ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកថោកទាបជាងគេ ដោយជាតិក្តី ដោយគោត្រក្តី ដោយភាពនៃខ្លួនជាកុលបុត្រក្តី ។ បេ ។ ដោយវត្ថុណាមួយក្តី តម្កល់ខ្លួនទុក ថា ថោកទាបជាងជនដទៃ

សោ តំ និស្សាយ ឱមានំ ជប្បេតិ យោ ឯវរូបោ ឱមានោ ឱមញ្ញនា ឱមញ្ញិតត្តំ ហីឡនា ឱហីឡនា ឱហីឡិតត្តំ អត្តុញ្ញា អត្តាវញ្ញា អត្តបរិភវោ អយំ វុច្ចតិ ហីនស្ស ហីនោហមស្មីតិ មានោ ។

(១២៩) តត្ថ កតមោ មានោ ។ យោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ មានោ ។

(១៣០) តត្ថ កតមោ អតិមានោ ។ ឥធេកច្ចោ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា ។ បេ ។ អញ្ញតរញ្ញតរេន វត្ថុនា បរេ អតិមញ្ញតិ យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ

បុគ្គលនោះ ញុំាងមានះដ៏ថោកទាប ឲ្យប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវការតម្កល់ខ្លួនទុក ថា ថោកទាបជាងជនដទៃនោះ ការមើលងាយថោកទាប អាការមើលងាយថោកទាប ភាពនៃសេចក្តីមើលងាយថោកទាប ការអៀនអន់ អាការអៀនអន់ ភាពនៃសេចក្តីអៀនអន់ ការមើលងាយខ្លួន អាការមើលងាយខ្លួន ភាពនៃសេចក្តីមើលងាយខ្លួន មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រកាន់នៃបុគ្គលថោកទាបជាងគេ ថា អញថោកទាបជាងគេ ។

[១៦៩] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់ តើដូចម្តេច ។ ការប្រកាន់ អាការប្រកាន់ ភាពនៃសេចក្តីប្រកាន់ ការធ្មេងធ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ ណា នេះហៅថា សេចក្តីប្រកាន់ ។

[១៧០] បណ្តាធម៌ទាំងនោះ សេចក្តីមើលងាយគេ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងមើលងាយបុគ្គល ទាំង-ឡាយដទៃ ដោយជាតិក្តី ដោយគោត្រក្តី ដោយភាពនៃខ្លួនជាកុល-បុត្រក្តី ។ បេ ។ ដោយវត្ថុណាមួយក្តី ការមើលងាយ អាការមើលងាយ ភាពនៃសេចក្តីមើលងាយ ការធ្មេងធ្មៃ អាការព្រហើន

ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ អតិមានោ ។

(១៣១) តត្ថ កតមោ មានាតិមានោ ។ ឥធេកច្ចោ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា ។ បេ ។ អញ្ញតរញ្ញតរេន វត្ថុនា បុព្វកាលំ បរេហិ សទិសំ អត្តានំ ទហតិ អបរកាលំ អត្តានំ សេយ្យំ ទហតិ បរេហិ ហីនំ ន ទហតិ យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ មានាតិមានោ ។

(១៣២) តត្ថ កតមោ ឱមានោ ។ ឥធេកច្ចោ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា

ភាពដូចជាទង់ ការលើកកំពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីមើលងាយគេ ។

[១៧១] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់ក្រៃលែង តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ កាលមុន តម្កល់ខ្លួនទុក ថា ស្មើនឹងជនដទៃ កាលជាខាងក្រោយមក តម្កល់ខ្លួនទុក ថា ប្រសើរជាងជនដទៃវិញ មិនតម្កល់ខ្លួនទុក ថា ថោកទាបជាងជនដទៃ ដោយជាតិក្តី ដោយគោត្រក្តី ដោយភាពនៃខ្លួនជាកុលបុត្រក្តី ។ បេ ។ ដោយវត្ថុណាមួយក្តី ការប្រកាន់ អាការប្រកាន់ ភាពនៃសេចក្តីប្រកាន់ ការឡើងខ្ពស់ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រកាន់ក្រៃលែង ។

[១៧២] បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់ថោកថយ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ញុំាងមានះឲ្យប្រព្រឹត្តទៅ ដោយជាតិក្តី ដោយគោត្រក្តី ដោយភាពនៃខ្លួនជាកុលបុត្រក្តី ដោយភាពនៃខ្លួនមានសម្បុរល្អក្តី ដោយទ្រព្យក្តី ដោយការរៀនមន្តក្តី ដោយការងារក្តី ដោយសិល្បសាស្ត្រក្តី ដោយទីតាំងនៃវិជ្ជាក្តី

សុតេន វា បដិភានេន វា អញ្ញតរញ្ញតរេន វត្ថុនា ឱមានំ ជប្បេតិ យោ ឯវរូបោ ឱមានោ ឱមញ្ញនា ឱមញ្ញិតត្តំ ហីឡនា ឱហីឡនា ឱហីឡិ-តត្តំ អត្តុញ្ញា អត្តាវញ្ញា អត្តបរិភវោ អយំ វុច្ចតិ ឱមានោ ។

(១៣៣) តត្ថ កតមោ អធិមានោ ។ អប្បត្តេ បត្តសញ្ញិតា អកតេ កតសញ្ញិតា អនធិគតេ អធិគតសញ្ញិតា អសច្ឆិកតេ សច្ឆិកតសញ្ញិតា យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧន្នតិ ឧន្នាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ អធិមានោ ។

(១៣៤) តត្ថ កតមោ អស្មិមានោ ។ រូបេ អស្មីតិ មានោ អស្មីតិ ឆន្ទោ អស្មីតិ អនុសយោ

ដោយការចេះដឹងក្តី ដោយបញ្ញាក្តី ដោយវត្ថុណាមួយក្តី ការប្រកាន់ដ៏ថោកថយ អាការប្រកាន់ដ៏ថោកថយ ភាពនៃសេចក្តីប្រកាន់ដ៏ថោកថយ ការអៀនអន់ អាការអៀនអន់ ភាពនៃសេចក្តីអៀនអន់ ការមើលងាយខ្លួន អាការមើលងាយខ្លួន ភាពនៃសេចក្តីមើលងាយខ្លួន មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រកាន់ថោកថយ ។

(១៣៣) បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់លើសលុប តើដូចម្តេច ។ សេចក្តីសំគាល់ក្នុងសច្ចៈទាំង ៤ ដែលខ្លួនមិនទាន់ដល់ ថា បានដល់ហើយ សេចក្តីសំគាល់ក្នុងកិច្ច ដែលខ្លួនមិនទាន់ធ្វើ ថា បានធ្វើហើយ សេចក្តីសំគាល់ក្នុងសច្ចៈទាំង ៤ ដែលខ្លួនមិនទាន់ត្រាស់ដឹង ថា បានត្រាស់ដឹងហើយ សេចក្តីសំគាល់ក្នុងសច្ចៈទាំង ៤ ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ហើយ ថា បានធ្វើឲ្យជាក់ច្បាស់ហើយ ការប្រកាន់ អាការប្រកាន់ ភាពនៃសេចក្តីប្រកាន់ ការឆ្មើងឆ្មៃ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រកាន់លើសលុប ។

(១៣៤) បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់ ថា អញមាន តើដូចម្តេច ។ សេចក្តីប្រកាន់ ក្នុងរូប ថា អញមាន សេចក្តីពេញចិត្ត ក្នុងរូប ថា អញមាន អនុស័យ ក្នុងរូប ថា អញមាន

វេទនាយ ។ បេ ។ សញ្ញាយ ។ បេ ។ សង្ខារេសុ ។ បេ ។ វិញ្ញាណេ អស្មីតិ មានោ អស្មីតិ ឆន្ទោ អស្មីតិ អនុសយោ យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ អស្មិមានោ ។

(៨៣៨) តត្ថ កតមោ មិច្ឆាមានោ ។ ឥធេកច្ចោ បាបកេន វា កម្មាយតនេន បាបកេន វា សិប្បាយតនេន បាបកេន វា វិជ្ជដ្ឋានេន បាបកេន វា សុតេន បាបកេន វា បដិភាណេន បាបកេន វា សីលេន បាបកេន វា វតេន បាបកេន វា សីលព្វតេន បាបិកាយ វា ទិដ្ឋិយា អញ្ញតរញ្ញតរេន វត្ថុនា មានំ ជប្បេតិ យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ មិច្ឆាមានោ ។

សេចក្តីប្រកាន់ ក្នុងវេទនា ។ បេ ។ ក្នុងសញ្ញា ។ បេ ។ ក្នុងសង្ខារទាំងឡាយ ។ បេ ។ ក្នុងវិញ្ញាណ ថា អញមាន សេចក្តីពេញចិត្ត ក្នុងវិញ្ញាណ ថា អញមាន អនុស័យ ក្នុងវិញ្ញាណ ថា អញមាន ការប្រកាន់ អាការប្រកាន់ ភាពនៃសេចក្តីប្រកាន់ ការឆ្ងើងឆ្ងៃ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រកាន់ ថា អញមាន ។

( ១៣៩ ) បណ្តាធម៌ទាំងនោះ សេចក្តីប្រកាន់ខុស តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ញុំាងមានះ ឲ្យប្រព្រឹត្តទៅ ដោយការងារដ៏លាមកក្តី ដោយសិល្បសាស្ត្រដ៏លាមកក្តី ដោយទីតាំងនៃវិជ្ជាដ៏លាមកក្តី ដោយការចេះដឹងដ៏លាមកក្តី ដោយបញ្ញាដ៏លាមកក្តី ដោយសីលដ៏លាមកក្តី ដោយវត្តដ៏លាមកក្តី ដោយសីលនិងវត្តដ៏លាមកក្តី ដោយទិដ្ឋិដ៏លាមកក្តី ដោយវត្ថុណាមួយក្តី ការប្រកាន់ អាការប្រកាន់ ភាពនៃសេចក្តីប្រកាន់ ការឆ្ងើងឆ្ងៃ អាការព្រហើន ភាពដូចជាទង់ ការលើកកំពស់ សេចក្តីប្រាថ្នានៃចិត្តដូចជាទង់ មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រកាន់ខុស ។

(១៣៦) តត្ថ កតមោ ញាតិវិតក្កោ ។ ញាតកេ អារព្ភ គេហសិតោ តក្កោ វិតក្កោ ។ បេ ។ មិច្ឆាសង្កប្បោ អយំ វុច្ចតិ ញាតិវិតក្កោ ។

(១៣៧) តត្ថ កតមោ ជនបទវិតក្កោ ។ ជនបទំ អារព្ភ គេហសិតោ តក្កោ វិតក្កោ ។បេ។ មិច្ឆាសង្កប្បោ អយំ វុច្ចតិ ជនបទវិតក្កោ ។

(១៣៨) តត្ថ កតមោ អមរវិតក្កោ ។ ទុក្ករការិកាបដិសំយុត្តោ វា ទិដ្ឋិគតប្បដិសំយុត្តោ វា គេហសិតោ តក្កោ វិតក្កោ ។ បេ ។ មិច្ឆាសង្កប្បោ អយំ វុច្ចតិ អមរវិតក្កោ ។

(១៣៩) តត្ថ កតមោ បរានុទយតាបដិសំយុត្តោ វិតក្កោ ។ ឥធេកច្ចោ គិហីហិ សំសដ្ឋោ វិហរតិ សហនន្ទី សហសោកី សុខិតេសុ សុខិតោ

## អភិធម្មបិដក វិភង្គ

( ១៣៦ ) បណ្ដាធម៌ទាំងនោះ សេចក្ដីនឹកដល់ញាតិ តើដូចម្ដេច ។ សេចក្ដីនឹក សេចក្ដីជញ្ជឹង ។បេ។ សេចក្ដីត្រិះរិះខុស អាស្រ័យនូវផ្ទះ គឺកាមគុណ ៥ ប្រារព្ធពួកញាតិ នេះហៅថា សេចក្ដីនឹកដល់ញាតិ ។

( ១៣៧ ) បណ្ដាធម៌ទាំងនោះ សេចក្ដីនឹកដល់ជនបទ តើដូចម្ដេច ។ សេចក្ដីនឹក សេចក្ដីជញ្ជឹង ។បេ។ សេចក្ដីត្រិះរិះខុស អាស្រ័យនូវផ្ទះ គឺកាមគុណ ៥ ប្រារព្ធជនបទ នេះហៅថា សេចក្ដីនឹកដល់ជនបទ ។

( ១៣៨ ) បណ្ដាធម៌ទាំងនោះ សេចក្ដីនឹកដល់ការមិនស្លាប់ តើដូចម្ដេច ។ សេចក្ដីនឹក សេចក្ដីជញ្ជឹង ។បេ។ សេចក្ដីត្រិះរិះខុស អាស្រ័យនូវផ្ទះ គឺកាមគុណ ៥ មិនប្រកបដោយអំពើដែលបុគ្គលធ្វើបានដោយកម្រក្ដី ប្រកបដោយទិដ្ឋិក្ដី នេះហៅថា សេចក្ដីនឹកដល់ការមិនស្លាប់ ។

(១៣៩) បណ្ដាធម៌ទាំងនោះ សេចក្ដីនឹកប្រកបដោយសេចក្ដីអាណិតអាសូរដល់អ្នកដទៃ តើដូចម្ដេច ។ ភិក្ខុពួកខ្លះ ក្នុងលោកនេះ នៅប្រឡូកប្រឡំដោយគ្រហស្ថ មានសេចក្ដីត្រេកអរជាមួយគ្នា មានសេចក្ដីសោកជាមួយគ្នា កាលបើគ្រហស្ថដល់នូវសេចក្ដីសុខ ខ្លួនក៏ដល់នូវសេចក្ដីសុខ

ទុក្ខិតេសុ ទុក្ខិតោ ឧប្បន្នេសុ កិច្ចករណីយេសុ អត្តនា វា យោគំ អាបជ្ជតិ យោ តត្ថ គេហសិតោ តក្កោ វិតក្កោ ។បេ។ មិច្ឆាសង្កប្បោ អយំ វុច្ចតិ បរានុទ្ទយតាបដិសំយុត្តោ វិតក្កោ ។

(១៦០) តត្ថ កតមោ លាភសក្ការសិលោកបដិសំយុត្តោ វិតក្កោ ។ លាភសក្ការសិលោកំ អារព្ភ គេហសិតោ តក្កោ វិតក្កោ ។បេ។ មិច្ឆាសង្កប្បោ អយំ វុច្ចតិ លាភសក្ការសិលោកបដិសំយុត្តោ វិតក្កោ ។

(១៦១) តត្ថ កតមោ អនវញ្ញត្តិបដិសំយុត្តោ វិតក្កោ ។ ឥធេកច្ចោ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា សុតេន វា បដិភានេន វា អញ្ញតរញ្ញតរេន វត្ថុនា មា មំ បរេ អវជានិំសូតិ យោ តត្ថ គេហសិតោ តក្កោ វិតក្កោ ។បេ។

ដែរ កាលបើគ្រហស្ថដល់នូវសេចក្ដីទុក្ខ ខ្លួនក៏ដល់នូវសេចក្ដីទុក្ខដែរ កាលបើគ្រហស្ថមានកិច្ច ដែលគួរធ្វើកើតឡើងហើយ ក៏ដល់នូវការជួយប្រកបដោយខ្លួនឯងដែរ សេចក្ដីទឹក សេចក្ដីជញ្ជឹន ។ បេ ។ សេចក្ដីត្រិះរិះខុស អាស្រ័យនូវផ្ទះ គឺកាមគុណ ៥ ក្នុងកិច្ចអម្បាលនោះណា នេះហៅថា សេចក្ដីទឹក ប្រកបដោយសេចក្ដីអាណិតអាសូរដល់អ្នកដទៃ ។

( ១៦០ ) បណ្ដាធម៌ទាំងនោះ សេចក្ដីទឹក ប្រកបដោយលាភសក្ការៈនិងសេចក្ដីសរសើរ តើដូចម្ដេច ។ សេចក្ដីទឹក សេចក្ដីជញ្ជឹន ។ បេ ។ សេចក្ដីត្រិះរិះខុស អាស្រ័យនូវផ្ទះគឺកាមគុណ៥ ប្រាថ្នាលាភសក្ការៈនិងសេចក្ដីសរសើរ នេះហៅថា សេចក្ដីទឹក ប្រកបដោយលាភសក្ការៈនិងសេចក្ដីសរសើរ ។

( ១៦១ ) បណ្ដាធម៌ទាំងនោះ សេចក្ដីទឹក ប្រកបដោយការណ៍ដែលគេមើលងាយមិនបាន តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ គិតថា ជនដទៃ កុំមើលងាយអញ ដោយជាតិក្ដី ដោយគោត្រក្ដី ដោយភាពនៃខ្លួនជាកុលបុត្រក្ដី ដោយភាពនៃខ្លួនមានសម្បុរល្អក្ដី ដោយទ្រព្យក្ដី ដោយការរៀនមន្តក្ដី ដោយការងារក្ដី ដោយសិល្បសាស្ត្រក្ដី ដោយទីតាំងនៃវិជ្ជាក្ដី ដោយការចេះដឹងក្ដី ដោយបញ្ញាក្ដី ដោយវត្ថុណាមួយក្ដី សេចក្ដីទឹក សេចក្ដីជញ្ជឹន ។ បេ ។

មិច្ឆាសង្កប្បោ អយំ វុច្ចតិ អនវញ្ញត្តិប្បដិសំយុត្តោ វិតក្កោ ។

ឯកកំ ។

(១៤២) តត្ថ កតមោ កោធោ ។ យោ កោធោ កុជ្ឈនា កុជ្ឈិតត្តំ ទោសោ ទុស្សនា ទុស្សិតត្តំ ព្យាបត្តិ ព្យាបជ្ជនា ព្យាបជ្ជិតត្តំ វិរោធោ បដិវិរោធោ ចណ្ឌិក្កំ អសុរោបោ អនត្តមនតា ចិត្តស្ស អយំ វុច្ចតិ កោធោ ។ តត្ថ កតមោ ឧបនាហោ ។ បុព្វកាលំ កោធោ អបរកាលំ ឧបនាហោ យោ ឯវរូបោ ឧបនាហោ ឧបនហនា ឧបនាហិតត្តំ អដ្ឋបនា ឋបនា សណ្ឋបនា អនុសំសន្ទនា អនុប្បពន្ធនា ទឡ្ហីកម្មំ កោធស្ស អយំ វុច្ចតិ ឧបនាហោ ។

សេចក្ដីត្រិះរិះខុស អាស្រ័យនូវផ្ទះ គឺកាមគុណ ៥ ក្នុងគំនិតថា ជនដទៃ កុំមើលងាយអញនោះ ណា នេះហៅថា សេចក្ដីទឹកប្រកបដោយការណ៍ដែលគេមើលងាយមិនបាន ។

ចប់ ធម៌ពួក ទី ១ ។

(១៤២) បណ្ដាធម៌ទាំងនោះ សេចក្ដីក្រោធ តើដូចម្ដេច ។ ការក្រោធ អាការក្រោធ ភាពនៃសេចក្ដីក្រោធ ការប្រទូស្ដ អាការប្រទូស្ដ ភាពនៃសេចក្ដីប្រទូស្ដ ការព្យាបាទ អាការព្យាបាទ ភាពនៃសេចក្ដីព្យាបាទ សេចក្ដីខឹង សេចក្ដីខឹងខ្លាំង សេចក្ដីសាប ការខឹង សេចក្ដីអាក់អន់ចិត្ត ណា នេះហៅថា សេចក្ដីក្រោធ ។ បណ្ដាធម៌ទាំងនោះ ការចងសេចក្ដីក្រោធទុក តើដូចម្ដេច ។ សេចក្ដីក្រោធ ក្នុងកាលជាខាងដើម ការចងសេចក្ដីក្រោធទុក ក្នុងកាលជាខាងក្រោយ ការចងសេចក្ដីក្រោធទុក អាការចងសេចក្ដីក្រោធទុក ភាពនៃការចងសេចក្ដីក្រោធទុក ការតម្កល់សេចក្ដីក្រោធ ទុកជាលំដាប់ ការតម្កល់សេចក្ដីក្រោធទុកជាប្រក្រតី ការតម្កល់សេចក្ដីក្រោធទុករឿយ ៗ ការប្រៀបផ្ទឹម[១]រឿយ ៗ ការចងទុក[២]រឿយ ៗ ការធ្វើសេចក្ដីក្រោធឲ្យមាំ ណា នេះហៅថា ការចងសេចក្ដីក្រោធទុក ។

---

១ ការមិនសំដែងទោសជាមួយនឹងសេចក្ដីក្រោធ ដែលកើតឡើងជាដំបូង ហើយលបធ្វើដោយការសម្ងាត់ ។ ២ ការតសេចក្ដីក្រោធខាងក្រោយ ជាមួយនឹងសេចក្ដីក្រោធខាងដើម ។អដ្ឋកថា។

(១៤៣) តត្ថ កតមោ មក្ខោ ។ យោ មក្ខោ មក្ខិយនា មក្ខិយិតត្តំ និដ្ឋុរិយំ និដ្ឋុរិយកម្មំ អយំ វុច្ចតិ មក្ខោ ។ តត្ថ កតមោ បឡាសោ ។ យោ បឡាសោ បឡាសាយនា បឡាសាយិតត្តំ បឡាសាហារោ វិវាទដ្ឋានំ យុគ្គាហោ អប្បដិនិស្សគ្គោ អយំ វុច្ចតិ បឡាសោ ។

(១៤៤) តត្ថ កតមា ឥស្សា ។ យា បរលាភសក្ការគរុការមាននវន្ទនបូជនាសុ ឥស្សា ឥស្សាយនា ឥស្សាយិតត្តំ ឧសូយា ឧសូយនា ឧសូយិតត្តំ អយំ វុច្ចតិ ឥស្សា ។ តត្ថ កតមំ មច្ឆរិយំ ។ បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ យំ ឯវរូបំ មច្ឆេរំ មច្ឆរាយនា មច្ឆរាយិតត្តំ វេវិច្ឆំ កទរិយំ កដុកញ្ចុកតា អគ្គហិតត្តំ ចិត្តស្ស ឥទំ វុច្ចតិ មច្ឆរិយំ ។

## ខុទ្ទកវត្ថុវិភង្គ ទុកនិទ្ទេស

(១៨៣) បណ្ដាធម៌ទាំងនោះ សេចក្ដីលុបគុណ តើដូចម្ដេច ។ ការលុបគុណ អាការលុបគុណ ភាពនៃសេចក្ដីលុបគុណ សេចក្ដីវេវឃ្លើគុណ ការធ្វើនូវសេចក្ដីវេវឃ្លើគុណ ណា នេះហៅថា សេចក្ដីលុបគុណ ។ បណ្ដាធម៌ទាំងនោះ ការវាយឫកស្មើ តើដូចម្ដេច ។ ការលើកខ្លួនផ្ទឹម អាការលើកខ្លួនផ្ទឹម ភាពនៃសេចក្ដីលើកខ្លួនផ្ទឹម ការប្រណាំងវាសនា ហេតុនៃសេចក្ដីវិវាទ ការប្រកាន់ជាគូ ការមិនលះបង់ ណា នេះហៅថា ការវាយឫកស្មើ ។

(១៨៤) បណ្ដាធម៌ទាំងនោះ សេចក្ដីច្រណែន តើដូចម្ដេច ។ ការច្រណែន អាការច្រណែន ភាពនៃសេចក្ដីច្រណែន ការឈ្នានីស អាការឈ្នានីស ភាពនៃសេចក្ដីឈ្នានីស ណា ក្នុងលាភសក្ការៈ សេចក្ដីគោរព ការរាប់អាន ការថ្វាយបង្គំ និងការបូជារបស់ជនដទៃ នេះហៅថា សេចក្ដីច្រណែន ។ បណ្ដាធម៌ទាំងនោះ សេចក្ដីកំណាញ់ តើដូចម្ដេច ។ សេចក្ដីកំណាញ់ ៥ យ៉ាង គឺ កំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់សេចក្ដីសរសើរ ១ កំណាញ់ធម៌ ១ ការកំណាញ់ អាការកំណាញ់ ភាពនៃសេចក្ដីកំណាញ់ សេចក្ដីប្រាថ្នាផ្សេងៗ សេចក្ដីកំណាញ់រឹង សេចក្ដីកំណាញ់ស្វិត ភាពនៃចិត្តមិនយកចិត្តគេ មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្ដីកំណាញ់ ។

## អភិធម្មបិដកេ វិភង្គោ

(១៤៨) តត្ថ កតមា មាយា ។ ឥធេកច្ចោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា តស្ស បដិច្ឆាទនហេតុ បាបិកំ ឥច្ឆំ បណិទហតិ មា មំ ជញ្ញាតិ ឥច្ឆតិ មា មំ ជញ្ញាតិ សង្កប្បេតិ មា មំ ជញ្ញាតិ វាចំ ភាសតិ មា មំ ជញ្ញាតិ កាយេន បរក្កមតិ យា ឯវរូបា មាយា មាយាវិតា អច្ចាសរា វញ្ចនា និកតិ និកិរណា បរិហរណា កុហនា បរិកុហនា ឆាទនា បដិច្ឆាទនា អនុត្តានីកម្មំ អនាវិកម្មំ វោច្ឆាទនា បាបកិរិយា អយំ វុច្ចតិ មាយា ។ តត្ថ កតមំ សាឋេយ្យំ ។ ឥធេកច្ចោ សឋោ ហោតិ បរិសឋោ យំ តត្ថ សឋំ សឋតា សាឋេយ្យំ កក្ករតា កក្ករិយំ បរិក្ខត្តតា បារិក្ខត្តិយំ ឥទំ វុច្ចតិ សាឋេយ្យំ ។

[ ១៨៩ ] បណ្តាធម៌ទាំងនោះ សេចក្តីបិទបាំងទោសរបស់ខ្លួន តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តម្កល់ទុកនូវសេចក្តីប្រាថ្នាដ៏លាមក ព្រោះបិទបាំងនូវអំពើទុច្ចរិតនោះ ជាហេតុ ប្រាថ្នាថា ពួកជនដទៃ កុំដឹងនូវអាត្មាអញឡើយ ត្រិះរិះថា ពួកជនដទៃ កុំដឹងនូវអាត្មាអញឡើយ ពោលវាចាថា ពួកជនដទៃ កុំដឹងនូវអាត្មាអញឡើយ ខ្នះខ្នែងដោយកាយថា ពួកជនដទៃ កុំដឹងនូវអាត្មាអញឡើយ ការបិទបាំងទោសរបស់ខ្លួន ភាពនៃបុគ្គលបិទបាំងទោសរបស់ខ្លួន ការធ្វើនូវអំពើអាក្រក់ហើយបិទបាំងទុកឲ្យកន្លងហួសទៅ ការបញ្ឆោត ការបោកប្រាស ការគេចវៃ ការពង្វេះពង្វាង ការបិទបាំង ការលាក់បំពួន ការគ្របទុក ការគ្របលុប ការមិនធ្វើឲ្យច្បាស់ ការមិនធ្វើឲ្យប្រាកដ ការបិទបាំងខ្ជាំង ការធ្វើនូវអំពើអាក្រក់ មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីបិទបាំងទោសរបស់ខ្លួន ។ បណ្តាធម៌ទាំងនោះ សេចក្តីអួតអាង តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកអួតអាង ជាអ្នកអួតអាងខ្លាំង ការអួតអាង អាការអួតអាង សេចក្តីអួតអាង សេចក្តីរឹងរូស អាការរឹងរូស អាការប៉ិនប្រសប់ សេចក្តីប៉ិនប្រសប់ មានក្នុងបុគ្គលនោះ ណា នេះហៅថា សេចក្តីអួតអាង ។

[១៦៦] តត្ថ កតមា អវិជ្ជា ។ យំ អញ្ញាណំ អទស្សនំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ អវិជ្ជា ។ តត្ថ កតមា ភវតណ្ហា ។ យោ ភវេសុ ភវច្ឆន្ទោ ភវរាគោ ភវនន្ទី ភវតណ្ហា ភវសិនេហោ ភវបរិឡាហោ ភវមុច្ឆា ភវជ្ឈោសានំ អយំ វុច្ចតិ ភវតណ្ហា ។

[១៦៧] តត្ថ កតមា ភវទិដ្ឋិ ។ ភវិស្សតិ អត្តា ច លោកោ ចាតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ ភវទិដ្ឋិ ។ តត្ថ កតមា វិភវទិដ្ឋិ ។ ន ភវិស្សតិ អត្តា ច លោកោ ចាតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ វិភវទិដ្ឋិ ។

## ខុទ្ទកវត្ថុវិភង្គ ទុកនិទ្ទេស

(១៤៦) បណ្ដាធម៌ទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនយល់ ។ បេ ។ គន្លឹះគឺអវិជ្ជា សេចក្ដីវង្វេងឫសគល់នៃអកុសល ណា នេះហៅ អវិជ្ជា ។ បណ្ដាធម៌ទាំងនោះ ភវតណ្ហា តើដូចម្ដេច ។ សេចក្ដីប្រាថ្នាភព ក្នុងភពទាំងឡាយ តម្រេក ក្នុងភព សេចក្ដីស្រើបស្រាល ក្នុងភព សេចក្ដីប្រាថ្នា ក្នុងភព សេចក្ដីស្នេហា ក្នុងភព សេចក្ដីអន្ទះអន្ទែង ក្នុងភព សេចក្ដីជ្រប់ ក្នុងភព ការចុះចិត្តស៊ប់ ក្នុងភព ក្នុងភពទាំងឡាយ ណា នេះហៅថា ភវតណ្ហា ។

(១៤៧) បណ្ដាធម៌ទាំងនោះ ភវទិដ្ឋិ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា ថា ខ្លួនក្ដី លោកក្ដី នឹងមាន នេះហៅថា ភវទិដ្ឋិ ។ បណ្ដាធម៌ទាំងនោះ វិភវទិដ្ឋិ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា ថា ខ្លួនក្ដី លោកក្ដី នឹងមិនមាន នេះហៅថា វិភវទិដ្ឋិ ។

(១៤៨) តត្ថ កតមា សស្សតទិដ្ឋិ ។ សស្សតោ អត្តា ច លោកោ ចាតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ សស្សតទិដ្ឋិ ។ តត្ថ កតមា ឧច្ឆេទទិដ្ឋិ ។ ឧច្ឆិជ្ជិស្សតិ អត្តា ច លោកោ ចាតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ ឧច្ឆេទទិដ្ឋិ ។

(១៤៩) តត្ថ កតមា អន្តវា ទិដ្ឋិ ។ អន្តវា អត្តា ច លោកោ ចាតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ អន្តវា ទិដ្ឋិ ។ តត្ថ កតមា អនន្តវា ទិដ្ឋិ ។ អនន្តវា អត្តា ច លោកោ ចាតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ អនន្តវា ទិដ្ឋិ ។

(១៥០) តត្ថ កតមា បុព្វន្តានុទិដ្ឋិ ។ បុព្វន្តំ អារព្ភ យា ឧប្បជ្ជតិ ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ បុព្វន្តានុទិដ្ឋិ ។

( ១៨៨ ) បណ្ដាធម៌ទាំងនោះ សស្សតទិដ្ឋិ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា ថា ខ្លួនក្ដី លោកក្ដី ទៀង នេះហៅថា សស្សតទិដ្ឋិ ។ បណ្ដាធម៌ទាំងនោះ ឧច្ឆេទទិដ្ឋិ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា ថា ខ្លួនក្ដី លោកក្ដី នឹងសូន្យ នេះហៅថា ឧច្ឆេទទិដ្ឋិ ។

( ១៨៩ ) បណ្ដាធម៌ទាំងនោះ អន្តវាទិដ្ឋិ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា ថា ខ្លួនក្ដី លោកក្ដី មានទីបំផុត នេះហៅថា អន្តវាទិដ្ឋិ ។ បណ្ដាធម៌ទាំងនោះ អនន្តវាទិដ្ឋិ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា ថា ខ្លួនក្ដី លោកក្ដី មិនមានទីបំផុត នេះហៅថា អនន្តវាទិដ្ឋិ ។

( ១៩០ ) បណ្ដាធម៌ទាំងនោះ បុព្វន្តានុទិដ្ឋិ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ក្នុងការស្វែងរកខុស ណា កើតឡើង ប្រារព្ធនូវទីបំផុតខាងដើម នេះហៅថា បុព្វន្តានុទិដ្ឋិ ។

តត្ថ កតមា អបរន្តានុទិដ្ឋិ ។ អបរន្តំ អារព្ភ យា ឧប្បជ្ជតិ ទិដ្ឋិ ទិដ្ឋិគតំ ។បេ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ អបរន្តានុទិដ្ឋិ ។

(១៨១) តត្ថ កតមំ អហិរិកំ ។ យំ ន ហិរិយតិ ហិរិយិតព្វេន ន ហិរិយតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ឥទំ វុច្ចតិ អហិរិកំ ។ តត្ថ កតមំ អនោត្តប្បំ ។ យំ ន ឱត្តប្បតិ ឱត្តប្បិតព្វេន ន ឱត្តប្បតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ឥទំ វុច្ចតិ អនោត្តប្បំ ។

(១៨២) តត្ថ កតមា ទោវចស្សតា ។ សហធម្មិកេ វុច្ចមានេ ទោវចស្សាយំ ទោវចស្សិយំ ទោវចស្សតា វិប្បដិកុលគ្គាហិតា វិបច្ចនីកសាតតា អនាទរិយំ អនាទរតា អគារវតា អប្បដិស្សវតា អយំ វុច្ចតិ ទោវចស្សតា ។ តត្ថ កតមា បាបមិត្តតា ។

បណ្ដាធម៌ទាំងនោះ អបរន្តានុទិដ្ឋិ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ក្នុងការស្វែងរកខុស ណា កើតឡើង ប្រារព្ធនូវទីបំផុតខាងចុង នេះហៅថា អបរន្តានុទិដ្ឋិ ។

(១៩១) បណ្ដាធម៌ទាំងនោះ សេចក្ដីមិនខ្មាសបាប តើដូចម្ដេច ។ គ្រង់ដែលបុគ្គលមិនខ្មាស ដោយហេតុដែលគួរខ្មាស មិនខ្មាស ដោយការជួបប្រទះ នឹងពួកអកុសលធម៌ដ៏លាមក នេះហៅថា សេចក្ដីមិនខ្មាសបាប ។ បណ្ដាធម៌ទាំងនោះ សេចក្ដីមិនក្ដៅនឹងបាប តើដូចម្ដេច ។ គ្រង់ដែលបុគ្គលមិនតក់ស្លុត ដោយហេតុដែលគួរតក់ស្លុត មិនតក់ស្លុត ដោយការជួបប្រទះ នឹងពួកអកុសលធម៌ដ៏លាមក នេះហៅថា សេចក្ដីមិនក្ដៅនឹងបាប ។

(១៩២) បណ្ដាធម៌ទាំងនោះ ការប្រដៅក្រ តើដូចម្ដេច ។ ការប្រដៅក្រ អាការប្រដៅក្រ ភាពនៃសេចក្ដីប្រដៅក្រ ការកាន់យកនូវអំពើដែលគួរខ្ពើម (អំពើផ្ដេសផ្ដាស) ការពេញចិត្តក្នុងធម៌ជាសត្រូវ ការមិនអើពើ សេចក្ដីមិនអើពើ សេចក្ដីមិនគោរព សេចក្ដីមិនស្ដាប់បង្គាប់ ចំពោះពាក្យប្រកបដោយធម៌ដែលគេពោល នេះហៅថា ការប្រដៅក្រ ។ បណ្ដាធម៌ទាំងនោះ ភាពអ្នកមានមិត្រអាក្រក់ តើដូចម្ដេច ។

យេ តេ បុគ្គលា អស្សទ្ធា ទុស្សីលា អប្បស្សុតា មច្ឆរិនោ ទុប្បញ្ញា យា តេសំ សេវនា និសេវនា សំសេវនា ភជនា សម្ភជនា ភត្តិ សម្ភត្តិ សម្បវង្កតា អយំ វុច្ចតិ បាបមិត្តតា ។

(១៥៣) តត្ថ កតមោ អនជ្ជវោ ។ យោ អនជ្ជវោ អនជ្ជវតា ជិម្ហតា វង្កតា កុដិលតា អយំ វុច្ចតិ អនជ្ជវោ ។ តត្ថ កតមោ អមទ្ទវោ ។ យា អមុទុតា អមទ្ទវតា កក្ខឡិយំ ផារុសិយំ កក្ខឡតា កឋិនតា ឧជុចិត្តតា អមុទុតា អយំ វុច្ចតិ អមទ្ទវោ ។

(១៥៤) តត្ថ កតមា អក្ខន្តិ ។ យា អក្ខន្តិ អក្ខមនតា អនធិវាសនតា ចណ្ឌិក្កំ អសុរោបោ អនត្តមនតា ចិត្តស្ស អយំ វុច្ចតិ អក្ខន្តិ ។

បុគ្គលទាំងឡាយ ណា ជាអ្នកមិនមានសទ្ធា ទ្រុស្តសីល ចេះដឹងតិច មានសេចក្តីកំណាញ់ ឥតបញ្ញា ការសេព ការសេពមិនដាច់ ការសេពរឿយ ៗ ការគប់រក ការគប់ករឿយៗ ការគប់ប្រសព្វ ការគប់ប្រសព្វរឿយ ៗ ការបែរេ ទៅរកបុគ្គលទាំងឡាយនោះ ណា នេះហៅថា ភាពនៃអ្នកមានមិត្រអាក្រក់ ។

(១៩៣) បណ្តាធម៌ទាំងនោះ អាការមិនត្រង់ តើដូចម្តេច ។ អាការមិនត្រង់ ភាពនៃអាការមិនត្រង់ ភាពនៃសេចក្តីវៀចវេរ ភាពនៃសេចក្តីកោង ភាពនៃសេចក្តីកិកក្ងក់ ណា នេះហៅថា អាការមិនត្រង់ ។ បណ្តាធម៌ទាំងនោះ សេចក្តីមិនទន់ភ្លន់ តើដូចម្តេច ។ សេចក្តីមិនទន់ភ្លន់ អាការនៃសេចក្តីមិនទន់ភ្លន់ សេចក្តីរឹងរូស សេចក្តីអាក្រក់ ភាពនៃសេចក្តីរឹងរូស ភាពនៃបុគ្គលមានចិត្តគគ្រើសគគ្រូស ភាពនៃបុគ្គលមានចិត្តរឹងកំព្រឹស ភាពនៃបុគ្គលមានចិត្តមិនទោរទន់ ណា នេះហៅថា សេចក្តីមិនទន់ភ្លន់ ។

(១៩៤) បណ្តាធម៌ទាំងនោះ សេចក្តីមិនអត់សង្កត់ តើដូចម្តេច ។ សេចក្តីមិនអត់សង្កត់ ភាពនៃសេចក្តីមិនអត់ធន់ ភាពនៃសេចក្តីមិនអត់ធ្មត់ សេចក្តីកាច ការពោលពាក្យមិនល្អ សេចក្តីមិនត្រេកអរនៃចិត្ត ណា នេះហៅថា សេចក្តីមិនអត់សង្កត់ ។

តត្ថ កតមំ អសោរច្ចំ ។ កាយិកោ វីតិក្កមោ វាចសិកោ វីតិក្កមោ កាយិកវាចសិកោ វីតិក្កមោ ឥទំ វុច្ចតិ អសោរច្ចំ សព្ពម្បិ ទុស្សីល្យំ អសោរច្ចំ ។

(១៨៤) តត្ថ កតមំ អសាខល្យំ ។ យា សា វាចា អណ្ឌកា កក្កសា បរកដុកា បរាភិសជ្ជនី កោធសាមន្តា អសមាធិសំវត្តនិកា តថារូបឹ វាចំ ភាសិតា ហោតិ យា តត្ថ អសណ្ហវាចតា អសខិលវាចតា ផរុសវាចតា ឥទំ វុច្ចតិ អសាខល្យំ ។ តត្ថ កតមោ អប្បដិសន្ថារោ ។ ទ្វេ បដិសន្ថារា អាមិសប្បដិសន្ថារោ ច ធម្មប្បដិសន្ថារោ ច ឥធេកច្ចោ អប្បដិសន្ថារកោ ហោតិ អាមិសប្បដិសន្ថារេន វា ធម្មប្បដិសន្ថារេន វា អយំ វុច្ចតិ អប្បដិសន្ថារោ ។

បណ្ដាធម៌ទាំងនោះ សេចក្ដីមិនស្លូតបូត តើដូចម្ដេច ។ ការប្រព្រឹត្តកន្លងប្រកបដោយកាយ ការប្រព្រឹត្តកន្លងប្រកបដោយវាចា ការប្រព្រឹត្តកន្លងប្រកបដោយកាយនិងវាចា នេះហៅថា សេចក្ដីមិនស្លូតបូត សូម្បីការទ្រុស្តសីលទាំងអស់ ក៏ឈ្មោះថា សេចក្ដីមិនស្លូតបូតដែរ ។

(១៨៩) បណ្ដាធម៌ទាំងនោះ សំដីមិនពីរោះ តើដូចម្ដេច ។ វាចា ណា ជាវាចារដិបរដុប គ្រោតគ្រាត ហឹរក្ដៅដល់ជនដទៃ ខ្ទាំងខ្ទប់ដល់ជនដទៃ ជិតសេចក្ដីក្រោធ មិនប្រព្រឹត្តទៅដើម្បីសមាធិ បុគ្គលពោលនូវវាចា មានសភាពដូច្នោះ ភាពនៃបុគ្គលមានវាចាមិនល្អិត ភាពនៃបុគ្គលមានវាចាមិនពីរោះ ភាពនៃបុគ្គលមានវាចាអាក្រក់ ណា ក្នុងវាចានោះ នេះហៅថា សំដីមិនពីរោះ ។ បណ្ដាធម៌ទាំងនោះ ការមិនទទួលរាក់ទាក់ តើដូចម្ដេច ។ ការទទួលរាក់ទាក់មាន ២ យ៉ាង គឺការទទួលរាក់ទាក់ដោយអាមិសៈ ១ ការទទួលរាក់ទាក់ដោយធម៌ ១ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនទទួលរាក់ទាក់ ដោយអាមិសប្បដិសន្ថារៈក្ដី ដោយធម្មប្បដិសន្ថារៈក្ដី នេះហៅថា ការមិនទទួលរាក់ទាក់ ។

## អភិធម្មបិដកេ វិភង្គោ

(១៥៦) តត្ថ កតមា ឥន្ទ្រិយេសុ អគុត្តទ្វារតា ។ ឥធេកច្ចោ ចក្ខុនា រូបំ ទិស្វា និមិត្តគ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈា ទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ ន បដិបជ្ជតិ ន រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ ន សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា ។ បេ ។ ឃានេន គន្ធំ ឃាយិត្វា ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ បេ ។ មនសា ធម្មំ វិញ្ញាយ និមិត្តគ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈា ទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ ន បដិបជ្ជតិ ន រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ ន សំវរំ អាបជ្ជតិ យា ឥមេសំ ឆន្នំ ឥន្ទ្រិយានំ អគុត្តិ អគោបនា អនារក្ខោ អសំវរោ អយំ វុច្ចតិ ឥន្ទ្រិយេសុ អគុត្តទ្វារតា ។

[ ១៩៦ ] បណ្ដាធម៌ទាំងនោះ ភាពនៃអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ បានឃើញនូវរូប ដោយចក្ខុហើយ កាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ ឯអភិជ្ឈានិងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួមនូវចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមនូវចក្ខុន្ទ្រិយ ណា ក៏មិនប្រតិបត្តិ ដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ មិនរក្សានូវចក្ខុន្ទ្រិយ មិនដល់នូវសេចក្ដីសង្រួម ក្នុងចក្ខុន្ទ្រិយ បានឮនូវសំឡេង ដោយត្រចៀកហើយ ។ បេ ។ បានហិតក្លិន ដោយច្រមុះហើយ ។ បេ ។ បានជញ្ជក់ជញ្ជាប់នូវរស ដោយអណ្ដាតហើយ ។ បេ ។ បានពាល់ត្រូវផ្សព្វ ដោយកាយហើយ ។ បេ ។ បានដឹងច្បាស់នូវធម្មា-រម្មណ៍ ដោយចិត្តហើយ កាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ ឯអភិជ្ឈានិងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួមនូវមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវមនិន្ទ្រិយ ណា ក៏មិនប្រព្រឹត្ត ដើម្បីសង្រួមនូវមនិន្ទ្រិយនោះ មិនរក្សានូវមនិន្ទ្រិយ មិនដល់នូវសេចក្ដីសង្រួម ក្នុងមនិន្ទ្រិយ ការមិនបិទ ការមិនគ្រប់គ្រង ការមិនរក្សា ការមិនសង្រួមនូវឥន្ទ្រិយទាំង ៦ នេះ ណា នេះហៅថា ភាពនៃអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ។

តត្ថ កតមា ភោជនេ អមត្តញ្ញុតា ។ ឥធេកច្ចោ អប្បដិសង្ខា អយោនិសោ អាហារំ អាហារេតិ ទវាយ មទាយ មណ្ឌនាយ វិភូសនាយ យា តត្ថ អសន្តុដ្ឋិតា អមត្តញ្ញុតា អប្បដិសង្ខា ភោជនេ អយំ វុច្ចតិ ភោជនេ អមត្តញ្ញុតា ។

(១៨៧) តត្ថ កតមំ មុដ្ឋស្សច្ចំ ។ យា អស្សតិ អននុស្សតិ អប្បដិស្សតិ អស្សតិ អសរណតា អធារណតា បិលាបនតា សម្មុសនតា ឥទំ វុច្ចតិ មុដ្ឋស្សច្ចំ ។ តត្ថ កតមំ អសម្បជញ្ញំ ។ យំ អញ្ញាណំ អទស្សនំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ ឥទំ វុច្ចតិ អសម្បជញ្ញំ ។

(១៨៨) តត្ថ កតមា សីលវិបត្តិ ។ កាយិកោ វីតិក្កមោ វាចសិកោ វីតិក្កមោ កាយិកវាចសិកោ វីតិក្កមោ អយំ វុច្ចតិ សីលវិបត្តិ សព្វម្បិ ទុស្សីល្យំ សីលវិបត្តិ ។

## ខុទ្ទកវត្ថុវិភង្គ ទុកនិទ្ទេស

បណ្ដាធម៌ទាំងនោះ ភាពនៃអ្នកមិនដឹងប្រមាណក្នុងភោជន តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនពិចារណា ដោយឧបាយនៃបញ្ញា តែងលេបនូវអាហារ ដើម្បីលេង ដើម្បីស្រវឹង ដើម្បីតាក់តែង ដើម្បីស្អិតស្អាង ភាពនៃអ្នកមិនសន្ដោស ភាពនៃអ្នកមិនដឹងប្រមាណ ការមិនពិចារណាភោជន ក្នុងសេចក្ដីមិនដឹងប្រមាណ ក្នុងភោជននោះណា នេះហៅថា ភាពនៃអ្នកមិនដឹងប្រមាណក្នុងភោជន ។

(១៨៧) បណ្ដាធម៌ទាំងនោះ ភាពនៃអ្នកភ្លេចស្មារតី តើដូចម្ដេច ។ ការមិនមានស្មារតី ការមិនរឭកឃើញ ការមិននឹកឃើញ ការមិនរឭក សេចក្ដីមិនរឭក សេចក្ដីមិនចងចាំ សេចក្ដីភ្លេចភ្លាំង សេចក្ដីវង្វេង ណា នេះហៅថា ភាពនៃអ្នកភ្លេចស្មារតី ។ បណ្ដាធម៌ទាំងនោះ ភាពនៃអ្នកមិនដឹងខ្លួន តើដូចម្ដេច ។ សេចក្ដីមិនដឹង សេចក្ដីមិនយល់ ។បេ។ គន្លឹះគឺអវិជ្ជា សេចក្ដីវង្វេង ឫសគល់នៃអកុសល ណា នេះហៅថា ភាពនៃអ្នកមិនដឹងខ្លួន ។

(១៨៨) បណ្ដាធម៌ទាំងនោះ វិបត្តិនៃសីល តើដូចម្ដេច ។ ការប្រព្រឹត្តកន្លង ប្រកបដោយកាយ ការប្រព្រឹត្តកន្លង ប្រកបដោយវាចា ការប្រព្រឹត្តកន្លង ប្រកបដោយកាយនិងវាចា នេះហៅថា វិបត្តិនៃសីល សូម្បីភាពនៃការទ្រុស្ដសីលទាំងអស់ ក៏ឈ្មោះថា វិបត្តិនៃសីលដែរ ។

តត្ថ កតមា ទិដ្ឋិវិបត្តិ ។ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ ។ បេ ។ យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ ទិដ្ឋិវិបត្តិ សព្វាបិ មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ ។

(១៨៩) តត្ថ កតមំ អជ្ឈត្តំ សញ្ញោជនំ ។ បញ្ចោរម្ភាគិយានិ សញ្ញោជនានិ អជ្ឈត្តំ សញ្ញោជនំ ។ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ ពហិទ្ធា សញ្ញោជនំ ។

ទុកំ ។

(១៩០) តត្ថ កតមានិ តីណិ អកុសលមូលានិ ។ លោភោ ទោសោ មោហោ ។ តត្ថ កតមោ លោភោ ។ យោ រាគោ សារាគោ អនុនយោ អនុរោធោ នន្ទី នន្ទិរាគោ ចិត្តស្ស សារាគោ

បណ្ដាធម៌ទាំងនោះ វិបត្តិនៃទិដ្ឋិ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា ថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជា មិនមានផល ។ បេ ។ ពួកសមណព្រាហ្មណ៍ ដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះផង នូវលោកដទៃផង ដោយបញ្ញា របស់ខ្លួនហើយប្រកាស មិនមានទេ នេះហៅថា វិបត្តិនៃទិដ្ឋិ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ ក៏ឈ្មោះថា វិបត្តិនៃទិដ្ឋិដែរ ។

(១៨៩) បណ្ដាធម៌ទាំងនោះ សញ្ញោជនៈ ខាងក្នុង តើដូចម្ដេច ។ សញ្ញោជនៈ ៥ ជាចំណែកខាងក្រោម ហៅថា សញ្ញោជនៈ ខាងក្នុង សញ្ញោជនៈ ៥ ជាចំណែកខាងលើ ហៅថា សញ្ញោជនៈ ខាងក្រៅ ។

ចប់ ពួកធម៌ទី ២ ។

(១៩០) បណ្ដាធម៌ទាំងនោះ អកុសលមូល ៣ តើដូចម្ដេច ។ លោភៈ ទោសៈ មោហៈ ។ បណ្ដាអកុសលមូល ៣ នោះ លោភៈ តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង សេចក្ដីត្រេកអរ សេចក្ដីត្រេកត្រអាល សេចក្ដីរីករាយ សេចក្ដីស្រើបស្រាល តម្រេកខ្លាំងនៃចិត្ត

ឥច្ឆា មុច្ឆា អជ្ឈោសានំ គេធោ បលិគេធោ(១)
សង្គោ បង្កោ ឯជា មាយា ជនិកា សញ្ជននី
សិព្វិនី ជាលិនី សរិតា វិសត្តិកា សុត្តំ វិសដា
អាយូហនី ទុតិយា បណិធិ ភវនេត្តិ វនំ វនថោ
សន្ថវោ សិនេហោ អបេក្ខា បដិពន្ធុ អាសា
អាសឹសនា អាសឹសិតត្តំ រូបាសា សទ្ទាសា គន្ធាសា
រសាសា ផោដ្ឋព្វាសា លាភាសា ធនាសា បុត្តាសា
ជីវិតាសា ជប្បា បជប្បា អភិជប្បា ជប្បា ជប្បនា
ជប្បិតត្តំ លោលុប្បំ លោលុប្បាយនា លោលុប្បា-
យិតត្តំ បុញ្ចិកតា(២) សាធុកម្យតា អធម្មរាគោ
វិសមលោភោ និកន្តិ និកាមនា បត្ថនា បិហនា
សម្បត្ថនា កាមតណ្ហា ភវតណ្ហា វិភវតណ្ហា

---

១ ម. បរិគេធោ ។ ២ ម. បុច្ឆញ្ជិកតា ។

សេចក្តីប្រាថ្នា សេចក្តីងល់ងប់ សេចក្តីជ្រប់ សេចក្តីចង់បាន សេចក្តីចង់បានខ្លាំង សេចក្តីជាប់ជំពាក់គឺតណ្ហា ភក់គឺតណ្ហា សេចក្តីស្វែងរក សេចក្តីបិទបាំង តណ្ហាជាគ្រឿងញុំាងសត្វឲ្យកើត តណ្ហាជាគ្រឿងញុំាងសត្វឲ្យកើតព្រម តណ្ហាជាគ្រឿងតាក់ស្រែះ ធម្មជាតិមានបណ្ដាញ ធម្មជាតិផ្សាយទៅ ធម្មជាតិដែលផ្សាយទៅផ្សេងៗ ធម្មជាតិជាគ្រឿងលក់ ធម្មជាតិដ៏ទូលាយ ធម្មជាតិជាគ្រឿងប្រមូល ធម្មជាតិជាគម្រប់ពីរ សេចក្តីតាំងទុក ធម្មជាតិជាគ្រឿងនាំសត្វទៅកាន់ភព ព្រៃធំគឺតណ្ហា ព្រៃតូចគឺតណ្ហា សេចក្តីស្និទ្ធស្នាល សេចក្តីស្នេហា សេចក្តីអាឡោះអាល័យ ផៅពង្សគឺតណ្ហា ការសង្ឃឹម អាការសង្ឃឹម ភាពនៃសេចក្តីសង្ឃឹម សេចក្តីប្រាថ្នារូប សេចក្តីប្រាថ្នាសំឡេង សេចក្តីប្រាថ្នាក្លិន សេចក្តីប្រាថ្នារស សេចក្តីប្រាថ្នាផ្សព្វ សេចក្តីប្រាថ្នាលាភ សេចក្តីប្រាថ្នាទ្រព្យ សេចក្តីប្រាថ្នាកូន សេចក្តីប្រាថ្នាជីវិត ការប៉ុនប៉ង អាការប៉ុនប៉ង សេចក្តីប៉ង បំណង អាការបំណង ភាពនៃសេចក្តីប៉ង ការចង់បាន អាការចង់បាន ភាពនៃសេចក្តីចង់បាន សេចក្តីស្វិតស្វាញ សេចក្តីប្រាថ្នាល្អ តម្រេកក្នុងអធម៌ សេចក្តីលោភហួសហេតុ សេចក្តីអាល័យ ការផ្ដេកផ្ដិត សេចក្តីប្រាថ្នា សេចក្តីស្រឡាញ់ សេចក្តីប្រាថ្នាខ្លាំង សេចក្តីប្រាថ្នាកាម សេចក្តីប្រាថ្នាភព សេចក្តីប្រាថ្នាប្រាសចាកភព

រូបតណ្ហា អរូបតណ្ហា និរោធតណ្ហា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ឱឃោ យោគោ គន្ថោ ឧបាទានំ អាវរណំ នីវរណំ ឆាទនំ ពន្ធនំ ឧបក្កិលេសោ អនុសយោ បរិយុដ្ឋានំ លតា វេវិច្ឆំ ទុក្ខមូលំ ទុក្ខនិទានំ ទុក្ខប្បភវោ មារបាសោ មារពលិសំ មារវិសយោ តណ្ហានទី តណ្ហាជាលំ តណ្ហាគទ្ទុលំ តណ្ហាសមុទ្ទោ អភិជ្ឈា លោភោ អកុសលមូលំ អយំ វុច្ចតិ លោភោ ។ តត្ថ កតមោ ទោសោ ។ អនត្ថំ មេ អចរីតិ អាឃាតោ ជាយតិ អនត្ថំ មេ ចរតីតិ អាឃាតោ ជាយតិ

សេចក្តីប្រាថ្នារូបភព សេចក្តីប្រាថ្នាអរូបភព សេចក្តីប្រាថ្នាការរំលត់ សេចក្តីប្រាថ្នារូប សេចក្តីប្រាថ្នាសំឡេង សេចក្តីប្រាថ្នាក្លិន សេចក្តីប្រាថ្នារស សេចក្តីប្រាថ្នាផ្សព្វ សេចក្តីប្រាថ្នាធម៌ ឱឃៈ (ធម៌ញុំាងសត្វឲ្យលង់នៅក្នុងវដ្តៈ) យោគៈ (ធម៌ញុំាងសត្វឲ្យជាប់នៅក្នុងវដ្តៈ) គន្ថៈ (ធម៌ដោតក្រងសត្វទុកក្នុងវដ្តៈ ដោយអំណាចចុតិនិងបដិសន្ធិ) សេចក្តីប្រកាន់មាំ ធម្មជាតិជាគ្រឿងរាំង ធម្មជាតិជាគ្រឿងឃាត់ ធម្មជាតិជាគ្រឿងបិទ ធម្មជាតិជាគ្រឿងចង សភាពជាគ្រឿងចូលទៅធ្វើឲ្យសៅហ្មង កិលេសជាគ្រឿងដេកនៅរឿយ ៗ កិលេសជាតជាគ្រឿងគ្របសង្កត់នូវចិត្ត តណ្ហាដូចជាវល្លិ សេចក្តីស្វិតស្វាញ ឬសគល់នៃសេចក្តីទុក្ខ ធម្មជាតជាហេតុនៃទុក្ខ សភាពមានទុក្ខជាដែនកើតមុន អន្ទាក់គឺមារ សន្ទូចគឺមារ វិស័យគឺមារ ស្ទឹងគឺតណ្ហា សំណាញ់គឺតណ្ហា ខ្នោះគឺតណ្ហា សមុទ្រគឺតណ្ហា សេចក្តីសំឡឹងរំពៃ សេចក្តីចង់បាន ឬសគល់នៃអកុសល ណា នេះហៅថា សេចក្តីលោភ ។

បណ្តាអកុសលមូលទាំងនោះ ទោសៈ តើដូចម្តេច ។ សេចក្តីគុំគួនតែងកើតឡើងថា បុគ្គលឯណោះ បានប្រព្រឹត្តហើយ នូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញ សេចក្តីគុំគួនតែងកើតឡើងថា បុគ្គលឯណោះ កំពុងប្រព្រឹត្ត នូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញ

អនត្ថំ មេ ចរិស្សតីតិ អាឃាតោ ជាយតិ
បិយស្ស មេ មនាបស្ស អនត្ថំ អចរិ អនត្ថំ ចរតិ
អនត្ថំ ចរិស្សតីតិ អាឃាតោ ជាយតិ អប្បិយស្ស មេ
អមនាបស្ស អត្ថំ អចរិ អត្ថំ ចរតិ អត្ថំ ចរិស្សតីតិ
អាឃាតោ ជាយតិ អដ្ឋានេ វា បន អាឃាតោ
ជាយតិ យោ ឯវរូបោ ចិត្តស្ស អាឃាតោ បដិឃាតោ
បដិឃំ បដិវិរោធោ កោបោ បកោបោ សម្បកោ-
បោ ទោសោ បទោសោ សម្បទោសោ ចិត្តស្ស
ព្យាបត្តិ មនោបទោសោ កោធោ កុជ្ឈនា កុជ្ឈិ-
តត្តំ ទោសោ ទុស្សនា ទុស្សិតត្តំ ព្យាបត្តិ ព្យាបជ្ជនា
ព្យាបជ្ជិតត្តំ វិរោធោ បដិវិរោធោ ចណ្ឌិក្កំ អសុរោបោ
អនត្តមនតា ចិត្តស្ស អយំ វុច្ចតិ ទោសោ ។

ខុទ្ទកវត្ថុវិភង្គ តិកនិទ្ទេស

សេចក្តីគុំគួនតែងកើតឡើងថា បុគ្គលឯណោះ នឹងប្រព្រឹត្ត នូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញ សេចក្តីគុំគួនតែងកើតឡើងថា បុគ្គលឯណោះ បានប្រព្រឹត្តហើយ នូវអំពើមិនជាប្រយោជន៍ កំពុងប្រព្រឹត្ត នូវអំពើមិនជាប្រយោជន៍ នឹងប្រព្រឹត្ត នូវអំពើមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្ត របស់អាត្មាអញ សេចក្តីគុំគួនតែងកើតឡើងថា បុគ្គលឯណោះ បានប្រព្រឹត្តហើយ នូវអំពើជាប្រយោជន៍ កំពុងប្រព្រឹត្ត នូវអំពើជាប្រយោជន៍ នឹងប្រព្រឹត្ត នូវអំពើជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត របស់អាត្មាអញ មួយវិញទៀត សេចក្តីគុំគួនតែងកើតឡើង ក្នុងទីមិនមែនជាហេតុ សេចក្តីគុំគួននៃចិត្ត សេចក្តីចង្អៀតចង្អល់ សេចក្តីតានតឹង សេចក្តីថ្នាំងថ្នាក់ សេចក្តីខឹង សេចក្តីខឹងខ្លាំង សេចក្តីខឹងក្រៃលែង សេចក្តីប្រទូស្ត សេចក្តីប្រទូស្តខ្លាំង សេចក្តីប្រទូស្តក្រៃលែង ការព្យាបាទនៃចិត្ត សេចក្តីប្រទូស្តក្នុងចិត្ត ការក្រោធ អាការក្រោធ ភាពនៃសេចក្តីក្រោធ ការប្រទូស្ត អាការប្រទូស្ត ភាពនៃសេចក្តីប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាពនៃសេចក្តីព្យាបាទ ការពិរោធ ការពិរោធផ្សេងៗ សេចក្តីកាច ការខឹង សេចក្តីអាក់អន់ចិត្ត មានសភាពយ៉ាងនេះ ណា នេះហៅថា ទោសៈ ។

តត្ថ កតមោ មោហោ ។ ទុក្ខេ អញ្ញាណំ ទុក្ខសមុទយេ អញ្ញាណំ ទុក្ខនិរោធេ អញ្ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ បុព្វន្តេ អញ្ញាណំ អបរន្តេ អញ្ញាណំ បុព្វន្តាបរន្តេ អញ្ញាណំ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ យំ ឯវរូបំ អញ្ញាណំ អទស្សនំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ មោហោ ។ ឥមានិ តីណិ អកុសលមូលានិ ។

(១៦១) តត្ថ កតមេ តយោ អកុសលវិតក្កា ។ កាមវិតក្កោ ព្យាបាទវិតក្កោ វិហឹសាវិតក្កោ ។ តត្ថ កតមោ កាមវិតក្កោ ។ កាមប្បដិសំយុត្តោ តក្កោ វិតក្កោ ។ បេ ។ មិច្ឆាសង្កប្បោ អយំ វុច្ចតិ កាមវិតក្កោ ។ តត្ថ កតមោ ព្យាបាទវិតក្កោ ។ ព្យាបាទប្បដិសំយុត្តោ តក្កោ វិតក្កោ ។ បេ ។ មិច្ឆាសង្កប្បោ អយំ វុច្ចតិ ព្យាបាទវិតក្កោ ។

បណ្ដាអកុសលមូលទាំង ៣ នោះ មោហៈ តើដូចម្ដេច ។ សេចក្ដីមិនដឹងក្នុងទុក្ខ សេចក្ដីមិនដឹង ក្នុងហេតុដែលនាំឲ្យកើតទុក្ខ សេចក្ដីមិនដឹង ក្នុងការរំលត់ទុក្ខ សេចក្ដីមិនដឹង ក្នុងបដិបទាជាដំណើរដល់នូវការរំលត់ទុក្ខ សេចក្ដីមិនដឹង ក្នុងទីបំផុតខាងដើម សេចក្ដីមិនដឹង ក្នុងទីបំផុតខាងចុង សេចក្ដីមិនដឹង ក្នុងទីបំផុតខាងដើម និងទីបំផុតខាងចុង សេចក្ដីមិនដឹង ក្នុងធម៌ទាំងឡាយ ដែលកើតឡើងព្រោះអាស្រ័យធម៌នេះជាបច្ច័យ សេចក្ដីមិនដឹង សេចក្ដីមិនយល់ ។ បេ ។ គន្លឹះគឺអវិជ្ជា សេចក្ដីវង្វេង ឫសគល់នៃអកុសល មានសភាពយ៉ាងនេះ ណា នេះហៅថា មោហៈ ។ នេះ អកុសលមូល ៣ ។

[ ១៦១ ] បណ្ដាធម៌ទាំងនោះ អកុសលវិតក្កៈ ៣ តើដូចម្ដេច ។ កាមវិតក្កៈ ១ ព្យាបាទវិតក្កៈ ១ វិហឹសាវិតក្កៈ ១ ។ បណ្ដាអកុសលវិតក្កៈទាំង ៣ នោះ កាមវិតក្កៈ តើដូចម្ដេច ។ សេចក្ដីត្រិះរិះ សេចក្ដីដញ្ចឹងប្រកបដោយកាម ។ បេ ។ សេចក្ដីត្រិះរិះខុស នេះហៅថា កាមវិតក្កៈ ។ បណ្ដាអកុសលវិតក្កៈទាំង ៣ នោះ ព្យាបាទ-វិតក្កៈ តើដូចម្ដេច ។ សេចក្ដីត្រិះរិះ សេចក្ដីដញ្ចឹងប្រកបដោយព្យាបាទ ។ បេ ។ សេចក្ដីត្រិះរិះខុស នេះហៅថា ព្យាបាទវិតក្កៈ ។

តត្ថ កតមោ វិហឹសាវិតក្កោ ។ វិហឹសាបដិសំយុត្តោ តក្កោ វិតក្កោ ។ បេ ។ មិច្ឆាសង្កប្បោ អយំ វុច្ចតិ វិហឹសាវិតក្កោ ។ ឥមេ តយោ អកុសលវិតក្កា ។

( ១៦២ ) តត្ថ កតមា តិស្សោ អកុសលសញ្ញា ។ កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា ។ តត្ថ កតមា កាមសញ្ញា ។ កាមបដិសំយុត្តា សញ្ញា សញ្ជានានា សញ្ជានិតត្តំ អយំ វុច្ចតិ កាមសញ្ញា ។ តត្ថ កតមា ព្យាបាទសញ្ញា ។ ព្យាបាទបដិសំយុត្តា សញ្ញា សញ្ជានានា សញ្ជានិតត្តំ អយំ វុច្ចតិ ព្យាបាទសញ្ញា ។ តត្ថ កតមា វិហឹសាសញ្ញា ។ វិហឹសាបដិសំយុត្តា សញ្ញា សញ្ជានានា សញ្ជានិតត្តំ អយំ វុច្ចតិ វិហឹសាសញ្ញា ។ ឥមា តិស្សោ អកុសលសញ្ញា ។

បណ្ដាអកុសលវិតក្កៈទាំង ៣ នោះ វិហឹសាវិតក្កៈ តើដូចម្ដេច ។ សេចក្ដីត្រិះរិះ សេចក្ដីជញ្ជឹងប្រកបដោយការបៀតបៀន ។ បេ ។ សេចក្ដីត្រិះរិះខុស នេះហៅថា វិហឹសាវិតក្កៈ ។ នេះ អកុសលវិតក្កៈ ៣ ។

[ ១៦៤ ] បណ្ដាធម៌ទាំងនោះ អកុសលសញ្ញា ៣ តើដូចម្ដេច ។ កាមសញ្ញា ១ ព្យាបាទសញ្ញា ១ វិហឹសាសញ្ញា ១ ។ បណ្ដាអកុសលសញ្ញាទាំង ៣ នោះ កាមសញ្ញា តើដូចម្ដេច ។ ការសំគាល់ អាការសំគាល់ ភាពនៃសេចក្ដីសំគាល់ ប្រកបដោយកាម នេះហៅថា កាមសញ្ញា ។ បណ្ដាអកុសលសញ្ញាទាំង ៣ នោះ ព្យាបាទសញ្ញា តើដូចម្ដេច ។ ការសំគាល់ អាការសំគាល់ ភាពនៃសេចក្ដីសំគាល់ប្រកបដោយព្យាបាទ នេះហៅថា ព្យាបាទសញ្ញា ។ បណ្ដាអកុសលសញ្ញាទាំង ៣ នោះ វិហឹសាសញ្ញា តើដូចម្ដេច ។ ការសំគាល់ អាការសំគាល់ ភាពនៃសេចក្ដីសំគាល់ ប្រកបដោយការបៀតបៀន នេះហៅថា វិហឹសាសញ្ញា ។ នេះ អកុសលសញ្ញា ៣ ។

(១៦៣) តត្ថ កតមា តិស្សោ អកុសលធាតុយោ ។ កាមធាតុ ព្យាបាទធាតុ វិហឹសាធាតុ ។ តត្ថ កតមា កាមធាតុ ។ កាមវិតក្កោ កាមធាតុ ។ ព្យាបាទវិតក្កោ ព្យាបាទធាតុ ។ វិហឹសាវិតក្កោ វិហឹសាធាតុ ។ តត្ថ កតមោ កាមវិតក្កោ ។ កាមប្បដិសំយុត្តោ តក្កោ វិតក្កោ ។ បេ ។ មិច្ឆាសង្កប្បោ អយំ វុច្ចតិ កាមវិតក្កោ ។ តត្ថ កតមោ ព្យាបាទវិតក្កោ ។ ព្យាបាទប្បដិសំយុត្តោ តក្កោ វិតក្កោ ។ បេ ។ មិច្ឆាសង្កប្បោ អយំ វុច្ចតិ ព្យាបាទវិតក្កោ ។ តត្ថ កតមោ វិហឹសាវិតក្កោ ។ វិហឹសាបដិសំយុត្តោ តក្កោ វិតក្កោ ។ បេ ។ មិច្ឆាសង្កប្បោ អយំ វុច្ចតិ វិហឹសាវិតក្កោ ។ ឥមា តិស្សោ អកុសលធាតុយោ ។

(១៦៤) តត្ថ កតមានិ តីណិ ទុច្ចរិតានិ ។ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ។ តត្ថ កតមំ

[ ១៦៣ ] បណ្ដាធម៌ទាំងនោះ អកុសលធាតុ ៣ តើដូចម្ដេច ។ កាមធាតុ ១ ព្យាបាទធាតុ ១ វិហឹសាធាតុ ១ ។ បណ្ដាអកុសលធាតុទាំង ៣ នោះ កាមធាតុ តើដូចម្ដេច ។ ការដញ្ហឹងក្នុងកាម ឈ្មោះថា កាមធាតុ ។ ការដញ្ហឹងក្នុងព្យាបាទ ឈ្មោះថា ព្យាបាទធាតុ ។ ការដញ្ហឹងក្នុងសេចក្ដីបៀតបៀន ឈ្មោះថា វិហឹសាធាតុ ។ បណ្ដាវិតក្កៈទាំង ៣ នោះ កាមវិតក្កៈ តើដូចម្ដេច ។ សេចក្ដីត្រិះរិះ សេចក្ដីដញ្ហឹងប្រកបដោយកាម ។ បេ ។ សេចក្ដីត្រិះរិះខុស នេះហៅថា កាមវិតក្កៈ ។ បណ្ដាវិតក្កៈទាំង ៣ នោះ ព្យាបាទវិតក្កៈ តើដូចម្ដេច ។ សេចក្ដីត្រិះរិះ សេចក្ដីដញ្ហឹង ប្រកបដោយព្យាបាទ ។ បេ ។ សេចក្ដីត្រិះរិះខុស នេះហៅថា ព្យាបាទវិតក្កៈ ។ បណ្ដាវិតក្កៈទាំង ៣ នោះ វិហឹសាវិតក្កៈ តើដូចម្ដេច ។ សេចក្ដីត្រិះរិះ សេចក្ដីដញ្ហឹង ប្រកបដោយការបៀតបៀន ។ បេ ។ សេចក្ដីត្រិះរិះខុស នេះហៅថា វិហឹសាវិតក្កៈ ។ នេះ អកុសលធាតុ ៣ ។

[ ១៦៤ ] បណ្ដាធម៌ទាំងនោះ ទុច្ចរិត ៣ តើដូចម្ដេច ។ កាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ ។ បណ្ដាទុច្ចរិតទាំង ៣ នោះ

កាយទុច្ចរិតំ ។ បាណាតិបាតោ អទិន្នាទានំ កាមេសុមិច្ឆាចារោ ឥទំ វុច្ចតិ កាយទុច្ចរិតំ ។ តត្ថ កតមំ វចីទុច្ចរិតំ ។ មុសាវាទោ បិសុណាវាចា ផរុសាវាចា សម្ផប្បលាបោ ឥទំ វុច្ចតិ វចីទុច្ចរិតំ ។ តត្ថ កតមំ មនោទុច្ចរិតំ ។ អភិជ្ឈា ព្យាបាទោ មិច្ឆាទិដ្ឋិ ឥទំ វុច្ចតិ មនោទុច្ចរិតំ ។ តត្ថ កតមំ កាយទុច្ចរិតំ ។ អកុសលំ កាយកម្មំ កាយទុច្ចរិតំ ។ អកុសលំ វចីកម្មំ វចីទុច្ចរិតំ ។ អកុសលំ មនោកម្មំ មនោទុច្ចរិតំ ។ តត្ថ កតមំ អកុសលំ កាយកម្មំ ។ អកុសលា កាយសញ្ចេតនា អកុសលំ កាយកម្មំ ។ អកុសលា វចីសញ្ចេតនា អកុសលំ វចីកម្មំ ។ អកុសលា មនោសញ្ចេតនា អកុសលំ មនោកម្មំ ។ ឥមានិ តីណិ ទុច្ចរិតានិ ។

ខុទ្ទកវត្ថុវិភង្គ តិកនិទ្ទេស

កាយទុច្ចរិត តើដូចម្ដេច ។ ការសម្លាប់សត្វ ការកាន់យកទ្រព្យដែលគេមិនបានឲ្យ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ នេះហៅថា កាយ-ទុច្ចរិត ។ បណ្ដាទុច្ចរិតទាំង ៣ នោះ វចីទុច្ចរិត តើដូចម្ដេច ។ ការពោលពាក្យកុហក វាចាញុះញង់ វាចាអាក្រក់ ការពោលពាក្យពេយពាយ នេះហៅថា វចីទុច្ចរិត ។ បណ្ដាទុច្ចរិតទាំង ៣ នោះ មនោទុច្ចរិត តើដូចម្ដេច ។ ការសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ការគុំគួនគេ សេចក្ដីយល់ខុស នេះហៅថា មនោទុច្ចរិត ។ បណ្ដាទុច្ចរិតទាំង ៣ នោះ កាយទុច្ចរិត តើដូចម្ដេច ។ កាយកម្ម ជាអកុសល ឈ្មោះថា កាយទុច្ចរិត ។ វចីកម្ម ជាអកុសល ឈ្មោះថា វចីទុច្ចរិត ។ មនោកម្ម ជាអកុសល ឈ្មោះថា មនោទុច្ចរិត ។ បណ្ដាទុច្ចរិតទាំង ៣ នោះ កាយកម្ម ជាអកុសល តើដូចម្ដេច ។ អាការក្លែងដោយកាយ ជាអកុសល ឈ្មោះថា កាយកម្មជាអកុសល ។ អាការក្លែងដោយវាចា ជាអកុសល ឈ្មោះថា វចីកម្មជាអកុសល ។ អាការក្លែងដោយចិត្ត ជាអកុសល ឈ្មោះថា មនោកម្មជាអកុសល ។ នេះ ទុច្ចរិត ៣ ។

[១៦៥] តត្ថ កតមេ តយោ អាសវា ។ កាមាសវោ ភវាសវោ អវិជ្ជាសវោ ។ តត្ថ កតមោ កាមាសវោ ។ យោ កាមេសុ កាមច្ឆន្ទោ ។ បេ ។ កាមជ្ឈោសានំ អយំ វុច្ចតិ កាមាសវោ ។ តត្ថ កតមោ ភវាសវោ ។ យោ ភវេសុ ភវច្ឆន្ទោ ។ បេ ។ ភវជ្ឈោសានំ អយំ វុច្ចតិ ភវាសវោ ។ តត្ថ កតមោ អវិជ្ជាសវោ ។ ទុក្ខេ អញ្ញាណំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ អវិជ្ជាសវោ ។ ឥមេ តយោ អាសវា ។

[១៦៦] តត្ថ កតមានិ តីណិ សញ្ញោជនានិ ។ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ ។ តត្ថ កតមា សក្កាយទិដ្ឋិ ។ ឥធ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុ-រិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ

[១៦៥] បណ្ដាធម៌ទាំងនោះ អាសវៈ ៣ តើដូចម្ដេច ។ កាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ បណ្ដាអាសវៈទាំង ៣ នោះ កាមាសវៈ តើដូចម្ដេច ។ សេចក្ដីពេញចិត្តនឹងកាម ក្នុងកាមទាំងឡាយ ។ បេ ។ សេចក្ដីជ្រប់ក្នុងកាម ណា នេះហៅថា កាមាសវៈ ។ បណ្ដាអាសវៈទាំង ៣ នោះ ភវាសវៈ តើដូចម្ដេច ។ សេចក្ដីពេញចិត្តនឹងភព ក្នុងភពទាំងឡាយ ។ បេ ។ សេចក្ដីជ្រប់ក្នុងភព ណា នេះហៅថា ភវាសវៈ ។ បណ្ដាអាសវៈទាំង ៣ នោះ អវិជ្ជាសវៈ តើដូចម្ដេច ។ សេចក្ដីមិនដឹងក្នុងទុក្ខ ។ បេ ។ គន្លឹះគឺអវិជ្ជា សេចក្ដីវង្វេង ឫសគល់នៃអកុសល នេះហៅថា អវិជ្ជាសវៈ ។ នេះ អាសវៈ ៣ ។

[១៦៦] បណ្ដាធម៌ទាំងនោះ សញ្ញោជនៈ ៣ តើដូចម្ដេច ។ សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ ។ បណ្ដាសញ្ញោជនៈទាំង ៣ នោះ សក្កាយទិដ្ឋិ តើដូចម្ដេច ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្ដាប់ មិនបានជួបប្រទះនឹងពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនទូន្មានខ្លួនក្នុងធម៌របស់ព្រះអរិយៈ មិនបានជួបប្រទះនឹងពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌របស់សប្បុរស មិនទូន្មានខ្លួនក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញនូវរូបថា ជាខ្លួន

អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ ។ បេ ។ សញ្ញំ ។ បេ ។ សង្ខារេ ។ បេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ សក្កាយទិដ្ឋិ ។ តត្ថ កតមា វិចិកិច្ឆា ។ សត្ថរិ កង្ខតិ វិចិកិច្ឆតិ ធម្មេ កង្ខតិ វិចិកិច្ឆតិ សង្ឃេ កង្ខតិ វិចិកិច្ឆតិ សិក្ខាយ កង្ខតិ វិចិកិច្ឆតិ បុព្វន្តេ កង្ខតិ វិចិកិច្ឆតិ អបរន្តេ កង្ខតិ វិចិកិច្ឆតិ បុព្វន្តាបរន្តេ កង្ខតិ វិចិកិច្ឆតិ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ កង្ខតិ វិចិកិច្ឆតិ យា ឯវរូបា កង្ខា កង្ខាយនា កង្ខាយិតត្តំ ។ បេ ។ ឆម្ភិតត្តំ ចិត្តស្ស មនោវិលេខោ អយំ វុច្ចតិ វិចិកិច្ឆា ។

ពិចារណាឃើញនូវខ្លួន ថាមានរូបខ្លះ ពិចារណាឃើញនូវរូប ថាមានក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួន ថាមានក្នុងរូបខ្លះ រមែងពិចារណាឃើញនូវវេទនា ។ បេ ។ នូវសញ្ញា ។ បេ ។ នូវសង្ខារទាំងឡាយ ។ បេ ។ នូវវិញ្ញាណ ថាជាខ្លួន ពិចារណាឃើញនូវខ្លួន ថាមានវិញ្ញាណខ្លះ ពិចារណាឃើញនូវវិញ្ញាណ ថាមានក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួន ថាមានក្នុងវិញ្ញាណខ្លះ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្តីប្រកាន់ ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា នេះហៅថា សក្កាយទិដ្ឋិ ។ បណ្តាសញ្ញោជនៈទាំងនោះ វិចិកិច្ឆា តើដូចម្តេច ។ បុគ្គល ងឿងឆ្ងល់ សង្ស័យ ក្នុងព្រះសាស្តា ងឿងឆ្ងល់ សង្ស័យ ក្នុងព្រះធម៌ ងឿងឆ្ងល់ សង្ស័យ ក្នុងព្រះសង្ឃ ងឿងឆ្ងល់ សង្ស័យ ក្នុងសិក្ខា ងឿងឆ្ងល់ សង្ស័យ ក្នុងទីបំផុតខាងដើម ងឿងឆ្ងល់ សង្ស័យ ក្នុងទីបំផុតខាងចុង ងឿងឆ្ងល់ សង្ស័យ ក្នុងទីបំផុតខាងដើមនិងខាងចុង ងឿងឆ្ងល់ សង្ស័យ ក្នុងធម៌ទាំងឡាយ ដែលកើតឡើងអាស្រ័យនូវគ្នានឹងគ្នា ព្រោះធម៌នេះជាបច្ច័យ ការងឿងឆ្ងល់ អាការងឿងឆ្ងល់ ភាពនៃសេចក្តីងឿងឆ្ងល់ ។ បេ ។ ភាពនៃចិត្តរឹងត្អឹង គំនូសនៃចិត្ត មានសភាពយ៉ាងនេះ ណា នេះហៅថា វិចិកិច្ឆា ។

តត្ថ កតមោ សីលព្វតបរាមាសោ ។ ឥតោ ពហិទ្ធា សមណព្រាហ្មណានំ សីលេន សុទ្ធិ វតេន សុទ្ធិ សីលព្វតេន សុទ្ធីតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។បេ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ សីលព្វតបរាមាសោ ។ ឥមានិ តីណិ សញ្ញោជនានិ ។

(១៦៧) តត្ថ កតមា តិស្សោ តណ្ហា ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ តត្ថ កតមា ភវតណ្ហា ។ ភវទិដ្ឋិសហគតោ រាគោ សារាគោ ។បេ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ ភវតណ្ហា ។ តត្ថ កតមា វិភវតណ្ហា ។ ឧច្ឆេទទិដ្ឋិសហគតោ រាគោ សារាគោ ។បេ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ វិភវតណ្ហា ។ អវសេសា តណ្ហា កាមតណ្ហា ។ តត្ថ កតមា កាមតណ្ហា ។ កាមធាតុប្បដិសំយុត្តោ រាគោ សារាគោ ។បេ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ កាមតណ្ហា ។

បណ្ដាសញ្ញោជនៈទាំង ៣ នោះ សីលព្វតបរាមាសៈ តើដូចម្ដេច ។ ពួកសមណព្រាហ្មណ៍ ខាងក្រៅសាសនានេះ មានទិដ្ឋិ ដំណើរតើទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ថា សេចក្ដីបរិសុទ្ធិ ព្រោះសីល សេចក្ដីបរិសុទ្ធិ ព្រោះវត្ត សេចក្ដីបរិសុទ្ធិ ព្រោះសីលនិងវត្ត នេះហៅថា សីលព្វតបរាមាសៈ ។ នេះ សញ្ញោជនៈ ៣ ។

(១៦៧) បណ្ដាធម៌ទាំងនោះ តណ្ហា ៣ តើដូចម្ដេច ។ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ បណ្ដាតណ្ហាទាំង ៣ នោះ ភវតណ្ហា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត ប្រព្រឹត្តទៅមួយអន្លើ ដោយភវទិដ្ឋិ នេះហៅថា ភវតណ្ហា ។ បណ្ដាតណ្ហាទាំង ៣ នោះ វិភវតណ្ហា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត ប្រព្រឹត្តទៅមួយអន្លើ ដោយឧច្ឆេទទិដ្ឋិ នេះហៅថា វិភវតណ្ហា ។ តណ្ហាដ៏សេស ឈ្មោះថា កាមតណ្ហា ។ បណ្ដាតណ្ហាទាំង ៣ នោះ កាមតណ្ហា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត ប្រកបដោយកាមធាតុ នេះហៅថា កាមតណ្ហា ។

រូបធាតុអរូបធាតុប្បដិសំយុត្តោ រាគោ សារាគោ ។បេ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ ភវតណ្ហា ។ ឧច្ឆេទទិដ្ឋិសហគតោ រាគោ សារាគោ ។បេ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ វិភវតណ្ហា ។ ឥមា តិស្សោ តណ្ហា ។

(១៦៨) តត្ថ កតមា អបរាបិ តិស្សោ តណ្ហា ។ កាមតណ្ហា រូបតណ្ហា អរូបតណ្ហា ។ តត្ថ កតមា កាមតណ្ហា ។ កាមធាតុប្បដិសំយុត្តោ រាគោ សារាគោ ។បេ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ កាមតណ្ហា ។ តត្ថ កតមា រូបតណ្ហា ។ រូប-ធាតុប្បដិសំយុត្តោ រាគោ សារាគោ ។បេ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ រូបតណ្ហា ។ តត្ថ កតមា អរូបតណ្ហា ។ អរូបធាតុប្បដិសំយុត្តោ រាគោ សារាគោ ។បេ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ អរូបតណ្ហា ។ ឥមា តិស្សោ តណ្ហា ។

(១៦៩) តត្ថ កតមា អបរាបិ តិស្សោ តណ្ហា ។

តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត ប្រកបដោយរូបធាតុ និងអរូបធាតុ នេះហៅថា ភវតណ្ហា ។ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត ប្រព្រឹត្តទៅមួយអន្លើ ដោយឧច្ឆេទទិដ្ឋិ នេះហៅថា វិភវតណ្ហា ។ នេះ តណ្ហា ៣ ។

(១៦៨) បណ្ដាធម៌ទាំងនោះ តណ្ហា ៣ ដទៃទៀត តើដូចម្ដេច ។ កាមតណ្ហា ១ រូបតណ្ហា ១ អរូបតណ្ហា ១ ។ បណ្ដាតណ្ហាទាំង ៣ នោះ កាមតណ្ហា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត ប្រកបដោយកាមធាតុ នេះហៅថា កាមតណ្ហា ។ បណ្ដាតណ្ហាទាំង ៣ នោះ រូបតណ្ហា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត ប្រកបដោយរូបធាតុ នេះហៅថា រូបតណ្ហា ។ បណ្ដាតណ្ហាទាំង ៣ នោះ អរូបតណ្ហា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត ប្រកបដោយអរូបធាតុ នេះហៅថា អរូបតណ្ហា ។ នេះ តណ្ហា ៣ ។

(១៦៩) បណ្ដាធម៌ទាំងនោះ តណ្ហា ៣ ដទៃទៀត តើដូចម្ដេច ។

រូបតណ្ហា អរូបតណ្ហា និរោធតណ្ហា ។ តត្ថ កតមា រូបតណ្ហា ។ រូបធាតុប្បដិសំយុត្តោ រាគោ សារាគោ ។ បេ ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ រូបតណ្ហា ។ តត្ថ កតមា អរូបតណ្ហា ។ អរូបធាតុប្បដិសំយុត្តោ រាគោ សារាគោ ។ បេ ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ អរូបតណ្ហា ។ តត្ថ កតមា និរោធតណ្ហា ។ ឧច្ឆេទទិដ្ឋិសហគតោ រាគោ សារាគោ ។ បេ ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ និរោធតណ្ហា ។ ឥមា តិស្សោ តណ្ហា ។

(១៧០) តត្ថ កតមា តិស្សោ ឯសនា ។ កាមេសនា ភវេសនា ព្រហ្មចរិយេសនា ។ តត្ថ កតមា កាមេសនា ។ យោ កាមេសុ កាមច្ឆន្ទោ ។ បេ ។ កាមជ្ឈោសានំ អយំ វុច្ចតិ កាមេសនា ។ តត្ថ កតមា ភវេសនា ។ យោ ភវេសុ ភវច្ឆន្ទោ ។ បេ ។ ភវជ្ឈោសានំ អយំ វុច្ចតិ ភវេសនា ។

រូបតណ្ហា ១ អរូបតណ្ហា ១ និរោធតណ្ហា ១ ។ បណ្ដាតណ្ហាទាំង ៣ នោះ រូបតណ្ហា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្ត ប្រកបដោយរូបធាតុ នេះហៅថា រូបតណ្ហា ។ បណ្ដាតណ្ហាទាំង ៣ នោះ អរូបតណ្ហា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្ត ប្រកបដោយអរូបធាតុ នេះហៅថា អរូបតណ្ហា ។ បណ្ដាតណ្ហាទាំង ៣ នោះ និរោធតណ្ហា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្ត ប្រព្រឹត្តទៅមួយអន្លើ ដោយឧច្ឆេទទិដ្ឋិ នេះហៅថា និរោធតណ្ហា ។ នេះតណ្ហា ៣ ។

(១៧០) បណ្ដាធម៌ទាំងនោះ ការស្វែងរក ៣ តើដូចម្ដេច ។ ការស្វែងរកកាម ១ ការស្វែងរកភព ១ ការស្វែងរកព្រហ្មចរិយៈ ១ ។ បណ្ដាការស្វែងរកទាំង ៣ នោះ ការស្វែងរកកាម តើដូចម្ដេច ។ សេចក្ដីពេញចិត្តនឹងកាម ក្នុងកាមទាំងឡាយ ។បេ។ សេចក្ដីជ្រប់ក្នុងកាម ណា នេះហៅថា ការស្វែងរកកាម ។ បណ្ដាការស្វែងរកទាំង ៣ នោះ ការស្វែងរកភព តើដូចម្ដេច ។ សេចក្ដីពេញចិត្តនឹងភព ក្នុងភពទាំងឡាយ ។បេ។ សេចក្ដីជ្រប់ក្នុងភព ណា នេះហៅថា ការស្វែងរកភព ។

តត្ថ កតមា ព្រហ្មចរិយេសនា ។ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។បេ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ ព្រហ្មចរិយេសនា ។ តត្ថ កតមា កាមេសនា ។ កាមរាគោ តទេកដ្ឋំ អកុសលំ កាយកម្មំ វចីកម្មំ មនោកម្មំ អយំ វុច្ចតិ កាមេសនា ។ តត្ថ កតមា ភវេសនា ។ ភវរាគោ តទេកដ្ឋំ អកុសលំ កាយកម្មំ វចីកម្មំ មនោកម្មំ អយំ វុច្ចតិ ភវេសនា ។ តត្ថ កតមា ព្រហ្មចរិយេសនា ។ អន្តគ្គាហិកា ទិដ្ឋិ តទេកដ្ឋំ អកុសលំ កាយកម្មំ វចីកម្មំ មនោកម្មំ អយំ វុច្ចតិ ព្រហ្មចរិយេសនា ។ ឥមា តិស្សោ ឯសនា ។

ខុទ្ទកវត្ថុវិភង្គ តិកនិទ្ទេស

បណ្ដាការស្វែងរកទាំង ៣ នោះ ការស្វែងរកព្រហ្មចរិយៈ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា ដូច្នេះ ថា លោកទៀងខ្លះ ថា លោកមិនទៀងខ្លះ ។ បេ ។ ថា សត្វ ខាងមុខអំពីសេចក្ដីស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ នេះហៅថា ការស្វែងរកព្រហ្មចរិយៈ ។ បណ្ដាការស្វែងរកទាំង ៣ នោះ ការស្វែងរកកាម តើដូចម្ដេច ។ សេចក្ដីត្រេកអរក្នុងកាម កាយកម្ម វចីកម្ម មនោកម្ម ជាអកុសល ដែលតាំងនៅក្នុងទីជាមួយគ្នា នឹងសេចក្ដីត្រេកអរក្នុងកាមនោះ នេះហៅថា ការស្វែងរកកាម ។ បណ្ដាការស្វែងរកទាំង ៣ នោះ ការស្វែងរកភព តើដូចម្ដេច ។ សេចក្ដីត្រេកអរក្នុងភព កាយកម្ម វចីកម្ម មនោកម្ម ជាអកុសល ដែលតាំងនៅក្នុងទីជាមួយគ្នា នឹងសេចក្ដីត្រេកអរក្នុងភពនោះ នេះហៅថា ការស្វែងរកភព ។ បណ្ដាការស្វែងរកទាំង ៣ នោះ ការស្វែងរកព្រហ្មចរិយៈ តើដូចម្ដេច ។ អន្តគ្គាហិកទិដ្ឋិ (ទិដ្ឋិដែលកាន់យកនូវទីបំផុត) កាយកម្ម វចីកម្ម មនោកម្ម ជាអកុសល ដែលតាំងនៅក្នុងទីជាមួយគ្នា នឹងអន្តគ្គាហិកទិដ្ឋិនោះ នេះហៅថា ការស្វែងរកព្រហ្មចរិយៈ ។ នេះ ការស្វែងរក ៣ ។

(១៧១) តត្ថ កតមា តិស្សោ វិធា ។ សេយ្យោហមស្មីតិ វិធា សទិសោហមស្មីតិ វិធា ហីនោហមស្មីតិ វិធា ។ ឥមា តិស្សោ វិធា ។

(១៧២) តត្ថ កតមានិ តីណិ ភយានិ ។ ជាតិភយំ ជរាភយំ មរណភយំ ។ តត្ថ កតមំ ជាតិភយំ ។ ជាតឹ បដិច្ច ភយំ ភយានកំ ឆម្ភិតត្តំ លោមហំសោ ចេតសោ ឧត្រាសោ ឥទំ វុច្ចតិ ជាតិភយំ ។ តត្ថ កតមំ ជរាភយំ ។ ជរំ បដិច្ច ភយំ ភយានកំ ឆម្ភិតត្តំ លោមហំសោ ចេតសោ ឧត្រាសោ ឥទំ វុច្ចតិ ជរាភយំ ។ តត្ថ កតមំ មរណភយំ ។ មរណំ បដិច្ច ភយំ ភយានកំ ឆម្ភិតត្តំ លោមហំសោ ចេតសោ ឧត្រាសោ ឥទំ វុច្ចតិ មរណភយំ ។ ឥមានិ តីណិ ភយានិ ។

[ ១៧១ ] បណ្ដាធម៌ទាំងនោះ ការធ្វើងខ្ពង់ ៣ តើដូចម្ដេច ។ ការធ្វើងខ្ពង់ ព្រោះតាំងខ្លួនថា អញប្រសើរជាងគេ ១ ការធ្វើងខ្ពង់ ព្រោះតាំងខ្លួនថា អញស្មើនឹងគេ ១ ការធ្វើងខ្ពង់ ព្រោះតាំងខ្លួនថា អញថោកទាបជាងគេ ១ ។ នេះ ការធ្វើងខ្ពង់ ៣ ។

[ ១៧២ ] បណ្ដាធម៌ទាំងនោះ ភ័យ ៣ តើដូចម្ដេច ។ ភ័យព្រោះជាតិ ១ ភ័យព្រោះជរា ១ ភ័យព្រោះមរណៈ ១ ។ បណ្ដាភ័យទាំង ៣ នោះ ភ័យព្រោះជាតិ តើដូចម្ដេច ។ ភ័យ ហេតុដែលគួរភ័យ សេចក្ដីខ្លាច សេចក្ដីព្រឺរោម សេចក្ដីតក់ស្លុតនៃចិត្ត ព្រោះអាស្រ័យជាតិ នេះហៅថា ភ័យព្រោះជាតិ ។ បណ្ដាភ័យទាំង ៣ នោះ ភ័យព្រោះជរា តើដូចម្ដេច ។ ភ័យ ហេតុដែលគួរភ័យ សេចក្ដីខ្លាច សេចក្ដីព្រឺរោម សេចក្ដីតក់ស្លុតនៃចិត្ត ព្រោះអាស្រ័យជរា នេះហៅថា ភ័យព្រោះជរា ។ បណ្ដាភ័យទាំង ៣ នោះ ភ័យព្រោះមរណៈ តើដូចម្ដេច ។ ភ័យ ហេតុដែលគួរភ័យ សេចក្ដីខ្លាច សេចក្ដីព្រឺរោម សេចក្ដីតក់ស្លុតនៃចិត្ត ព្រោះអាស្រ័យមរណៈ នេះហៅថា ភ័យព្រោះមរណៈ ។ នេះ ភ័យ ៣ ។

[១៧៣] តត្ថ កតមានិ តីណិ តមានិ ។ អតីតំ អទ្ធានំ អារព្ភ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ អនាគតំ អទ្ធានំ អារព្ភ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ(១) បច្ចុប្បន្នំ អទ្ធានំ អារព្ភ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ ឥមានិ តីណិ តមានិ ។

[១៧៤] តត្ថ កតមានិ តីណិ តិត្ថាយតនានិ ។ ឥធេកច្ចោ សមណោ វា ព្រាហ្មណោ វា ឯវំវាទី ហោតិ ឯវំទិដ្ឋិ យង្កិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ បុព្វេកតហេតូតិ ឥធ បនេកច្ចោ សមណោ វា ព្រាហ្មណោ វា ឯវំវាទី ហោតិ ឯវំទិដ្ឋិ យង្កិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ ឥស្សរនិម្មានហេតូតិ ឥធ បនេកច្ចោ

---

១ ឱ. ម. ឯត្តកេ ឯតរហិ វាតិ ទិស្សតិ ។

( ១៧៣ ) បណ្តាធម៌ទាំងនោះ ងងឹត ៣ តើដូចម្តេច ។ បុគ្គល ងឿងឆ្ងល់ សង្ស័យ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ព្រោះប្រារព្ធនូវកាលជាអតីត ១ បុគ្គល ងឿងឆ្ងល់ សង្ស័យ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ព្រោះប្រារព្ធនូវកាលជាអនាគត ១ បុគ្គលងឿងឆ្ងល់ សង្ស័យ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ព្រោះប្រារព្ធនូវកាលជាបច្ចុប្បន្ន ១ នេះ ងងឹត ៣ ។

( ១៧៤ ) បណ្តាធម៌ទាំងនោះ លទ្ធិដូចជាកំពង់ ៣ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាសមណៈក្តី ជាព្រាហ្មណ៍ក្តី តែងពោលយ៉ាងនេះ យល់ឃើញយ៉ាងនេះថា បុរសបុគ្គល នេះតែងទទួលនូវអារម្មណ៍ណាមួយ ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខ មិនមែនសុខក្តី អារម្មណ៍ទាំងអស់នោះ មានអំពើដែលខ្លួនធ្វើទុក ក្នុងកាលមុនជាហេតុ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាសមណៈក្តី ជាព្រាហ្មណ៍ក្តី តែងពោលយ៉ាងនេះ ឃើញយ៉ាងនេះថា បុរសបុគ្គលនេះ តែងទទួលនូវអារម្មណ៍ណាមួយ ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខ មិនមែនសុខក្តី អារម្មណ៍ទាំងអស់នោះ មានការតាក់តែងរបស់ព្រះឥស្សរជាហេតុ មួយវិញទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ

សមណោ វា ព្រាហ្មណោ វា ឯវំវាទី ហោតិ ឯវំទិដ្ឋិ យំកិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ អហេតុអប្បច្ចយាតិ ឥមានិ តីណិ តិត្ថាយតនានិ ។

(១៧៥) តត្ថ កតមេ តយោ កិញ្ចនា ។ រាគោ កិញ្ចនំ ទោសោ កិញ្ចនំ មោហោ កិញ្ចនំ ឥមេ តយោ កិញ្ចនា ។

(១៧៦) តត្ថ កតមានិ តីណិ អង្គណានិ ។ រាគោ អង្គណំ ទោសោ អង្គណំ មោហោ អង្គណំ ឥមានិ តីណិ អង្គណានិ ។

(១៧៧) តត្ថ កតមានិ តីណិ មលានិ ។ រាគោ មលំ ទោសោ មលំ មោហោ មលំ ឥមានិ តីណិ មលានិ ។

(១៧៨) តត្ថ កតមានិ តីណិ វិសមានិ ។ រាគោ វិសមំ ទោសោ វិសមំ មោហោ វិសមំ ឥមានិ តីណិ វិសមានិ ។

ជាសមណៈក្តី ជាព្រាហ្មណ៍ក្តី រមែងពោលយ៉ាងនេះ យល់ឃើញយ៉ាងនេះថា បុរសបុគ្គលនេះ រមែងទទួលនូវអារម្មណ៍ណាមួយ ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខ មិនមែនសុខក្តី អារម្មណ៍ទាំងអស់នោះ មិនមានហេតុ មិនមានបច្ច័យ នេះ លទ្ធិដូចជាកំពង់ ៣ ។

[ ១៧៥ ] បណ្តាធម៌ទាំងនោះ កង្វល់ ៣ តើដូចម្តេច ។ រាគៈ ជាកង្វល់ ១ ទោសៈ ជាកង្វល់ ១ មោហៈ ជាកង្វល់ ១ នេះ កង្វល់ ៣ ។

[ ១៧៦ ] បណ្តាធម៌ទាំងនោះ ទីទួល ៣ តើដូចម្តេច ។ រាគៈ ជាទីទួល ១ ទោសៈ ជាទីទួល ១ មោហៈ ជាទីទួល ១ នេះ ទីទួល ៣ ។

[ ១៧៧ ] បណ្តាធម៌ទាំងនោះ មន្ទិល ៣ តើដូចម្តេច ។ រាគៈ ជាមន្ទិល ១ ទោសៈ ជាមន្ទិល ១ មោហៈ ជាមន្ទិល ១ នេះ មន្ទិល ៣ ។

[ ១៧៨ ] បណ្តាធម៌ទាំងនោះ ធម្មជាតមិនកបស្មើ ៣ តើដូចម្តេច ។ រាគៈ ជាធម្មជាតមិនកបស្មើ ១ ទោសៈ ជាធម្មជាតមិនកបស្មើ ១ មោហៈ ជាធម្មជាតមិនកបស្មើ ១ នេះ ធម្មជាតមិនកបស្មើ ៣ ។

(១៧៩) តត្ថ កតមានិ អបរានិបិ តីណិ វិសមានិ ។ កាយវិសមំ វចីវិសមំ មនោវិសមំ ឥមានិ តីណិ វិសមានិ ។

(១៨០) តត្ថ កតមេ តយោ អគ្គី ។ រាគគ្គិ ទោសគ្គិ មោហគ្គិ ឥមេ តយោ អគ្គី ។

(១៨១) តត្ថ កតមេ តយោ កសាវា ។ រាគកសាវោ ទោសកសាវោ មោហកសាវោ ឥមេ តយោ កសាវា ។

(១៨២) តត្ថ កតមេ អបរេបិ តយោ កសាវា ។ កាយកសាវោ វចីកសាវោ មនោកសាវោ ឥមេ តយោ កសាវា ។

(១៨៣) តត្ថ កតមា អស្សាទទិដ្ឋិ ។ ឥធេកច្ចោ សមណោ វា ព្រាហ្មណោ វា ឯវំវាទី ហោតិ ឯវំទិដ្ឋិ នត្ថិ កាមេសុ ទោសោតិ សោ កាមេសុ បាតព្យតំ អាបជ្ជតិ អយំ វុច្ចតិ អស្សាទទិដ្ឋិ ។ តត្ថ កតមា អត្តានុទិដ្ឋិ ។

(១៧៩) បណ្ដាធម៌ទាំងនោះ ធម្មជាតមិនរាបស្មើ ៣ ដទៃទៀត តើដូចម្ដេច ។ ធម្មជាតមិនរាបស្មើគឺកាយ ១ ធម្មជាតមិនរាបស្មើគឺវាចា ១ ធម្មជាតមិនរាបស្មើគឺចិត្ត ១ នេះ ធម្មជាតមិនរាបស្មើ ៣ ។

(១៨០) បណ្ដាធម៌ទាំងនោះ ភ្លើង ៣ តើដូចម្ដេច ។ ភ្លើងគឺរាគៈ ១ ភ្លើងគឺទោសៈ ១ ភ្លើងគឺមោហៈ ១ នេះ ភ្លើង ៣ ។

(១៨១) បណ្ដាធម៌ទាំងនោះ ទឹកចត់ ៣ តើដូចម្ដេច ។ ទឹកចត់គឺរាគៈ ១ ទឹកចត់គឺទោសៈ ១ ទឹកចត់គឺមោហៈ ១ នេះ ទឹកចត់ ៣ ។

(១៨២) បណ្ដាធម៌ទាំងនោះ ទឹកចត់ ៣ ដទៃទៀត តើដូចម្ដេច ។ ទឹកចត់គឺកាយ ១ ទឹកចត់គឺវាចា ១ ទឹកចត់គឺចិត្ត ១ នេះ ទឹកចត់ ៣ ។

(១៨៣) បណ្ដាធម៌ទាំងនោះ សេចក្ដីយល់ឃើញថា គួរត្រេកអរ តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាសមណៈក្ដី ជាព្រាហ្មណ៍ក្ដី រមែងពោលយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ទោសក្នុងកាមទាំងឡាយមិនមាន បុគ្គលនោះ តែងដល់នូវភាពជាអ្នកធ្លាក់ចុះក្នុងកាមទាំងឡាយ នេះហៅថា សេចក្ដីយល់ឃើញថា គួរត្រេកអរ ។ បណ្ដាធម៌ទាំងនោះ សេចក្ដីយល់ឃើញថាជាខ្លួន តើដូចម្ដេច ។

ឥធ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ ។បេ។ សញ្ញំ ។បេ។ សង្ខារេ ។បេ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។បេ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ អត្តានុទិដ្ឋិ ។ តត្ថ កតមា មិច្ឆាទិដ្ឋិ ។ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ ។បេ។ យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។បេ។

បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនជួបប្រទះនឹងពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនទូន្មានខ្លួនក្នុងធម៌របស់ព្រះអរិយៈ មិនបានជួបប្រទះនឹងពួកសប្បុរស មិនឈ្លាសវៃ ក្នុងធម៌របស់សប្បុរស មិនទូន្មានខ្លួន ក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញនូវរូប ថាជាខ្លួន ពិចារណាឃើញនូវខ្លួន ថាមានរូបខ្លះ ពិចារណាឃើញនូវរូប ថាមានក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួន ថាមានក្នុងរូបខ្លះ រមែងពិចារណាឃើញនូវវេទនា ។ បេ ។ នូវសញ្ញា ។ បេ ។ នូវសង្ខារទាំងឡាយ ។ បេ ។ នូវវិញ្ញាណ ថាជាខ្លួន ពិចារណាឃើញនូវខ្លួន ថាមានវិញ្ញាណខ្លះ រមែងពិចារណាឃើញនូវវិញ្ញាណ ថាមានក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួន ថាមានក្នុងវិញ្ញាណខ្លះ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្ដីយល់ឃើញ ថាជាខ្លួន ។ បណ្ដាធម៌ទាំងនោះ សេចក្ដីយល់ឃើញខុស តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា ថាទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជា មិនមានផល ។ បេ ។

វិបរិយេសគ្គាហោ អយំ វុច្ចតិ មិច្ឆាទិដ្ឋិ ។ សស្ស-
តទិដ្ឋិ អស្សាទទិដ្ឋិ ។ សក្កាយទិដ្ឋិ អត្តានុទិដ្ឋិ ។
ឧច្ឆេទទិដ្ឋិ មិច្ឆាទិដ្ឋិ ។

(១៨៤) តត្ថ កតមា អរតិ ។ បន្តេសុ វា សេនាសនេសុ អញ្ញតរញ្ញតរេសុ វា អធិកុសលេសុ ធម្មេសុ អរតិ អរតិតា អនភិរតិ អនភិរមនា ឧក្កណ្ឋិតា បរិតស្សិតា អយំ វុច្ចតិ អរតិ ។ តត្ថ កតមា វិហេសា ។ ឥធេកច្ចោ បាណិនា វា លេឌ្ឌុនា វា ទណ្ឌេន វា សត្ថេន វា រជ្ជុយា វា អញ្ញតរញ្ញតរេន សត្តេ វិហេឋេតិ យា ឯវរូបា ហេឋនា វិហេឋនា ហឹសនា វិហឹសនា រោសនា វិរោសនា បរូបឃាតោ អយំ វុច្ចតិ វិហេសា ។

ពួកសមណព្រាហ្មណ៍ ដែលបានធ្វើឲ្យជាក់ច្បាស់នូវលោកនេះផង នូវលោកដទៃផង ដោយបញ្ញារបស់ខ្លួនហើយសំដែង មិនមានទេ នេះហៅថា សេចក្តីយល់ឃើញខុស ។ សស្សតទិដ្ឋិ ឈ្មោះថា អស្សាទ-ទិដ្ឋិ ។ សក្កាយទិដ្ឋិ ឈ្មោះថា អត្តានុទិដ្ឋិ ។ ឧច្ឆេទទិដ្ឋិ ឈ្មោះថា មិច្ឆាទិដ្ឋិ ។

(១៨៤) បណ្តាធម៌ទាំងនោះ សេចក្តីមិនត្រេកអរ តើដូចម្តេច ។ ការមិនត្រេកអរ សេចក្តីមិនត្រេកអរ ការមិនរីករាយ សេចក្តីមិនរីករាយ សេចក្តីអផ្សុក សេចក្តីសោប់សល់ ក្នុងសេនាសនៈដ៏ស្ងាត់ក្តី ក្នុងធម៌ជាកុសលដ៏លើសលុបដទៃទៀតក្តី នេះហៅថា សេចក្តីមិនត្រេកអរ ។ បណ្តាធម៌ទាំងនោះ សេចក្តីបៀតបៀន តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ តែងបៀតបៀន នូវសត្វទាំងឡាយ ដោយវត្ថុណាមួយ គឺដៃក្តី ដុំដីក្តី ដំបងក្តី គ្រឿងសស្ត្រាក្តី ខ្សែក្តី ការធ្វើឲ្យលំបាក ការធ្វើឲ្យលំបាកខ្លាំង ការបៀតបៀន ការបៀតបៀនខ្លាំង ការប្រទូស្ត ការប្រទូស្តខ្លាំង ការបៀតបៀននូវសត្វដទៃ មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីបៀតបៀន ។

## អភិធម្មបិដកេ វិភង្គោ

តត្ថ កតមា អធម្មចរិយា ៗ កាយេន អធម្មចរិយា វិសមចរិយា វាចាយ អធម្មចរិយា វិសមចរិយា មនសា អធម្មចរិយា វិសមចរិយា អយំ វុច្ចតិ អធម្មចរិយា ៗ

(១៨៨) តត្ថ កតមា ទោវចស្សតា ៗ សហធម្មិកេ វុច្ចមានេ ទោវចស្សាយំ ទោវចស្សិយំ ទោវចស្សតា វិប្បដិកុលគ្គាហិតា វិបច្ចនីកសាតតា អនាទរិយំ អនាទរតា អគារវតា អប្បដិស្សវតា អយំ វុច្ចតិ ទោវចស្សតា ៗ តត្ថ កតមា បាបមិត្តតា ៗ យេ តេ បុគ្គលា អស្សទ្ធា ទុស្សីលា អប្បស្សុតា មច្ឆរិនោ ទុប្បញ្ញា យា តេសំ សេវនា និសេវនា សំសេវនា ភជនា សម្ភជនា ភត្តិ សម្ភត្តិ តំសម្បវង្កតា អយំ វុច្ចតិ បាបមិត្តតា ៗ

បណ្ដាធម៌ទាំងនោះ ការប្រព្រឹត្តនូវអំពើមិនមែនធម៌ តើដូចម្ដេច ។ ការប្រព្រឹត្តមិនស្មើដោយកាយ ឈ្មោះថា ការប្រព្រឹត្តនូវអំពើមិនមែនធម៌ ការប្រព្រឹត្តមិនស្មើដោយវាចា ឈ្មោះថា ការប្រព្រឹត្តនូវអំពើមិនមែនធម៌ ការប្រព្រឹត្តមិនស្មើដោយចិត្ត ឈ្មោះថា ការប្រព្រឹត្តនូវអំពើមិនមែនធម៌ នេះហៅថា ការប្រព្រឹត្តនូវអំពើមិនមែនធម៌ ។

[១៨៩] បណ្ដាធម៌ទាំងនោះ ការប្រដៅក្រ តើដូចម្ដេច ។ ការប្រដៅក្រ អាការប្រដៅក្រ ភាពនៃសេចក្ដីប្រដៅក្រ ការកាន់យកនូវអំពើដែលគួរខ្ពើម (អំពើផ្ដេសផ្ដាស) ការពេញចិត្តក្នុងធម៌ជាសត្រូវ ការមិនអើពើ សេចក្ដីមិនអើពើ សេចក្ដីមិនគោរព សេចក្ដីមិនស្ដាប់បង្គាប់ ចំពោះពាក្យប្រកបដោយធម៌ ដែលគេពោល នេះហៅថា ការប្រដៅក្រ ។ បណ្ដាធម៌ទាំងនោះ ភាពជាអ្នកមានមិត្តអាក្រក់ តើដូចម្ដេច ។ បុគ្គលទាំងឡាយណា ជាអ្នកមិនមានសទ្ធា ទ្រុស្ដសីល ចេះដឹងតិច មានសេចក្ដីកំណាញ់ ឥតប្រាជ្ញា ការសេព ការសេពមិនដាច់ ការសេពរឿយ ៗ ការគប់រក ការគប់រករឿយ ៗ ការគប់ប្រសព្វ ការគប់ប្រសព្វរឿយ ៗ នូវបុគ្គលទាំងឡាយនោះ ការបែរទៅរកបុគ្គលនោះ ណា នេះហៅថា ភាពជាអ្នកមានមិត្តអាក្រក់ ។

ខុទ្ទកវត្ថុវិភង្គ តិកនិទ្ទេសោ

តត្ថ កតមា នានត្តសញ្ញា ។ កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា អយំ វុច្ចតិ នានត្តសញ្ញា សព្វាបិ អកុសលសញ្ញា នានត្តសញ្ញា ។

(១៨៦) តត្ថ កតមំ ឧទ្ធច្ចំ ។ យំ ចិត្តស្ស ឧទ្ធច្ចំ អវូបសមោ ចេតសោ វិក្ខេបោ ភន្តត្តំ ចិត្តស្ស ឥទំ វុច្ចតិ ឧទ្ធច្ចំ ។ តត្ថ កតមំ កោសជ្ជំ ។ កាយទុច្ចរិតេ វា វចីទុច្ចរិតេ វា មនោទុច្ចរិតេ វា បញ្ចសុ វា កាមគុណេសុ ចិត្តស្ស វោស្សគ្គោ វោស្សគ្គានុប្បទានំ កុសលានំ វា ធម្មានំ ភាវនាយ អសក្កច្ចកិរិយតា អសាតច្ចកិរិយតា អនដ្ឋិតកិរិយតា ឱលីនវុត្តិតា និក្ខិត្តច្ឆន្ទតា និក្ខិត្តធុរតា អនាសេវនា អភាវនា អពហុលីកម្មំ អនធិដ្ឋានំ អននុយោគោ បមាទោ ឥទំ វុច្ចតិ កោសជ្ជំ ។ តត្ថ កតមោ បមាទោ ។ កាយទុច្ចរិតេ វា វចីទុច្ចរិតេ វា មនោទុច្ចរិតេ វា

បណ្ដាធម៌ទាំងនោះ សញ្ញាវិបល្លាស តើដូចម្ដេច ។ សេចក្ដីសំគាល់ក្នុងកាម សេចក្ដីសំគាល់ក្នុងព្យាបាទ សេចក្ដីសំគាល់ក្នុងការបៀតបៀន នេះហៅថា សញ្ញាវិបល្លាស ។ សូម្បីសេចក្ដីសំគាល់ក្នុងអកុសលទាំងអស់ ក៏ឈ្មោះថា សញ្ញាវិបល្លាស ដែរ ។

(១៨៦) បណ្ដាធម៌ទាំងនោះ សេចក្ដីរាយមាយ តើដូចម្ដេច ។ សេចក្ដីរាយមាយនៃចិត្ត ការមិនស្ងប់នៃចិត្ត ការរវើរវាយនៃចិត្ត សេចក្ដីប្រែប្រួលនៃចិត្ត ណា នេះហៅថា សេចក្ដីរាយមាយ ។ បណ្ដាធម៌ទាំងនោះ សេចក្ដីខ្ជិល តើដូចម្ដេច ។ ការបណ្ដោយចិត្ត ការឲ្យកម្លាំងដល់ការបណ្ដោយចិត្តទៅ ក្នុងកាយទុច្ចរិតក្ដី ក្នុងវចីទុច្ចរិតក្ដី ក្នុងមនោទុច្ចរិតក្ដី ក្នុងកាមគុណទាំង ៥ ក្ដី ឬការធ្វើដោយមិនគោរព ការធ្វើមិនរឿយ ៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តទំរន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិនប្រកបរឿយ ៗ ការធ្វេសប្រហែស ក្នុងការចំរើននូវធម៌ជាកុសល នេះហៅថា សេចក្ដីខ្ជិល ។ បណ្ដាធម៌ទាំងនោះ សេចក្ដីប្រមាទ តើដូចម្ដេច ។ ការបណ្ដោយចិត្ត ការឲ្យកម្លាំងដល់ការបណ្ដោយចិត្តទៅ ក្នុងកាយទុច្ចរិតក្ដី ក្នុងវចីទុច្ចរិតក្ដី ក្នុងមនោទុច្ចរិតក្ដី

បញ្ចសុ វា កាមគុណេសុ ចិត្តស្ស វោស្សគ្គោ វោស្សគ្គានុប្បទានំ កុសលានំ វា ធម្មានំ ភាវនាយ អសក្កច្ចកិរិយតា អសាតច្ចកិរិយតា អនដ្ឋិតកិរិយតា ឱលីនវុត្តិតា និក្ខិត្តច្ឆន្ទតា និក្ខិត្តធុរតា អនាសេវនា អភាវនា អពហុលីកម្មំ អនធិដ្ឋានំ អននុយោគោ បមាទោ យោ ឯវរូបោ បមាទោ បមជ្ជនា បមជ្ជិតត្តំ អយំ វុច្ចតិ បមាទោ ។

(១៨៧) តត្ថ កតមា អសន្តុដ្ឋិតា ។ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ បញ្ចហិ វា កាមគុណេហិ អសន្តុដ្ឋស្ស ភិយ្យោកម្យតា យា ឯវរូបា ឥច្ឆា ឥច្ឆាគតំ អសន្តុដ្ឋិតា រាគោ សារាគោ ។ បេ ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ អសន្តុដ្ឋិតា ។ តត្ថ កតមា អសម្បជញ្ញតា ។ យំ អញ្ញាណំ អទស្សនំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ អសម្បជញ្ញតា ។ តត្ថ កតមា មហិច្ឆតា ។

ក្នុងកាមគុណទាំង ៥ ក្តី ឬការធ្វើដោយមិនគោរព ការធ្វើមិនរឿយ ៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តិទន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិនប្រកបរឿយ ៗ ការធ្វេសប្រហែស ក្នុងការចំរើននូវធម៌ជាកុសល ការធ្វេសប្រហែស អាការធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រមាទ ។

(១៨៧) បណ្តាធម៌ទាំងនោះ សេចក្តីមិនសន្តោស តើដូចម្តេច ។ សេចក្តីប្រាថ្នាដ៏ក្រៃលែង នៃបុគ្គលមិនសន្តោស ដោយចីវរប្បច្ច័យ បិណ្ឌ-បាតប្បច្ច័យ សេនាសនប្បច្ច័យ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ តាមមានតាមបាន ឬដោយកាមគុណទាំង ៥ សេចក្តីប្រាថ្នា ការប្រព្រឹត្តិទៅដោយសេចក្តីប្រាថ្នា សេចក្តីមិនសន្តោស តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីមិនសន្តោស ។ បណ្តាធម៌ទាំងនោះ សេចក្តីមិនដឹងខ្លួន តើដូចម្តេច ។ សេចក្តីមិនដឹង សេចក្តីមិនយល់ ។ បេ ។ គន្លឹះគឺអវិជ្ជា សេចក្តីវង្វេង ឬសគល់នៃអកុសល ណា នេះហៅថា សេចក្តីមិនដឹងខ្លួន ។ បណ្តាធម៌ទាំងនោះ សេចក្តីប្រាថ្នាធំ តើដូចម្តេច ។

ឥតរិតរចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ បញ្ចហិ វា កាមគុណេហិ អសន្តុដ្ឋស្ស ភិយ្យោកម្យតា យា ឯវរូបា ឥច្ឆា ឥច្ឆាគតំ មហិច្ឆតា រាគោ សារាគោ ។បេ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ មហិច្ឆតា ។

(១៨៨) តត្ថ កតមំ អហិរិកំ ។ យំ ន ហិរិយតិ ហិរិយិតព្វេន ន ហិរិយតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ឥទំ វុច្ចតិ អហិរិកំ ។ តត្ថ កតមំ អនោត្តប្បំ ។ យំ ន ឱត្តប្បតិ ឱត្តប្បិតព្វេន ន ឱត្តប្បតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ឥទំ វុច្ចតិ អនោត្តប្បំ ។ តត្ថ កតមោ បមាទោ ។ កាយទុច្ចរិតេ វា វចីទុច្ចរិតេ វា មនោទុច្ចរិតេ វា បញ្ចសុ កាមគុណេសុ

សេចក្តីប្រាថ្នាដ៏ក្រៃលែង នៃបុគ្គលមិនសន្តោស ដោយចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ តាមមានតាមបាន ឬដោយកាមគុណទាំង ៥ សេចក្តីប្រាថ្នា ការប្រព្រឹត្តិទៅដោយសេចក្តីប្រាថ្នា សេចក្តីប្រាថ្នាធំ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រាថ្នាធំ ។

(១៨៨) បណ្តាធម៌ទាំងនោះ សេចក្តីមិនខ្មាសបាប តើដូចម្តេច ។ គ្រប់ដែលបុគ្គលមិនខ្មាស ដោយវត្ថុដែលគួរខ្មាស មិនខ្មាស ដោយការជួបប្រទះ នឹងពួកអកុសលធម៌ដ៏លាមក នេះហៅថា សេចក្តីមិនខ្មាសបាប ។ បណ្តាធម៌ទាំងនោះ សេចក្តីមិនក្តៅនឹងបាប តើដូចម្តេច ។ គ្រប់ដែលបុគ្គល មិនតក់ស្លុត ដោយវត្ថុដែលគួរតក់ស្លុត មិនតក់ស្លុត ដោយការជួបប្រទះ នឹងពួកអកុសលធម៌ដ៏លាមក នេះហៅថា សេចក្តីមិនក្តៅនឹងបាប ។ បណ្តាធម៌ទាំងនោះ សេចក្តីប្រមាទ តើដូចម្តេច ។ ការបណ្តោយចិត្ត ការឲ្យកម្លាំងដល់ការបណ្តោយចិត្តទៅ ក្នុងកាយ-ទុច្ចរិតក្តី ក្នុងវចីទុច្ចរិតក្តី ក្នុងមនោទុច្ចរិតក្តី ក្នុងកាមគុណទាំង ៥ ក្តី

ចិត្តស្ស វោស្សគ្គោ វោស្សគ្គានុប្បទានំ កុសលានំ វា ធម្មានំ ភាវនាយ អសក្កច្ចកិរិយតា អសាតច្ច-កិរិយតា អនដ្ឋិតកិរិយតា ឱលីនវុត្តិតា និក្ខិ-ត្តច្ឆន្ទតា និក្ខិត្តធុរតា អនាសេវនា អភាវនា អពហុលីកម្មំ អនធិដ្ឋានំ អននុយោគោ បមាទោ យោ ឯវរូបោ បមាទោ បមជ្ជនា បមជ្ជិតត្តំ អយំ វុច្ចតិ បមាទោ ។

(១៨៩) តត្ថ កតមំ អនាទរិយំ ។ យំ អនា-ទរិយំ អនាទរតា អគារវតា អប្បដិស្សវតា អនាទា អនាទាយនា អនាទាយិតត្តំ អសីល្យំ អចិតិការោ ឥទំ វុច្ចតិ អនាទរិយំ ។ តត្ថ កតមា ទោវចស្សតា ។ សហធម្មិកេ វុច្ចមានេ ទោវចស្សាយំ ទោវចស្សិយំ ទោវចស្សតា វិប្បដិកូលគ្គាហិតា វិបច្ចនីកសាតតា អនាទរិយំ អនាទរតា អគារវតា អប្បដិស្សវតា អយំ វុច្ចតិ ទោវចស្សតា ។ តត្ថ កតមា

ឬការធ្វើដោយមិនគោរព ការធ្វើមិនរឿយ ៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តិទំរន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិនប្រកបរឿយ ៗ ការធ្វេសប្រហែស ក្នុងការចំរើននូវធម៌ជាកុសល ការធ្វេសប្រហែស អាការធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីប្រមាទ ។

[១៨៩] បណ្ដាធម៌ទាំងនោះ សេចក្តីមិនអើពើ តើដូចម្តេច ។ ការមិនអើពើ សេចក្តីមិនអើពើ សេចក្តីមិនគោរព ការមិនស្តាប់បង្គាប់ ការមិនកាន់យក អាការមិនកាន់យក ភាពនៃសេចក្តីមិនកាន់យក ការមិនមានប្រក្រតី ការមិនធ្វើនូវសេចក្តីឱនលំទោន ណា នេះហៅថា សេចក្តីមិនអើពើ ។ បណ្ដាធម៌ទាំងនោះ ការប្រដៅក្រ តើដូចម្តេច ។ ការប្រដៅក្រ អាការប្រដៅក្រ ភាពនៃសេចក្តីប្រដៅក្រ ការកាន់យកនូវអំពើដែលគួរខ្ពើម (អំពើផ្តេសផ្តាស) ការពេញចិត្តក្នុងធម៌ជាសត្រូវ ការមិនអើពើ សេចក្តីមិនអើពើ សេចក្តីមិនគោរព សេចក្តីមិនស្តាប់បង្គាប់ ចំពោះពាក្យប្រកបដោយធម៌ ដែលគេពោល នេះហៅថា ការប្រដៅក្រ ។ បណ្ដាធម៌ទាំងនោះ

ចាបមិត្តតា ។ យេ តេ បុគ្គលា អស្សទ្ធា ទុស្សីលា អប្បស្សុតា មច្ឆរិនោ ទុប្បញ្ញា យា តេសំ សេវនា និសេវនា ភជនា សម្ភជនា ភត្តិ សម្ភត្តិ តំសម្ប-វង្កតា អយំ វុច្ចតិ ចាបមិត្តតា ។

(១៩០) តត្ថ កតមំ អស្សទ្ធិយំ ។ ឥធេកច្ចោ អស្សទ្ធោ ហោតិ ន សទ្ទហតិ ពុទ្ធំ វា ធម្មំ វា សង្ឃំ វា យំ ឯវរូបំ អស្សទ្ធិយំ អសទ្ទហនា អនោកប្បនា អនភិប្បសាទោ ឥទំ វុច្ចតិ អស្ស-ទ្ធិយំ ។ តត្ថ កតមា អវទញ្ញុតា ។ បញ្ច មច្ឆរិ-យានិ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ យំ ឯវរូបំ មច្ឆេរំ មច្ឆរា-យនា មច្ឆរាយិតត្តំ វេវិច្ឆំ កទរិយំ កដុកញ្ចុកតា អគ្គហិតត្តំ ចិត្តស្ស អយំ វុច្ចតិ អវទញ្ញុតា ។

ភាពជាអ្នកមានមិត្រអាក្រក់ តើដូចម្តេច ។ បុគ្គលទាំងឡាយណា ជាអ្នកមិនមានសទ្ធា ទ្រុស្តសីល បេះដឹងតិច មានសេចក្តីកំណាញ់ ឥតបញ្ញា ការសេព ការសេពមិនដាច់ ការគប់រក ការគប់រករឿយៗ ការគប់ប្រសព្វ ការគប់ប្រសព្វរឿយ ៗ នូវបុគ្គលទាំងឡាយនោះ ការបែររេទៅរកបុគ្គលនោះ ណា នេះហៅថា ភាពជាអ្នកមានមិត្តអាក្រក់ ។

(១៩០) បណ្តាធម៌ទាំងនោះ សេចក្តីមិនជឿ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនមានសទ្ធា មិនជឿព្រះពុទ្ធក្តី ព្រះធម៌ក្តី ព្រះសង្ឃក្តី សេចក្តីមិនជឿ ការមិនជឿ ការមិនចុះចិត្តស៊ប់ ការមិនជ្រះថ្លាខ្លាំង មានសភាពយ៉ាងនេះ ណា នេះហៅថា សេចក្តីមិនជឿ ។ បណ្តាធម៌ទាំងនោះ ការមិនធ្វើដឹងឮពាក្យ (សូម) តើដូចម្តេច ។ សេចក្តីកំណាញ់ ៥ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់សេចក្តីសរសើរ ១ កំណាញ់ធម៌ ១ ការកំណាញ់ អាការកំណាញ់ សេចក្តីកំណាញ់ សេចក្តីប្រាថ្នាផ្សេង ៗ សេចក្តីកំណាញ់រឹង សេចក្តីស្វិតស្វាញ ភាពនៃចិត្តមិនយកចិត្តគេ មានសភាពយ៉ាងនេះ ណា នេះហៅថា ការមិនធ្វើដឹងឮពាក្យ (សូម) ។

តត្ថ កតមំ កោសជ្ជំ កាយទុច្ចរិតេ វា វចីទុច្ចរិតេ វា មនោទុច្ចរិតេ វា បញ្ចសុ វា កាមគុណេសុ ចិត្តស្ស វោស្សគ្គោ វោស្សគ្គានុប្បទានំ កុសលានំ វា ធម្មានំ ភាវនាយ អសក្កច្ចកិរិយតា អសាតច្ចកិរិយតា អនដ្ឋិតកិរិយតា ឱលីនវុត្តិតា និក្ខិត្តច្ឆន្ទតា និក្ខិត្តធុរតា អនាសេវនា អភាវនា អពហុលីកម្មំ អនធិដ្ឋានំ អននុយោគោ បមាទោ ឥទំ វុច្ចតិ កោសជ្ជំ ។

(១៩១) តត្ថ កតមំ ឧទ្ធច្ចំ ។ យំ ចិត្តស្ស ឧទ្ធច្ចំ អវូបសមោ ចេតសោ វិក្ខេបោ ភន្តត្តំ ចិត្តស្ស ឥទំ វុច្ចតិ ឧទ្ធច្ចំ ។ តត្ថ កតមោ អសំវរោ ។ ឥធេកច្ចោ ចក្ខុនា រូបំ ទិស្វា និមិត្តគ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ ន បដិបជ្ជតិ ន រក្ខតិ ចក្ខុន្ទ្រិយំ

បណ្ដាធម៌ទាំងនោះ សេចក្ដីខ្ជិល តើដូចម្ដេច ។ ការបណ្ដោយចិត្ត ការឲ្យកម្លាំងដល់ការបណ្ដោយចិត្តទៅ ក្នុងកាយទុច្ចរិតក្ដី វចីទុច្ចរិតក្ដី មនោទុច្ចរិតក្ដី ក្នុងកាមគុណទាំង ៥ ក្ដី ឬ ការធ្វើដោយមិនគោរព ការធ្វើមិនរឿយ ៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តទន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិនប្រកបរឿយ ៗ ការធ្វេសប្រហែសក្នុងការចំរើននូវធម៌ជាកុសល នេះហៅថា សេចក្ដីខ្ជិល ។

( ១៩១ ) បណ្ដាធម៌ទាំងនោះ សេចក្ដីពុយមាយ តើដូចម្ដេច ។ សេចក្ដីពុយមាយនៃចិត្ត ការមិនស្ងប់ស្ងាប់នៃចិត្ត ការរវើរវាយនៃចិត្ត សេចក្ដីប្រែប្រួលនៃចិត្ត ណា នេះហៅថា សេចក្ដីពុយមាយ ។ បណ្ដាធម៌ទាំងនោះ សេចក្ដីមិនសង្រួម តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឃើញនូវរូបដោយចក្ខុ ហើយកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ ឯអភិជ្ឈានិងទោមនស្ស ដែលជាអកុសល-ធម៌ដ៏លាមក តែងតែគ្របសង្កត់នូវបុគ្គល ដែលមិនបានសង្រួម នូវ-ចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួម នូវចក្ខុន្ទ្រិយ ណា ក៏មិនប្រតិបត្តិដើម្បីសង្រួម នូវចក្ខុន្ទ្រិយនោះ មិនរក្សា នូវចក្ខុន្ទ្រិយ

ចក្ខុន្ទ្រិយេ ន សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា ។ បេ ។ ឃានេន គន្ធំ ឃាយិត្វា ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ បេ ។ មនសា ធម្មំ វិញ្ញាយ និមិត្តគ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ ន បដិបជ្ជតិ ន រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ ន សំវរំ អាបជ្ជតិ អយំ វុច្ចតិ អសំវរោ ។ តត្ថ កតមំ ទុស្សីល្យំ ។ កាយិកោ វីតិក្កមោ វាចសិកោ វីតិក្កមោ កាយិកវាចសិកោ វីតិក្កមោ ឥទំ វុច្ចតិ ទុស្សីល្យំ ។

(០៩២) តត្ថ កតមា អរិយានំ អទស្សនកម្យតា ។ តត្ថ កតមេ អរិយា ។ អរិយា វុច្ចន្តិ ពុទ្ធា ច ពុទ្ធសាវកា ច

មិនដល់នូវសេចក្តីសង្រួម ក្នុងចក្ខុន្ទ្រិយ ឮសម្លេងដោយត្រចៀក ។ បេ ។ ធុំក្លិនដោយច្រមុះ ។ បេ ។ ជញ្ជក់រសដោយអណ្តាត ។ បេ ។ ពាល់ត្រូវផ្សព្វដោយកាយ ។ បេ ។ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ហើយកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ ឯអភិជ្ឈាទិនទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងតែគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួម នូវមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួម នូវមនិន្ទ្រិយ ណា ក៏មិនប្រតិបត្តិ ដើម្បីសង្រួមនូវមនិន្ទ្រិយនោះ មិនរក្សា នូវមនិន្ទ្រិយ មិនដល់នូវសេចក្តីសង្រួមក្នុងមនិន្ទ្រិយ នេះហៅថា សេចក្តីមិនសង្រួម ។ បណ្តាធម៌ទាំងនោះ សេចក្តីទ្រុស្តសីល តើដូចម្តេច ។ ការប្រព្រឹត្តិកន្លង ប្រកបដោយកាយ ការប្រព្រឹត្តិកន្លង ប្រកបដោយវាចា ការប្រព្រឹត្តិកន្លង ប្រកបដោយកាយ និងប្រកបដោយវាចា នេះហៅថា សេចក្តីទ្រុស្តសីល ។

(១៩២) បណ្តាធម៌ទាំងនោះ សេចក្តីមិនប្រាថ្នាដើម្បីឃើញព្រះអរិយៈ តើដូចម្តេច ។ បណ្តាបុគ្គលទាំងនោះ ព្រះអរិយៈ តើដូចម្តេច ។ ព្រះពុទ្ធទាំងឡាយក្តី សាវ័ករបស់ព្រះពុទ្ធក្តី ហៅថា ព្រះអរិយៈ

យា ឥមេសំ អរិយានំ អទស្សនកម្យតា អទដ្ឋុ-
កម្យតា អសមេតុកម្យតា អសមាគន្តុកម្យតា អយំ
វុច្ចតិ អរិយានំ អទស្សនកម្យតា ។ តត្ថ កតមា
សទ្ធម្មំ អសោតុកម្យតា ។ តត្ថ កតមោ សទ្ធម្មោ ។
ចត្តារោ សតិបដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ
ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត
ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ អយំ វុច្ចតិ
សទ្ធម្មោ យា ឥមស្ស សទ្ធម្មស្ស អសោតុកម្យតា
អស្សវនកម្យតា អនុគ្គហេតុកម្យតា អធារេតុកម្យតា
អយំ វុច្ចតិ សទ្ធម្មំ អសោតុកម្យតា ។ តត្ថ កតមា
ឧបារម្ភចិត្តតា ។ តត្ថ កតមោ ឧបារម្ភោ ។ យោ
ឧបារម្ភោ អនុបារម្ភោ ឧបារម្ភនា អនុបារម្ភនា អនុ-
បារម្ភិតត្តំ ឧញ្ញា អវញ្ញា បរិភវោ រន្ធគវេសិតា អយំ
វុច្ចតិ ឧបារម្ភចិត្តតា ។

ការមិនប្រាថ្នាដើម្បីឃើញ ការមិនប្រាថ្នាដើម្បីជួប ការមិនប្រាថ្នាដើម្បីទៅកាន់ទីជិត ការមិនប្រាថ្នាដើម្បីទៅជាមួយ នឹងព្រះអរិយៈទាំងឡាយនេះ ណា នេះហៅថា សេចក្តីមិនប្រាថ្នាដើម្បីឃើញព្រះអរិយៈ ។ បណ្តាធម៌ទាំងនោះ សេចក្តីមិនប្រាថ្នាដើម្បីស្តាប់នូវព្រះសទ្ធម្ម តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ព្រះសទ្ធម្ម តើដូចម្តេច ។ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ នេះហៅថា ព្រះសទ្ធម្ម សេចក្តីមិនប្រាថ្នាដើម្បីស្តាប់ សេចក្តីមិនប្រាថ្នាដើម្បីឮ សេចក្តីមិនប្រាថ្នាដើម្បីរៀន សេចក្តីមិនប្រាថ្នាដើម្បីទ្រទ្រង់ នូវព្រះសទ្ធម្មនេះ ណា នេះហៅថា សេចក្តីមិនប្រាថ្នាដើម្បីស្តាប់នូវព្រះសទ្ធម្ម ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គល មានចិត្តប្រណាំងប្រជែង តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ សេចក្តីប្រណាំងប្រជែង តើដូចម្តេច ។ ការប្រណាំងប្រជែង ការប្រណាំងប្រជែងរឿយ ៗ អាការប្រណាំងប្រជែង អាការប្រណាំងប្រជែងរឿយ ៗ ភាពនៃសេចក្តីប្រណាំងប្រជែងរឿយ ៗ ការផ្ទើមផ្ទែ ការមើលងាយ ការពេបជ្រាយ ការស្វែងរកទោស ណា នេះហៅថា ភាពនៃបុគ្គលមានចិត្តប្រណាំងប្រជែង ។

### ខុទ្ទកវត្ថុវិភង្គេ តិកនិទ្ទេសោ

(១៩៣) តត្ថ កតមំ មុដ្ឋស្សច្ចំ ។ យា អស្សតិ អនុស្សតិ អប្បដិស្សតិ អស្សតិ អសរណតា អធារណតា បិលាបនតា សម្មុសនតា ឥទំ វុច្ចតិ មុដ្ឋស្សច្ចំ ។ តត្ថ កតមំ អសម្បជញ្ញំ ។ យំ អញ្ញាណំ អទស្សនំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ ឥទំ វុច្ចតិ អសម្បជញ្ញំ ។ តត្ថ កតមោ ចេតសោ វិក្ខេបោ ។ យំ ចិត្តស្ស ឧទ្ធច្ចំ អវូបសមោ ចេតសោ វិក្ខេបោ ភន្តត្តំ ចិត្តស្ស អយំ វុច្ចតិ ចេតសោ វិក្ខេបោ ។

(១៩៤) តត្ថ កតមោ អយោនិសោ មនសិការោ ។ អនិច្ចេ និច្ចន្តិ អយោនិសោ មនសិការោ ទុក្ខេ សុខន្តិ អយោនិសោ មនសិការោ អនត្តនិ អត្តាតិ អយោនិសោ មនសិការោ អសុភេ សុភន្តិ អយោនិសោ មនសិការោ សច្ចវិប្បដិកូលេន វា

ខុទ្ទកវត្ថុវិភង្គ តិកនិទ្ទេស

(១៩៣) បណ្ដាធម៌ទាំងនោះ ការភ្លេចស្មារតី តើដូចម្ដេច ។ ការមិនមានស្មារតី ការមិនរលឹកឃើញ ការមិននឹកឃើញ ការមិនរលឹក សេចក្ដីមិនរលឹក សេចក្ដីមិនចងចាំ សេចក្ដីភ្លេចភ្លាំង សេចក្ដីវង្វេង ណា នេះហៅថា ការភ្លេចស្មារតី ។ បណ្ដាធម៌ទាំងនោះ សេចក្ដីមិនដឹងខ្លួន តើដូចម្ដេច ។ សេចក្ដីមិនដឹង សេចក្ដីមិនយល់ ។ បេ ។ គន្លឹះគឺអវិជ្ជា សេចក្ដីវង្វេង ឫសគល់នៃអកុសល ណា នេះហៅថា សេចក្ដីមិនដឹងខ្លួន ។ បណ្ដាធម៌ទាំងនោះ សេចក្ដីពាយមាយនៃចិត្ត តើដូចម្ដេច ។ សេចក្ដីអណ្ដែតអណ្ដូងនៃចិត្ត ការមិនស្ងប់រម្ងាប់នៃចិត្ត សេចក្ដីពាយមាយនៃចិត្ត ការប្រែប្រួលនៃចិត្ត ណា នេះហៅថា សេចក្ដីពាយមាយនៃចិត្ត ។

(១៩៤) បណ្ដាធម៌ទាំងនោះ ការធ្វើទុកក្នុងចិត្ត ដោយខុសឧបាយ តើដូចម្ដេច ។ ការធ្វើទុកក្នុងចិត្ត ដោយខុសឧបាយ ក្នុងរបស់ដែលមិនទៀងថា ទៀង ការធ្វើទុកក្នុងចិត្ត ដោយខុសឧបាយ ក្នុងរបស់ដែលជាទុក្ខថា សុខ ការធ្វើទុកក្នុងចិត្ត ដោយខុសឧបាយ ក្នុងរបស់ដែលមិនមែនខ្លួនថា ខ្លួន ការធ្វើទុកក្នុងចិត្ត ដោយខុសឧបាយ ក្នុងរបស់មិនស្អាតថា ស្អាត មួយទៀត ការពឹង ការពឹងរឿយ ៗ

ចិត្តស្ស អាវដ្ដនា អនាវដ្ដនា[១] អាភោគោ សមន្នាហារោ មនសិការោ អយំ វុច្ចតិ អយោនិសោ មនសិការោ ។ តត្ថ កតមា កុម្មគ្គសេវនា ។ តត្ថ កតមោ កុម្មគ្គោ ។ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បោ មិច្ឆាវាចា មិច្ឆាកម្មន្តោ មិច្ឆាអាជីវោ មិច្ឆាវាយាមោ មិច្ឆាសតិ មិច្ឆាសមាធិ អយំ វុច្ចតិ កុម្មគ្គោ យា ឥមស្ស កុម្មគ្គស្ស សេវនា និសេវនា សំសេវនា ភជនា សម្ភជនា ភត្តិ សម្ភត្តិ តំសម្បវង្កតា អយំ វុច្ចតិ កុម្មគ្គសេវនា ។ តត្ថ កតមំ ចេតសោ លីនត្តំ ។ យា ចិត្តស្ស អកល្យតា អកម្មញ្ញតា ឱលីយនា សល្លីយនា លីនំ លីយនា លីយិតត្តំ ថីនំ ថីយនា ថីយិតត្តំ ចិត្តស្ស ឥទំ វុច្ចតិ ចេតសោ លីនត្តំ ។

តិកំ ។

១ ឱ. ម. អាវដ្ដនា អនាវដ្ដនាតិ ទិស្សន្តិ ។

ការផ្គងចិត្តទុក ការតម្រង់ចិត្តទុក ការធ្វើទុកក្នុងចិត្ត ដោយខុសពាក សច្ចៈ នេះហៅថា ការធ្វើទុកក្នុងចិត្តដោយខុសឧបាយ ។ បណ្តាធម៌ទាំងនោះ ការសេពផ្លូវខុស តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ផ្លូវខុស តើដូចម្តេច ។ សេចក្តីយល់ខុស តម្រិះខុស វាចាខុស ការងារខុស ការចិញ្ចឹមជីវិតខុស ការព្យាយាមខុស សេចក្តីរលឹកខុស ការតម្កល់ចិត្តខុស នេះហៅថា ផ្លូវខុស ការសេព ការសេពមិនដាច់ ការសេពព្រម ការគប់រក ការគប់រករឿយ ៗ សេចក្តីគប់រក សេចក្តីគប់រករឿយ ៗ នូវផ្លូវខុសនេះ ការបែរទៅរកនូវផ្លូវខុសនេះណា នេះហៅថា ការសេពផ្លូវខុស ។ បណ្តាធម៌ទាំងនោះ ភាពនៃចិត្តរួញរា តើដូចម្តេច ។ ភាពមិនគួរ ភាពមិនគួរដល់ការងារ ការរួញថយ ការរួញចូល ការលឹបល អាការលឹបល ភាពនៃសេចក្តីលឹបល ការក្រាញនៅ អាការក្រាញនៅ ភាពនៃសេចក្តីក្រាញនៅ នៃចិត្ត ណា នេះហៅថា ភាពនៃចិត្តរួញរា ។

ចប់ ពួកធម៌ទី ៣ ។

## ខុទ្ទកវត្ថុវិភង្គេ ចតុក្កនិទ្ទេសោ

( ១៩៨ ) តត្ថ កតមេ ចត្តារោ អាសវា ។ កាមាសវោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ ។ តត្ថ កតមោ កាមាសវោ ។ យោ កាមេសុ កាមច្ឆន្ទោ ។ បេ ។ កាមជ្ឈោសានំ អយំ វុច្ចតិ កាមាសវោ ។ តត្ថ កតមោ ភវាសវោ ។ យោ ភវេសុ ភវច្ឆន្ទោ ។ បេ ។ ភវជ្ឈោសានំ អយំ វុច្ចតិ ភវាសវោ ។ តត្ថ កតមោ ទិដ្ឋាសវោ ។ សស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ ទិដ្ឋាសវោ សព្វាបិ មិច្ឆាទិដ្ឋិ ទិដ្ឋាសវោ ។ តត្ថ កតមោ អវិជ្ជាសវោ ។ ទុក្ខេ អញ្ញាណំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ អវិជ្ជាសវោ ។ ឥមេ ចត្តារោ អាសវា ។

ខុទ្ទកវត្ថុវិភង្គ បត្តុកនិទ្ទេស

(១៩៤) បណ្តាធម៌ទាំងនោះ អាសវៈ ៤ តើដូចម្តេច ។ កាមាសវៈ ១ ភវាសវៈ ១ ទិដ្ឋាសវៈ ១ អវិជ្ជាសវៈ ១ ។ បណ្តាអាសវៈទាំង ៤ នោះ កាមាសវៈ តើដូចម្តេច ។ សេចក្តីប្រាថ្នាកាម ក្នុងកាមទាំងឡាយ ។ បេ ។ ការជ្រុលជ្រប់ក្នុងកាម ណា នេះហៅថា កាមាសវៈ ។ បណ្តាអាសវៈទាំង ៤ នោះ ភវាសវៈ តើដូចម្តេច ។ សេចក្តីប្រាថ្នាភព ក្នុងភពទាំងឡាយ ។ បេ ។ ការជ្រុលជ្រប់ក្នុងភព ណា នេះហៅថា ភវាសវៈ ។ បណ្តាអាសវៈទាំង ៤ នោះ ទិដ្ឋាសវៈ តើដូចម្តេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ ការប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា ដូច្នេះថា លោកទៀងក្តី ។ បេ ។ ថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀត ក៏មិនមែនក្តី នេះហៅថា ទិដ្ឋាសវៈ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ ក៏ឈ្មោះថា ទិដ្ឋាសវៈ ។ បណ្តាអាសវៈទាំង ៤ នោះ អវិជ្ជាសវៈ តើដូចម្តេច ។ ការមិនដឹងក្នុងទុក្ខ ។ បេ ។ គន្លឹះគឺអវិជ្ជា សេចក្តីវង្វេង ឫសគល់នៃអកុសល នេះហៅថា អវិជ្ជាសវៈ ។ នេះ អាសវៈ ៤ ។

[១៩៦] តត្ថ កតមេ ចត្តារោ គន្ថា ។ អភិជ្ឈា កាយគន្ថោ ព្យាបាទោ កាយគន្ថោ សីលព្វតបរា-មាសោ កាយគន្ថោ ឥទំសច្ចាភិនិវេសោ កាយ-គន្ថោ ។ តត្ថ កតមោ អភិជ្ឈា កាយគន្ថោ ។ យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ អយំ វុច្ចតិ អភិជ្ឈា កាយគន្ថោ ។ តត្ថ កតមោ ព្យាបាទោ កាយគន្ថោ ។ អនត្ថំ មេ អចរីតិ ។ បេ ។ ចណ្ឌិក្កំ អសុរោបោ អនត្ត-មនតា ចិត្តស្ស អយំ វុច្ចតិ ព្យាបាទោ កាយគន្ថោ ។ តត្ថ កតមោ សីលព្វតបរាមាសោ កាយគន្ថោ ។ ឥតោ ពហិទ្ធា សមណព្រាហ្មណានំ សីលេន សុទ្ធិ វតេន សុទ្ធិ សីលព្វតេន សុទ្ធីតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ សីលព្វតបរាមាសោ កាយគន្ថោ ។ តត្ថ កតមោ ឥទំសច្ចាភិនិវេសោ កាយគន្ថោ ។

[ ១៩៦ ] បណ្តាធម៌ទាំងនោះ គន្ថៈ (ធម៌ជាគ្រឿងចាក់ស្រែះ) ៤ តើដូចម្តេច ។ អភិជ្ឈាកាយគន្ថៈ ១ ព្យាបាទកាយគន្ថៈ ១ សីលព្វតបរាមាសកាយគន្ថៈ ១ ឥទំសច្ចាភិនិវេសកាយគន្ថៈ ១ ។ បណ្តាគន្ថៈទាំង ៤ នោះ អភិជ្ឈាកាយគន្ថៈ តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ សេចក្តីសំឡឹងរំពៃ សេចក្តីលោភ ឫសគល់នៃអកុសល ណា នេះហៅថា អភិជ្ឈាកាយគន្ថៈ ។ បណ្តាគន្ថៈទាំង ៤ នោះ ព្យាបាទកាយគន្ថៈ តើដូចម្តេច ។ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញ ។បេ។ សេចក្តីកាច ការទទឹង សេចក្តីមិនត្រេកអរនៃចិត្ត នេះហៅថា ព្យាបាទកាយគន្ថៈ ។ បណ្តាគន្ថៈទាំង៤នោះ សីលព្វតបរាមាសកាយគន្ថៈ តើដូចម្តេច ។ ពួកសមណព្រាហ្មណ៍ ខាងក្រៅសាសនានេះ មានទិដ្ឋិ ដំណើរតែទិដ្ឋិ ។បេ។ សេចក្តីប្រកាន់ភ្ជាប់ការស្វែងរកខុស មានសភាពយ៉ាងនេះ ណា ដូច្នេះថា សេចក្តីបរិសុទ្ធិ ព្រោះសីល សេចក្តីបរិសុទ្ធិ ព្រោះវត្ត សេចក្តីបរិសុទ្ធិ ព្រោះសីលនិងវត្ត នេះហៅថា សីលព្វតបរាមាសកាយគន្ថៈ ។ បណ្តាគន្ថៈទាំង ៤ នោះ ឥទំសច្ចាភិនិវេសកាយគន្ថៈ តើដូចម្តេច ។

សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ វា អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ វា យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ អយំ វុច្ចតិ ឥទំសច្ចាភិនិវេសោ កាយគន្ថោ ។ ឋបេត្វា សីលព្វតបរាមាសំ កាយគន្ថំ សព្វាបិ មិច្ឆាទិដ្ឋិ ឥទំសច្ចាភិនិវេសោ កាយគន្ថោ ។ ឥមេ ចត្តារោ គន្ថា ។

(១៩៧) តត្ថ កតមេ ចត្តារោ ឱឃា ។ បេ ។ យោគា ។ បេ ។ ចត្តារិ ឧបាទានានិ កាមុបាទានំ ទិដ្ឋុបាទានំ សីលព្វតុបាទានំ អត្តវាទុបាទានំ ។ តត្ថ កតមំ កាមុបាទានំ ។ យោ កាមេសុ កាមច្ឆន្ទោ ។ បេ ។ កាមជ្ឈោសានំ ឥទំ វុច្ចតិ កាមុបាទានំ ។ តត្ថ កតមំ ទិដ្ឋុបាទានំ ។

ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា ដូច្នេះថា លោកទៀង សេចក្តីយល់នេះពិត សេចក្តីយល់ដទៃជាមោឃៈក្តី ថា លោកមិនទៀង សេចក្តីយល់នេះពិត សេចក្តីយល់ដទៃជាមោឃៈក្តី ។ បេ ។ ថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន សេចក្តីយល់នេះពិត សេចក្តីយល់ដទៃជាមោឃៈក្តី នេះហៅថា ឥទំសច្ចាភិនិវេសកាយគន្ថៈ ។ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ លើកលែងតែសីលព្វតបរាមាសកាយគន្ថៈចេញ ក៏ឈ្មោះថា ឥទំសច្ចាភិនិវេសកាយគន្ថៈដែរ ។ នេះគន្ថៈ ៤ ។

(១៩៧) បណ្តាធម៌ទាំងនោះ ឱឃៈ ៤ តើដូចម្តេច ។ បេ ។ យោគៈ ។ បេ ។ ឧបាទាន ៤ គឺ កាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។ បណ្តាឧបាទានទាំង ៤ នោះ កាមុបាទាន តើដូចម្តេច ។ សេចក្តីប្រាថ្នាទូវកាម ក្នុងកាមទាំងឡាយ ។ បេ ។ ការងុលងប់ក្នុងកាម ណា នេះហៅថា កាមុបាទាន ។ បណ្តាឧបាទានទាំង ៤ នោះ ទិដ្ឋុបាទាន តើដូចម្តេច ។

នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ ។ បេ ។ យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ ឥទំ វុច្ចតិ ទិដ្ឋុបាទានំ ។ ឋបេត្វា សីលព្វតុបាទានញ្ច អត្តវាទុបាទានញ្ច សព្វាបិ មិច្ឆាទិដ្ឋិ ទិដ្ឋុបាទានំ ។ តត្ថ កតមំ សីលព្វតុបាទានំ ។ ឥតោ ពហិទ្ធា សមណព្រាហ្មណានំ សីលេន សុទ្ធិ វតេន សុទ្ធិ សីលព្វតេន សុទ្ធីតិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ ឥទំ វុច្ចតិ សីលព្វតុបាទានំ ។ តត្ថ កតមំ អត្តវាទុបាទានំ ។ ឥធ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ

ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា ដូច្នេះថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជា មិនមានផល ។ បេ ។ សមណព្រាហ្មណ៍ទាំងឡាយ ដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្ដមខ្លួនឯងហើយសំដែង មិនមានទេ នេះហៅថា ទិដ្ឋុបាទាន ។ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ លើកតែសីលព្វតុបាទាន និងអត្តវាទុបាទានចេញ ក៏ឈ្មោះថា ទិដ្ឋុបាទានដែរ ។ បណ្ដាឧបាទានទាំង ៤ នោះ សីលព្វតុបាទាន តើដូចម្ដេច ។ សមណព្រាហ្មណ៍ទាំងឡាយខាងក្រៅសាសនានេះ មានទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្ដីប្រកាន់ ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះ ណា ដូច្នេះថា សេចក្ដីបរិសុទ្ធិ ព្រោះសីល សេចក្ដីបរិសុទ្ធិ ព្រោះវ័ត សេចក្ដីបរិសុទ្ធិ ព្រោះសីលនឹងវ័ត នេះហៅថា សីលព្វតុបាទាន ។ បណ្ដាឧបាទានទាំង ៤ នោះ អត្តវាទុបាទាន តើដូចម្ដេច ។ បុថុជ្ជន ក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាស ក្នុងធម៌របស់ព្រះអរិយៈ មិនទូន្មានខ្លួន ក្នុងធម៌របស់ព្រះអរិយៈ មិនបានឃើញពួកសប្បុរស មិនឈ្លាស ក្នុងធម៌របស់ពួកសប្បុរស មិនទូន្មានខ្លួន ក្នុងធម៌របស់ពួកសប្បុរស

ខុទ្ទកវត្ថុវិភង្គេ ចតុក្កនិទ្ទេសោ

រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ ។ បេ ។ សញ្ញំ ។ បេ ។ សង្ខារេ ។ បេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ វិបរិយេសគ្គាហោ ឥទំ វុច្ចតិ អត្តវាទុបាទានំ ។ ឥមានិ ចត្តារិ ឧបាទានានិ ។

(១៩៨) តត្ថ កតមេ ចត្តារោ តណ្ហុប្បាទា ។ ចីវរហេតុ វា ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ បិណ្ឌបាតហេតុ វា ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ សេនាសនហេតុ វា ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឥតិភវាភវហេតុ វា ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឥមេ ចត្តារោ តណ្ហុប្បាទា ។

រមែងពិចារណាឃើញនូវរូប ថា ជាខ្លួន ពិចារណាឃើញនូវខ្លួន ថា មានរូបខ្លះ ពិចារណាឃើញនូវរូប ថា មានក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួន ថា មានក្នុងរូបខ្លះ ពិចារណាឃើញនូវវេទនា ។ បេ ។ នូវសញ្ញា ។ បេ ។ នូវសង្ខារទាំងឡាយ ។ បេ ។ នូវវិញ្ញាណ ថា ជាខ្លួន ពិចារណាឃើញនូវខ្លួន ថា មានវិញ្ញាណខ្លះ ពិចារណាឃើញនូវវិញ្ញាណ ថា មានក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួន ថា មានក្នុងវិញ្ញាណខ្លះ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ សេចក្តីប្រកាន់ក្នុងការវែងរកខុស មានសភាពយ៉ាងនេះ ណា នេះ ហៅថា អត្តវាទុបាទាន ។ នេះ ឧបាទាន ៤ ។

[១៩៨] បណ្តាធម៌ទាំងនោះ តណ្ហុប្បាទ ៤ តើដូចម្តេច ។ តណ្ហានៃភិក្ខុ កាលនឹងកើត រមែងកើតឡើង ព្រោះហេតុនៃចីវរខ្លះ តណ្ហានៃភិក្ខុ កាលនឹងកើត រមែងកើតឡើង ព្រោះហេតុនៃបិណ្ឌបាតខ្លះ តណ្ហានៃភិក្ខុ កាលនឹងកើត រមែងកើតឡើង ព្រោះហេតុនៃសេនាសនៈខ្លះ តណ្ហានៃភិក្ខុ កាលនឹងកើត រមែងកើតឡើង ព្រោះហេតុនៃសេចក្តីចំរើននិងសេចក្តីវិនាសដូច្នេះៗខ្លះ នេះ តណ្ហុប្បាទ ៤ ។

## អភិធម្មបិដកេ វិភង្គោ

(១៩៩) តត្ថ កតមានិ ចត្តារិ អគតិគមនានិ ។ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ យា ឯវរូបា អគតិ អគតិគមនំ ឆន្ទគមនំ វគ្គគមនំ វារិគមនំ ឥមានិ ចត្តារិ អគតិគមនានិ ។

(២០០) តត្ថ កតមេ ចត្តារោ វិបរិយេសា ។ អនិច្ចេ និច្ចន្តិ សញ្ញាវិបរិយេសោ ចិត្តវិបរិយេសោ ទិដ្ឋិវិបរិយេសោ ទុក្ខេ សុខន្តិ សញ្ញាវិបរិយេសោ ចិត្តវិបរិយេសោ ទិដ្ឋិវិបរិយេសោ អនត្តនិ អត្តាតិ សញ្ញាវិបរិយេសោ ចិត្តវិបរិយេសោ ទិដ្ឋិវិបរិយេសោ អសុភេ សុភន្តិ សញ្ញាវិបរិយេសោ ចិត្តវិបរិយេសោ ទិដ្ឋិវិបរិយេសោ ឥមេ ចត្តារោ វិបរិយេសា ។

(២០១) តត្ថ កតមេ ចត្តារោ អនរិយវោហារា ។

(១៩៩) បណ្ដាធម៌ទាំងនោះ ការលុះក្នុងអគតិ ៤ តើដូចម្ដេច ។ បុគ្គល ដល់នូវការលំអៀង ព្រោះស្រឡាញ់ ១ ដល់នូវការលំអៀង ព្រោះស្អប់ ១ ដល់នូវការលំអៀង ព្រោះវង្វេង ១ ដល់នូវការលំអៀង ព្រោះខ្លាច ១ សេចក្ដីលំអៀង ការលុះក្នុងសេចក្ដីលំអៀង ការលុះដោយឆន្ទៈ ការលុះដោយពួក ការលុះដូចជាទឹក មានសភាពយ៉ាងនេះ ណា នេះ ការលុះក្នុងអគតិ ៤ ។

(២០០) បណ្ដាធម៌ទាំងនោះ ការស្វែងរកខុស ៤ តើដូចម្ដេច ។ ការស្វែងរកខុសយេដាសញ្ញា ការស្វែងរកខុសដោយចិត្ត ការស្វែងរកខុសដោយទិដ្ឋិ ក្នុងវត្ថុមិនទៀងថា ទៀង ១ ការស្វែងរកខុសដោយសញ្ញា ការស្វែងរកខុសដោយចិត្ត ការស្វែងរកខុសដោយទិដ្ឋិ ក្នុងវត្ថុជាទុក្ខថា សុខ ១ ការស្វែងរកខុសដោយសញ្ញា ការស្វែងរកខុសដោយចិត្ត ការស្វែងរកខុសដោយទិដ្ឋិ ក្នុងសភាវៈមិនមែនខ្លួនថា ជាខ្លួន ១ ការស្វែងរកខុសដោយសញ្ញា ការស្វែងរកខុសដោយចិត្ត ការស្វែងរកខុសដោយទិដ្ឋិ ក្នុងវត្ថុមិនស្អាតថា ស្អាត ១ នេះ ការស្វែងរកខុស ៤ ។

(២០១) បណ្ដាធម៌ទាំងនោះ វោហារមិនប្រសើរ ៤ តើដូចម្ដេច ។

អទិដ្ឋេ ទិដ្ឋវាទិតា អសុតេ សុតវាទិតា អមុតេ មុតវាទិតា អវិញ្ញាតេ វិញ្ញាតវាទិតា ឥមេ ចត្តារោ អនរិយវោហារា ។

(២០២) តត្ថ កតមេ អបរេបិ ចត្តារោ អនរិយវោហារា ។ ទិដ្ឋេ អទិដ្ឋវាទិតា សុតេ អសុតវាទិតា មុតេ អមុតវាទិតា វិញ្ញាតេ អវិញ្ញាតវាទិតា ឥមេ ចត្តារោ អនរិយវោហារា ។

(២០៣) តត្ថ កតមានិ ចត្តារិ ទុច្ចរិតានិ ។ បាណាតិបាតោ អទិន្នាទានំ កាមេសុ មិច្ឆាចារោ មុសាវាទោ ឥមានិ ចត្តារិ ទុច្ចរិតានិ ។

(២០៤) តត្ថ កតមានិ អបរានិបិ ចត្តារិ ទុច្ចរិតានិ ។ មុសាវាទោ បិសុណា វាចា ផរុសា វាចា សម្ផប្បលាបោ ឥមានិ ចត្តារិ ទុច្ចរិតានិ ។

(២០៥) តត្ថ កតមានិ ចត្តារិ ភយានិ ។ ជាតិភយំ ជរាភយំ ព្យាធិភយំ មរណភយំ ឥមានិ ចត្តារិ ភយានិ ។

ការពោល ថា ឃើញ ក្នុងហេតុដែលមិនបានឃើញ ១ ការពោល ថា ឮ ក្នុងហេតុដែលមិនបានឮ ១ ការពោល ថា លិទ្ធភ្លក្ស ក្នុងហេតុដែលមិនបានលិទ្ធភ្លក្ស ១ ការពោល ថា ដឹង ក្នុងហេតុដែលមិនបានដឹង ១ នេះ វោហារមិនប្រសើរ ៤ ។

( ២០២ ) បណ្តាធម៌ទាំងនោះ វោហារមិនប្រសើរ ៤ ដទៃទៀត តើដូចម្តេច ។ ការពោល ថា មិនឃើញ ក្នុងហេតុដែលបានឃើញ ១ ការពោល ថា មិនឮ ក្នុងហេតុដែលបានឮ ១ ការពោលថា មិនបានលិទ្ធភ្លក្ស ក្នុងហេតុដែលបានលិទ្ធភ្លក្ស ១ ការពោល ថា មិនបានដឹង ក្នុងហេតុដែលបានដឹង ១ នេះ វោហារមិនប្រសើរ ៤ ។

( ២០៣ ) បណ្តាធម៌ទាំងនោះ ទុច្ចរិត ៤ តើដូចម្តេច ។ បាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ នេះ ទុច្ចរិត ៤ ។

( ២០៤ ) បណ្តាធម៌ទាំងនោះ ទុច្ចរិត ៤ ដទៃទៀត តើដូចម្តេច ។ មុសាវាទ ១ បិសុណាវាចា ១ ផរុសាវាចា ១ សម្ផប្ប-លាបៈ ១ នេះ ទុច្ចរិត ៤ ។

( ២០៥ ) បណ្តាធម៌ទាំងនោះ ភ័យ ៤ តើដូចម្តេច ។ ជាតិភ័យ ១ ជរាភ័យ ១ ព្យាធិភ័យ ១ មរណភ័យ ១ នេះ ភ័យ ៤ ។

អភិធម្មបិដកេ វិភង្គោ

(២០៦) តត្ថ កតមានិ អបរានិបិ ចត្តារិ ភយានិ ។ រាជភយំ ចោរភយំ អគ្គិភយំ ឧទកភយំ ឥមានិ ចត្តារិ ភយានិ ។

(២០៧) តត្ថ កតមានិ អបរានិបិ ចត្តារិ ភយានិ ។ ឩមិភយំ កុម្ភីលភយំ អាវដ្ដភយំ សុសុកាភយំ ឥមានិ ចត្តារិ ភយានិ ។

(២០៨) តត្ថ កតមានិ អបរានិបិ ចត្តារិ ភយានិ ។ អត្តានុវាទភយំ បរានុវាទភយំ ទណ្ឌភយំ ទុគ្គតិភយំ ឥមានិ ចត្តារិ ភយានិ។

(២០៩) តត្ថ កតមា ចតស្សោ ទិដ្ឋិយោ ។ សយំកតំ សុខទុក្ខន្តិ សច្ចតោ ថេតតោ ទិដ្ឋិ ឧប្បជ្ជតិ បរកតំ សុខទុក្ខន្តិ សច្ចតោ ថេតតោ ទិដ្ឋិ ឧប្បជ្ជតិ សយំកតញ្ច បរកតញ្ច សុខទុក្ខន្តិ សច្ចតោ ថេតតោ ទិដ្ឋិ ឧប្បជ្ជតិ អសយំកតំ អបរកតំ(១) អធិច្ចសមុប្បន្នំ សុខទុក្ខន្តិ សច្ចតោ ថេតតោ ទិដ្ឋិ ឧប្បជ្ជតិ ឥមា ចតស្សោ ទិដ្ឋិយោ ។

ចតុក្កំ ។

---

១ ឱ.ម. អសយំ-ការំ អបរំការន្តិ ទិស្សន្តិ ។

[២០៦] បណ្ដាធម៌ទាំងនោះ ភ័យ ៤ ដទៃទៀត តើដូចម្ដេច ។ រាជភ័យ ១ ចោរភ័យ ១ អគ្គិភ័យ ១ ឧទកភ័យ ១ នេះ ភ័យ ៤ ។

[២០៧] បណ្ដាធម៌ទាំងនោះ ភ័យ ៤ ដទៃទៀត តើដូចម្ដេច ។ ភ័យអំពីរលក ១ ភ័យអំពីក្រពើ ១ ភ័យអំពីអន្លង់ទឹក ១ ភ័យអំពីត្រីសាហាវ ១ នេះ ភ័យ ៤ ។

[២០៨] បណ្ដាធម៌ទាំងនោះ ភ័យ ៤ ដទៃទៀត តើដូចម្ដេច ។ ភ័យអំពីសេចក្ដីតិះដៀលខ្លួនឯង ១ ភ័យអំពីសេចក្ដីតិះដៀលរបស់បុគ្គលដទៃ ១ ភ័យអំពីអាជ្ញា ១ ភ័យអំពីទុគ្គតិ ១ នេះ ភ័យ ៤ ។

[២០៩] បណ្ដាធម៌ទាំងនោះ ទិដ្ឋិ ៤ តើដូចម្ដេច ។ ទិដ្ឋិតែងកើតឡើង ដោយទៀងទាត់មាំមួនថា សុខនិងទុក្ខគឺខ្លួនឯងធ្វើ ១ ទិដ្ឋិតែងកើតឡើង ដោយទៀងទាត់មាំមួនថា សុខនិងទុក្ខគឺអ្នកដទៃធ្វើ ១ ទិដ្ឋិតែងកើតឡើង ដោយទៀងទាត់មាំមួនថា សុខនិងទុក្ខគឺខ្លួនឯងធ្វើផង អ្នកដទៃធ្វើផង ១ ទិដ្ឋិតែងកើតឡើង ដោយទៀងទាត់មាំមួនថា សុខនិងទុក្ខមិនមែនខ្លួនឯងធ្វើ មិនមែនអ្នកដទៃធ្វើ គឺកើតឡើងដោយអាស្រ័យហេតុ ១ នេះ ទិដ្ឋិ ៤ ។

ចប់ ពួកធម៌ ៤ ។

ខុទ្ទកវត្ថុវិភង្គេ បញ្ចកនិទ្ទេសោ

(២១០) តត្ថ កតមានិ បញ្ចោរម្ភាគិយានិ សញ្ញោជនានិ ។ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ កាមច្ឆន្ទោ ព្យាបាទោ ឥមានិ បញ្ចោរម្ភាគិយានិ សញ្ញោជនានិ ។

(២១១) តត្ថ កតមានិ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ឥមានិ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ ។

(២១២) តត្ថ កតមានិ បញ្ច មច្ឆរិយានិ ។ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ ឥមានិ បញ្ច មច្ឆរិយានិ ។

(២១៣) តត្ថ កតមេ បញ្ច សង្គា ។ រាគសង្គោ ទោសសង្គោ មោហសង្គោ មានសង្គោ ទិដ្ឋិសង្គោ ឥមេ បញ្ច សង្គា ។

(២១៤) តត្ថ កតមេ បញ្ច សល្លា ។ រាគសល្លំ ទោសសល្លំ មោហសល្លំ មានសល្លំ ទិដ្ឋិសល្លំ ឥមេ បញ្ច សល្លា ។

ខុទ្ទកវត្ថុវិភង្គ បញ្ចកនិទ្ទេស

(២១០) បណ្តាធម៌ទាំងនោះ សំយោជនៈជាចំណែកខាងក្រោម ៥ តើដូចម្តេច ។ សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ កាមច្ឆន្ទៈ ១ ព្យាបាទៈ ១ នេះ សំយោជនៈជាចំណែកខាងក្រោម ៥ ។

(២១១) បណ្តាធម៌ទាំងនោះ សំយោជនៈជាចំណែកខាងលើ ៥ តើដូចម្តេច ។ រូបរាគៈ ១ អរូបរាគៈ ១ មានះ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ នេះ សំយោជនៈជាចំណែកខាងលើ ៥ ។

(២១២) បណ្តាធម៌ទាំងនោះ មច្ឆរិយៈ ៥ តើដូចម្តេច ។ អាវាសមច្ឆរិយៈ ១ កុលមច្ឆរិយៈ ១ លាភមច្ឆរិយៈ ១ វណ្ណមច្ឆរិយៈ ១ ធម្មមច្ឆរិយៈ ១ នេះ មច្ឆរិយៈ ៥ ។

(២១៣) បណ្តាធម៌ទាំងនោះ កិលេសជាគ្រឿងចំពាក់ ៥ តើដូចម្តេច ។ កិលេសជាគ្រឿងចំពាក់គឺរាគៈ ១ កិលេសជាគ្រឿងចំពាក់គឺទោសៈ ១ កិលេសជាគ្រឿងចំពាក់គឺមោហៈ ១ កិលេសជាគ្រឿងចំពាក់គឺមានះ ១ កិលេសជាគ្រឿងចំពាក់គឺទិដ្ឋិ ១ នេះ កិលេសជាគ្រឿងចំពាក់ ៥ ។

(២១៤) បណ្តាធម៌ទាំងនោះ សរ ៥ តើដូចម្តេច ។ សរគឺរាគៈ ១ សរគឺទោសៈ ១ សរគឺមោហៈ ១ សរគឺមានះ ១ សរគឺទិដ្ឋិ ១ នេះ សរ ៥ ។

[ ២១៥ ] តត្ថ កតមេ បញ្ច ចេតោខិលា ។ សត្ថរិ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ ធម្មេ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្ប-សីទតិ សង្ឃេ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ សិក្ខាយ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ សព្រហ្មចារីសុ កុបិតោ ហោតិ អនត្តមនោ អាហតចិត្តោ ខិលជាតោ ឥមេ បញ្ច ចេតោខិលា ។

[ ២១៦ ] តត្ថ កតមេ បញ្ច ចេតសោវិនិពន្ធា ។ កាមេ អវីតរាគោ ហោតិ អវិគ-តច្ឆន្ទោ អវិគតប្បេមោ អវិគតបិបាសោ អវិគត-បរិឡាហោ អវិគតតណ្ហោ កាយេ អវីតរាគោ ហោតិ អវិគតច្ឆន្ទោ អវិគតប្បេមោ អវិគតបិបាសោ

(២១៥) បណ្តាធម៌ទាំងនោះ បង្គោលចិត្ត ៥ តើដូចម្តេច ។ បុគ្គល សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ក្នុងព្រះសាស្តា ១ បុគ្គល សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ក្នុងព្រះធម៌ ១ បុគ្គល សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ក្នុងព្រះសង្ឃ ១ បុគ្គល សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លា ក្នុងសិក្ខា ១ បុគ្គល ក្រោធ អាក់អន់ចិត្ត មានចិត្តចងគំនុំ មានចិត្តរឹងត្អឹង ចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ១ នេះ បង្គោលចិត្ត ៥ ។

(២១៦) បណ្តាធម៌ទាំងនោះ ចំណងរបស់ចិត្ត ៥ តើដូចម្តេច ។ បុគ្គល មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកចំណង់ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្រវល់ក្រវាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នា ក្នុងកាម ១ មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកចំណង់ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន

អវិគតបរិឡាហោ អវិគតតណ្ហោ រូបេ អវីតរាគោ ហោតិ អវិគតច្ឆន្ទោ អវិគតប្បេមោ អវិគតបិបាសោ អវិគតបរិឡាហោ អវិគតតណ្ហោ យាវទត្ថំ ឧទរាវទេហកំ ភុញ្ជិត្វា សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ អនុយុត្តោ វិហរតិ អញ្ញតរំ ទេវនិកាយំ បណិធាយ ព្រហ្មចរិយំ ចរតិ ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ ឥមេ បញ្ច ចេតសោ វិនិពន្ធា ។

(២១៧) តត្ថ កតមានិ បញ្ច នីវរណានិ ។ កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ ឥមានិ បញ្ច នីវរណានិ ។

(២១៨) តត្ថ កតមានិ បញ្ច កម្មានិ អានន្តរិកានិ ។ មាតា ជីវិតា វោរោបិតា ហោតិ បិតា ជីវិតា វោរោបិតោ ហោតិ

មិនទាន់ប្រាសចាកសេចក្តីក្រវល់ក្រវាយ មិនទាន់ប្រាសចាកសេចក្តីប្រា-ថ្នាក្នុងកាយ ១ មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកចំណង់ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្រវល់ក្រវាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នា ក្នុងរូប ១ បរិភោគត្រាតែឆ្អែតពេញពោះ ហើយប្រកបរឿយ ៗ នូវសេចក្តីសុខ ក្នុងទីដេក នូវសេចក្តីសុខ (ក្នុងការដេកប្រែប្រួល) ទៅខាងស្តាំខាងឆ្វេង នូវសេចក្តីសុខ ក្នុងការដេកលក់ស៊ប់ ១ ប្រព្រឹត្តព្រហ្មចរិយៈ ព្រោះប្រាថ្នា នូវពួកទេវតាណាមួយថាអាត្មាអញនឹងបានជាទេវតា (មានស័ក្តិធំ) ឬទេវតា (មានស័ក្តិតូច) ណាមួយ ដោយសីលនេះក្តី ដោយវតនេះក្តី ដោយតបៈនេះក្តី ដោយព្រហ្មចរិយៈនេះក្តី នេះ ចំណងរបស់ចិត្ត ៥ ។

(៤១៧) បណ្តាធម៌ទាំងនោះ នីវរណៈ ៥ តើដូចម្តេច ។ កាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ច-កុក្កុច្ចនីវរណៈ ១ វិចិកិច្ឆានីវរណៈ ១ នេះ នីវរណៈ ៥ ។

(៤១៨) បណ្តាធម៌ទាំងនោះ អនន្តរិយកម្ម ៥ តើដូចម្តេច ៗ បុគ្គល ផ្តាច់បង់មាតាចាកជីវិត ១ ផ្តាច់បង់បិតាចាកជីវិត ១

អរហា ជីវិតា វោរោបិតោ ហោតិ ទុដ្ឋេន ចិត្តេន តថាគតស្ស លោហិតំ ឧប្បាទិតំ ហោតិ សង្ឃោ ភិន្នោ ហោតិ ឥមានិ បញ្ច កម្មានិ អានន្តរិកានិ ។

(២១៩) តត្ថ កតមា បញ្ច ទិដ្ឋិយោ ។ សញ្ញី អត្តា ហោតិ អរោគោ បរម្មរណាតិ ឥត្ថេកេ អភិវទន្តិ អសញ្ញី អត្តា ហោតិ អរោគោ បរម្មរណាតិ ឥត្ថេកេ អភិវទន្តិ នេវសញ្ញីនាសញ្ញី អត្តា ហោតិ អរោគោ បរម្មរណាតិ ឥត្ថេកេ អភិវទន្តិ សតោ វា បន សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេន្តិ ទិដ្ឋធម្មនិព្វានំ វា បនេកេ អភិវទន្តិ ឥមា បញ្ច ទិដ្ឋិយោ ។

(២២០) តត្ថ កតមេ បញ្ច វេរា ។ បាណាតិបាតោ អទិន្នាទានំ កាមេសុ មិច្ឆាចារោ មុសាវាទោ សុរាមេរយមជ្ជប្បមាទដ្ឋានំ ឥមេ បញ្ច វេរា ។

ផ្តាច់បង់ព្រះអរហន្តចាកជីវិត ១ បុគ្គលមានចិត្តប្រទូស្ត ញុំាងព្រះលោហិត របស់ព្រះតថាគត ឲ្យកើតឡើង ១ បំបែកសង្ឃ ១ នេះ អនន្តរិយកម្ម ៥ ។

[៦១៩] បណ្តាធម៌ទាំងនោះ ទិដ្ឋិ ៥ តើដូចម្តេច ។ បុគ្គលមួយពួក ប្រកាសយ៉ាងនេះថា ខ្លួនមានសញ្ញា មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ១ បុគ្គលមួយពួក ប្រកាសយ៉ាងនេះថា ខ្លួនមិនមានសញ្ញា មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ១ បុគ្គលមួយពួក ប្រកាសយ៉ាងនេះថា ខ្លួនមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន មិនមានរោគ ខាងមុខអំពីសេចក្តីស្លាប់ ១ បុគ្គលមួយពួក បញ្ញត្តនូវសេចក្តីដាច់សូន្យ សេចក្តីវិនាស សេចក្តីមិនចម្រើន របស់សត្វដែលកើតមាន ១ បុគ្គលមួយពួក ប្រកាសនូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន ១ នេះ ទិដ្ឋិ ៥ ។

[៦២០] បណ្តាធម៌ទាំងនោះ ពៀរ ៥ តើដូចម្តេច ។ បាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ សុរាមេរយមជ្ជប្បមាទដ្ឋាន ១ នេះ ពៀរ ៥ ។

(២២១) តត្ថ កតមេ បញ្ច ព្យសនា ។ ញាតិព្យសនំ ភោគព្យសនំ រោគព្យសនំ សីលព្យសនំ ទិដ្ឋិព្យសនំ ឥមេ បញ្ច ព្យសនា ។

(២២២) តត្ថ កតមេ បញ្ច អក្ខន្តិយា អាទីនវា ។ ពហុនោ ជនស្ស អប្បិយោ ហោតិ អមនាបោ វេរពហុលោ ហោតិ វជ្ជពហុលោ សម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ឥមេ បញ្ច អក្ខន្តិយា អាទីនវា ។

(២២៣) តត្ថ កតមានិ បញ្ច ភយានិ ។ អាជីវកភយំ អសិលោកភយំ បរិសសារជ្ជភយំ មរណភយំ ទុគ្គតិភយំ ឥមានិ បញ្ច ភយានិ ។

(២២៤) តត្ថ កតមេ បញ្ច ទិដ្ឋធម្មនិព្វានវាទា ។ ឥធេកច្ចោ សមណោ វា ព្រាហ្មណោ វា ឯវំវាទី ហោតិ ឯវំទិដ្ឋិ យតោ ខោ ភោ

## ខុទ្ទកវត្ថុវិភង្គ បញ្ចកនិទ្ទេស

[២២១] បណ្ដាធម៌ទាំងនោះ សេចក្ដីវិនាស ៥ តើដូចម្ដេច ។ សេចក្ដីវិនាសញាតិ ១ សេចក្ដីវិនាសភោគៈ ១ សេចក្ដីវិនាសគឺរោគ ១ សេចក្ដីវិនាសសីល ១ សេចក្ដីវិនាសគឺទិដ្ឋិ ១ នេះ សេចក្ដីវិនាស៥ ។

[២២២] បណ្ដាធម៌ទាំងនោះ ទោសនៃសេចក្ដីមិនអត់ធន់ ៥ តើដូចម្ដេច ។ បុគ្គលអ្នកមិនអត់ធន់ រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តនៃជនច្រើនគ្នា ១ ច្រើនដោយពៀរ ១ ច្រើនដោយទោស ១ វង្វេងធ្វើមរណកាល ១ បែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ រមែងចូលទៅកាន់អបាយ ទុគ្គតិ វិនិបាត នរក ១ នេះ ទោសនៃការមិនអត់ធន់ ៥ ។

[២២៣] បណ្ដាធម៌ទាំងនោះ ភ័យ ៥ តើដូចម្ដេច ។ ភ័យអំពីការចិញ្ចឹមជីវិត ១ ភ័យអំពីគេមិនសរសើរ ១ ភ័យអំពីសេចក្ដីកោតញញើតក្នុងបរិស័ទ ១ ភ័យអំពីសេចក្ដីស្លាប់ ១ ភ័យអំពីទុគ្គតិ ១ នេះ ភ័យ ៥ ។

[២២៤] បណ្ដាធម៌ទាំងនោះ ការពោលនូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន ៥ តើដូចម្ដេច ។ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈ ឬព្រាហ្មណ៍ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន

អយំ អត្តា បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេតិ ឯត្តាវតា ខោ ភោ អយំ អត្តា បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតីតិ ឥត្ថេកេ សតោ សត្តស្ស បរមទិដ្ឋធម្មនិព្វានំ បញ្ញបេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតិ តំ កិស្ស ហេតុ កាមា ហិ ភោ អនិច្ចា ទុក្ខា វិបរិណាមធម្មា តេសំ វិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា យតោ ខោ ភោ អយំ អត្តា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតា ខោ ភោ អយំ អត្តា បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតីតិ

កាលណាបើខ្លួននេះ ឆ្អែតស្កប់ស្កល់ ឲ្យគេបម្រើដោយកាមគុណ ៥ ម្នាលអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះឯង ទើបខ្លួននេះ ឈ្មោះថាជាអត្តភាព ដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន ដែលជាគុណជាត យ៉ាងក្រៃលែង សមណៈឬព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន ថាជាគុណយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃ ក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា នែអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះមិនមានទេ នែអ្នកដ៏ចម្រើន តែថាខ្លួននេះ មិនមែនដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន ដែលជាគុណយ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណប៉ុណ្ណោះទេ ពាក្យដែលខ្ញុំថាដូច្នោះ តើព្រោះហេតុអ្វី ម្នាលអ្នកដ៏ចំរើន ព្រោះហេតុថា កាមទាំងឡាយមិនទៀងជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា មានសេចក្តីសោកខ្សឹកខ្សួល ទុក្ខទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងកើតឡើង ព្រោះកាមទាំងឡាយនោះ ប្រែប្រួលទៅ ប្រព្រឹត្តទៅ ដោយប្រការដទៃ ម្នាលអ្នកដ៏ចម្រើន ខ្លួននេះឯង កាលណាបានស្ងប់ស្ងាត់ ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះឈ្មោះថា បានដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន

ឥត្ថេកេ សតោ សត្តស្ស បរមទិដ្ឋធម្មនិព្វានំ បញ្ញបេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតិ តំ កិស្ស ហេតុ យទេវ តត្ថ វិតក្កិតំ វិចារិតំ ឯតេន ឯតំ ឱឡារិកំ អក្ខាយតិ យតោ ខោ ភោ អយំ អត្តា វិតក្កវិចារានំ វូបសមា ។បេ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតា ខោ ភោ អយំ អត្តា បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតីតិ ឥត្ថេកេ សតោ សត្តស្ស បរមទិដ្ឋធម្ម-និព្វានំ បញ្ញបេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ

## ខុទ្ទកវត្ថុវិភង្គ បញ្ចកនិទ្ទេស

ជាគុណយ៉ាងក្រៃលែង សមណៈឬព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវព្រះនិព្វាន ជាគុណយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ៗ មានបុគ្គលដទៃ ក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះមិនមានទេ ម្នាលអ្នកដ៏ចម្រើន តែថាខ្លួននេះ មិនមែនដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន ដែលជាគុណជាតយ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណប៉ុណ្ណោះទេ ពាក្យដែលខ្ញុំថាដូច្នោះ តើព្រោះហេតុអ្វី ព្រោះហេតុថា ចិត្តដែលប្រកបដោយវិតក្កៈនិងវិចារៈមានទៅក្នុងបឋមជ្ឈាននោះ បឋមជ្ឈាននុ៎ះនៅប្រាកដ ជាឈានគ្រោតគ្រាត ព្រោះមានវិតក្កៈនិងវិចារៈនុ៎ះនៅឡើយ ម្នាលអ្នកដ៏ចម្រើន កាលណាបើខ្លួននេះ បានរម្ងាប់វិតក្កៈនិងវិចារៈអស់ហើយ ៗ បេ ៗ បានដល់ទុតិយជ្ឈាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះឈ្មោះថា បានដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន ដែលជាគុណជាតយ៉ាងក្រៃលែង សមណៈ ឬព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវព្រះនិព្វានក្នុងបច្ចុប្បន្នថា ជាគុណជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ៗ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា

ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ
នត្ថីតិ វទាមិ នោ ច ខោ ភោ អយំ អត្តា
ឯត្តាវតា បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតិ តំ កិស្ស
ហេតុ យទេវ តត្ថ បីតិគតំ ចេតសោ ឧព្វិលាវិតំ
អក្ខាយតិ យតោ ខោ ភោ អយំ អត្តា បីតិយា ច
វិរាគា ។បេ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ
ឯត្តាវតា ខោ ភោ អយំ អត្តា បរមទិដ្ឋធម្មនិព្វាន-
ប្បត្តោ ហោតីតិ ឥត្ថេកេ សតោ សត្តស្ស បរម-
ទិដ្ឋធម្មនិព្វានំ បញ្ញបេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ
ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ
នត្ថីតិ វទាមិ នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា
បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតិ តំ កិស្ស ហេតុ

ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ខ្ញុំមិននិយាយថា ខ្លួននុ៎ះមិនមានទេ ម្នាលអ្នកដ៏ចម្រើន តែថាខ្លួននេះ មិនមែនបានដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន ដែលជាគុណជាតយ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណប៉ុណ្ណោះទេ ពាក្យដែលខ្ញុំថាយ៉ាងនោះ តើព្រោះហេតុអ្វី ព្រោះហេតុថា បីតិ ជាទីកើតឡើងនៃចិត្ត មានក្នុងទុតិយជ្ឈាននុ៎ះ នៅប្រាកដ ជាឈានគ្រោតគ្រាត ព្រោះមានបីតិនុ៎ះនៅឡើយ ម្នាលអ្នកដ៏ចម្រើន កាលណាបើខ្លួននេះ ព្រោះអស់ទៅនៃបីតិ ។ បេ ។ ក៏បានដល់នូវតតិយជ្ឈាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះ ឈ្មោះថា បានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ដែលជាគុណជាតយ៉ាងក្រៃលែង សមណៈឬព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន ថាជាគុណជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃ ក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន តែថាខ្លួននេះ មិនមែនបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ដែលជាគុណជាតយ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណប៉ុណ្ណោះទេ ពាក្យដែលខ្ញុំនិយាយនោះ តើព្រោះហេតុអ្វី

យេនេវ តត្ថ សុខំ ចេតសោ អាភោគោ ឯតេន

ឯតំ ឧឡារិកំ អក្ខាយតិ យតោ ខោ ភោ អយំ

អត្តា សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ

ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតា ខោ ភោ

អយំ អត្តា បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតីតិ

ឥត្ថេកេ សតោ សត្តស្ស បរមទិដ្ឋធម្មនិព្វានំ

បញ្ញាបេន្តិ ។ ឥមេ បញ្ច ទិដ្ឋធម្មនិព្វានវាទា ។

បញ្ចកំ ។

(២២៨) តត្ថ កតមានិ ឆ វិវាទមូលានិ ។

កោធោ មក្ខោ ឥស្សា សាឋេយ្យំ បាបិច្ឆតា

សន្ទិដ្ឋិបរាមាសិតា ឥមានិ ឆ វិវាទមូលានិ ។

ព្រោះហេតុថា សេចក្ដីអើពើ ឬសេចក្ដីក្ដួចកាន់នៃចិត្តថា សុខ រមែងមានក្នុងតតិយជ្ឈាននោះ ឯតតិយជ្ឈាននុ៎ះ នៅប្រាកដ ជាឈានគ្រោតគ្រាត ព្រោះមានសុខនៅឡើយ ម្នាលអ្នកដ៏ចម្រើន កាលណាបើខ្លួននេះ បានលះបង់នូវសុខផង ។ បេ ។ ហើយបានដល់នូវចតុត្ថជ្ឈាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះឯង ទើបខ្លួនឈ្មោះថា បានដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន ដែលជាគុណជាតយ៉ាងក្រៃលែង សមណៈឬព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន ថាជាគុណជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ នេះ ទិដ្ឋធម្មនិព្វានវាទ ៥ ។

ចប់ ពួកធម៌ទី ៥ ។

[៦៦៥] បណ្ដាធម៌ទាំងនោះ មូលនៃវិវាទ ៦ តើដូចម្ដេច ។ សេចក្ដីក្រោធ ១ សេចក្ដីលុបគុណ ១ សេចក្ដីប្រណែន ១ សេចក្ដីអួតអាង ១ សេចក្ដីប្រាថ្នាដ៏លាមក ១ ការស្ទាបអង្អែលទិដ្ឋិរបស់ខ្លួន ១ នេះ មូលនៃវិវាទ ៦ ។

[២២៦] តត្ថ កតមេ ឆ ឆន្ទរាគា គេហសិតា ធម្មា ។ មនាបិកេសុ រូបេសុ គេហសិតោ រាគោ សារាគោ ។ បេ ។ ចិត្តស្ស សារាគោ មនាបិកេសុ សទ្ទេសុ ។ បេ ។ មនាបិកេសុ គន្ធេសុ ។ បេ ។ មនាបិកេសុ រសេសុ ។ បេ ។ មនាបិកេសុ ផោដ្ឋព្វេសុ ។ បេ ។ មនាបិកេសុ ធម្មេសុ គេហសិតោ រាគោ សារាគោ ។ បេ ។ ចិត្តស្ស សារាគោ ឥមេ ឆ ឆន្ទរាគា គេហសិតា ធម្មា ។

[២២៧] តត្ថ កតមានិ ឆ វិរោធវត្ថូនិ ។ អមនាបិកេសុ រូបេសុ ចិត្តស្ស អាឃាតោ បដិឃាតោ ។ បេ ។ ចណ្ឌិក្កំ អសុរោបោ អនត្តមនតា ចិត្តស្ស អមនាបិកេសុ សទ្ទេសុ ។ បេ ។ អមនាបិកេសុ គន្ធេសុ ។ បេ ។ អមនាបិកេសុ រសេសុ ។ បេ ។ អមនាបិកេសុ ផោដ្ឋព្វេសុ ។ បេ ។ អមនាបិកេសុ ធម្មេសុ ចិត្តស្ស អាឃាតោ បដិឃាតោ ។ បេ ។

(៦៦៦) បណ្ដាធម៌ទាំងនោះ ឆន្ទរាគ ៦ ជាធម៌អាស្រ័យនូវផ្ទះ គឺកាមគុណ តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត ដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ក្នុងរូបទាំងឡាយ ជាទីគាប់ចិត្ត ១ ។ បេ ។ ក្នុងសំឡេងទាំងឡាយ ជាទីគាប់ចិត្ត ១ ។ បេ ។ ក្នុងក្លិនទាំងឡាយ ជាទីគាប់ចិត្ត ១ ។ បេ ។ ក្នុងរសទាំងឡាយ ជាទីគាប់ចិត្ត ១ ។ បេ ។ ក្នុងផោដ្ឋព្វៈទាំងឡាយ ជាទីគាប់ចិត្ត ១ ។ បេ ។ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត ដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ក្នុងធម៌ទាំងឡាយ ជាទីគាប់ចិត្ត ១ នេះ ឆន្ទរាគ ៦ ជាធម៌អាស្រ័យនូវផ្ទះ គឺកាមគុណ ។

(៦៦៧) បណ្ដាធម៌ទាំងនោះ វិរោធវត្ថុ (ហេតុនៃសេចក្ដីក្រោធ) ៦ តើដូចម្ដេច ។ គំនុំ ការចងគំនុំតបនៃចិត្ត ។ បេ ។ សេចក្ដីកាច ការខឹង ការអាក់អន់ចិត្ត ក្នុងរូបទាំងឡាយមិនជាទីគាប់ចិត្ត ១ ក្នុងសំឡេងទាំងឡាយមិនជាទីគាប់ចិត្ត ១ ។ បេ ។ ក្នុងក្លិនទាំងឡាយមិនជាទីគាប់ចិត្ត ១ ។ បេ ។ ក្នុងរសទាំងឡាយមិនជាទីគាប់ចិត្ត ១ ។ បេ ។ ក្នុងផ្សព្វទាំងឡាយមិនជាទីគាប់ចិត្ត ១ ។ បេ ។ គំនុំ ការចងគំនុំនៃចិត្ត ។ បេ ។

ចណ្ឌិក្កំ អសុរោបោ អនត្តមនតា ចិត្តស្ស ឥមានិ ឆ វិរោធវត្ថូនិ ។

(២២៨) តត្ថ កតមេ ឆ តណ្ហាកាយា ។ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ឥមេ ឆ តណ្ហាកាយា ។

(២២៩) តត្ថ កតមេ ឆ អគារវា ។ សត្ថរិ អគារវោ វិហរតិ អប្បដិស្សោ ធម្មេ ។ បេ ។ សង្ឃេ ។ បេ ។ សិក្ខាយ ។ បេ ។ អប្បមាទេ ។ បេ ។ បដិសន្ថារេ អគារវោ វិហរតិ អប្បដិស្សោ ឥមេ ឆ អគារវា ។

(២៣០) តត្ថ កតមេ ឆ បរិហានិយា ធម្មា ។ កាមារាមតា ភស្សារាមតា និទ្ទារាមតា សង្គណិការាមតា សំសគ្គារាមតា បបញ្ចារាមតា ឥមេ ឆ បរិហានិយា ធម្មា ។

សេចក្ដីកាច ការពោលពាក្យអសុរោះ ការអាក់អន់ចិត្ត ក្នុងធម៌ទាំងឡាយ មិនជាទីគាប់ចិត្ត ១ នេះ វិរោធវត្ថុ ៦ ។

(២២៨) បណ្ដាធម៌ទាំងនោះ ពួកនៃតណ្ហា ៦ តើដូចម្ដេច ។ រូបតណ្ហា ១ សទ្ទតណ្ហា ១ គន្ធតណ្ហា ១ រសតណ្ហា ១ ផោដ្ឋព្វតណ្ហា ១ ធម្មតណ្ហា ១ នេះ ពួកនៃតណ្ហា ៦ ។

(២២៩) បណ្ដាធម៌ទាំងនោះ អគារវៈ (សេចក្ដីមិនគោរព) ៦ តើដូចម្ដេច ។ បុគ្គល មិនមានសេចក្ដីគោរព កោតក្រែង ក្នុងព្រះសាស្ដា ១ ក្នុងព្រះធម៌ ១ ។ បេ ។ ក្នុងព្រះសង្ឃ ១ ។ បេ ។ ក្នុងសិក្ខា ១ ។ បេ ។ ក្នុងអប្បមាទ ១ ។ បេ ។ មិនមានសេចក្ដីគោរព កោតក្រែង ក្នុងបដិសណ្ឋារៈ ១ នេះ អគារវៈ ៦ ។

(២៣០) បណ្ដាធម៌ទាំងនោះ បរិហានិយធម៌ (ធម៌ដែលនាំឲ្យសាបសូន្យ) ៦ តើដូចម្ដេច ។ សេចក្ដីត្រេកអរ ក្នុងកាម ១ សេចក្ដីត្រេកអរ ក្នុងការនិយាយពាក្យពេយកាយ ១ សេចក្ដីត្រេកអរ ក្នុងការដេកលក់ ១ សេចក្ដីត្រេកអរ ក្នុងការប្រឡូកប្រឡំដោយពួក ១ សេចក្ដីត្រេកអរ ក្នុងការជាប់ចំពាក់ ១ សេចក្ដីត្រេកអរ ក្នុងបបញ្ចធម៌ ១ នេះ បរិហានិយធម៌ ៦ ។

(២៣១) តត្ថ កតមេ អបរេបិ ច បរិហានិយា ធម្មា ។ កម្មារាមតា ភស្សារាមតា និទ្ទារាមតា សង្គណិការាមតា ទោវចស្សតា បាបមិត្តតា ឥមេ ច បរិហានិយា ធម្មា ។

(២៣២) តត្ថ កតមេ ច សោមនស្សុបវិចារា ។ ចក្ខុនា រូបំ ទិស្វា សោមនស្សដ្ឋានិយំ រូបំ ឧបវិចរតិ សោតេន សទ្ទំ សុត្វា ។ បេ ។ ឃានេន គន្ធំ ឃាយិត្វា ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ បេ ។ មនសា ធម្មំ វិញ្ញាយ សោមនស្សដ្ឋានិយំ ធម្មំ ឧបវិចរតិ ឥមេ ច សោមនស្សុបវិចារា ។

(២៣៣) តត្ថ កតមេ ច ទោមនស្សុបវិចារា ។ ចក្ខុនា រូបំ ទិស្វា ទោមនស្សដ្ឋានិយំ រូបំ ឧបវិចរតិ សោតេន សទ្ទំ សុត្វា ។ បេ ។

(២៣១) បណ្ដាធម៌ទាំងនោះ បរិហានិយធម៌ ៦ ដទៃទៀត តើដូចម្ដេច ។ សេចក្ដីត្រេកអរ ក្នុងការងារ ១ សេចក្ដីត្រេកអរ ក្នុងការនិយាយពាក្យពេយពាយ ១ សេចក្ដីត្រេកអរ ក្នុងការដេកលក់ ១ សេចក្ដីត្រេកអរ ក្នុងការប្រឡូកប្រឡំ (ដោយពួក) ១ សេចក្ដីប្រដៅក្រ ១ ភាពអ្នកមានមិត្តអាក្រក់ ១ នេះ បរិហានិយធម៌ ៦ ។

(២៣២) បណ្ដាធម៌ទាំងនោះ ធម៌ជាទីពិចារណាដោយសោមនស្ស ៦ តើដូចម្ដេច ។ បុគ្គលឃើញរូបដោយចក្ខុ ហើយពិចារណានូវរូប ជាទីតាំងនៃសោមនស្ស ១ ឮសំឡេងដោយត្រចៀក ១ ។ បេ ។ ធុំក្លិនដោយច្រមុះ ១ ។ បេ ។ លិទ្ធភ្លក្សរសដោយអណ្ដាត ១ ។ បេ ។ ប៉ះពាល់ផ្សព្វដោយកាយ ១ ។ បេ ។ ដឹងនូវធម៌ដោយចិត្ត ហើយពិចារណានូវធម៌ ជាទីតាំងនៃសោមនស្ស ១ នេះ ធម៌ជាទីពិចារណាដោយសោមនស្ស ៦ ។

(២៣៣) បណ្ដាធម៌ទាំងនោះ ធម៌ជាទីពិចារណាដោយទោមនស្ស ៦ តើដូចម្ដេច ។ បុគ្គលឃើញរូបដោយចក្ខុហើយ ពិចារណានូវរូប ជាទីតាំងនៃទោមនស្ស ១ ឮសំឡេងដោយត្រចៀក ១ ។ បេ ។

ខុទ្ទកវត្ថុវិភង្គោ ឆក្កនិទ្ទេសោ

ឃានេន គន្ធំ ឃាយិត្វា ។បេ។ ជិវ្ហាយ រសំ សាយិត្វា ។បេ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។បេ។ មនសា ធម្មំ វិញ្ញាយ សោមនស្សដ្ឋានិយំ ធម្មំ ឧបវិចរតិ ឥមេ ឆ សោមនស្សុបវិចារា ។

(២៣៧) តត្ថ កតមេ ឆ ឧបេក្ខុបវិចារា ។ ចក្ខុនា រូបំ ទិស្វា ឧបេក្ខដ្ឋានិយំ រូបំ ឧបវិចរតិ សោតេន សទ្ទំ សុត្វា ។បេ។ ឃានេន គន្ធំ ឃាយិត្វា ។បេ។ ជិវ្ហាយ រសំ សាយិត្វា ។បេ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។បេ។ មនសា ធម្មំ វិញ្ញាយ ឧបេក្ខដ្ឋានិយំ ធម្មំ ឧបវិចរតិ ឥមេ ឆ ឧបេក្ខុបវិចារា ។

(២៣៨) តត្ថ កតមានិ ឆ គេហសិតានិ សោមនស្សានិ ។ មនាបិកេសុ រូបេសុ គេហសិតំ ចេតសិកំ សាតំ ចេតសិកំ សុខំ ចេតោសម្ផស្សជំ សាតំ សុខំ វេទយិតំ ចេតោសម្ផស្សជា សាតា សុខា វេទនា មនាបិកេសុ សទ្ទេសុ ។បេ។

ធុំក្លិនដោយច្រមុះ ១ ។ បេ ។ លិទ្ធភ្លក្សរសដោយអណ្ដាត ១ ។ បេ ។ ប៉ះពាល់ផ្សព្វដោយកាយ ១ ។ បេ ។ ដឹងច្បាស់នូវធម៌ដោយចិត្ត ហើយពិចារណានូវធម៌ ជាទីតាំងនៃទោមនស្ស ១ នេះ ធម៌ជាទីពិចារណាដោយទោមនស្ស ៦ ។

[២៣៨] បណ្ដាធម៌ទាំងនោះ ធម៌ជាទីពិចារណាដោយឧបេក្ខា ៦ តើដូចម្ដេច ។ បុគ្គលឃើញរូបដោយចក្ខុ ហើយពិចារណានូវរូបជាទីតាំងនៃឧបេក្ខា ១ ឮសំឡេងដោយត្រចៀក ១ ។ បេ ។ ធុំក្លិនដោយច្រមុះ ១ ។ បេ ។ លិទ្ធភ្លក្សរសដោយអណ្ដាត ១ ។ បេ ។ ប៉ះពាល់ផ្សព្វដោយកាយ ១ ។ បេ ។ ដឹងច្បាស់នូវធម៌ដោយចិត្ត ហើយពិចារណានូវធម៌ ជាទីតាំងនៃឧបេក្ខា ១ នេះ ធម៌ជាទីពិចារណាដោយឧបេក្ខា ៦ ។

[២៣៩] បណ្ដាធម៌ទាំងនោះ សោមនស្ស ៦ ដែលអាស្រ័យនូវផ្ទះគឺកាមគុណ តើដូចម្ដេច ។ សេចក្ដីឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសា ជាសុខ កើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសា ជាសុខ កើតអំពីសម្ផស្សនៃចិត្ត ដែលអាស្រ័យនូវផ្ទះគឺកាមគុណ ក្នុងរូបទាំង-ឡាយជាទីគាប់ចិត្ត ១ ក្នុងសំឡេងទាំងឡាយជាទីគាប់ចិត្ត ១ ។ បេ ។

មនាបិកេសុ គន្ធេសុ ។បេ។ មនាបិកេសុ រសេសុ ។បេ។ មនាបិកេសុ ផោដ្ឋព្វេសុ ។បេ។ មនាបិកេសុ ធម្មេសុ គេហសិតំ ចេតសិកំ សាតំ ចេតសិកំ សុខំ ចេតោសម្ផស្សជំ សាតំ សុខំ វេទយិតំ ចេតោសម្ផស្សជា សាតា សុខា វេទនា ឥមានិ ឆ គេហសិតានិ សោមនស្សានិ ។

(២៣៦) តត្ថ កតមានិ ឆ គេហសិតានិ ទោមនស្សានិ ។ អមនាបិកេសុ រូបេសុ គេហសិតំ ចេតសិកំ អសាតំ ចេតសិកំ ទុក្ខំ ចេតោសម្ផស្សជំ អសាតំ ទុក្ខំ វេទយិតំ ចេតោសម្ផស្សជា អសាតា ទុក្ខា វេទនា អមនាបិកេសុ សទ្ទេសុ ។បេ។ អមនាបិកេសុ គន្ធេសុ ។បេ។ អមនាបិកេសុ រសេសុ ។បេ។ អមនាបិកេសុ ផោដ្ឋព្វេសុ ។បេ។

ក្នុងក្លិនទាំងឡាយជាទីគាប់ចិត្ត ១ ។ បេ ។ ក្នុងរសទាំងឡាយជាទីគាប់ចិត្ត ១ ។ បេ ។ ក្នុងផ្សព្វទាំងឡាយជាទីគាប់ចិត្ត ១ ។ បេ ។ សេចក្តីឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ ដ៏ឆ្ងាញ់ពិសា ជាសុខ កើតអំពីសម្ផស្សនៃចិត្ត វេទនា ដ៏ឆ្ងាញ់ពិសា ជាសុខ កើតអំពីសម្ផស្សនៃចិត្ត ដែលអាស្រ័យនូវផ្ទះគឺកាមគុណ ក្នុងធម៌ទាំងឡាយជាទីគាប់ចិត្ត ១ នេះ សោមនស្ស ៦ ដែលអាស្រ័យនូវផ្ទះគឺកាមគុណ ។

( ២៣៦ ) បណ្តាធម៌ទាំងនោះ ទោមនស្ស ៦ ដែលអាស្រ័យនូវផ្ទះគឺកាមគុណ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនឆ្ងាញ់ពិសា ជាទុក្ខ កើតអំពីសម្ផស្សនៃចិត្ត វេទនាមិនឆ្ងាញ់ពិសា ជាទុក្ខ កើតអំពីសម្ផស្សនៃចិត្ត ដែលអាស្រ័យនូវផ្ទះគឺកាមគុណ ក្នុងរូបទាំងឡាយមិនជាទីគាប់ចិត្ត ១ ក្នុងសំឡេងទាំងឡាយមិនជាទីគាប់ចិត្ត ១ ។ បេ ។ ក្នុងក្លិនទាំងឡាយមិនជាទីគាប់ចិត្ត ១ ។ បេ ។ ក្នុងរសទាំងឡាយមិនជាទីគាប់ចិត្ត ១ ។ បេ ។ ក្នុងផ្សព្វទាំងឡាយមិនជាទីគាប់ចិត្ត ១ ។ បេ ។

អមនាបិកេសុ ធម្មេសុ គេហសិតំ ចេតសិកំ អសាតំ ចេតសិកំ ទុក្ខំ ចេតោសម្ផស្សជំ អសាតំ ទុក្ខំ វេទយិតំ ចេតោសម្ផស្សជា អសាតា ទុក្ខា វេទនា ឥមានិ ឆ គេហសិតានិ ទោមនស្សានិ ។

(២៣៧) តត្ថ កតមា ឆ គេហសិតា ឧបេក្ខា ។ ឧបេក្ខដ្ឋានិយេសុ រូបេសុ គេហសិតំ ចេតសិកំ នេវ សាតំ នាសាតំ ចេតោសម្ផស្សជំ អទុក្ខមសុខំ វេទយិតំ ចេតោសម្ផស្សជា អទុក្ខមសុខា វេទនា ឧបេក្ខដ្ឋានិយេសុ សទ្ទេសុ ។ បេ ។ ឧបេក្ខដ្ឋានិយេសុ គន្ធេសុ ។ បេ ។ ឧបេក្ខដ្ឋានិយេសុ រសេសុ ។ បេ ។ ឧបេក្ខដ្ឋានិយេសុ ផោដ្ឋព្វេសុ ។ បេ ។ ឧបេក្ខដ្ឋានិយេសុ ធម្មេសុ គេហសិតំ ចេតសិកំ នេវ សាតំ នាសាតំ ចេតោសម្ផស្សជំ អទុក្ខមសុខំ វេទយិតំ ចេតោសម្ផស្សជា អទុក្ខមសុខា វេទនា

សេចក្តីមិនឆ្ងាញ់ពីសា ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនឆ្ងាញ់ពីសា ជាទុក្ខ កើតអំពីសម្ផស្សនៃចិត្ត វេទនាមិនឆ្ងាញ់ពីសា ជាទុក្ខ កើតអំពីសម្ផស្សនៃចិត្ត ដែលអាស្រ័យនូវផ្ទះគឺកាមគុណ ក្នុងធម៌ទាំងឡាយ មិនជាទីគាប់ចិត្ត ១ នេះទោមនស្ស ៦ អាស្រ័យនូវផ្ទះគឺកាមគុណ ។

( ២៣៧ ) បណ្តាធម៌ទាំងនោះ ឧបេក្ខា ៦ ដែលអាស្រ័យនូវផ្ទះគឺកាមគុណ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពីសា ក៏មិនមែន សេចក្តីមិនឆ្ងាញ់ពីសា ក៏មិនមែន ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនមែនទុក្ខ មិនមែនសុខ កើតអំពីសម្ផស្សនៃចិត្ត វេទនាមិនមែនទុក្ខ មិនមែនសុខ កើតអំពីសម្ផស្សនៃចិត្ត ដែលអាស្រ័យនូវផ្ទះគឺកាមគុណ ក្នុងរូបទាំងឡាយដែលជាទីតាំងនៃឧបេក្ខា ១ ក្នុងសំឡេងទាំងឡាយដែលជាទីតាំងនៃឧបេក្ខា ១ ។ បេ ។ ក្នុងក្លិនទាំងឡាយដែលជាទីតាំងនៃឧបេក្ខា ១ ។ បេ ។ ក្នុងរសទាំងឡាយដែលជាទីតាំងនៃឧបេក្ខា ១ ។ បេ ។ ក្នុងផ្សព្វទាំងឡាយដែលជាទីតាំងនៃឧបេក្ខា ១ ។ បេ ។ សេចក្តីឆ្ងាញ់ពីសាក៏មិនមែន សេចក្តីមិនឆ្ងាញ់ពីសាក៏មិនមែន ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនមែនទុក្ខមិនមែនសុខ កើតអំពីសម្ផស្សនៃចិត្ត វេទនាមិនមែនទុក្ខមិនមែនសុខ កើតអំពីសម្ផស្សនៃចិត្ត ដែលអាស្រ័យនូវផ្ទះគឺកាមគុណ ក្នុងធម៌ទាំងឡាយដែលជាទីតាំងនៃឧបេក្ខា ១

ឥមា ច គេហសិតា ឧបេក្ខា ។

(២៣៨) តត្ថ កតមា ឆ ទិដ្ឋិយោ ។ អត្ថិ មេ អត្តាតិ វា អស្ស សច្ចតោ ថេតតោ ទិដ្ឋិ ឧប្បជ្ជតិ នត្ថិ មេ អត្តាតិ វា អស្ស សច្ចតោ ថេតតោ ទិដ្ឋិ ឧប្បជ្ជតិ អត្តនា អត្តានំ សញ្ជានាមីតិ វា អស្ស សច្ចតោ ថេតតោ ទិដ្ឋិ ឧប្បជ្ជតិ អត្តនា អនត្តានំ សញ្ជានាមីតិ វា អស្ស សច្ចតោ ថេតតោ ទិដ្ឋិ ឧប្បជ្ជតិ អនត្តនា អត្តានំ សញ្ជា-នាមីតិ វា អស្ស សច្ចតោ ថេតតោ ទិដ្ឋិ ឧប្បជ្ជតិ(១) សោ មេ អយំ អត្តា វទោ វេទេយ្យោ(២) តត្រ តត្រ ទីឃរត្តំ កល្យាណបាបកានំ ធម្មានំ(៣) វិបាកំ បច្ចនុភោតិ ន សោ ជាតោ នាហោសិ ន សោ ជាតោ ន ភវិស្សតិ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោតិ វា អស្ស សច្ចតោ ថេតតោ ទិដ្ឋិ ឧប្បជ្ជតិ ឥមា ឆ ទិដ្ឋិយោ ។

ឆក្កំ ។

---

១ ឱ.ម. ឯត្ថន្តរេ អថវា បនស្ស ឯវំ ទិដ្ឋិ ហោតីតិ ទិស្សតិ ។ ២ ឱ.ម. វេទេយ្យោតិ ។
៣ ម. កម្មានំ ។

នេះ ឧបេក្ខា ៦ ដែលអាស្រ័យនូវផ្ទះគឺកាមគុណ ។

(២៣៨) បណ្ដាធម៌ទាំងនោះ ទិដ្ឋិ ៦ តើដូចម្ដេច ។ ទិដ្ឋិរបស់បុគ្គលនោះ តែងកើតឡើង ដោយទៀងទាត់មាំមួន ថា អញមានខ្លួន ១ ទិដ្ឋិរបស់បុគ្គលនោះ តែងកើតឡើង ដោយទៀងទាត់មាំមួន ថា អញមិនមានខ្លួន ១ ទិដ្ឋិរបស់បុគ្គលនោះ តែងកើតឡើង ដោយទៀងទាត់មាំមួន ថា អញស្គាល់ច្បាស់នូវខ្លួន ដោយខ្លួន ១ ទិដ្ឋិរបស់បុគ្គលនោះ តែងកើតឡើង ដោយទៀងទាត់មាំមួន ថា អញស្គាល់ច្បាស់នូវសភាពមិនមែនខ្លួន ដោយខ្លួន ១ ទិដ្ឋិរបស់បុគ្គលនោះ តែងកើតឡើង ដោយទៀងទាត់មាំមួន ថា អញស្គាល់ច្បាស់នូវខ្លួន ដោយសភាពមិនមែនខ្លួន ១ ទិដ្ឋិរបស់បុគ្គលនោះ តែងកើតឡើង ដោយទៀងទាត់មាំមួន ថា ខ្លួនរបស់អញនេះ ជាអ្នកពោល អ្នកទទួលផល រមែងទទួលនូវវិបាក នៃធម៌ល្អនិងអាក្រក់ អស់កាលដ៏វែង ក្នុងអារម្មណ៍នោះៗ ខ្លួននោះមិនកើតឡើង ហើយក៏មិនមែន ខ្លួននោះនឹងមិនកើតឡើង ក៏មិនមែន ជាសភាវៈទៀង ឋិតថេរ មាំមួន មិនប្រែប្រួលជាធម្មតា ១ នេះ ទិដ្ឋិ ៦ ។

ចប់ ពួកធម៌ ៦ ។

(២៣៩) តត្ថ កតមេ សត្ត អនុសយា ។ កាមរាគានុសយោ បដិឃានុសយោ មានានុសយោ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ ភវរាគានុសយោ អវិជ្ជានុសយោ ឥមេ សត្ត អនុសយា ។

(២៤០) តត្ថ កតមានិ សត្ត បរិយុដ្ឋានានិ ។ កាមរាគបរិយុដ្ឋានំ បដិឃបរិយុដ្ឋានំ មានបរិយុដ្ឋានំ ទិដ្ឋិបរិយុដ្ឋានំ វិចិកិច្ឆាបរិយុដ្ឋានំ ភវរាគបរិយុដ្ឋានំ អវិជ្ជាបរិយុដ្ឋានំ ឥមានិ សត្ត បរិយុដ្ឋានានិ ។

(២៤១) តត្ថ កតមានិ សត្ត សញ្ញោជនានិ ។ កាមរាគសញ្ញោជនំ បដិឃសញ្ញោជនំ មានសញ្ញោជនំ ទិដ្ឋិសញ្ញោជនំ វិចិកិច្ឆាសញ្ញោជនំ ភវរាគសញ្ញោជនំ អវិជ្ជាសញ្ញោជនំ ឥមានិ សត្ត សញ្ញោជនានិ ។

(២៤២) តត្ថ កតមេ សត្ត អសទ្ធម្មា ។ អស្សទ្ធោ ហោតិ អហិរិកោ ហោតិ អនោត្តប្បី ហោតិ អប្បស្សុតោ ហោតិ កុសីតោ ហោតិ មុដ្ឋស្សតិ ហោតិ ទុប្បញ្ញោ ហោតិ ឥមេ សត្ត អសទ្ធម្មា ។

[៦៣៩] បណ្ដាធម៌ទាំងនោះ អនុសយកិលេស ៧ តើដូចម្ដេច ។ កាមរាគានុស័យ ១ បដិឃានុស័យ ១ មានានុស័យ ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ ភវរាគានុស័យ ១ អវិជ្ជានុស័យ ១ នេះ អនុស័យ ៧ ។

[៦៤០] បណ្ដាធម៌ទាំងនោះ បរិយុដ្ឋានកិលេស ៧ តើដូចម្ដេច ។ កាមរាគបរិយុដ្ឋាន ១ បដិឃបរិយុដ្ឋាន ១ មានបរិយុដ្ឋាន ១ ទិដ្ឋិបរិយុដ្ឋាន ១ វិចិកិច្ឆាបរិយុដ្ឋាន ១ ភវរាគបរិយុដ្ឋាន ១ អវិជ្ជាបរិយុដ្ឋាន ១ នេះ បរិយុដ្ឋានកិលេស ៧ ។

[៦៤១] បណ្ដាធម៌ទាំងនោះ សញ្ញោជនៈ ៧ តើដូចម្ដេច ។ កាមរាគសញ្ញោជនៈ ១ បដិឃសញ្ញោជនៈ ១ មានសញ្ញោជនៈ ១ ទិដ្ឋិសញ្ញោជនៈ ១ វិចិកិច្ឆាសញ្ញោជនៈ ១ ភវរាគសញ្ញោជនៈ ១ អវិជ្ជាសញ្ញោជនៈ ១ នេះ សញ្ញោជនៈ ៧ ។

[៦៤២] បណ្ដាធម៌ទាំងនោះ អសទ្ធម្ម (ធម៌របស់អសប្បុរស) ៧ តើដូចម្ដេច ។ បុគ្គលមិនមានសទ្ធា ១ មិនមានហិរិ ១ មិនមានឱត្តប្បៈ ១ ចេះដឹងតិច ១ មានសេចក្ដីខ្ជិល ១ ភ្លេចស្មារតី ១ មិនមានបញ្ញា ១ នេះ អសទ្ធម្ម ៧ ។

[ ២៤៣ ] តត្ថ កតមានិ សត្ត ទុច្ចរិតានិ ។ បាណាតិបាតោ អទិន្នាទានំ កាមេសុ មិច្ឆាចារោ មុសាវាទោ បិសុណា វាចា ផរុសា វាចា សម្ផប្បលាបោ ឥមានិ សត្ត ទុច្ចរិតានិ ។

[ ២៤៤ ] តត្ថ កតមេ សត្ត មានា ។ មានោ អតិមានោ មានាតិមានោ ឱមានោ អធិមានោ អស្មិមានោ មិច្ឆាមានោ ឥមេ សត្ត មានា ។

[ ២៤៥ ] តត្ថ កតមា សត្ត ទិដ្ឋិយោ ។ ឥធេកច្ចោ សមណោ វា ព្រាហ្មណោ វា ឯវំវាទី ហោតិ ឯវំទិដ្ឋិ យតោ ខោ ភោ អយំ អត្តា រូបី ចាតុម្មហាភូតិកោ មាតាបេត្តិកសម្ភវោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណា ឯត្តាវតា ខោ ភោ អយំ អត្តា សម្មា សមុច្ឆិន្នោ ហោតីតិ ឥត្ថេកេ សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ ខោ ភោ

(៦៤៣) បណ្ដាធម៌ទាំងនោះ ទុច្ចរិត ៧ តើដូចម្ដេច ។ បាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ បិសុណាវាចា ១ ផរុសវាចា ១ សម្ផប្បលាបៈ ១ នេះ ទុច្ចរិត ៧ ។

(៦៤៤) បណ្ដាធម៌ទាំងនោះ មានះ ៧ តើដូចម្ដេច ។ មានះ ១ អតិមានះ ១ មានាតិមានះ ១ ឱមានះ ១ អធិមានះ ១ អស្មិមានះ ១ មិច្ឆាមានះ ១ នេះ មានះ ៧ ។

(៦៤៥) បណ្ដាធម៌ទាំងនោះ ទិដ្ឋិ ៧ តើដូចម្ដេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ មានវាទៈ យ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន ខ្លួននេះ មានរូប កើតអំពីមហាភូតរូប កកើតអំពីមាតាបិតា លុះកាយបែកធ្លាយទៅកាល ណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងមិនមាន ម្នាលអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះឯង ឈ្មោះថា ដាច់សូន្យប្រាកដ ។ សមណៈឬព្រាហ្មណ៍ ពួកមួយ បញ្ញត្តនូវសេចក្ដីដាច់សូន្យ នូវសេចក្ដីវិនាស នូវសេចក្ដីមិន កើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ មានបុគ្គល ដទៃ ក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន

ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា សម្មា សមុច្ឆិន្នោ ហោតិ អត្ថិ ខោ ភោ អញ្ញោ អត្តា ទិព្វោ រូបី កាមាវចរោ កពឡីការាហារភក្ខោ[១] តំ ត្វំ ន ជានាសិ ន បស្សសិ តមហំ ជានាមិ បស្សាមិ សោ ខោ ភោ អត្តា យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណា ឯត្តាវតា ខោ ភោ អយំ អត្តា សម្មា សមុច្ឆិន្នោ ហោតីតិ ឥត្ថេកេ សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា សម្មា សមុច្ឆិន្នោ ហោតិ អត្ថិ ខោ ភោ អញ្ញោ អត្តា ទិព្វោ រូបី មនោមយោ សព្វង្គបច្ចង្គី

---

១ ម. កពឡីការភក្ខោ ។

ខុទ្ទកវត្ថុវិភង្គ សត្តកនិទ្ទេស

អ្នកនិយាយថា ខ្លួនមាននុ៎ះក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះមិនមានទេ ម្នាលអ្នកដ៏ចំរើន តែថាខ្លួននេះ មិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ ម្នាលអ្នកដ៏ចំរើន មានខ្លួនដទៃទៀត មានរូបជាទិព្វ ជាកាមាវចរទេវតា (ត្រាច់ទៅក្នុងភព) មានកវឡិង្ការាហារជាចំណី អ្នកមិនដឹង មិនឃើញ នូវខ្លួននោះឡើយ ឯខ្ញុំទើប ដឹងទើបឃើញ នូវខ្លួននោះ ម្នាលអ្នកដ៏ចំរើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅ មិនកើតទៀតទេ ម្នាលអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះ ឈ្មោះថា ជាសភាវៈដាច់សូន្យដោយពិត សមណៈឬព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវសេចក្តីដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃ ក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះ មិនមានទេ ម្នាលអ្នកដ៏ចំរើន តែថាខ្លួននេះ មិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ នែអ្នកដ៏ចំរើន មានខ្លួនដទៃទៀត មានរូបជាទិព្វ សម្រេចដោយឈានចិត្ត មានអវយវៈធំតូចគ្រប់សព្វ

អហីនិន្ទ្រិយោ តំ ត្វំ ន ជានាសិ ន បស្សសិ
តមហំ ជានាមិ បស្សាមិ សោ ខោ ភោ អត្តា
យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន
ហោតិ បរម្មរណា ឯត្តាវតា ខោ ភោ អយំ អត្តា
សម្មា សមុច្ឆិន្នោ ហោតីតិ ឥត្ថេកេ សតោ សត្តស្ស
ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេន្តិ ៗ តមញ្ញោ
ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ
វទេសិ នេសោ នត្ថីតិ វទាមិ នោ ច ខោ ភោ
អយំ អត្តា ឯត្តាវតា សម្មា សមុច្ឆិន្នោ ហោតិ
អត្ថិ ខោ ភោ អញ្ញោ អត្តា សព្វសោ រូបសញ្ញានំ
សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្ត-
សញ្ញានំ អមនសិការា អនន្តោ អាកាសោតិ
អាកាសានញ្ចាយតនូបគោ តំ ត្វំ ន ជានាសិ ន

មានឥន្ទ្រិយមិនថោកទាប គឺមានឥន្ទ្រិយពេញលេញ អ្នកមិនដឹង មិនឃើញ នូវខ្លួននោះឡើយ ឯខ្ញុំទើបដឹង ទើបឃើញ នូវខ្លួននោះ ម្នាលអ្នកដ៏ចម្រើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅ មិនកើតទៀតទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ទើបខ្លួននេះ ឈ្មោះថា ជាសភាវៈដាច់សូន្យដោយពិត សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវសេចក្តីដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃ ក្រៅអំពីបុគ្គលនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះមិនមានទេ ម្នាលអ្នកដ៏ចម្រើន តែថាខ្លួននេះ មិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណេះឡើយ ម្នាលអ្នកដ៏ចម្រើន មានខ្លួនដទៃ ដែលចូលទៅកាន់អាកាសានញ្ចាយតនភព មានអារម្មណ៍ថា អាកាសមិនមានទីបំផុតដូច្នេះ ព្រោះកន្លងនូវរូបសញ្ញា គឺសេចក្តីសំគាល់ក្នុងរូប ព្រោះអស់ទៅនៃបដិឃសញ្ញា គឺសេចក្តីសំគាល់ក្នុងអារម្មណ៍ដែលជាទីខ្ទាំងខ្ទប់ចិត្ត ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា គឺសេចក្តីសំគាល់ ក្នុងអារម្មណ៍ផ្សេង ៗ ដោយសព្វគ្រប់ អ្នកមិនដឹង

បស្សសិ តមហំ ជានាមិ បស្សាមិ សោ ខោ ភោ
អត្តា យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន
ហោតិ បរម្មរណា ឯត្តាវតា ខោ ភោ អយំ អត្តា
សម្មា សមុច្ឆិន្នោ ហោតីតិ ឥត្ថេកេ សតោ
សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ ។
តមញ្ញោ ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា
យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នោ ច
ខោ ភោ អយំ អត្តា ឯត្តាវតា សម្មា សមុច្ឆិន្នោ
ហោតិ អត្ថិ ខោ ភោ អញ្ញោ អត្តា សព្វសោ
អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ
វិញ្ញាណញ្ចាយតនូបគោ តំ ត្វំ ន ជានាសិ ន
បស្សសិ តមហំ ជានាមិ បស្សាមិ សោ ខោ
ភោ អត្តា យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ
វិនស្សតិ ន ហោតិ បរម្មរណា ឯត្តាវតា

## ខុទ្ទកវត្ថុវិភង្គ សត្តកនិទ្ទេស

មិនឃើញ នូវខ្លួននោះឡើយ ខ្ញុំទើបដឹង ទើបឃើញ នូវខ្លួននោះ ម្នាលអ្នកដ៏ចម្រើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅ មិនកើតទៀតទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះ ឈ្មោះថា ជាសភាវៈដាច់សូន្យដោយពិត សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវសេចក្តីដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃ ក្រៅអំពីបុគ្គលនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមានទុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួនទុ៎ះមិនមានទេ ម្នាលអ្នកដ៏ចម្រើន តែថាខ្លួននេះ មិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ ម្នាលអ្នកដ៏ចម្រើន មានខ្លួនដទៃ ដែលកន្លងបង់នូវអាកាសានញ្ចា-យតនជ្ឈាន ដោយសព្វគ្រប់ ហើយចូលទៅកាន់វិញ្ញាណញ្ចាយតនភព មានអារម្មណ៍ថា វិញ្ញាណមិនមានទីបំផុតដូច្នេះ អ្នកមិនដឹង មិនឃើញ នូវខ្លួននោះឡើយ ខ្ញុំទើបដឹង ទើបឃើញ នូវខ្លួននោះ ម្នាលអ្នកដ៏ចម្រើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅ មិនកើតទៀតឡើយ

ខោ ភោ អយំ អត្តា សម្មា សមុច្ឆិន្នោ ហោតីតិ ឥត្ថេកេ សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា សម្មា សមុច្ឆិន្នោ ហោតិ អត្ថិ ខោ ភោ អញ្ញោ អត្តា សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនូបគោ តំ ត្វំ ន ជានាសិ ន បស្សសិ តមហំ ជានាមិ បស្សាមិ សោ ខោ ភោ អត្តា យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណា ឯត្តាវតា ខោ ភោ អយំ អត្តា សម្មា សមុច្ឆិន្នោ ហោតីតិ ឥត្ថេកេ សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេន្តិ ។

ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះ ឈ្មោះថា ជាសភាវៈដាច់សូន្យដោយពិត សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវសេចក្តីដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។ មានបុគ្គលដទៃ ក្រៅអំពីបុគ្គលនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះមិនមានទេ ម្នាលអ្នកដ៏ចម្រើន តែថាខ្លួននេះ មិនមែនជាសភាវៈដាច់សូន្យ ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ ម្នាលអ្នកដ៏ចម្រើន មានខ្លួនដទៃដែលកន្លងបង់ នូវវិញ្ញាណញ្ចាយតនៈដោយសព្វគ្រប់ ហើយចូលទៅកាន់អាកិញ្ចញ្ញាយតនភព មានអារម្មណ៍ថា អ្វីតិចតួច ក៏មិនមានដូច្នេះ អ្នកមិនដឹង មិនឃើញ នូវខ្លួននោះឡើយ ឯខ្ញុំទើបដឹង ទើបឃើញ នូវខ្លួននោះ ម្នាលអ្នកដ៏ចម្រើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅ មិនកើតទៀតឡើយ ម្នាលអ្នកដ៏ចម្រើន ខ្លួននេះ ឈ្មោះថា ជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឯង សមណ-ព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវសេចក្តីសូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះ ១ ។

តមញ្ញោ ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា សម្មា សមុច្ឆិន្នោ ហោតិ អត្ថិ ខោ ភោ អញ្ញោ អត្តា សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនូបគោ តំ ត្វំ ន ជានាសិ ន បស្សសិ តមហំ ជានាមិ បស្សាមិ សោ ខោ ភោ អត្តា យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណា ឯត្តាវតា ខោ ភោ អយំ អត្តា សម្មា សមុច្ឆិន្នោ ហោតីតិ ឥត្ថេកេ សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេន្តិ ។ ឥមា សត្ត ទិដ្ឋិយោ ។

សត្តកំ ។

(២៤៦) តត្ថ កតមានិ អដ្ឋ កិលេសវត្ថូនិ ។ លោភោ ទោសោ មោហោ មានោ ទិដ្ឋិ វិចិកិច្ឆា ថីនំ ឧទ្ធច្ចំ ឥមានិ អដ្ឋ កិលេសវត្ថូនិ ។

មានបុគ្គលដទៃ ក្រៅអំពីបុគ្គលនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកនិយាយថា ខ្លួនមាននុះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុះមិនមានទេ ម្នាលអ្នកដ៏ចំរើន តែថាខ្លួននេះ មិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ ម្នាលអ្នកដ៏ចម្រើន មានខ្លួនដទៃ ដែលកន្លងបង់ នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយសព្វគ្រប់ ហើយចូលទៅកាន់នេវសញ្ញានាសញ្ញាយតនភព អ្នកមិនដឹង មិនឃើញ នូវខ្លួននោះឡើយ ឯខ្ញុំទើបដឹង ទើបឃើញ នូវខ្លួននោះ ម្នាលអ្នកដ៏ចម្រើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀតឡើយ ម្នាលអ្នកដ៏ចម្រើន ខ្លួននេះ ឈ្មោះថា ជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឯង សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវសេចក្តីដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀតនៃសត្វដែលមានទៅ ដោយប្រការដូច្នេះ ១ ។ នេះ ទិដ្ឋិ ៧ ។

ចប់ ពួកធម៌ ៧ ។

(៩៤៦) បណ្តាធម៌ទាំងនោះ កិលេសវត្ថុ ៨ តើដូចម្តេច ។ លោភៈ ១ ទោសៈ ១ មោហៈ ១ មានះ ១ ទិដ្ឋិ ១ វិចិកិច្ឆា ១ ថីនៈ ១ ឧទ្ធច្ចៈ ១ នេះ កិលេសវត្ថុ ៨ ។

(២៤៧) តត្ថ កតមានិ អដ្ឋ កុសីតវត្ថូនិ ។ ឥធ ភិក្ខុនា កម្មំ កត្តព្វំ ហោតិ តស្ស ឯវំ ហោតិ កម្មំ ខោ មេ កត្តព្វំ ភវិស្សតិ កម្មំ ខោ បន មេ ករោន្តស្ស កាយោ កិលមិស្សតិ ហន្ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ បឋមំ កុសីតវត្ថុំ ។ បុន ច បរំ ភិក្ខុនា កម្មំ កតំ ហោតិ តស្ស ឯវំ ហោតិ អហំ ខោ កម្មំ អកាសឹ កម្មំ ខោ បន មេ ករោន្តស្ស កាយោ កិលន្តោ ហន្ទ-ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ ទុតិយំ កុសីតវត្ថុំ ។

(៤៤៧) បណ្ដាធម៌ទាំងនោះ កុសីតវត្ថុ (ហេតុនៃបុគ្គលខ្ជិល) ៨ តើដូចម្ដេច ។ ការងារ (មានរវល់កាត់ចីវរជាដើម) ភិក្ខុក្នុងសាសនានេះត្រូវធ្វើ ភិក្ខុនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា ការងារដែលអញត្រូវធ្វើ មុខជានឹងមាន តែកាលបើអញធ្វើការងារ(នោះ) កាយនឹងលំបាក បើដូច្នោះ មានតែអញដេកសិន ភិក្ខុនោះ ក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់ នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹង នូវធម៌ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះ កុសីតវត្ថុទី ១ ។ មួយទៀត ការងារ ភិក្ខុធ្វើរួចហើយ ភិក្ខុនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា អញបានធ្វើការងាររួចហើយ តែកាលដែលអញកំពុងធ្វើការងារ កាយលំបាកទៅហើយ បើដូច្នោះ មានតែអញដេកសិន ភិក្ខុនោះ ក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់ នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹង នូវធម៌ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះ កុសីតវត្ថុទី ២ ។

## ខុទ្ទកវត្ថុវិភង្គេ អដ្ឋកនិទ្ទេសោ

បុន ច បរំ ភិក្ខុនា មគ្គោ គន្តព្វោ ហោតិ តស្ស
ឯវំ ហោតិ មគ្គោ ខោ មេ គន្តព្វោ ភវិស្សតិ មគ្គំ
ខោ បន មេ គច្ឆន្តស្ស កាយោ កិលមិស្សតិ
ហន្ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ
អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិ-
កតស្ស សច្ឆិកិរិយាយ ឥទំ តតិយំ កុសីតវត្ថុ ។

បុន ច បរំ ភិក្ខុនា មគ្គោ គតោ ហោតិ តស្ស
ឯវំ ហោតិ អហំ ខោ មគ្គំ អគមាសឹ មគ្គំ ខោ
បន មេ គច្ឆន្តស្ស កាយោ កិលន្តោ ហន្ទាហំ
និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ
អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិ-
កតស្ស សច្ឆិកិរិយាយ ឥទំ ចតុត្ថំ កុសីតវត្ថុ ។

បុន ច បរំ ភិក្ខុ គាមំ វា និគមំ វា បិណ្ឌាយ
ចរន្តោ ន លភតិ លូខស្ស វា បណីតស្ស វា
ភោជនស្ស យាវទត្ថំ បារិបូរឹ តស្ស ឯវំ ហោតិ

## ខុទ្ទកវត្ថុវិភង្គ អដ្ឋកនិទ្ទេស

មួយទៀត ភិក្ខុត្រូវដើរផ្លូវ ភិក្ខុនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញនឹងត្រូវដើរផ្លូវ តែបើអាត្មាអញដើរផ្លូវ កាយនឹងលំបាក បើដូច្នោះ មានតែអញដេកសិន ភិក្ខុនោះ ក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់ នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹង នូវធម៌ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះ កុសីតវត្ថុទី ៣ ។ មួយទៀត ភិក្ខុដើរផ្លូវរួចហើយ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញបានដើរផ្លូវរួចហើយ តែកាលដែលអាត្មាអញដើរផ្លូវ កាយលំបាកទៅហើយ បើដូច្នោះ មានតែអាត្មាអញដេកសិន ភិក្ខុនោះ ក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់ នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹង នូវធម៌ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះ កុសីតវត្ថុទី ៤ ។ មួយទៀត ភិក្ខុត្រាច់ទៅកាន់ស្រុកក្តី និគមក្តី ដើម្បីបិណ្ឌបាត តែមិនបានភោជនដ៏សៅហ្មង ឬថ្លៃថ្លា ឲ្យបរិបូណ៌ ដរាបដល់ឆ្អែតទេ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា

អហំ ខោ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ នាលត្ថំ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ តស្ស មេ កាយោ កិលន្តោ អកម្មញ្ញោ ហន្ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ បញ្ចមំ កុសីតវត្ថុំ ។ បុន ច បរំ ភិក្ខុ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ លភតិ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ តស្ស ឯវំ ហោតិ អហំ ខោ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ អលត្ថំ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ តស្ស មេ កាយោ គរុកោ(១) អកម្មញ្ញោ មាសាចិតំ មញ្ញេ ហន្ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ ឆដ្ឋំ កុសីតវត្ថុំ ។

---

១ ម. កិលន្តោ ។

អាត្មាអញ កាលដែលដើរទៅកាន់ស្រុក ឬនិគមក្តី ដើម្បីបិណ្ឌបាត មិនបានភោជន ដ៏សៅហ្មង ឬថ្លៃថ្លា ឲ្យបរិបូណ៌ ដរាបដល់ឆ្អែត សោះ កាយរបស់អាត្មាអញនោះ លំបាកទៅហើយ ធ្វើការងារមិនកើតទេ បើដូច្នោះ មានតែអាត្មាអញដេកសិន ភិក្ខុនោះ ក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់ នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹង នូវធម៌ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះ កុសីតវត្ថុទី ៥ ។ មួយទៀត ភិក្ខុដើរទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត បានភោជនដ៏សៅហ្មង ឬថ្លៃថ្លា បរិបូណ៌ ដរាបដល់ឆ្អែត ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ កាលដែលដើរទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត បានភោជនដ៏សៅហ្មង ឬថ្លៃថ្លា បរិបូណ៌ ដរាបដល់ឆ្អែតដែរហើយ តែកាយរបស់អាត្មាអញនោះធ្ងន់ ធ្វើការងារមិនកើត ទំនងដូចជាសណ្តែកដែលត្រាំទឹក បើដូច្នោះ មានតែអាត្មាអញដេកសិន ភិក្ខុនោះ ក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់ នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹង នូវធម៌ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះ កុសីតវត្ថុទី ៦ ។

បុន ច បរំ ភិក្ខុនោ ឧប្បន្នោ ហោតិ អប្បមត្តកោ អាពាធោ តស្ស ឯវំ ហោតិ ឧប្បន្នោ ខោ មេ អយំ អប្បមត្តកោ អាពាធោ អត្ថិ កប្បោ និបជ្ជិតុំ ហន្ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារ-ភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ សត្តមំ កុសី-តវត្ថុំ ។ បុន ច បរំ ភិក្ខុ គិលានា វុដ្ឋិតោ ហោតិ អចិរវុដ្ឋិតោ គេលញ្ញា តស្ស ឯវំ ហោតិ អហំ ខោ គិលានា វុដ្ឋិតោ អចិរវុដ្ឋិតោ គេលញ្ញា តស្ស មេ កាយោ ទុព្វលោ អកម្មញ្ញោ ហន្ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ អដ្ឋមំ កុសី-តវត្ថុំ ។ ឥមានិ អដ្ឋ កុសីតវត្ថូនិ ។

មួយទៀត ភិក្ខុកើតអាពាធបន្តិចបន្តួច ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញកើតអាពាធបន្តិចបន្តួចនេះហើយ អាត្មាអញគួរតែដេក បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះ ក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹង នូវធម៌ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះ កុសីតវត្ថុទី ៧ ។ មួយទៀត ភិក្ខុជាសះស្បើយអំពីជម្ងឺហើយ តែទើបនឹងសះស្បើយមិនយូរប៉ុន្មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញសះស្បើយអំពីជម្ងឺហើយ តែសះស្បើយមិនទាន់យូរប៉ុន្មាន កាយរបស់អាត្មាអញនោះនៅមិនទាន់មានកម្លាំង ធ្វើការងារមិនទាន់កើត បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះ ក៏ដេក មិនប្រារព្ធព្យាយាម ដើម្បីដល់ នូវធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹង នូវធម៌ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះ កុសីតវត្ថុទី ៨ ។ នេះ កុសីតវត្ថុ ៨ ។

( ២៤៨ ) តត្ថ កតមេសុ អដ្ឋសុ លោកធម្មេសុ ចិត្តស្ស បដិឃាតោ ។ លាភេ សារាគោ អលាភេ បដិវិរោធោ យសេ សារាគោ អយសេ បដិវិរោធោ បសំសាយ សារាគោ និន្ទាយ បដិវិរោធោ សុខេ សារាគោ ទុក្ខេ បដិវិរោធោ ឥមេសុ អដ្ឋសុ លោកធម្មេសុ ចិត្តស្ស បដិឃាតោ ។

( ២៤៩ ) តត្ថ កតមេ អដ្ឋ អនរិយវោហារា ។ អទិដ្ឋេ ទិដ្ឋវាទិតា អស្សុតេ សុតវាទិតា អមុតេ មុតវាទិតា អវិញ្ញាតេ វិញ្ញាតវាទិតា ទិដ្ឋេ អទិដ្ឋវាទិតា សុតេ អស្សុតវាទិតា មុតេ អមុតវាទិតា វិញ្ញាតេ អវិញ្ញាតវាទិតា ឥមេ អដ្ឋ អនរិយវោហារា ។

( ២៥០ ) តត្ថ កតមេ អដ្ឋ មិច្ឆត្តា ។ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បោ មិច្ឆាវាចា មិច្ឆាកម្មន្តោ

( ៩៦៨ ) បណ្ដាធម៌ទាំងនោះ សេចក្ដីបង្វៀតបង្វិលចិត្ត ព្រោះលោកធម៌ ៨ តើដូចម្ដេច ។ សេចក្ដីត្រេកត្រអាល ក្នុងលាភ (ការបាន) ១ សេចក្ដីថ្នាំងថ្នាក់ ក្នុងអលាភ ( ការមិនបាន ) ១ សេចក្ដីត្រេកត្រអាល ក្នុងយស ១ សេចក្ដីថ្នាំងថ្នាក់ ក្នុងអយស ( ការមិនមានយស ) ១ សេចក្ដីត្រេកត្រអាល ក្នុងពាក្យសរសើរ ១ សេចក្ដីថ្នាំងថ្នាក់ ក្នុងពាក្យតិះដៀល ១ សេចក្ដីត្រេកត្រអាល ក្នុងសុខ ១ សេចក្ដីថ្នាំងថ្នាក់ ក្នុងទុក្ខ ១ នេះសេចក្ដីបង្វៀតបង្វិលចិត្ត ព្រោះលោកធម៌ ៨ ។

( ៩៦៩ ) បណ្ដាធម៌ទាំងនោះ វោហារមិនប្រសើរ ៨ តើដូចម្ដេច ។ ការពោលថា ឃើញក្នុងហេតុដែលមិនបានឃើញ ១ ការពោលថា បានឮក្នុងហេតុដែលមិនបានឮ ១ ការពោលថា បានលិទ្ធភ្លក្សក្នុងហេតុដែលមិនបានលិទ្ធភ្លក្ស ១ ការពោលថា បានដឹងក្នុងហេតុដែលមិនបានដឹង ១ ការពោលថា មិនបានឃើញក្នុងហេតុដែលបានឃើញ ១ ការពោលថា មិនបានឮក្នុងហេតុដែលបានឮ ១ ការពោលថា មិនបានលិទ្ធភ្លក្សក្នុងហេតុដែលបានលិទ្ធភ្លក្ស ១ ការពោលថា មិនបានដឹងក្នុងហេតុដែលបានដឹង ១ នេះ វោហារមិនប្រសើរ ៨ ។

( ៩៧០ ) បណ្ដាធម៌ទាំងនោះ មិច្ឆត្តធម៌ (សេចក្ដីខុស) ៨ តើដូចម្ដេច ។ ការយល់ខុស ១ ត្រិះរិះខុស ១ វាចាខុស ១ ការងារខុស ១

មិច្ឆាអាជីវោ មិច្ឆាវាយាមោ មិច្ឆាសតិ មិច្ឆាសមាធិ ឥមេ អដ្ឋ មិច្ឆត្តា ។

(២៨១) តត្ថ កតមេ អដ្ឋ បុរិសទោសា ។ ឥធ ភិក្ខូ ភិក្ខុំ អាបត្តិយា ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ ន សរាមិ ន សរាមីតិ អសតិយាវ និព្វេឋេតិ អយំ បឋមោ បុរិសទោសោ ។ បុន ច បរំ ភិក្ខូ ភិក្ខុំ អាបត្តិយា ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ ចោទកំយេវ បដិប្ផរតិ កិន្នុ ខោ តុយ្ហំ ពាលស្ស អព្យត្តស្ស ភណិតេន ត្វំបិ នាម មំ ភណិតព្វំ មញ្ញសីតិ អយំ ទុតិយោ បុរិសទោសោ ។ បុន ច បរំ ភិក្ខូ ភិក្ខុំ អាបត្តិយា ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ ចោទកស្ស បច្ចារោបេតិ ត្វំបិ ខោសិ ឥត្ថន្នាមំ អាបត្តឹ អាបន្នោ ត្វំ តាវ បឋមំ បដិករោហីតិ អយំ តតិយោ បុរិសទោសោ ។ បុន ច បរំ ភិក្ខូ

ការចិញ្ចឹមជីវិតខុស ១ ព្យាយាមខុស ១ ការរលឹកខុស ១ ការតំកល់ចិត្តខុស ១ នេះ មិច្ឆត្តធម៌ ៨ ។

[៦៨១] បណ្តាធម៌ទាំងនោះ ទោសរបស់បុរស ៨ តើដូចម្តេច ។ ពួកភិក្ខុក្នុងសាសនានេះ ចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលបើត្រូវពួកភិក្ខុ ចោទដោយអាបត្តិ ក៏ដោះស្រាយដោយអស្សតិ (ការគ្មានស្មារតី) ថា ខ្ញុំនឹកមិនឃើញ ខ្ញុំនឹកមិនឃើញ នេះ ទោសរបស់បុរសទី ១ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលបើត្រូវពួកភិក្ខុ ចោទដោយអាបត្តិ ក៏និយាយគេចកែនឹងភិក្ខុអ្នកចោទវិញថា ប្រយោជន៍អ្វី អ្នកជាមនុស្សល្ងង់ មិនឈ្លាស មកស្តីថាឲ្យយើងអម្បាលយ៉ាងអ្នក ហ៊ានសម្គាល់យើងថា គួរនឹងស្តីថាបាន នេះ ទោសរបស់បុរសទី ២ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលបើត្រូវពួកភិក្ខុ ចោទដោយអាបត្តិ ក៏ត្រឡប់លើកពាក្យរបស់អ្នកចោទវិញថា លោកឯងត្រូវអាបត្តិឈ្មោះនេះ ចូរលោកសំដែងមុនសិនទៅ នេះ ទោសរបស់បុរសទី ៣ ។ មួយទៀត ពួកភិក្ខុចោទ

ភិក្ខុំ អាបត្តិយា ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ អញ្ញេនញ្ញំ បដិចរតិ ពហិទ្ធា កថំ អបនាមេតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ អយំ ចតុត្ថោ បុរិសទោសោ ។ បុន ច បរំ ភិក្ខូ ភិក្ខុំ អាបត្តិយា ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ សង្ឃមជ្ឈេ ពាហាវិក្ខេបកំ ភណតិ អយំ បញ្ចមោ បុរិសទោសោ ។ បុន ច បរំ ភិក្ខូ ភិក្ខុំ អាបត្តិយា ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ(១) តុណ្ហីភូតោ សង្ឃំ វិហេសេតិ អយំ ឆដ្ឋោ បុរិសទោសោ ។ បុន ច បរំ ភិក្ខូ ភិក្ខុំ អាបត្តិយា ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ អនាទិយិត្វា សង្ឃំ អនាទិយិត្វា ចោទកំ សាបត្តិកោវ(២) យេន កាមំ បក្កមតិ អយំ សត្តមោ បុរិសទោសោ ។

---

១ ម. ឯត្តន្តរេ នេវាហំ អាបន្នោម្ហិ ន បនាហំ អនាបន្នោម្ហីតិ ទិស្សន្តិ ។ ២ ម. អាបត្តិកោវ ។

ភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលបើត្រូវពួកភិក្ខុ ចោទដោយអាបត្តិ ក៏បិទបាំងនូវហេតុដទៃ ដោយហេតុដទៃ យកពាក្យខាងក្រៅ មកបញ្ចេញ ធ្វើនូវសេចក្តីក្រោធ ខឹង មិនត្រេកអរ ឲ្យប្រាកដឡើង នេះ ទោសរបស់បុរសទី ៤ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិ ក៏និយាយផ្កាដៃក្នុងកណ្តាលសង្ឃ នេះ ទោសរបស់បុរសទី ៥ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិ ក៏នៅស្ងៀម ធ្វើសង្ឃឲ្យលំបាក នេះ ទោសរបស់បុរសទី ៦ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិ ក៏មិនអើពើនឹងសង្ឃ មិនអើពើនឹងភិក្ខុអ្នកចោទ ជាបុគ្គលមានអាបត្តិ ដើរចៀសចេញទៅតាមប្រាថ្នា នេះ ទោសរបស់បុរសទី ៧ ។

បុន ច បរំ ភិក្ខូ ភិក្ខុំ អាបត្តិយា ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ ឯវមាហ កិន្នុខោ តុម្ហេ អាយស្មន្តោ អតិពាឡ្ហំ មយិ ព្យាវដា ឥទានាហំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សាមីតិ សោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិត្វា ឯវមាហ ឥទានិ ខោ តុម្ហេ អាយស្មន្តោ អត្តមនា ហោថាតិ អយំ អដ្ឋមោ បុរិសទោសោ ឥមេ អដ្ឋ បុរិសទោសា ។

(២៨២) តត្ថ កតមេ អដ្ឋ អសញ្ញីវាទា ។ រូបី អត្តា ហោតិ អរោគោ បរម្មរណាតិ អសញ្ញីតិ នំ បញ្ញបេន្តិ អរូបី អត្តា ហោតិ អរោគោ បរម្មរណាតិ អសញ្ញីតិ នំ បញ្ញបេន្តិ រូបី ច អរូបី ច អត្តា ហោតិ អរោគោ បរម្មរណាតិ អសញ្ញីតិ នំ បញ្ញបេន្តិ

មួយទៀត ពួកភិក្ខុ ចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលបើត្រូវពួកភិក្ខុ ចោទដោយអាបត្តិ ក៏និយាយយ៉ាងនេះថា បពិត្រលោកមានអាយុទាំងឡាយ លោកខ្វល់ខ្វាយនឹងខ្ញុំ ហួសប្រមាណ ធ្វើអ្វី ឥឡូវនេះ ខ្ញុំនឹងលាសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ភិក្ខុនោះលុះលាសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបហើយ ក៏និយាយយ៉ាងនេះថា បពិត្រលោកមានអាយុទាំងឡាយ ឥឡូវនេះ លោកទាំងឡាយ ចូរជាអ្នកមានចិត្តត្រេកអរចុះ នេះ ទោសរបស់បុរសទី៨ នេះ ទោសរបស់បុរស ៨ ។

(២៧២) បណ្ដាធម៌ទាំងនោះ អសញ្ញីវាទ ៨ តើដូចម្ដេច ។ ខ្លួនមានរូប[១] មិនមានរោគ ខាងមុខអំពីសេចក្ដីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ ខ្លួនមិនមានរូប[២] មិនមានរោគ ខាងមុខអំពីសេចក្ដីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ ខ្លួនមានរូបខ្លះមិនមានរូបខ្លះ[៣] មិនមានរោគ ខាងមុខអំពីសេចក្ដីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១

---

១ សំដៅយករូបកសិណ ។ ២ និមិត្តរបស់អរូបសមាបត្តិ ។ ៣ រូបជ្ឈានអរូបជ្ឈាន ។ អដ្ឋកថា ។

នេវ រូបី នារូបី អត្តា ហោតិ អរោគោ បរម្មរណាតិ អសញ្ញីតិ នំ បញ្ញាបេន្តិ អន្តវា អត្តា ហោតិ អរោគោ បរម្មរណាតិ អសញ្ញីតិ នំ បញ្ញាបេន្តិ អនន្តវា អត្តា ហោតិ អរោគោ បរម្មរណាតិ អសញ្ញី(១) នំ បញ្ញាបេន្តិ អន្តវា ច អនន្តវា ច អត្តា ហោតិ អរោគោ បរម្មរណាតិ អសញ្ញី(១) នំ បញ្ញាបេន្តិ នេវន្តវា នានន្តវា អត្តា ហោតិ អរោគោ បរម្មរណាតិ អសញ្ញី(១) នំ បញ្ញាបេន្តិ ឥមេ អដ្ឋ អសញ្ញីវាទា ។

(២៥៣) តត្ថ កតមេ អដ្ឋ នេវសញ្ញីនាសញ្ញីវាទា ។ រូបី អត្តា ហោតិ អរោគោ បរម្មរណាតិ

---

១ ម. អសញ្ញីតិ ។

ខ្លួនមានរូបក៏មិនមែន មិនមានរូបក៏មិនមែន(១) មិនមានរោគ ខាងមុខអំពីសេចក្ដីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ ខ្លួនមានទីបំផុត(២) មិនមានរោគ ខាងមុខអំពីសេចក្ដីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ ខ្លួនមិនមានទីបំផុត(៣) មិនមានរោគ ខាងមុខអំពីសេចក្ដីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ(៤) មិនមានរោគ ខាងមុខអំពីសេចក្ដីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ ខ្លួនមានទីបំផុតក៏មិនមែន មិនមានទីបំផុត ក៏មិនមែន(៥) មិនមានរោគ ខាងមុខអំពីសេចក្ដីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មិនមានសញ្ញា ១ នេះ អសញ្ញីវាទ ៨ ។

(២៩៣) បណ្ដាធម៌ទាំងនោះ នេវសញ្ញីនាសញ្ញីវាទ ៨ តើដូចម្ដេច ។ ខ្លួនមានរូប មិនមានរោគ ខាងមុខអំពីសេចក្ដីស្លាប់

---

១ ការយល់ឃើញដោយការត្រិះរិះតែម្យ៉ាង ។ ២ កសិណតូច ។ ៣ កសិណធំ ។ ៤ កសិណមានទីបំផុតនិងមិនមានទីបំផុត ។ ៥ ការយល់ឃើញដោយការត្រិះរិះ ។ អដ្ឋកថា ។

នេវ សញ្ញី នាសញ្ញីតិ នំ បញ្ញបេន្តិ អរូបី អត្តា ហោតិ អរោគោ បរម្មរណាតិ នេវ សញ្ញី នាសញ្ញីតិ នំ បញ្ញបេន្តិ រូបី ច អរូបី ច អត្តា ហោតិ អរោគោ បរម្មរណាតិ នេវ សញ្ញី នាសញ្ញីតិ នំ បញ្ញបេន្តិ នេវ រូបី នារូបី អត្តា ហោតិ អរោគោ បរម្មរណាតិ នេវ សញ្ញី នាសញ្ញីតិ នំ បញ្ញបេន្តិ អន្តវា អត្តា ហោតិ អរោគោ បរម្មរណាតិ នេវ សញ្ញី នាសញ្ញីតិ នំ បញ្ញបេន្តិ អនន្តវា អត្តា ហោតិ អរោគោ បរម្មរណាតិ នេវ សញ្ញី នាសញ្ញីតិ នំ បញ្ញបេន្តិ អន្តវា ច អនន្តវា ច អត្តា ហោតិ អរោគោ បរម្មរណាតិ នេវ សញ្ញី នាសញ្ញីតិ នំ បញ្ញបេន្តិ

ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខន្ធនោះថា មានសញ្ញាក៏មិនមែន មិនមានសញ្ញា ក៏មិនមែន១ ខន្ធមិនមានរូប មិនមានភេគខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខន្ធនោះថា មានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន១ ខន្ធមានរូបខ្លះ មិនមានរូបខ្លះ មិនមានភេគ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខន្ធនោះថា មានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន១ ខន្ធមានរូប ក៏មិនមែន មិនមានរូបក៏មិនមែន មិនមានភេគ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខន្ធនោះថា មានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន១ ខន្ធមានទីបំផុត មិនមានភេគ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខន្ធនោះថា មានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន១ ខន្ធមិនមានទីបំផុត មិនមានភេគ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខន្ធនោះថា មានសញ្ញា ក៏មិនមែន មិនមានសញ្ញាក៏មិនមែន១ ខន្ធមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ មិនមានភេគ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខន្ធនោះថា មានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន ១

នេវន្តវា នានន្តវា អត្តា ហោតិ អរោគោ បរម្មរ-ណាតិ នេវ សញ្ញី នាសញ្ញីតិ នំ បញ្ញាបេន្តិ ឥមេ អដ្ឋ នេវសញ្ញីនាសញ្ញីវាទា ។

## អដ្ឋកំ ។

(២៩៨) តត្ថ កតមានិ នវ អាឃាតវត្ថូនិ ។ អនត្ថំ មេ អចរីតិ អាឃាតោ ជាយតិ អនត្ថំ មេ ចរតីតិ អាឃាតោ ជាយតិ អនត្ថំ មេ ចរិស្សតីតិ អាឃាតោ ជាយតិ បិយស្ស មេ មនាបស្ស អនត្ថំ អចរិ អនត្ថំ ចរតិ អនត្ថំ ចរិស្សតីតិ អាឃាតោ ជាយតិ អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរិ អត្ថំ ចរតិ

ខ្លួនមានមានទីបំផុត ក៏មិនមែន មិនមានទីបំផុត ក៏មិនមែន មិនមានរោគ ខាងមុខអំពីសេចក្ដីស្លាប់ ព្រោះហេតុនោះ បុគ្គលទាំងឡាយ បញ្ញត្តនូវខ្លួននោះថា មានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន ១ នេះ នេវសញ្ញានាសញ្ញីវាទ ៨ ។

ចប់ ពួកធម៌ ៨ ។

(៤៩៤) បណ្ដាធម៌ទាំងនោះ អាឃាតវត្ថុ (ហេតុនៃគំនុំ) ៩ តើដូចម្ដេច ។ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តហើយ នូវអំពើមិនមានប្រយោជន៍ ដល់អញ ១ គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្ត នូវអំពើមិនមានប្រយោជន៍ ដល់អញ ១ គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្ត នូវអំពើមិនមានប្រយោជន៍ ដល់អញ ១ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តហើយ នូវអំពើមិនមានប្រយោជន៍ ដល់ជនជាទីស្រឡាញ់ពេញចិត្តរបស់អញ ១ ជនឯណោះ កំពុងប្រព្រឹត្ត នូវអំពើមិនមានប្រយោជន៍ ដល់ជនជាទីស្រឡាញ់ពេញចិត្តរបស់អញ ១ ជនឯណោះ នឹងប្រព្រឹត្ត នូវអំពើមិនមានប្រយោជន៍ ដល់ជនជាទីស្រឡាញ់ពេញចិត្តរបស់អញ ១ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តហើយ នូវអំពើមានប្រយោជន៍ ដល់ជនមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អញ ១ ជនឯណោះ កំពុងប្រព្រឹត្ត

អត្ថំ ចរិស្សតីតិ អាឃាតោ ជាយតិ ឥមានិ នវ អាឃាតវត្ថូនិ ។

[២៥៨] តត្ថ កតមានិ នវ បុរិសមលានិ ។ កោធោ មក្ខោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ មុសាវាទោ បាបិច្ឆា មិច្ឆាទិដ្ឋិ ឥមានិ នវ បុរិសមលានិ ។

[២៥៩] តត្ថ កតមេ នវវិធា មានា ។ សេយ្យស្ស សេយ្យោហមស្មីតិ មានោ សេយ្យស្ស សទិសោហមស្មីតិ មានោ សេយ្យស្ស ហីនោហមស្មីតិ មានោ សទិសស្ស សេយ្យោហមស្មីតិ មានោ សទិសស្ស សទិសោហមស្មីតិ មានោ សទិសស្ស ហីនោហមស្មីតិ មានោ ហីនស្ស សេយ្យោហមស្មីតិ មានោ

នូវអំពើមានប្រយោជន៍ ដល់ជនមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត របស់អញ ១ ជនឯណោះ នឹងប្រព្រឹត្ត នូវអំពើមានប្រយោជន៍ ដល់ជន មិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត របស់អញ ១ នេះ អាឃាតវត្ថុ ៩ ។

(៤៥៥) បណ្តាធម៌ទាំងនោះ មន្ទិលរបស់បុរស ៩ តើដូចម្តេច ។ សេចក្តីក្រោធ ១ សេចក្តីលុបគុណ ១ សេចក្តីប្រណែន ១ សេចក្តីកំណាញ់ ១ ការលាក់ពុតត្បុត ១ សេចក្តីអួតអាង ១ ការពោលពាក្យមិនពិត ១ សេចក្តីប្រាថ្នាដ៏លាមក ១ សេចក្តីយល់ឃើញខុស ១ នេះ មន្ទិលរបស់បុរស ៩ ។

(៤៥៦) បណ្តាធម៌ទាំងនោះ មានះយ៉ាង ៩ តើដូចម្តេច ។ សេចក្តីប្រកាន់ របស់បុគ្គលប្រសើរជាងគេថា អញប្រសើរជាងគេ ១ សេចក្តីប្រកាន់ របស់បុគ្គលប្រសើរជាងគេថា អញស្មើនឹងគេ ១ សេចក្តីប្រកាន់ របស់បុគ្គលប្រសើរជាងគេថា អញថោកទាបជាងគេ ១ សេចក្តីប្រកាន់ របស់បុគ្គលស្មើនឹងគេថា អញប្រសើរជាងគេ ១ សេចក្តីប្រកាន របស់បុគ្គលស្មើនឹងគេថា អញស្មើនឹងគេ ១ សេចក្តីប្រកាន់ របស់បុគ្គលស្មើនឹងគេថា អញថោកទាបជាងគេ ១ សេចក្តីប្រកាន់ របស់បុគ្គលថោកទាបជាងគេថា អញប្រសើរជាងគេ ១

ហីនស្ស សទិសោហមស្មីតិ មានោ ហីនស្ស ហីនោហមស្មីតិ មានោ ឥមេ នវវិធា មានា ។

(២៥៧) តត្ថ កតមេ នវ តណ្ហាមូលកា ធម្មា ។ តណ្ហំ បដិច្ច បរិយេសនា បរិយេសនំ បដិច្ច លាភោ លាភំ បដិច្ច វិនិច្ឆយោ វិនិច្ឆយំ បដិច្ច ឆន្ទរាគោ ឆន្ទរាគំ បដិច្ច អជ្ឈោសានំ អជ្ឈោសានំ បដិច្ច បរិគ្គហោ បរិគ្គហំ បដិច្ច មច្ឆរិយំ មច្ឆរិយំ បដិច្ច អារក្ខោ អារក្ខាធិករណំ បដិច្ច ទណ្ឌាទានំ សត្ថាទានំ កលហោ វិគ្គហោ វិវាទោ តុវំតុវំ បេសុញ្ញំ មុសាវាទោ អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ ឥមេ នវ តណ្ហាមូលកា ធម្មា ។

(២៥៨) តត្ថ កតមានិ នវ ឥញ្ជិតានិ ។

សេចក្ដីប្រកាន់ របស់បុគ្គលថោកទាបជាងគេ ថា អញស្មើនឹងគេ ១ សេចក្ដីប្រកាន់ របស់បុគ្គលថោកទាបជាងគេ ថា អញថោកទាបជាងគេ ១ នេះ មានះ ៩ ។

[២៨៧] បណ្ដាធម៌ទាំងនោះ ធម៌មានតណ្ហាជាមូល ៩ តើដូចម្ដេច ។ ការស្វែងរក (កើតមាន) ព្រោះអាស្រ័យតណ្ហា ១ លាភ (កើតមាន) ព្រោះអាស្រ័យការស្វែងរក ១ សេចក្ដីត្រិះរិះ (កើតមាន) ព្រោះអាស្រ័យលាភ ១ ឆន្ទរាគ (កើតមាន) ព្រោះអាស្រ័យសេចក្ដីត្រិះរិះ ១ សេចក្ដីចូលចិត្តខ្លាំង (កើតមាន) ព្រោះអាស្រ័យឆន្ទរាគ ១ សេចក្ដីប្រកាន់ (កើតមាន) ព្រោះអាស្រ័យសេចក្ដីចូលចិត្តខ្លាំង ១ សេចក្ដីកំណាញ់ (កើតមាន) ព្រោះអាស្រ័យសេចក្ដីប្រកាន់ ១ ការរក្សា (កើតមាន) ព្រោះអាស្រ័យសេចក្ដីកំណាញ់ ១ ការកាន់ដំបង កាន់សស្ត្រាវុធ ឈ្លោះទាស់ទែង ជជែកគ្នាថា ឯងៗ ការពោលពាក្យញុះញង់ ការពោលពាក្យកុហក អកុសលធម៌ដ៏លាមកដ៏ច្រើន (កើតមាន) ព្រោះការរក្សាជាហេតុ ១ នេះ ធម៌មានតណ្ហាជាមូល ៩ ។

[២៨៨] បណ្ដាធម៌ទាំងនោះ សេចក្ដីញាប់ញ័រ[១] ៩ តើដូចម្ដេច ។

---

១ សេចក្ដីញាប់ញ័រ ៩ យ៉ាងនេះ សំដែងតាមប្រភេទរបស់មានះ ។ អដ្ឋកថា ។

អស្មីតិ ឥញ្ជិតមេតំ អហមស្មីតិ ឥញ្ជិតមេតំ អយមហមស្មីតិ ឥញ្ជិតមេតំ ភវិស្សន្តិ ឥញ្ជិតមេតំ រូបី ភវិស្សន្តិ ឥញ្ជិតមេតំ អរូបី ភវិស្សន្តិ ឥញ្ជិតមេតំ សញ្ញី ភវិស្សន្តិ ឥញ្ជិតមេតំ អសញ្ញី ភវិស្សន្តិ ឥញ្ជិតមេតំ នេវសញ្ញីនាសញ្ញី ភវិស្សន្តិ ឥញ្ជិតមេតំ ឥមានិ នវ ឥញ្ជិតានិ ។

(២៥៩) តត្ថ កតមានិ នវ មញ្ញិតានិ នវ ផន្ទិតានិ នវ បបញ្ចិតានិ នវ សង្ខតានិ ។ អស្មីតិ សង្ខតមេតំ អហមស្មីតិ សង្ខតមេតំ[1] អយមហមស្មីតិ សង្ខតមេតំ ភវិស្សន្តិ សង្ខតមេតំ[2] រូបី ភវិស្សន្តិ សង្ខតមេតំ អរូបី ភវិស្សន្តិ សង្ខតមេតំ សញ្ញី ភវិស្សន្តិ សង្ខតមេតំ អសញ្ញី ភវិស្សន្តិ សង្ខតមេតំ

---

១ ឱ. ឥមេ បាឋា ន ទិស្សន្តិ ។ ២ ឱ. ឯត្ថន្តរេ ន ភវិស្សន្តិ សង្ខតមេតន្តិ ទិស្សន្តិ ។

ពាក្យថា មាន នេះជាសេចក្ដីញាប់ញ័រ ១ ពាក្យថា អញមាន នេះជាសេចក្ដីញាប់ញ័រ ១ ពាក្យថា អញនេះមាន នេះជាសេចក្ដីញាប់ញ័រ ១ ពាក្យថា អញនឹងមាន នេះជាសេចក្ដីញាប់ញ័រ ១ ពាក្យថា អញនឹងមានរូប នេះជាសេចក្ដីញាប់ញ័រ ១ ពាក្យថា អញនឹងមិនមានរូប នេះជាសេចក្ដីញាប់ញ័រ ១ ពាក្យថា អញនឹងមានសញ្ញា នេះជាសេចក្ដីញាប់ញ័រ ១ ពាក្យថា អញនឹងមិនមានសញ្ញា នេះជាសេចក្ដីញាប់ញ័រ ១ ពាក្យថា អញនឹងមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន នេះជាសេចក្ដីញាប់ញ័រ ១ នេះ សេចក្ដីញាប់ញ័រ ៩ ។

(៦៥៩) បណ្ដាធម៌ទាំងនោះ សេចក្ដីសំគាល់ ៩ សេចក្ដីឃ្វេងឃ្វាង ៩ ដំណើរយឺតយូរ ៩ សង្ខតធម៌ (ធម៌ដែលបច្ច័យប្រជុំតាក់តែង) ៩ តើដូចម្ដេច ។ ពាក្យថា មាន នេះជាសង្ខតធម៌ ១ ពាក្យថា អញមាន នេះជាសង្ខតធម៌ ១ ពាក្យថា អញនេះមាន នេះជាសង្ខតធម៌ ១ ពាក្យថា អញនឹងមាន នេះជាសង្ខតធម៌ ១ ពាក្យថា អញនឹងមានរូប នេះជាសង្ខតធម៌ ១ ពាក្យថា អញនឹងមិនមានរូប នេះជាសង្ខតធម៌ ១ ពាក្យថា អញនឹងមានសញ្ញា នេះជាសង្ខតធម៌ ១ ពាក្យថា អញនឹងមិនមានសញ្ញា នេះជាសង្ខតធម៌ ១

នេវសញ្ញីនាសញ្ញី ភវិស្សន្តិ សង្ខតមេតំ ឥមានិ ទស សង្ខតានិ ។

ទសកំ ។

(២៦០) តត្ថ កតមានិ ទស កិលេសវត្ថូនិ ។ លោភោ ទោសោ មោហោ មានោ ទិដ្ឋិ វិចិកិច្ឆា ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ ឥមានិ ទស កិលេសវត្ថូនិ ។

(២៦១) តត្ថ កតមានិ ទស អាឃាតវត្ថូនិ ។ អនត្ថំ មេ អចរីតិ អាឃាតោ ជាយតិ អនត្ថំ មេ ចរតីតិ អាឃាតោ ជាយតិ អនត្ថំ មេ ចរិស្សតីតិ អាឃាតោ ជាយតិ បិយស្ស មេ មនាបស្ស អនត្ថំ អចរិ អនត្ថំ ចរតិ អនត្ថំ ចរិស្សតីតិ

ពាក្យថា អញ្ញទឹងមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន នេះជាសន្ធតធម៌ ១ នេះ សន្ធតធម៌ ៩ ។

ចប់ ពួកធម៌ ៩ ។

(៦៦០) បណ្តាធម៌ទាំងនោះ កិលេសវត្ថុ ១០ តើដូចម្តេច ។ លោភៈ ១ ទោសៈ ១ មោហៈ ១ មានះ ១ ទិដ្ឋិ ១ វិចិកិច្ឆា ១ ថីនៈ ១ ឧទ្ធច្ចៈ ១ អហិរិកៈ ១ អនោត្តប្បៈ ១ នេះ កិលេសវត្ថុ ១០ ។

(៦៦១) បណ្តាធម៌ទាំងនោះ អាឃាតវត្ថុ ១០ យ៉ាង តើដូចម្តេច ។ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តហើយ នូវអំពើមិនមានប្រយោជន៍ ដល់អញ ១ គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្ត នូវអំពើមិនមានប្រយោជន៍ ដល់អញ ១ គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្ត នូវអំពើមិនមានប្រយោជន៍ ដល់អញ ១ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តហើយ នូវអំពើមិនមានប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ពេញចិត្តរបស់អញ ១ ជនឯណោះ កំពុងប្រព្រឹត្ត នូវអំពើមិនមានប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ពេញចិត្តរបស់អញ ១ ជនឯណោះ នឹងប្រព្រឹត្ត នូវអំពើមិនមានប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ពេញចិត្តរបស់អញ ១

អាឃាតោ ជាយតិ អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរិ អត្ថំ ចរតិ អត្ថំ ចរិស្សតីតិ អាឃាតោ ជាយតិ អដ្ឋានេ វា បន អាឃាតោ ជាយតិ ឥមានិ ទស អាឃាតវត្ថូនិ ។

(២៦២) តត្ថ កតមេ ទស អកុសលកម្មបថា ។ បាណាតិបាតោ អទិន្នាទានំ កាមេសុ មិច្ឆាចារោ មុសាវាទោ បិសុណា វាចា ផរុសា វាចា សម្ផប្បលាបោ អភិជ្ឈា ព្យាបាទោ មិច្ឆាទិដ្ឋិ ឥមេ ទស អកុសលកម្មបថា ។

(២៦៣) តត្ថ កតមានិ ទស សញ្ញោជនានិ ។ កាមរាគសញ្ញោជនំ បដិឃសញ្ញោជនំ មានសញ្ញោជនំ ទិដ្ឋិសញ្ញោជនំ វិចិកិច្ឆាសញ្ញោជនំ សីលព្វតបរាមាសសញ្ញោជនំ ភវរាគសញ្ញោជនំ ឥស្សាសញ្ញោជនំ មច្ឆរិយសញ្ញោជនំ អវិជ្ជាសញ្ញោជនំ ឥមានិ ទស សញ្ញោជនានិ ។

(២៦៤) តត្ថ កតមេ ទស មិច្ឆត្តា ។ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បោ មិច្ឆាវាចា មិច្ឆាកម្មន្តោ

គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្ត នូវអំពើមានប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់មិនជាទីពេញចិត្តរបស់អញ ១ ជនឯណោះ កំពុងប្រព្រឹត្ត នូវអំពើមានប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់មិនជាទីពេញចិត្តរបស់អញ ១ ជនឯណោះ នឹងប្រព្រឹត្ត នូវអំពើមានប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អញ ១ ឬថា គំនុំកើតឡើង ក្នុងទីមិនគួរ ១ នេះ អាឃាតវត្ថុ ១០ ។

(២៦២) បណ្ដាធម៌ទាំងនោះ អកុសលកម្មបថ ១០ តើដូចម្ដេច ។ បាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ បិសុណាវាចា ១ ផរុសវាចា ១ សម្ផប្បលាបៈ ១ អភិជ្ឈា ១ ព្យាបាទ ១ មិច្ឆាទិដ្ឋិ ១ នេះ អកុសលកម្មបថ ១០ ។

(២៦៣) បណ្ដាធម៌ទាំងនោះ សញ្ញោជនៈ ១០ តើដូចម្ដេច ។ កាមរាគសញ្ញោជនៈ ១ បដិឃសញ្ញោជនៈ ១ មានសញ្ញោជនៈ ១ ទិដ្ឋិសញ្ញោជនៈ ១ វិចិកិច្ឆាសញ្ញោជនៈ ១ សីលព្វតបរាមាសសញ្ញោជនៈ ១ ភវរាគសញ្ញោជនៈ ១ ឥស្សាសញ្ញោជនៈ ១ មច្ឆរិយសញ្ញោជនៈ ១ អវិជ្ជាសញ្ញោជនៈ ១ នេះ សញ្ញោជនៈ ១០ ។

(២៦៤) បណ្ដាធម៌ទាំងនោះ មិច្ឆត្តធម៌ (សេចក្ដីខុស) ១០ តើដូចម្ដេច ។ មិច្ឆាទិដ្ឋិ ១ មិច្ឆាសង្កប្បៈ ១ មិច្ឆាវាចា ១ មិច្ឆាកម្មន្តៈ ១

មិច្ឆាអាជីវោ មិច្ឆាវាយាមោ មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាញាណំ មិច្ឆាវិមុត្តិ ឥមេ ទស មិច្ឆត្តា ។

(២៦៥) តត្ថ កតមា ទសវត្ថុកា មិច្ឆាទិដ្ឋិ ។ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកដទុក្កដានំ កម្មានំ ផលវិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ អយំ ទសវត្ថុកា មិច្ឆាទិដ្ឋិ ។

(២៦៦) តត្ថ កតមា ទសវត្ថុកា អន្តគ្គាហិកា ទិដ្ឋិ ។ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា

មិច្ឆាអាជីវៈ ១ មិច្ឆាវាយាមៈ ១ មិច្ឆាសតិ ១ មិច្ឆាសមាធិ ១ មិច្ឆា-ញាណ ១ មិច្ឆាវិមុត្តិ ១ នេះ មិច្ឆត្តធម៌ ១០ ។

(២៦៥) បណ្ដាធម៌ទាំងនោះ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ តើដូចម្ដេច ។ ទានដែលបុគ្គលឲ្យហើយ មិនមានផល ១ ការបូជាធំ មិនមានផល ១ ការបូជាតូច មិនមានផល ១ ផលវិបាកនៃកម្មដែលសត្វធ្វើល្អ និងធ្វើអាក្រក់ មិនមាន ១ លោកនេះ មិនមាន ១ លោកដទៃ មិនមាន ១ មាតា មិនមានគុណ ១ បិតា មិនមានគុណ ១ សត្វជាឧបបាតិកៈកំណើត មិនមាន ១ សមណព្រាហ្មណ៍ទាំងឡាយ ក្នុងលោក អ្នកប្រព្រឹត្តល្អ ប្រតិបត្តិល្អ ដែលបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្ដមខ្លួនឯង នូវលោកនេះ និងលោកខាងមុខ ហើយប្រកាស មិនមាន ១ នេះ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ ។

(២៦៦) បណ្ដាធម៌ទាំងនោះ អន្តគ្គាហិកទិដ្ឋិ (ទិដ្ឋិដែលប្រកាន់ថា លោកមានទីបំផុត) មានវត្ថុ ១០ តើដូចម្ដេច ។ លោកទៀង ១ លោកមិនទៀង ១ លោកមានទីបំផុត ១ លោកមិនមានទីបំផុត ១ ជីវិតក៏គឺសរីរៈ ១ ជីវិតដទៃ សរីរៈដទៃ ១ សត្វខាងមុខអំពីសេចក្ដីស្លាប់កើតទៀត ១ សត្វខាងមុខអំពីសេចក្ដីស្លាប់មិនកើតទៀត ១

ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា អយំ ទសវត្ថុកា អន្តគ្គាហិកា ទិដ្ឋិ ។

ទសកំ ។

[២៦៧] តត្ថ កតមានិ អដ្ឋារស តណ្ហាវិចរិតានិ អជ្ឈត្តិកស្ស ឧបាទាយ ។ អស្មីតិ ហោតិ ឥត្ថស្មីតិ ហោតិ ឯវស្មីតិ ហោតិ អញ្ញថាស្មីតិ ហោតិ ភវិស្សន្តិ ហោតិ ឥត្ថំ ភវិស្សន្តិ ហោតិ ឯវំ ភវិស្សន្តិ ហោតិ អញ្ញថា ភវិស្សន្តិ ហោតិ អសស្មីតិ ហោតិ សាតស្មីតិ ហោតិ សិយន្តិ ហោតិ ឥត្ថំ សិយន្តិ ហោតិ ឯវំ សិយន្តិ ហោតិ អញ្ញថា សិយន្តិ ហោតិ អបាហំ សិយន្តិ ហោតិ អបាហំ ឥត្ថំ សិយន្តិ ហោតិ អបាហំ ឯវំ សិយន្តិ ហោតិ

សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មាន មិនកើតទៀតក៏មាន ១ សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀត ក៏មិនមែន មិនកើតទៀតក៏មិនមែន ១ នេះ អន្តគ្គាហិកទិដ្ឋិ មានវត្ថុ ១០ ។

ចប់ ពួកធម៌ ១០ ។

[៦៦៧] បណ្តាធម៌ទាំងនោះ តណ្ហាវិចរិត (ការប្រព្រឹត្តិនៃតណ្ហា) ១៨ អាស្រ័យខន្ធបញ្ចកៈខាងក្នុង តើដូចម្តេច ។ តណ្ហាវិចរិតថា អញមាន ១ តណ្ហាវិចរិតថា អញមាន ដោយប្រការនេះ ១ តណ្ហាវិចរិតថា អញមាន យ៉ាងនេះ ១ តណ្ហាវិចរិតថា អញមាន ដោយប្រការដទៃ ១ តណ្ហាវិចរិតថា អញនឹងមាន ១ តណ្ហាវិចរិតថា អញនឹងមាន ដោយប្រការនេះ ១ តណ្ហាវិចរិតថា អញនឹងមាន យ៉ាងនេះ ១ តណ្ហាវិចរិតថា អញនឹងមាន ដោយប្រការដទៃ ១ តណ្ហាវិចរិតថា អញទៀង ១ តណ្ហាវិចរិតថា អញសុខស្រួល ១ តណ្ហាវិចរិតថា អញគួរមាន ១ តណ្ហាវិចរិតថា អញគួរមាន ដោយប្រការនេះ ១ តណ្ហាវិចរិតថា អញគួរមាន យ៉ាងនេះ ១ តណ្ហាវិចរិតថា អញគួរមាន ដោយប្រការដទៃ ១ តណ្ហាវិចរិតថា អម្បាលយ៉ាងអញគួរមាន ១ តណ្ហាវិចរិតថា អម្បាលយ៉ាងអញ គួរមាន ដោយប្រការនេះ ១ តណ្ហាវិចរិតថា អម្បាលយ៉ាងអញ គួរមាន យ៉ាងនេះ ១

អថាហំ អញ្ញថា សិយន្តិ ហោតិ ។

(២៦៨) កថញ្ច អស្មីតិ ហោតិ ។ កិញ្ចិ ធម្មំ អនវការី ករិត្វា រូបំ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អស្មីតិ ឆន្ទំ បដិលភតិ អស្មីតិ មានំ បដិលភតិ អស្មីតិ ទិដ្ឋឹ បដិលភតិ តស្មិំ សតិ ឥមានិ បបញ្ចិតានិ ហោន្តិ ឥត្ថស្មីតិ វា ឯវស្មីតិ វា អញ្ញថាស្មីតិ វា ។

(២៦៩) កថញ្ច ឥត្ថស្មីតិ ហោតិ ។ ខត្តិ-យោស្មីតិ វា ព្រាហ្មណោស្មីតិ វា វេស្សោស្មីតិ វា សុទ្ទោស្មីតិ វា គហដ្ឋោស្មីតិ វា បព្វជិតោស្មីតិ វា ទេវោស្មីតិ វា មនុស្សោស្មីតិ វា រូបីស្មីតិ វា អរូបីស្មីតិ វា សញ្ញីស្មីតិ វា អសញ្ញីស្មីតិ វា នេវ-សញ្ញីនាសញ្ញីស្មីតិ វា ឯវំ ឥត្ថស្មីតិ ហោតិ ។

តណ្ហាវិចរិតថា អម្បាលយ៉ាំងអញ គួរមាន ដោយប្រការដទៃ ១ ។

(២៦៨) ចុះតណ្ហាវិចរិតថា អញមាន តើដូចម្តេច ។ បុគ្គលធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនឲ្យបែកចេញពីគ្នាហើយ បាននូវឆន្ទៈ ថា អញមាន បាននូវមានះ ថា អញមាន បាននូវទិដ្ឋិ ថា អញមាន កាលបើធម៌មានឆន្ទៈជាដើមនោះ មាន ដំណើរយឺតយូរនេះ ក៏មានថា អញមាន ដោយប្រការនេះខ្លះ ថា អញមានយ៉ាំងនេះខ្លះ ថា អញមាន ដោយប្រការដទៃខ្លះ ។

(២៦៩) ចុះតណ្ហាវិចរិតថា អញមានដោយប្រការនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហា ថា អញ ជាក្សត្រ ឬថា អញ ជាព្រាហ្មណ៍ ថា អញ ជាអ្នកជំនួញ ឬថា អញ ជាអ្នកគ្រួ ថា អញ ជាគ្រហស្ថ ឬថា អញ ជាបព្វជិត ថា អញ ជាទេវតា ឬថា អញ ជាមនុស្ស ថា អញ មានរូប ឬថា អញ មិនមានរូប ថា អញ មានសញ្ញា ឬថា អញ មិនមានសញ្ញា ថា អញ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន យ៉ាំងនេះ ឈ្មោះថា តណ្ហាវិចរិត ថា អញមាន ដោយប្រការនេះ ។

( ២៧០ ) កថញ្ច ឯវស្មីតិ ហោតិ ។ យំ
បុគ្គលំ ឧបនិធាយ យថា សោ ខត្តិយោ តថាហំ
ខត្តិយោស្មីតិ វា យថា សោ ព្រាហ្មណោ តថាហំ
ព្រាហ្មណោស្មីតិ វា យថា សោ វេស្សោ តថាហំ
វេស្សោស្មីតិ វា យថា សោ សុទ្ទោ តថាហំ
សុទ្ទោស្មីតិ វា យថា សោ គហដ្ឋោ តថាហំ
គហដ្ឋោស្មីតិ វា យថា សោ បព្វជិតោ តថាហំ
បព្វជិតោស្មីតិ វា យថា សោ ទេវោ តថាហំ
ទេវោស្មីតិ វា យថា សោ មនុស្សោ តថាហំ
មនុស្សោស្មីតិ វា យថា សោ រូបី តថាហំ
រូបីស្មីតិ វា យថា សោ អរូបី តថាហំ អរូបីស្មីតិ
វា យថា សោ សញ្ញី តថាហំ សញ្ញីស្មីតិ វា
យថា សោ អសញ្ញី តថាហំ អសញ្ញីស្មីតិ
វា យថា សោ នេវសញ្ញីនាសញ្ញី តថាហំ នេវ-
សញ្ញីនាសញ្ញីស្មីតិ វា ឯវំ ឯវស្មីតិ ហោតិ ។

## ខុទ្ទកវត្ថុវិភង្គ អដ្ឋារសកនិទ្ទេស

(២៧០) ចុះតណ្ហាវិចរិត ថា អញមាន យ៉ាងនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបធៀបបុគ្គលដទៃ ថា បុគ្គលនោះ ជាក្សត្រ យ៉ាងណា អញ ក៏ជាក្សត្រ យ៉ាងនោះដែរ ឬថា បុគ្គលនោះ ជាព្រាហ្មណ៍ យ៉ាងណា អញក៏ជាព្រាហ្មណ៍ យ៉ាងនោះដែរ ថា បុគ្គលនោះ ជាអ្នកជំនួញ យ៉ាងណា អញ ក៏ជាអ្នកជំនួញ យ៉ាងនោះដែរ ឬថា បុគ្គលនោះជាអ្នកគ្រួ យ៉ាងណា អញក៏ជាអ្នកគ្រួ យ៉ាងនោះដែរ ថា បុគ្គលនោះជាគ្រហស្ថ យ៉ាងណា អញក៏ជាគ្រហស្ថ យ៉ាងនោះដែរ ឬថា បុគ្គលនោះជាបព្វជិត យ៉ាងណា អញក៏ជាបព្វជិត យ៉ាងនោះដែរ ថា បុគ្គលនោះជាទេវតា យ៉ាងណា អញក៏ជាទេវតា យ៉ាងនោះដែរ ឬថា បុគ្គលនោះជាមនុស្ស យ៉ាងណា អញក៏ជាមនុស្ស យ៉ាងនោះដែរ ថា បុគ្គលនោះមានរូប យ៉ាងណា អញក៏មានរូប យ៉ាងនោះដែរ ឬថា បុគ្គលនោះមិនមានរូប យ៉ាងណា អញក៏មិនមានរូប យ៉ាងនោះដែរ ថា បុគ្គលនោះមានសញ្ញា យ៉ាងណា អញក៏មានសញ្ញា យ៉ាងនោះដែរ ឬថា បុគ្គលនោះមិនមានសញ្ញា យ៉ាងណា អញក៏មិនមានសញ្ញា យ៉ាងនោះដែរ ថា បុគ្គលនោះមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងណា អញជាបុគ្គលមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងនោះដែរ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិត ថា អញមានយ៉ាងនេះ ។

(២៧១) កថញ្ច អញ្ញថាស្មីតិ ហោតិ ។ បរំ បុគ្គលំ ឧបនិធាយ យថា សោ ខត្តិយោ នាហំ តថា ខត្តិយោស្មីតិ វា យថា សោ ព្រាហ្មណោ នាហំ តថា ព្រាហ្មណោស្មីតិ វា យថា សោ វេស្សោ នាហំ តថា វេស្សោស្មីតិ វា យថា សោ សុទ្ទោ នាហំ តថា សុទ្ទោស្មីតិ វា យថា សោ គហដ្ឋោ នាហំ តថា គហដ្ឋោស្មីតិ វា យថា សោ បព្វជិតោ នាហំ តថា បព្វជិតោស្មីតិ វា យថា សោ ទេវោ នាហំ តថា ទេវោស្មីតិ វា យថា សោ មនុស្សោ នាហំ តថា មនុស្សោស្មីតិ វា យថា សោ រូបី នាហំ តថា រូបីស្មីតិ វា យថា សោ អរូបី នាហំ តថា អរូបីស្មីតិ វា យថា សោ សញ្ញី នាហំ តថា សញ្ញីស្មីតិ វា យថា សោ អសញ្ញី នាហំ តថា អសញ្ញីស្មីតិ វា

( ៩៧១ ) ចុះតណ្ហាវិចរិតថា អញមាន ដោយប្រការដទៃ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រ យ៉ាងណា អញមិនមែនជាក្សត្រ យ៉ាងនោះទេ ឬថា បុគ្គលនោះជាព្រាហ្មណ៍ យ៉ាងណា អញមិនមែនជាព្រាហ្មណ៍ យ៉ាងនោះទេ ថា បុគ្គលនោះជាអ្នកជំនួញ យ៉ាងណា អញមិនមែនជាអ្នកជំនួញ យ៉ាងនោះទេ ឬថា បុគ្គលនោះជាអ្នកគ្រួ យ៉ាងណា អញមិនមែនជាអ្នកគ្រួ យ៉ាងនោះទេ ថា បុគ្គលនោះជាគ្រហស្ថ យ៉ាងណា អញមិនមែនជាគ្រហស្ថ យ៉ាងនោះទេ ឬថា បុគ្គលនោះជាបព្វជិត យ៉ាងណា អញមិនមែនជាបព្វជិត យ៉ាងនោះទេ ថា បុគ្គលនោះជាទេវតា យ៉ាងណា អញមិនមែនជាទេវតា យ៉ាងនោះទេ ឬថា បុគ្គលនោះជាមនុស្ស យ៉ាងណា អញមិនមែនជាមនុស្ស យ៉ាងនោះទេ ថា បុគ្គលនោះមានរូប យ៉ាងណា អញមិនមានរូប យ៉ាងនោះទេ ឬថា បុគ្គលនោះមិនមានរូប យ៉ាងណា អញមិនមែនមិនមានរូប យ៉ាងនោះទេ ថា បុគ្គលនោះមានសញ្ញា យ៉ាងណា អញមិនមានសញ្ញា យ៉ាងនោះទេ ឬថា បុគ្គលនោះមិនមានសញ្ញា យ៉ាងណា អញមិនមែនមិនមានសញ្ញា យ៉ាងនោះទេ ថា

យថា សោ តេន សញ្ញី ជាសញ្ញី ជាហំ តថា តេន សញ្ញី ជាសញ្ញីស្មីតិ វា ឯវំ អញ្ញថាស្មីតិ ហោតិ ។

(២៧២) កតមញ្ច ករិស្សន្តិ ហោតិ ។ កញ្ចិ ធម្មំ អនវការី ការិត្វា រូបំ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ ករិស្សន្តិ ឆន្ទំ បដិលភតិ ករិស្សន្តិ មានំ បដិលភតិ ករិស្សន្តិ ទិដ្ឋឹ បដិលភតិ តស្មិំ សតិ ឥមានិ បបញ្ចិតានិ ហោន្តិ ឥត្ថំ ករិស្សន្តិ វា ឯវំ ករិស្សន្តិ វា អញ្ញថា ករិស្សន្តិ វា ។

(២៧៣) កតមញ្ច ឥត្ថំ ករិស្សន្តិ ហោតិ ។ ខត្តិយោ ករិស្សន្តិ វា ព្រាហ្មណោ ករិស្សន្តិ វា វេស្សោ ករិស្សន្តិ វា សុទ្ទោ ករិស្សន្តិ វា គហដ្ឋោ ករិស្សន្តិ វា បព្វជិតោ ករិស្សន្តិ វា ទេវោ ករិស្សន្តិ វា មនុស្សោ ករិស្សន្តិ វា រូបី ករិស្សន្តិ វា អរូបី ករិស្សន្តិ វា

បុគ្គលនោះមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងណា អញមិនមែនមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងនោះទេ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញមាន ដោយប្រការដទៃ ។

(៤៧២) ចុះតណ្ហាវិចរិតថា អញនឹងមាន តើដូចម្តេច ។ បុគ្គលធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនឲ្យបែកចេញពីគ្នា ហើយបាននូវឆន្ទៈថា អញនឹងមាន បាននូវមានះថា អញនឹងមាន បាននូវទិដ្ឋិថា អញនឹងមាន កាលបើធម៌មានឆន្ទៈជាដើមនោះមាន ដំណើរយឺតយូរនេះក៏មាន ថា អញនឹងមាន ដោយប្រការនេះខ្លះ ថា អញនឹងមាន យ៉ាងនេះខ្លះ ថា អញនឹងមាន ដោយប្រការដទៃខ្លះ ។

(៤៧៣) ចុះតណ្ហាវិចរិតថា អញនឹងមាន ដោយប្រការនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហាថា អញនឹងជាក្សត្រ ឬថា អញនឹងជាព្រាហ្មណ៍ ថា អញនឹងជាអ្នកជំនួញ ឬថា អញនឹងជាអ្នកគ្រួ ថា អញនឹងជាគ្រហស្ថ ឬថា អញនឹងជាបព្វជិត ថា អញនឹងជាទេវតា ឬថា អញនឹងជាមនុស្ស ថា អញនឹងជាបុគ្គលមិនមានរូប ឬថា អញនឹងជាបុគ្គលមានរូប ថា

សញ្ញី ភវិស្សន្តិ វា អសញ្ញី ភវិស្សន្តិ វា នេវសញ្ញី នាសញ្ញី ភវិស្សន្តិ វា ឯវំ ឥត្ថំ ភវិស្សន្តិ ហោតិ ។

(៩៣៦) កថញ្ច ឯវំ ភវិស្សន្តិ ហោតិ ។ ឯវំ បុគ្គលំ ឧបនិធាយ យថា សោ ខត្តិយោ តថាហំ ខត្តិយោ ភវិស្សន្តិ វា យថា សោ ព្រាហ្មណោ តថាហំ ព្រាហ្មណោ ភវិស្សន្តិ វា ។បេ។ យថា សោ នេវសញ្ញី នាសញ្ញី តថាហំ នេវសញ្ញី នាសញ្ញី ភវិស្សន្តិ វា ឯវំ **ឯវំ** ភវិស្សន្តិ ហោតិ ។

(៩៣៧) កថញ្ច អញ្ញថា ភវិស្សន្តិ ហោតិ ។ ឯវំ បុគ្គលំ ឧបនិធាយ យថា សោ ខត្តិយោ នាហំ តថា ខត្តិយោ ភវិស្សន្តិ វា យថា សោ ព្រាហ្មណោ នាហំ តថា ព្រាហ្មណោ ភវិស្សន្តិ វា ។បេ។

អញនឹងជាបុគ្គលមានសញ្ញា ឬថា អញនឹងជាបុគ្គលមិនមានសញ្ញា ថា អញនឹងជាបុគ្គលមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញនឹងមាន ដោយប្រការនេះ ។

( ៦៧៤ ) ចុះតណ្ហាវិចរិតថា អញនឹងមាន យ៉ាងនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃ ថា បុគ្គលនោះជាក្សត្រ យ៉ាងណា អញនឹងបានជាក្សត្រ យ៉ាងនោះដែរ ឬថា បុគ្គលនោះជាព្រាហ្មណ៍ យ៉ាងណា អញនឹងបានជាព្រាហ្មណ៍ យ៉ាងនោះដែរ ។ បេ ។ ថា បុគ្គលនោះមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងណា អញនឹងមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងនេះដែរ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញនឹងមាន យ៉ាងនេះ ។

( ៦៧៥ ) ចុះតណ្ហាវិចរិតថា អញនឹងមាន ដោយប្រការដទៃ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួន ទៅប្រៀបនឹងបុគ្គលដទៃថា បុគ្គលនោះជាក្សត្រ យ៉ាងណា អញនឹងមិនមែនជាក្សត្រ យ៉ាងនោះទេ ឬថា បុគ្គលនោះជាព្រាហ្មណ៍ យ៉ាងណា អញនឹងមិនមែនជាព្រាហ្មណ៍ យ៉ាងនោះទេ ។ បេ ។

យថា សោ ទេវ សញ្ញី នាសញ្ញី នាហំ តថា ទេវ សញ្ញី នាសញ្ញី ភវិស្សន្តិ ក ឯវំ អញ្ញថា ភវិស្សន្តិ ហោតិ ។

(២៧៦) កថញ្ច អសស្មីតិ ហោតិ ។ កញ្ចិ ធម្មំ អនវការី ករិត្វា រូបំ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ និច្ចោស្មិ ធុវោស្មិ សស្សតោស្មិ អវិបរិ-ណាមធម្មោស្មីតិ ឯវំ អសស្មីតិ ហោតិ ។

(២៧៧) កថញ្ច សាតស្មីតិ ហោតិ ។ កញ្ចិ ធម្មំ អនវការី ករិត្វា រូបំ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ ឧច្ឆិជ្ជិស្សាមិ វិនស្សិស្សាមិ ន ភវិស្សាមីតិ ឯវំ សាតស្មីតិ ហោតិ ។

(២៧៨) កថញ្ច សិយន្តិ ហោតិ ។ កញ្ចិ ធម្មំ អនវការី ករិត្វា រូបំ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ សិយន្តិ ឆន្ទំ បដិលភតិ សិយន្តិ មានំ

ថា បុគ្គលនោះមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងណា អញនឹងមិនមែនមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងនោះទេ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញនឹងមាន ដោយប្រការដទៃ ។

(២៧៦) ចុះតណ្ហាវិចរិតថា អញទៀង តើដូចម្ដេច ។ ដំណើរនៃតណ្ហា ព្រោះធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនឲ្យបែកចេញពីគ្នា ថា អញជាបុគ្គលទៀង មាំមួន ប្រាកដ មិនប្រែប្រួលជាធម្មតា យ៉ាងនេះ ឈ្មោះថា តណ្ហា-វិចរិតថា អញទៀង ។

(២៧៧) ចុះតណ្ហាវិចរិតថា អញសុខស្រួល តើដូចម្ដេច ។ ដំណើរនៃតណ្ហា ព្រោះធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនឲ្យបែកចេញពីគ្នា ថា អញនឹងដាច់សូន្យ នឹងវិនាស នឹងមិនកើតទៀត យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញសុខស្រួល ។

(២៧៨) ចុះតណ្ហាវិចរិតថា អញគួរមាន តើដូចម្ដេច ។ បុគ្គលធ្វើនូវធម៌ណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនឲ្យបែកចេញពីគ្នា ហើយបាននូវឆន្ទៈថា អញគួរមាន បាននូវមានះថា

បដិលភតិ សិយន្តិ ឥដ្ឋី បដិលភតិ តស្មិំ សតិ ឥទានិ បបញ្ចិតានិ ហោតិ ឥត្ថំ សិយន្តិ វា ឯវំ សិយន្តិ វា អញ្ញថា សិយន្តិ វា ។

(២៧៩) កតមញ្ច ឥត្ថំ សិយន្តិ ហោតិ ។ ខត្តិយោ សិយន្តិ វា ព្រាហ្មណោ សិយន្តិ វា វេស្សោ សិយន្តិ វា សុទ្ទោ សិយន្តិ វា គហដ្ឋោ សិយន្តិ វា បព្ពជិតោ សិយន្តិ វា ទេវោ សិយន្តិ វា មនុស្សោ សិយន្តិ វា រូបី សិយន្តិ វា អរូបី សិយន្តិ វា សញ្ញី សិយន្តិ វា អសញ្ញី សិយន្តិ វា នេវ សញ្ញី នាសញ្ញី សិយន្តិ វា ឯវំ ឥត្ថំ សិយន្តិ ហោតិ ។

(២៨០) កតមញ្ច ឯវំ សិយន្តិ ហោតិ ។ បរំ បុគ្គលំ ឧបនិធាយ យថា សោ ខត្តិយោ តថាហំ ខត្តិយោ សិយន្តិ វា យថា សោ ព្រាហ្មណោ តថាហំ ព្រាហ្មណោ សិយន្តិ វា ។ បេ ។

អញគួរមាន បានទទួលទិដ្ឋថា អញគួរមាន កាលបើធម៌មានឆន្ទៈជាដើមនោះមាន ដំណើរយឺតយូរនេះក៏មាន ថា អញគួរមាន ដោយប្រការនេះខ្លះ ថា អញគួរមាន យ៉ាងនេះខ្លះ ថា អញគួរមាន ដោយប្រការដទៃខ្លះ ។

(២៧៩) ចុះតណ្ហាវិចរិតថា អញគួរមាន ដោយប្រការនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហា ថា អញគួរតែជាក្សត្រ ឬថា អញគួរតែជាព្រាហ្មណ៍ ថា អញគួរតែជាអ្នកជំនួញ ឬថា អញគួរតែជាអ្នកគ្រួ ថា អញគួរតែជាគ្រហស្ថ ឬថា អញគួរតែជាបព្វជិត ថា អញគួរតែជាទេវតា ឬថា អញគួរតែជាមនុស្ស ថា អញគួរតែជាបុគ្គលមានរូប ឬថា អញគួរតែជាបុគ្គលមិនមានរូប ថា អញគួរតែជាបុគ្គលមានសញ្ញា ឬថា អញគួរតែជាបុគ្គលមិនមានសញ្ញា ថា អញគួរតែជាបុគ្គលមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញគួរមាន ដោយប្រការនេះ ។

(២៨០) ចុះតណ្ហាវិចរិតថា អញគួរមាន យ៉ាងនេះ តើដូចម្តេច ។ ដំណើរនៃតណ្ហា ព្រោះយកខ្លួនទៅប្រៀបនឹងបុគ្គលដទៃ ថា បុគ្គលនោះជាក្សត្រ យ៉ាងណា អញគួរតែជាក្សត្រ យ៉ាងនោះដែរ ឬថា បុគ្គលនោះជាព្រាហ្មណ៍ យ៉ាងណា អញគួរតែជាព្រាហ្មណ៍ យ៉ាងនោះដែរ ។បេ។

យថា សោ នេវ សញ្ញី នាសញ្ញី តថាហំ នេវ សញ្ញី
នាសញ្ញី សិយន្តិ វា ឯវំ ឯវំ សិយន្តិ ហោតិ ។

(២៨១) កថញ្ច អញ្ញថា សិយន្តិ ហោតិ ។
បរំ បុគ្គលំ ឧបនិធាយ យថា សោ ខត្តិយោ
នាហំ តថា ខត្តិយោ សិយន្តិ វា យថា សោ
ព្រាហ្មណោ នាហំ តថា ព្រាហ្មណោ សិយន្តិ វា
។បេ។ យថា សោ នេវ សញ្ញី នាសញ្ញី នាហំ
តថា នេវ សញ្ញី នាសញ្ញី សិយន្តិ វា ឯវំ អញ្ញថា
សិយន្តិ ហោតិ ។

(២៨២) កថញ្ច អបាហំ សិយន្តិ ហោតិ ។
កញ្ចិ ធម្មំ អនវការឹ ករិត្វា រូបំ វេទនំ សញ្ញំ
សង្ខារេ វិញ្ញាណំ អបាហំ សិយន្តិ ឆន្ទំ បដិលភតិ
អបាហំ សិយន្តិ មានំ បដិលភតិ អបាហំ សិយន្តិ

ថា បុគ្គលនោះ មានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងណា អញ្ញត្រៃតែជាបុគ្គលមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន យ៉ាងនោះដែរ យ៉ាងនេះ ឈ្មោះថា តណ្ហាវិចរិតថា អញ្ញត្រមាន យ៉ាងនេះ ។

